

វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# កម្មវិធីចុះបញ្ជីដីធ្លីនៅប្រទេសកម្ពុជា
# របាយការណ៍អង្កេតមូលដ្ឋាននៅតំបន់ជនបទ

ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

ខែធ្នូ ឆ្នាំ២០០៧

# កម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា

## របាយការណ៍អង្កេតមូលដ្ឋាននៅតំបន់ជនបទ

**Cambodia Land Titling Rural Baseline Survey Report**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

*ក្រោមកិច្ចសហប្រតិបត្តិការជាមួយ*

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដនស)**

**ភ្នំពេញ, ខែធ្នូ ឆ្នាំ២០០៧**

**បេសកកម្ម វបសអ**

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់អំពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។*

*វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

**© រក្សាសិទ្ធិឆ្នាំ២០០៧ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560 9812**

# កម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា
# របាយការណ៍អង្កេតមូលដ្ឋាននៅតំបន់ជនបទ

ខែធ្នូ ឆ្នាំ២០០៧

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
**អ៊ីមែល:** cdrimail@online.com.kh **website:** http://www.cdri.org.kh

កែសម្រួល និងរចនាដោយ: យូ-សិទ្ធីរិទ្ធ អ៊ុំ ចាន់ថា យេន-សុផានី និងគឹម-ចិត្រា

# មាតិកា


សេចក្តីថ្លែងអំណរគុណ ..... ១

បញ្ជីអក្សរកាត់ ..... ៣

សេចក្តីសង្ខេប ..... ៥

**ជំពូក ១. សេចក្តីផ្តើម** ..... ១៥

១.១ ដំណើរការនៃគំរោង LMAP ..... ១៦

១.២ រចនាសម្ព័ន្ធនៃរបាយការណ៍ ..... ១៧

**ជំពូក ២. សាវតា: រដ្ឋបាលដីធ្លី និងសភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ន** ..... ១៩

២.១. សភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ន ..... ២១

២.១.១ ការវិនិយោគលើវិស័យកសិកម្ម និងផលិតកម្ម ..... ២២

២.១.២. អសមភាពលើការកាន់កាប់ដីធ្លី ..... ២៣

២.១.៣ សិទ្ធិកាន់កាប់ដីធ្លី ..... ២៤

២.១.៤ ការផ្ទេរដី / ទីផ្សារដី ..... ២៥

២.១.៥ វិវាទដីធ្លី ..... ២៦

**ជំពូក ៣. ក្របខ័ណ្ឌគំនិត** ..... ២៧

៣.១ សម្មតិកម្មនៃការស្រាវជ្រាវ ..... ២៩

៣.១.១ ផលប៉ះពាល់សេដ្ឋកិច្ច ..... ៣០

៣.១.២. ផលប៉ះពាល់សង្គម ..... ៣២

**ជំពូក ៤. វិធីសាស្រ្តនៃការស្រាវជ្រាវ** ..... ៣៥

៤.១. ការជ្រើសរើសតំបន់អង្កេត និងតំបន់ប៉ាន់គំរូ ..... ៣៦

៤.១.១. ការជ្រើសរើសទីតាំង ..... ៣៦

៤.២. ការជ្រើសរើសគំរូនៃគ្រួសារ ..... ៣៨

៤.២.១. គ្រួសារគ្មានដីធ្លី ..... ៣៨

៤.២.៣. ស្រ្តីមេម៉ាយជាមេគ្រួសារ ..... ៣៩

៤.៣. ការអនុវត្តន៏ ..... ៣៩

ជំពូក ៥. អង្កេតប្រជាពលរដ្ឋនៅជនបទៈ ការកត់សំគាល់បឋមនិងការពិភាក្សា ៤១
៥.១. លក្ខណៈនៃគ្រួសារ ៤១
៥.១.១. យេនឌ័រ ៤៤
៥.១.២. ភាពគ្រប់គ្រាន់នៃផលស្រូវ ៤៦
៥.១.៣ សេចក្តីសង្ខេប ៤៧
៥.២. លក្ខណៈភូមិ ៤៨
៥.២.១. សេចក្តីសង្ខេប ៥១

ជំពូក ៦. ការរកឃើញ និងការវិភាគលើគ្រួសារនៅជនបទ ៥៣
៦.១. ឥណទានៈ សកម្មភាពខ្ចីប្រាក់ និងការផ្តល់ប្រាក់ឱ្យខ្ចីនៅថ្នាក់គ្រួសារនីមួយៗ ៥៣
៦.២. ការវិនិយោគលើការងារកសិកម្ម ផលិតភាព និងការប្រើប្រាស់ដី ៥៧
៦.២.១ ប្រភពហិរញ្ញវត្ថុសំរាប់ការចំណាយ ៥៨
៦.២.២ ផលិតភាព ៥៩
៦.២.៣ ការប្រើប្រាស់ដី ៦២
៦.៣. ទីផ្សារដីធ្លីៈ តំលៃ ថ្លៃ និងការផ្ទេរដីធ្លី ៦៥
៦.៣.១ ការផ្ទេរដីធ្លី ៦៦
៦.៤ រដ្ឋបាល និងគ្រប់គ្រងដីធ្លី ៦៩
៦.៤.១ ការផ្ទេរដី ៧១
៦.៥. វិវាទដីធ្លី និងការដោះស្រាយ ៧៣
៦.៥.១ ការដោះស្រាយវិវាទដីធ្លី ៧៤
៦.៥.១ សេចក្តីសង្ខេប ៧៥

ជំពូក ៧. ខេត្តកំពង់ឆ្នាំងៈ តំបន់សិក្សា ៧៧
៧.១ លក្ខណៈរបស់គ្រួសារ ៧៧
៧.១.១. យេនឌ័រ ៧៩
៧.១.២. ភាពគ្រប់គ្រាន់នៃផលស្រូវ ៨១
៧.២. ឥណទានៈ សកម្មភាពខ្ចីប្រាក់ និង ការផ្តល់ប្រាក់ឱ្យខ្ចីនៅកំរិតគ្រួសារ ៨២
៧.៣ ការវិនិយោគលើវិស័យកសិកម្ម ការផលិតកម្ម និងការប្រើប្រាស់ដីធ្លី ៨៤
៧.៣.១ ប្រភពនៃហិរញ្ញវត្ថុសំរាប់ធ្វើការចំណាយ ៨៥
៧.៣.២ ផលិតភាព ៨៦
៧.៣.៣ ការប្រើប្រាស់ដី ៨៨

៧.៤ ទីផ្សារដីធ្លី៖ តំលៃ ថ្លៃ និងការផ្ទេរដីធ្លី ..... ៨៩
៧.៥ ការរៀបចំដែនដី និងរដ្ឋបាលដីធ្លី ..... ៩១
៧.៦. វិវាទ និងជំលោះដីធ្លី ..... ៩៣
៧.៦.១ ការដោះស្រាយវិវាទ ..... ៩៤

**ជំពូក ៨. សេចក្តីសន្និដ្ឋាន និងការកត់សំគាល់នានា ..... ៩៧**
៨.១ ការកត់សំគាល់មួយចំនួន ..... ៩៩
៨.១.១ ក្រុមអង្កេតនៃគំរោង LMAP ..... ៩៩
៨.១.២ ការសំរបសំរួលរវាងការធ្វើអង្កេតបឋម ជាមួយនឹងការអនុវត្តគំរោង LMAP ..... ៩៩
៨.១.៣ ការធ្វើអត្តសញ្ញាណក្បាលដី ..... ១០០
៨.១.៤ ការយល់ដឹងពីដំណើរការនៃគំរោង LMAP ..... ១០០
៨.១.៤ ក្រុមប្រឹក្សាឃុំ ..... ១០០
៨.១.៥ សោហ៊ុយសេវាលើការប្រើប្រាស់ ..... ១០១
៨.១.៦ ការប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីដីធ្លី ..... ១០១
៨.១.៧ សិទ្ធិលើទ្រព្យជាប្រពៃណីនៅមូលដ្ឋាន ..... ១០១
៨.២ ការធ្វើផែនការ និងគោលនយោបាយ ..... ១០២
៨.២.១ ផលប៉ះពាល់វិជ្ជមាន ..... ១០២

**ឯកសារយោង ..... ១០៤**
**កំរងសំណួរ ..... ១០៧**
**បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ *វបសអ* ..... ១៣៧**

# សេចក្តីថ្លែងអំណរគុណ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) សូមថ្លែងអំណរគុណដល់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃរាជរដ្ឋាភិបាលកម្ពុជា ចំពោះឱកាសដ៏មានតំលៃដែលបានផ្តល់ឱ្យ វបសអ អនុវត្តគំរោងអង្កេតមូលដ្ឋាន ។ វបសអ ក៏សូមថ្លែងអំណរគុណចំពោះការជួយជ្រោមជ្រែងរបស់ធនាគារពិភពលោក ដែលបានផ្តល់កំចីសំរាប់ការសិក្សា ក៏ដូចជា ការគាំទ្រខាងបច្ចេកទេស និងការពិគ្រោះយោបល់ជាបន្តបន្ទាប់ ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលជាច្រើនគឺមាន កសិករនៅតាមតំបន់ជនបទ អ្នកលក់ដូរ និងអ្នកផ្សេងទៀត នៅក្រុងព្រះសីហនុ ដែលបានចំណាយពេលវេលាមានតំលៃក្នុងការជួបជាមួយអ្នកចុះអង្កេត និងផ្តល់ចំលើយយ៉ាងយកចិត្តទុកដាក់ ។ ជាពិសេស យើងសូមថ្លែងអំណរគុណដល់ប្រជាជននៅខេត្តកំពង់ឆ្នាំង ។ ទោះបីជាខេត្តនេះ មិនស្ថិតនៅក្នុងគំរោងចុះបញ្ជីដីធ្លីបច្ចុប្បន្នក្តី ក៏ពួកគេបានទទួលជួបជាមួយនឹងអ្នកចុះធ្វើអង្កេត និងបានឆ្លើយសំនួរជាច្រើន ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំនានា ដែលបានចំណាយពេលវេលាដ៏មានតំលៃជួបជាមួយអ្នកស្រាវជ្រាវរបស់ វបសអ និងជួយឱ្យពួកគេបានយល់កាន់តែច្បាស់ថែមទៀតពីការវិវត្តន៍ស្ថានភាពដីធ្លីនៅតាមមូលដ្ឋាន ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះមេភូមិនានា ដែលបានជួយរៀបចំកន្លែងស្នាក់នៅសំរាប់ក្រុមអង្កេតនៅមូលដ្ឋាន ព្រមទាំងចំណាយពេលវេលាឆ្លើយសំនួរជាច្រើន និងប្រាប់ពីរឿងដីធ្លីក្នុងភូមិរបស់ពួកគេ ។

ក្រុមអង្កេតមូលដ្ឋាន សូមថ្លែងអំណរគុណដល់មន្ត្រីនៃគំរោងរដ្ឋបាលនិងគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត និងមន្ត្រីសុរិយោដី ដែលបានផ្តល់ការបូកសរុបដ៏ល្អអំពីការងាររបស់គំរោងរដ្ឋបាលនិងគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត ក៏ដូចជាទិន្នន័យ និងព័ត៌មានផ្សេងទៀតតាមសំណូមពរ ។ ក្រុមគំរោងរដ្ឋបាលនិងគ្រប់គ្រងដីធ្លីដែលកំពុងធ្វើការនៅតាមមូលដ្ឋាន ក៏តែងពេញចិត្តនឹងចំណាយពេលវេលាដើម្បីជួយពន្យល់ពីការងារ របស់ពួកគេនៅក្នុងភូមិដែរ ។ យើងខ្ញុំសូមថ្លែងសរសើរដល់ពួកគេដែលបានបំពេញការងារដ៏ស្មុគស្មាញប្រកបដោយលក្ខណៈវិជ្ជាជីវៈ ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានផ្តល់បុគ្គលិកពីរនាក់ គឺលោក មាន ចាន់ផាធី និងលោក ម៉េង ប៊ុណ្ណារិទ្ធ មកជួយធ្វើការងារមួយរយៈ និងចូលរួមចំណែកយ៉ាងសំខាន់ដល់ការចុះអង្កេត ។ ដោយឡែក លោកស្រីបណ្ឌិត អ៊ូ វីឌី ក្នុងឋានៈជាមន្ត្រីទំនាក់ទំនងក្នុងគំរោងរបស់ក្រសួង បានដើរតួយ៉ាងសំខាន់ក្នុងការជួយញ៉ាំងឱ្យការងារប្រព្រឹត្តទៅបានស្របតាមផែនការ ។ លោក សរ សុវណ្ណ ក៏បានផ្តល់ការគាំទ្រ និងសេចក្តីណែនាំដ៏មានតំលៃក្នុងសមត្ថកិច្ចរបស់លោកជាប្រធាននៃគំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី ។ ឯកឧត្តម អ៊ឹម ឈុនលឹម បានផ្តល់ការដឹកនាំ និងទិសដៅដល់គំរោង ស្របតាមចក្ខុវិស័យនៃការផ្តល់សេវារដ្ឋបាលដីធ្លីដោយយុត្តិធម៌ និងមិនលំអៀងដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នា ។ ក្រុមគំរោងអង្កេតមូលដ្ឋាន ក៏សូមថ្លែងអំណរគុណដល់ការគាំទ្រ និងការយកចិត្តទុកដាក់ជាប់ជានិច្ចរបស់អ្នកតំណាងមកពី GTZ និង FinnMap ផងដែរ ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិក វបសអ ដែលបានផ្តល់ការគាំទ្រខាងរដ្ឋបាល និងសំភារៈដល់គំរោងទាំងមូល ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ លោកស្រី ប៉ុន ដូរីណា ចំពោះការចុះជួយការងារដល់កន្លែង និងលោក តុង គីមស៊ុន ចំពោះការជួយធ្វើវិភាគទិន្នន័យ ។ ម្យ៉ាងទៀត ការសិក្សានេះនឹងមិនអាចសំរេចបានទេ បើសិនជាពុំមានការយកចិត្តទុកដាក់ និងការគាំទ្រតាំងពីដំបូងពីលោកស្រី Eva Mysliwiec ជាអតីតនាយកប្រតិបត្តិ វបសអ ។ លោក Larry Strange ដែលបន្តតំណែងជានាយកប្រតិបត្តិ លោកបណ្ឌិត K.A.S Murshid ជាអតីតនាយកស្រាវជ្រាវ និង លោក Ray Hossinger ជាអ្នកគ្រប់គ្រងប្រតិបត្តិ និង លោក អ៊ឹង ស៊ានលី ដែលបន្តតំណែងជានាយកផ្នែកប្រតិបត្តិ ក៏បានបន្តផ្តល់ការគាំទ្រ និងជួយជំរុញគំរោងឱ្យទទួលបានជោគជ័យជាស្ថាពរ ។

*ភ្នំពេញ ខែធ្នូ ឆ្នាំ២០០៧*

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ACLEDA | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា<br>(Association of Cambodian Local Economic Development) |
| BSC | គំរោងអង្កេតមូលដ្ឋាន<br>Baseline Survey Project |
| វបសអ/CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia's Leading Independent Development Policy Research Institute) |
| HCA | តំបន់សមត្ថភាពខ្ពស់<br>High Capacity Area |
| HPI | ផលប៉ះពាល់ជាសក្តានុពលខ្ពស់<br>High Potential Impact |
| LCA | តំបន់សមត្ថភាពទាប<br>Low Capacity Area |
| LPI | ផលប៉ះពាល់ជាសក្តានុពលទាប<br>Low Potential Impact |
| LAMDP | កម្មវិធីរដ្ឋបាល និងគ្រប់គ្រងដីធ្លី<br>Land Administration, Management and Distribution Programme |
| LMAP | គំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី<br>Land Management and Administration Project |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>Ministry of Land Management, Urban Planning, and Construction |
| NGO | អង្គការមិនមែនរដ្ឋាភិបាល<br>Non-Government Organization |
| PAD | ឯកសារវាយតំលៃគំរោង<br>Project Appraisal Document |
| RGC | រាជរដ្ឋាភិបាលកម្ពុជា<br>Royal Government of Cambodia |
| SES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច<br>Socio-EConomic Survey |

# សេចក្តីសង្ខេប

ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (MLMUPC) ដោយមានការគាំទ្រពីអ្នកផ្តល់ជំនួយអន្តរជាតិ កំពុងអនុវត្តគំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី (LMAP) ដើម្បីកែលំអសន្តិសុខនៃការកាន់កាប់ដីធ្លី និងពង្រឹងប្រព័ន្ធរដ្ឋបាលដីធ្លី ។ ក្នុងចំណោមសកម្មភាពដទៃទៀត គំរោងនឹងបង្កើតកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធដែលនឹងមានការចេញប័ណ្ណកម្មសិទ្ធិដីធ្លីចំនួនមួយលានប័ណ្ណក្នុងរយៈពេល ៥ឆ្នាំ ។ គំរោងនេះរំពឹងថា ប័ណ្ណកម្មសិទ្ធិដី នឹងជួយៈ (ក) បង្កើនលទ្ធភាពរបស់កសិករក្នុងការទទួលឥណទានផ្លូវការ (ខ) លើកទឹកចិត្តដល់ការធ្វើវិនិយោគខាងកសិកម្ម និងពាណិជ្ជកម្ម នៅក្នុងតំបន់ជនបទ និងទីក្រុង ដែលនឹងបង្កើនផលិតភាព និងការងារ (គ) ជំរុញឱ្យទីផ្សារដីធ្លីកាន់តែមានប្រសិទ្ធភាពខ្ពស់ និង (ឃ) រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។

ក្នុងពេលថ្មីៗនេះ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (វបសអ) បានសហការជាមួយ MLMUPC ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន ដែលនឹងត្រូវប្រើប្រាស់សំរាប់វាយតំលៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៃប័ណ្ណកម្មសិទ្ធិដីធ្លីនៅរយៈពេល៣ឆ្នាំក្រោយ ។ គំរោងអង្កេតមូលដ្ឋានបានធ្វើសំភាសន៏ ១.២៣២គ្រួសារជនបទនៅក្នុង ៤0ភូមិ ដែលស្ថិតក្នុង ១0ឃុំ និងក្នុង ៥ខេត្ត នៅអំឡុងថ្ងៃទី១៩ មករា- ២៩ កុម្ភៈ ២00៤ ។ ខេត្ត-ក្រុងក្នុងគំរោង LMAP មានចំនួន ៤ រួមមាន កំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងតាកែវ ។ ខេត្តទីប្រាំគឺ ខេត្តកំពង់ឆ្នាំង ស្ថិតនៅក្រៅគំរោង LMAP ទុកសំរាប់ប្រៀបធៀបគ្នាជាមួយនឹងខេត្តទាំង ៤ ដែលស្ថិតនៅក្នុងគំរោងLMAP ។ គ្រួសារត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងបញ្ជីភូមិយកមកធ្វើការសិក្សា ដោយយោងទៅតាមទំហំដីកាន់កាប់ និងភេទនៃមេគ្រួសារ ។ ៩៩គ្រួសារផ្សេងទៀតរស់នៅក្នុងខ័ណ្ឌមិត្តភាព (សង្កាត់២) ក្រុងព្រះសីហនុ ត្រូវបានសំភាសន៏ និងបញ្ចូលក្នុងរបាយការណ៏ស្តីពីគំរោងអង្កេតមូលដ្ឋាន ដែលនឹងធ្វើនៅក្នុង និងនៅជុំវិញទីក្រុងភ្នំពេញ ។

ហេតុផលនៃកម្មវិធីចេញប័ណ្ណកម្មសិទ្ធិដីធ្លី ផ្អែកទៅលើទ្រឹស្តីសិទ្ធិកាន់កាប់អចលនទ្រព្យ និងការស្រាវជ្រាវដែលបានចងភ្ជាប់សុវត្ថិភាពកាន់កាប់ដីធ្លី ទៅនឹងការលើកទឹកចិត្តដល់ការវិនិយោគទុន ក៏ដូចជាបង្កើនតំលៃ និងការប្រើប្រាស់ដី ។ ទ្រឹស្តីទាំងនេះបង្កើតបាននូវសម្មតិកម្មមួយចំនួនដែលអាចសាកល្បងបាន ដោយប្រើវិធីសាស្ត្រដកបទពិសោធន៏ (quasi-experiment) ដែលប្រៀបធៀបទិន្នន័យគ្រួសារ និងទិន្នន័យភូមិ ដែលបានមកពីគំរោងអង្កេតមូលដ្ឋាននាពេលបច្ចុប្បន្នទៅនឹង ទិន្នន័យប្រមូលបានពីអង្កេត គ្រួសារក្នុងពេលអនាគតទាំងក្នុងតំបន់មានគំរោង LMAP និងក្នុងតំបន់គ្មានគំរោង LMAP ។ សម្មតិកម្មជាគន្លឹះមួយចំនួន ដែលអាចកំណត់បានពីការធ្វើអង្កេតមូលដ្ឋានរួមមានៈ

- **លទ្ធភាពទទួលឥណទានៈ** ប្រជាជននឹងប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីជាវត្ថុសំរាប់ដាក់ធានា ដើម្បីទទួលឥណទានពីស្ថាប័នផ្តល់កំចីជាផ្លូវការ
- **វិនិយោគៈ** ប្រជាជននៅជនបទនឹងបង្កើនវិនិយោគក្នុងផលិតកម្មកសិកម្ម និងកែលំអដីធ្លី ដូច្នេះនឹងមានកំណើនទិន្នផល និងប្រាក់ចំណូល

- **ទីផ្សារដីធ្លី:** នៅពេលតំលៃដីកើនឡើង ហើយការចំណាយក្នុងការលក់ឬផ្ទេរដីថយចុះ ទីផ្សារដីធ្លីនឹងឈានទៅរកការប្រើប្រាស់ដីធ្លីកាន់តែមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច
- **រដ្ឋបាលដីធ្លី:** កំណើនអត្រាលក់ឬផ្ទេរដី (ឧ. ការលក់ រឺការបន្តមរតក) នឹងត្រូវបានសំរបសំរួលតាមរយៈប្រព័ន្ធចុះបញ្ជីដីធ្លីជាផ្លូវការ
- **វិវាទ:** ប័ណ្ណកម្មសិទ្ធិដីមានសុវត្ថិភាព នឹងកាត់បន្ថយចំនួន និងភាពញឹកញាប់នៃវិវាទដីធ្លី ដោយវាបញ្ជាក់ច្បាស់ពីកម្មសិទ្ធិព្រំប្រទល់ដី និងនីតិវិធីនៃការលក់ឬផ្ទេរ ។

## ការបែងចែកកម្មសិទ្ធិដីធ្លី

ដើម្បីធ្វើការវិភាគ គ្រួសារជាមុខសញ្ញានៃអង្កេតត្រូវបានបែងចែកជា ៥ចំណាត់ថ្នាក់ ទៅតាមទំហំដីកាន់កាប់ និងភេទនៃមេគ្រួសារ ។[១] គ្រួសារកាន់កាប់ដីតូចៗ មានក្បាលដីចំនួនតិច ហើយក្បាលដីក៏មានទំហំតូច បើធៀបនឹងគ្រួសារដែលកាន់កាប់ដីធំៗ ។ ចំនួននិងទំហំក្បាលដី កើនឡើងយ៉ាងទៀងទាត់ពីចំណាត់ថ្នាក់ដីកាន់កាប់មួយទៅចំណាត់ថ្នាក់មួយទៀត ។ ការពន្យល់ដែលបានលើកឡើងញឹកញាប់បំផុតនៃលំនាំនៃការបែងចែកដីនេះ បានចាប់ផ្តើមតាំងពីនៅឆ្នាំ១៩៨៩ ដែលនៅពេលនោះ មានការខិតខំចែកដីដែលមានគុណភាពល្អឱ្យបានស្មើៗគ្នា ដោយយោងទៅតាមចំនួនសមាជិកគ្រួសារគ្រប់អាយុពលកម្ម ។ តាមរូបមន្តនេះ គ្រួសារណាមានសមាជិកធ្វើពលកម្មច្រើននាក់ គឺទទួលបានដីច្រើន ហើយជាលទ្ធផលនាំឱ្យមានលក្ខណ:ខុសគ្នាមួយក៏រឹត ក្នុងការបែងចែកដីនៅឆ្នាំ១៩៨៩ នៅពេលធ្វើការកំណត់ទំហំកាន់កាប់ដីទៅតាមគ្រួសារ ។

លំនាំនៃការបែងចែកដីនេះ គឺមានលក្ខណ:ពិតជាក់ស្តែងទាំងសំរាប់គ្រួសារមានស្ត្រី និងគ្រួសារមានបុរសជាមេគ្រួសារ ។ ប៉ុន្តែគ្រួសារមានបុរសជាមេគ្រួ មានដីជាមធ្យម ៤.៤ក្បាលដី/គ្រួសារ ដែលមានទំហំ ០,៣៩ហ.ត/ក្បាលដី រីឯគ្រួសារមានស្ត្រីជាមេគ្រួ មានដីជាមធ្យម ៣.៨ក្បាលដី/គ្រួសារ ដែលមានទំហំ ០,៣០ហ.ត/ក្បាលដី ។ ៣៤% នៃគ្រួសារមានស្ត្រីជាមេគ្រួ និង ១៨% នៃគ្រួសារមានបុរសជាមេគ្រួ មានដីកសិកម្មតិចជាងកន្លះហិកតា ។ ផ្ទុយទៅវិញ ១៧% នៃគ្រួសារមានស្ត្រីជាមេគ្រួ និង ៣១% នៃគ្រួសារមានបុរសជាមេគ្រួ មានដីកសិកម្មច្រើនជាង ២ហិកតា ។

គ្រួសារកាន់កាប់ដីធំៗ បានទទួលដីកសិកម្មច្រើន តាមរយ:ការទិញនិងការកាប់រានដីថ្មី ជាងគ្រួសារកាន់កាប់ដីតូចៗ ប៉ុន្តែគ្រួសារកាន់កាប់ដីតូច បានទទួលដីពីរដ្ឋ (គឺការបែងចែកដីឆ្នាំ១៩៨៩) និងពីការបន្តមរតកច្រើនជាង ។ ហេតុផលនេះគឺដោយសារអ្នកកាន់កាប់ដីធំៗ មានប្រាក់ចំណូលជាមធ្យមខ្ពស់ និងលទ្ធភាពពលកម្មច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ គ្រួសារមានស្ត្រីជាមេគ្រួ បានទទួលដីពីរដ្ឋច្រើនជាងគ្រួសារមានបុរសជាមេគ្រួ ។ ទន្ទឹមគ្នានេះ ភាគរយនៃក្បាលដីទទួលបានតាមរយ:ការបន្តមរតក សំរាប់គ្រួសារមានស្ត្រីជាមេគ្រួ (១១,២%) ទាបខ្លាំងជាងគ្រួសារមានបុរសជាមេគ្រួ (២៤.៦%) ។ ភាគរយនៃការទទួលបានដី ដោយការទិញនិងការកាប់រាន ក៏មានក៏រឹតទាបជាង សំរាប់គ្រួសារមានស្ត្រីជាមេគ្រួដែរ ។ ការទទួលបានដីតាមរយ:ការបន្តមរតក ការទិញ និងការកាប់រាន មានភាគរយទាបនោះ បានផ្តល់ជាគំនិតថា គ្រួសារមានស្ត្រីជាមេគ្រួ មានលទ្ធភាពទទួលបានក្បាលដីបន្ថែមតិចជាងគ្រួសារមានបុរសជាមេគ្រួ ។

[១] ចំណាត់ថ្នាក់ទាំង ៥ នៃការកាន់កាប់ដីគឺ <០,៥ហ.ត, ០,៥-០,៩៩ហ.ត, ១,០-១,៩៩ហ.ត, ២,០-២,៩៩ហ.ត និង >៣,០ហ.ត ។ គ្រួសារគ្មានដីទាំងអស់ ៧៦គ្រួសារ ក៏ត្រូវបានដាក់បញ្ចូលក្នុងប្រជាជនដែលត្រូវធ្វើអង្កេតដែរ ។

**លទ្ធភាពទទួលបានឥណទាន**

ក្រុមអង្កេត LMAP បានរាយការណ៍ថា មានកំចីសរុប ៧៤៣កំចី ក្នុងអំឡុងពេល៦ខែមុនពេលអង្កេត ។ ប្រហែល ៦០% នៃកំចីទទួលពីវិស័យក្រៅផ្លូវការ ក្នុងនោះមានសាច់ញាតិនិងមិត្តភក្តិ (៤៣,៧%) និងអ្នករកស៊ីចងការប្រាក់ (១៦,០%) ។ កំចី ៣១% ទទួលបានពីវិស័យផ្លូវការ គឺមានធនាគារ ACLEDA(៦,១%) ឬស្ថាប័នមីក្រូហិរញ្ញវត្ថុផ្សេងទៀត (MFI) (២៤,៩%) ។ កំចី ៩%ទៀត ទទួលបានពីវិស័យពាក់កណ្តាលផ្លូវការគឺ NGO (ដូចជា ក្រុមសន្សំប្រាក់ និងក្រុមកំចីតូចៗ) ។

ការវិនិយោគក្នុងផលិតកម្មតំណាងឱ្យ ៣៦% នៃសកម្មភាពឥណទានទាំងអស់នៅក្នុងក្រុមមុខសញ្ញាអង្កេត ក្នុងនោះមានអាជីវកម្មតូចៗ (១២%) ផលិតកម្មកសិកម្ម (១៤,៤%) និងការចិញ្ចឹមសត្វ (៩,៦%) ។ គ្រួសារមានបុរសជាមេគ្រួ បានខ្ចីសំរាប់ការដាំដុះ និងសកម្មភាពជំនួញច្រើនជាងគេ រីឯគ្រួសារមានស្ត្រីជាមេគ្រួបានខ្ចីសំរាប់សកម្មភាពចិញ្ចឹមសត្វច្រើនជាងគេ ។ ប៉ុន្តែការថែទាំសុខភាព (២១,៧%) និងកង្វះស្បៀងអាហារ (១៧,៩%) តំណាងឱ្យជិតដល់ ៤០% នៃកំចីទាំងអស់ ។ គ្រួសារមានបុរសជាមេគ្រួ និងគ្រួសារមានស្ត្រីជាមេគ្រួ មានភាគរយប្រហាក់ប្រហែលគ្នាក្នុងការខ្ចីសំរាប់ការថែទាំសុខភាព ប៉ុន្តែភាគរយគ្រួសារមានស្ត្រីជាមេគ្រួ បានខ្ចីប្រាក់សំរាប់ដោះស្រាយកង្វះស្បៀងអាហារ មានកំរិតខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួ ។ កំចីនៅសល់ (២៤,៥%) គឺសំរាប់សកម្មភាពផ្សេងៗទៀតដូចជា ពិធីបុណ្យ ការសង់ផ្ទះ និងការដឹកជញ្ជូន ។

ប័ណ្ណកម្មសិទ្ធិដីត្រូវគេរំពឹងថា នឹងជួយបង្កើនចំនួន និងទំហំទឹកប្រាក់កំចីជាមធ្យម សំរាប់ការធ្វើវិនិយោគក្នុងផលិតកម្មកសិកម្ម និងសកម្មភាពបង្កើតប្រាក់ចំណូលផ្សេងទៀត (ឧ. ការចិញ្ចឹមសត្វ រឺអាជីវកម្មតូចៗ) ។ រឿងនេះសន្មតថា ទីផ្សារឥណទាន មានដំណើរការល្អគួរសមក្នុងតំបន់ជាក់លាក់ណាមួយ ហើយប្រជាជនមានចំណង់ និងមានសមត្ថភាពក្នុងការខ្ចីប្រាក់ ។ ជាទូទៅ សម្មតិកម្មនៃការស្រាវជ្រាវ បានទស្សន៍ទាយថា សកម្មភាពឥណទាន នឹងកើនឡើងនៅក្នុងតំបន់ដែលស្ថាប័នឥណទានជាផ្លូវការ បានផ្តល់លទ្ធភាពច្រើនឡើងៗដល់កសិករតាមមូលដ្ឋាន ។ សម្មតិកម្មនៃការស្រាវជ្រាវ ក៏បានទស្សន៍ទាយដែរថា មានការប្រែប្រួលខុសគ្នាខ្លះចំពោះភាពញឹកញាប់ ទំហំ និងការប្រើប្រាស់ឥណទាន ទៅតាមទំហំកាន់កាប់ដី និងភេទនៃមេគ្រួសារ ។

**វិនិយោគកសិកម្ម ផលិតភាព និងការប្រើប្រាស់ដី**

ចំនួនជាមធ្យមនៃការចំណាយលើកសិកម្មក្នុងគ្រួសារនិមួយៗ កើនឡើងទៅតាមទំហំកាន់កាប់ដី ។ ឧទាហរណ៍ ចំណាត់ថ្នាក់កាន់កាប់ដីទាបជាងគេពីរក្រុម មានចំណាយជាមធ្យមក្នុងមួយគ្រួសារៗគឺ ១៣,០៣ និង ២១,៩៧ម៉ឺនរៀលរៀងគ្នា រីឯចំណាត់ថ្នាក់កាន់កាប់ដីខ្ពស់ជាគេពីរក្រុមវិញមានចំណាយជាមធ្យម ៣១,៦ និង ៥១,៩៨ម៉ឺនរៀលរៀងគ្នា ។ គ្រួសារមានបុរសជាមេគ្រួចំណាយប្រហែល ៥០% ច្រើនជាងគ្រួសារមានស្ត្រីជាមេគ្រួសំរាប់ផលិតកម្មស្រូវ ។ ជិត ៩០% នៃចំណាយលើផលិតកម្មស្រូវត្រូវដោះស្រាយដោយទុនប្រភពផ្ទាល់ខ្លួន ហើយបន្ទាប់មកគឺ កំចីពីសាច់ញាតិ និងមិត្តភក្តិ (៨,៣%) និងឥណទានពីកម្មវិធីផ្សេងៗ ដូចជា គំរោងពាក់កណ្តាលផ្លូវការរបស់ NGOs, MFIs និងធនាគារពាណិជ្ជ (២,៣%) ។

## *ផលិតភាព*

ទិន្នន័យអង្កេតបានបញ្ជាក់អោយឃើញពីភាពផ្ទុយគ្នារវាងទំហំកសិដ្ឋាននិងផលិតភាព ដែលគេបានសង្កេតឃើញនៅកម្ពុជា និងប្រទេសឯទៀតនៅអាស៊ី ។ កសិដ្ឋានតូចៗ ច្រើនមានទិន្នផលស្រូវក្នុង ១ហ.ត ខ្ពស់ជាងកសិដ្ឋានធំៗ ដោយគ្មាន ទាក់ទងអ្វីទៅនឹងភេទនៃមេគ្រួសារទេ ។ ហេតុផលមួយដែលមានលើកឡើងជារឿយៗ ដើម្បីពន្យល់ពីលំនាំនេះ គឺក្បាលដីតូចៗច្រើនកើតចេញពីការពុះច្រៀកដីមានជីជាតិល្អ ។ ហេតុផលមួយទៀត គឺពលកម្មក្នុងគ្រួសារ និងកត្តាផលិតកម្មផ្ទាល់ខ្លួនផ្សេងទៀត បានប្រើប្រាស់ច្រើននៅក្នុងកសិដ្ឋានតូចៗ ដែលពុំមានប្រើបច្ចេកទេសកសិកម្មទំនើប ។ យោងតាមទិន្នន័យអង្កេតកសិដ្ឋានតូចៗក៏ហាក់ដូចមានប្រើប្រាស់កត្តាផលិតកម្ម ដែលទិញគេសំរាប់ផលិតកម្មស្រូវ ច្រើនជាងកសិដ្ឋានធំៗដែរ ។ ឧទាហរណ៍ ចំណាត់ថ្នាក់ដីកាន់កាប់តូចជាងគេពីរក្រុម បានចំណាយ ៥១,៣ម៉ឺនរៀល និង ៣២,៤ ម៉ឺនរៀល ក្នុងដីមួយហិកតា រីឯចំណាត់ថ្នាក់ដីកាន់កាប់ធំជាងគេពីរក្រុម ចំណាយតែ ១៨,៥ ម៉ឺនរៀល និង ១៩,៥ម៉ឺនរៀលក្នុងមួយហិកតា ។

ថ្វីបើដីកសិដ្ឋានតូចៗអាចមានផលិតភាពខ្ពស់ជាងកសិដ្ឋានធំៗក្តី (គិតជាគីឡូក្រាម/ហិកតា) ក៏កសិដ្ឋានតូចៗ មានផលិតភាពទាបជាងវិញបើគិតពីទុនវិនិយោគ (គិតជាគីឡូក្រាម/ម៉ឺនរៀល) ។ ឧទាហរណ៍ កសិដ្ឋានមានដីតិចជាង ០,៥ហ.ត ទទួលបាន ៣៩,៩៨គ.កស្រូវ ក្នុងការចំណាយមួយម៉ឺនរៀល រីឯកសិដ្ឋានមានដី ២,០-២,៩៩ហ.ត និងធំជាង ៣,០ហ.ត ទទួលបាន ៦១,៨៩គ.កស្រូវ និង ៥២,១គ.កស្រូវ ក្នុងការចំណាយមួយម៉ឺនរៀល ។ តួលេខនេះបង្ហាញថា ផលិតភាពនៃដើមទុនមានសារៈសំខាន់ជាងការវិនិយោគទៅលើអចលនទ្រព្យ ។ ការពង្រីកសេវាផ្សព្វផ្សាយបច្ចេកទេស និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអោយកាន់តែប្រសើរឡើង អាចជួយបង្កើនផលិតភាពនៃដើមទុន ដែលមានទាំងទុនខ្ចីពីប្រភពឥណទានផ្លូវការដោយប្រើប័ណ្ណកម្មសិទ្ធិដីសំរាប់ធានាផង ។

ទិន្នផលខ្ពស់ (គិតជាគីឡូក្រាម/ហិកតា) ដែលកសិដ្ឋានតូចៗទទួលបាន មិនបានធ្វើឱ្យផលិតកម្មស្រូវសរុបក្នុងមួយគ្រួសារៗ កើនខ្ពស់ទេ ។ ឧទាហរណ៍ គ្រួសារមានដីតិចជាង ០,៥ហ.ត ផលិតស្រូវបានតែ ៦៤០,៣គ.ក ប៉ុណ្ណោះ រីឯ កសិដ្ឋានធំៗ ផលិតស្រូវ បានសរុប ៣.២៧០គ.ក/គ្រួសារ ។ ពិតហើយចំនួននេះវាជាប់ទាក់ទងនឹងទំហំកាន់កាប់ដី ។ កសិដ្ឋានតូចៗមានការចាញ់ប្រៀបមួយក៏រិត ពីព្រោះជារឿយៗត្រូវតែបន្តប្រើប្រាស់ធនធាននៅសេសសល់របស់គ្រួសារ (បន្ទាប់ពីការចំណាយលើកសិដ្ឋាន) ដើម្បីបំពេញកង្វះខាតស្បៀងអាហារ ដោយមិនបានធ្វើវិនិយោគក្នុងសកម្មភាពផ្សេងទៀតទេ ។ ម្យ៉ាងទៀត បើសិនកសិដ្ឋានតូចៗខ្ចីបុលគេ មកវិនិយោគលើការដាំដុះដែលមិនអាចផ្តល់អង្ករបានគ្រប់គ្រាន់សំរាប់ការហូបចុកក្នុងគ្រួសារ ឬមាននៅសល់ខ្លះសំរាប់លក់ទេ ពួកគេនឹងជំពាក់បំណុលកាន់តែធ្ងន់ពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែពួកគេមានប្រភពចំណូលអ្វីផ្សេងទៀត ។

## *ការប្រើប្រាស់ដីធ្លី*

ទិន្នន័យអង្កេតបង្ហាញថា លំនាំនៃការប្រើប្រាស់ដីធ្លីមានលក្ខណៈប្លែកទៅៗ នៅពេលទំហំដីកាន់កាប់កើនឡើង ។ ឧទាហរណ៍ ភាគរយនៃក្បាលដីសំរាប់ស្រូវវស្សាធ្លាក់ចុះ នៅពេលទំហំដីកើនឡើង រីឯភាគរយនៃក្បាលដីសំរាប់ស្រូវប្រាំង កើនឡើងស្របតាមកំណើនទំហំកាន់កាប់ដី ។ ប៉ុន្តែភាគរយនៃក្បាលដីសំរាប់ចំការ មានកំរិតថេរសំរាប់ស្ទើរគ្រប់ចំណាត់ថ្នាក់កាន់កាប់ដី រីឯ

ភាគរយនៃក្បាលដីទំនេរ កើនឡើងស្របតាមកំណើនទំហំដី ។ ភាគរយនៃក្បាលដីសំរាប់ធ្វើចំការ (ដំណាំជាដើមឈើ) និង ដំណាំចំរុះ មានកំរិតទាបសំរាប់គ្រប់ចំណាត់ថ្នាក់កាន់កាប់ដី ។ ជាលទ្ធផល វាហាក់ដូចជាមានសក្តានុពលច្រើនណាស់សំរាប់ការដាំដំណាំចំរុះ នៅក្នុងតំបន់អង្កេតជាច្រើន ។

ចំពោះការប្រើប្រាស់ដីជាក់ស្តែង ប្រហែល ៩០% នៃក្បាលដីទាំងអស់មានការដាំដុះ ទោះជាបីភាគរយនេះថយចុះស្របតាមទំហំដីក្តី ។ ភាគរយនៃក្បាលដីដាំដុះ មានកំរិតប្រហាក់ប្រហែលគ្នាសំរាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ ក្នុងគ្រប់ចំណាត់ថ្នាក់ដីកាន់កាប់ទាំងអស់ ។ ភាគរយនៃក្បាលដីទំនេរ (៧.៦%) កើនឡើងស្របតាមទំហំដី រីឯភាគរយនៃក្បាលដី ជួលឱ្យគេ (១.៦%) មានកំរិតស្មើគ្នាសំរាប់គ្រប់ចំណាត់ថ្នាក់កាន់កាប់ដី ។ គ្រួសារមានស្ត្រីជាមេគ្រួ ច្រើនតែមានភាគរយក្បាលដីទំនេរ ខ្ពស់ជាងគេបន្តិច និងមានភាគរយក្បាលដីជួលឱ្យគេខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួ ។

សម្មតិកម្មនៃការស្រាវជ្រាវបានទស្សន៍ទាយពីការប្រើប្រាស់ដីប្លែកៗ ដូចជា ផលិតកម្មចំការ និងដំណាំចំរុះ ដែលផ្តល់ផលក្នុងរយៈពេលវែង (ស្វាយចន្ទី ដើមកៅស៊ូ...) ។ សម្មតិកម្មនៃការស្រាវជ្រាវក៏បានទស្សន៍ទាយដែរថា ទំហំនិងឱកាសនៃការប្រើប្រាស់ដីប្លែកៗនេះ នឹងកើនកាន់តែលឿនស្របតាមទំហំកាន់កាប់ដី រីឯអត្រានៃការប្រើប្រាស់ដីក្នុងគ្រប់ចំណាត់ថ្នាក់កាន់កាប់ដី នឹងកើនឡើង នៅខណៈពេលដែលកសិករចាប់ផ្តើមខ្ចីប្រាក់កាន់តែច្រើនសំរាប់វិនិយោគក្នុងកសិកម្ម ។ ប៉ុន្តែ ឥទ្ធិពលនៃប័ណ្ណកម្មសិទ្ធិដីធ្លី ក៏ប្រែប្រួលទៅតាមទីតាំង និងកត្តាស្ថានការណ៍ដទៃទៀតដូចជា លទ្ធភាពទទួលឥណទាន ការពង្រីកសេវាកម្មផ្សព្វផ្សាយបច្ចេកទេស ការវិនិយោគ ខាងហេដ្ឋារចនាសម្ព័ន្ធ និងថ្លៃនៅទីផ្សារ ។

## ទីផ្សារដីធ្លី: តំលៃ និងការទិញលក់ដី

យោងតាមទិន្នន័យអង្កេតតំលៃដី (ម៉ឺនរៀល/ហ.ត) ថយចុះនៅពេលទំហំកាន់កាប់ដីកើនឡើង ទាំងគ្រួសារមានបុរសជាមេគ្រួ និងគ្រួសារមានស្ត្រីជាមេគ្រួ ។ ប៉ុន្តែគេគួររំពឹងថា តំលៃដីមានការប្រែប្រួលខ្លះដែរទៅតាមទីតាំងនៃក្បាលដី (ឧ. នៅជិតឬជាប់ផ្លូវធំ/នៅជិតផ្ទះ) ។ ថ្វីបើតំលៃដីក្នុង១ហិកតានៃកសិដ្ឋានតូចៗ មានកំរិតខ្ពស់ក្តី ប៉ុន្តែតំលៃក្បាលដីជាមធ្យមរបស់កសិដ្ឋានតូចៗ មានកំរិតទាបជាងតំលៃក្បាលដីជាមធ្យមរបស់កសិដ្ឋានធំៗ ពីព្រោះវាជាប់ទាក់ទងដោយផ្ទាល់ទៅនឹងទំហំក្បាលដី ។ ឥទ្ធិពលមួយនៃលំនាំនេះ គឺលទ្ធភាពទទួលឥណទាន ។ បើទំហំប្រាក់កំចី វាជាប់ទាក់ទងមួយផ្អែកទៅនឹងតំលៃវត្ថុ ដែលគេមានសំរាប់ដាក់ធានា ដូច្នេះកសិដ្ឋានធំៗ អាចទទួលបានកំចីមានទឹកប្រាក់ច្រើនជាងកសិដ្ឋានតូចៗ ។

ជារួម សម្មតិកម្មនៃការស្រាវជ្រាវបានទស្សន៍ទាយថា តំលៃដីនឹងកើនឡើង នៅពេលដែលគ្រួសារកសិករកែលំអការប្រើប្រាស់ដី និងអាចប្រើប្រាស់ដីរបស់ខ្លួនអោយបានប្លែកៗក្នុងទិសដៅបង្កើនការប្រើប្រាស់ដីអោយមានប្រសិទ្ធភាពសេដ្ឋកិច្ច ។ តំលៃដីនៅតាមដង ផ្លូវធំៗ នៅជិតមណ្ឌលរដ្ឋបាល និងទីផ្សារ នឹងកើនឡើងយ៉ាងលឿន ។

### *ការលក់ដី*

២០១គ្រួសារ បានរាយការណ៍ពីការលក់ដីសរុប ៣០៣លើក គិតតាំងពីឆ្នាំ១៩៨៩ ដែលតំណាងឱ្យ ៧.៨% នៃក្បាលដីទាំងអស់ក្នុងអង្កេតនេះ ។ ការលក់ដីក្នុងចំណាត់ថ្នាក់កាន់កាប់ដីទាបជាងគេពីរក្រុម គឺមានច្រើនហួសកំរិត បើធៀបនឹងចំណាត់ថ្នាក់

កាន់កាប់ដីខ្ពស់ៗបីក្រុមទៀត ។ ឧទាហរណ៍ ចំណាត់ថ្នាក់ដីកាន់កាប់ទាបៗទាំងពីរក្រុមមាន ៣៣,៧% នៃក្បាលដីទាំងអស់ ក្នុងតំបន់អង្កេតនៃគំរោង LMAP ប៉ុន្តែវាតំណាងឱ្យ ៥០,៨% នៃចំនួនក្បាលដីសរុបបានលក់ ។ ក្នុងពេលជាមួយគ្នា ចំណាត់ថ្នាក់កាន់កាប់ដី ខ្ពស់ជាងគេពីរក្រុម មាន ៣៨% នៃក្បាលដីទាំងអស់ ប៉ុន្តែតំណាងឱ្យតែ ២៩% នៃក្បាលដីបានលក់ប៉ុណ្ណោះ ។

ជារឿយៗ ហេតុផលនៃការលក់ដីបានលើកឡើង គឺសំរាប់ថែទាំសុខភាព (២៤,៩%) បន្ទាប់មកគឺ វិនិយោគលើរបររកស៊ី (១៨,៦%) ហើយនិងលក្ខណៈដីផ្ទាល់ដូចជា ដីតូចពេកគ្មានផលចំណេញ ដីខ្វះជីជាតិ ឬ ដីនៅឆ្ងាយពេក (៩,៧%) ។ ការលក់ដី ៨,៥% ទៀត គឺសំរាប់ដោះស្រាយកង្វះខាតស្បៀង ។ យើងរំពឹងថា ការលក់ដីដោយសារហេតុផលទាំងនេះ នឹងមានជាបន្តក្នុងកំរិតដដែល (បើមិនខ្ពស់ជាងនេះ) នៅតាមតំបន់នានាដែលកំពុងខ្វះខាតឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសេវាថែទាំសុខភាព ។ ហេតុផលផ្សេងទៀតនៃការលក់ដី មានដូចជា ការសងបំណុល បុណ្យសព សោហ៊ុយធ្វើចំណាកស្រុក និងគ្រោះថ្នាក់ធម្មជាតិ (ទឹកជំនន់ កង្វះទឹកភ្លៀង) ។

តំបន់ទាំងបួន ដែលមានថ្លៃលក់ដីជាមធ្យមខ្ពស់ជាងគេ គឺស្ថិតនៅជិតក្រុងភ្នំពេញ ឬទីរួមខេត្ត និង/ឬ មានគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងផែនការ ឬកំពុងអនុវត្ត ។ ថ្លៃដីអាចនឹងកើនឡើងនៅក្នុងតំបន់នានា ដែលមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីហើយ ។ ទន្ទឹមគ្នានេះ ឃុំពីរស្ថិតនៅឆ្ងាយពីផ្លូវធំ និងឆ្ងាយពីទីផ្សារ/មណ្ឌលរដ្ឋបាលមានថ្លៃលក់ដីទាបបំផុត ។ ដីក្នុងតំបន់ទាំងនេះ ក៏អាចឡើងថ្លៃដែរ ប៉ុន្តែដោយល្បឿនយឺតបំផុត ។

ប័ណ្ណកម្មសិទ្ធិដីធ្លីតែមួយមុខ មិនអាចពន្យឺតឬពន្លឿនអត្រាលក់ដីរបស់ក្រុមចំណាត់ថ្នាក់កាន់កាប់ដីមួយណាបានឡើយ ។ ឧទាហរណ៍ នៅក្នុងតំបន់អង្កេត ប្រសិនបើសេវាព្យាបាលសុខភាពមិនមានតំលៃថោកទេ ការលក់ដីរំពឹងថានឹងនៅមានកំរិតដូចមុន ឬមានច្រើនថែមទៀត ។ ម្យ៉ាងទៀត បើសិនទៅអនាគតប្រជាជនប្រើប័ណ្ណកម្មសិទ្ធិដីធ្លីសំរាប់ធានាកំចីដើម្បីយកមកវិនិយោគក្នុងជំនួញ និងសកម្មភាពផ្សេងទៀត ការលក់ដីរំពឹងថានឹងថយចុះ ។ ប៉ុន្តែបើវិនិយោគទទួលបរាជ័យ ប្រជាជនអាចត្រូវលក់ដីដើម្បីសងបំណុល ។ ក្នុងករណីណាក៏ដោយ ប័ណ្ណកម្មសិទ្ធិដីធ្លី អាចជួយប្រជាជនឱ្យលក់ដីបានថ្លៃជាងមុន ទោះបីជាវាជួយសំរាលការលំបាកបានតិចតួចក្តី ចំពោះអ្នកគ្មានចំណូលជាក់លាក់អ្វីផ្សេងទៀតក្រៅពីការធ្វើស្រែចំការ ។

## ការរៀបចំដែនដី និងរដ្ឋបាលដីធ្លី

ក្បាលដីសំរាប់កសិកម្មប្រហែល ៦២,៧% ក្នុងតំបន់អង្កេតនៃគំរោង LMAP មិនទាន់មានការកត់ត្រាបញ្ជាក់ជាឯកសារអ្វីទេ ។ ក្នុងចំណោមក្បាលដីមានឯកសារកត់ត្រា ៦១,៦% មានបង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដីរីឯ ១៤,៩% មានឯកសារកំណត់ហេតុអង្កេតដី ។ ក្បាលដីតែ ៨,១% ប៉ុណ្ណោះ បានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ឬប័ណ្ណកម្មសិទ្ធិដី ហើយ ៦,៣% ប្រើប្រាស់ឯកសារបញ្ជាក់ផ្សេងទៀត ។ ជាទូទៅ នៅក្នុងគ្រប់ចំណាត់ថ្នាក់កាន់កាប់ដី យើងឃើញមានប្រើឯកសារបញ្ជាក់មិនផ្លូវការដូចគ្នា ។

អ្នកឆ្លើយសំនួរទាំងអស់ បានផ្តល់ហេតុផលផ្សេងៗចំពោះការមិនបានចុះបញ្ជីដីធ្លីរបស់ខ្លួន ក្នុងនោះមាន ២៣% និយាយថា មិនបានដឹងពីនីតិវិធី ២១% និយាយថា ដីធ្លីមិនចាំបាច់ចុះបញ្ជីទេបើតាមការយល់ឃើញរបស់គាត់ ហើយ ៧% ផ្សេងទៀតនិយាយថា ដំណើរការចុះបញ្ជីមានភាពស្មុគស្មាញពេក ។ ទាំងអស់នេះ សុទ្ធតែជាហេតុផលពាក់ព័ន្ធនឹងដំណើរការដែលបង្ហាញពី

ការយល់ច្រឡំ យ៉ាងខ្លាំងក្នុងចំណោមប្រជាជន អំពីទិដ្ឋភាពផ្សេងៗនៃប្រព័ន្ធចុះបញ្ជីដីធ្លី ។ ជាលទ្ធផល វាក៏បង្ហាញដែរថា កំណើននៃការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីដីធ្លី គឺពឹងផ្អែកមួយភាគធំទៅលើបរិមាណ និងគុណភាពព័ត៌មានដែលបានទៅដល់ប្រជាជននៅមូលដ្ឋាន ហើយនិងកំរិតយល់ដឹងរបស់ប្រជាជនអំពីនីតិវិធីចុះបញ្ជីដីធ្លី ។ វាក៏ជាប់ទាក់ទងផងដែរទៅនឹងលទ្ធភាពរបស់ប្រជាជនក្នុងការប្រើប្រាស់ប្រព័ន្ធ ព្រមទាំងប្រសិទ្ធភាពនៃប្រព័ន្ធនេះផងដែរ ។

អ្នកធ្វើផែនការរបស់រដ្ឋ បានរំពឹងថានឹងមានកំណើនភាគរយនៃការលក់ឬផ្ទេរដី ដែលត្រូវបានគេសំរបសំរួលតាមរយៈប្រព័ន្ធចុះបញ្ជីផ្លូវការ ជាពិសេសក្នុងទីផ្សារដីមានសកម្មភាពខ្លាំង និងមានកំណើនថ្លៃដី ។ ការរំពឹងទុកទាំងនេះបានសន្មតថា (១) ការចំណាយទៅលើការលក់/ផ្ទេរដី រួមទាំងការចុះបញ្ជីផ្លូវការ នឹងចុះទាបជាងសព្វថ្ងៃ (២) ប្រជាជនកាន់តែមានទំនុកចិត្តទៅលើសន្តិសុខនៃការកាន់កាប់ដី និង (៣) ប្រជាជនមានចំណេះដឹងអំពីនីតិវិធីដ៏សមស្រប និងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីប្រើប្រាស់ប្រព័ន្ធនេះ ។

កំរិតដែលប្រជាជននឹងប្រើប្រាស់ប្រព័ន្ធចុះបញ្ជីផ្លូវការដើម្បីសំរួលនិងកត់ត្រាការផ្ទេរដីធ្លី ក៏ពឹងផ្អែកផងដែរទៅលើសមត្ថភាពរបស់រដ្ឋបាលសាធារណៈក្នុងការគ្រប់គ្រង និងពង្រឹងកម្មសិទ្ធិអចលនទ្រព្យឱ្យមានប្រសិទ្ធភាព ។ ក្នុងន័យនេះ ប្រជាជនក្នុងតំបន់អង្កេតមូលដ្ឋាន បានបញ្ជាក់ពីទំនុកចិត្តយ៉ាងច្រើនតាំងពីដំបូងទៅលើប័ណ្ណកម្មសិទ្ធិដីធ្លី ដែល LMAP កំពុងផ្តល់ឱ្យ ។ កំរិតដែលប្រជាជន នឹងប្រើប្រាស់ប្រព័ន្ធចុះបញ្ជីផ្លូវការ ក៏អាចប្រែប្រួលផងដែរទៅតាមសមត្ថភាព និងឆន្ទៈរបស់គេក្នុងការបង់ប្រាក់កំរៃផ្សេងៗ និងពន្ធដារ ដែលជាប់ទាក់ទិន ។ ប្រជាជននឹងបន្តចៀសវាងការចុះបញ្ជីជាផ្លូវការតទៅទៀត បើសិនពួកគេមានអារម្មណ៍ថា អត្រាពន្ធវាខ្ពស់ពេក និង/ឬ វិធានការបែបនេះមិនត្រូវបានគ្រប់គ្រងដោយសមស្របល្អ ឬដោយយុត្តិធម៌ទេនោះ ។

## ទំនាស់ដីធ្លី

នៅក្នុងតំបន់អង្កេតនៃគំរោង LMAP គេឃើញមានសេចក្តីរាយការណ៍ពីទំនាស់ដីធ្លី ៦១ករណី ដែលបានកើតឡើង គិតតាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់មក និងមានចំនួនប្រហាក់ប្រហែលគ្នាសំរាប់ដីកសិកម្ម និងដីសង់លំនៅដ្ឋាន ។ ក្នុងនោះទំនាស់ព្រំប្រទល់ដីរវាងអ្នកជិតខាងគ្នាមាន ៣៨,៣%, បន្ទាប់មកគឺ ទំនាស់ជាមួយអ្នកភូមិផ្សេងទៀត (២១,៦%) និងទំនាស់រវាងសាច់ញាតិ (២0%) និងមាន ៦ករណី ពាក់ព័ន្ធនឹងការទន្ទ្រានយកដី ឬការរំលោភយកដីពីសំណាក់អាជ្ញាធរ ឬអ្នកមានអំណាច ។ របាយតាមប្រភេទនៃទំនាស់ដីធ្លី បានបញ្ជាក់លើការសង្កេតឃើញពីលើកមុន (So *et al.*, 2002) ដែរថា ទំនាស់ដីធ្លីភាគច្រើន រហូតមកទល់ពេលនេះ គឺជាទំនាស់នៅក្នុងមូលដ្ឋាន ដែលពាក់ព័ន្ធនឹងបញ្ហាព្រំប្រទល់ដីរវាងអ្នកជិតខាង ឬ វិវាទអំពីកម្មសិទ្ធិដីរវាងសាច់ញាតិ ។ ទោះយ៉ាងនេះក្តី មានការសិក្សាផ្សេងៗទៀតបានរាយការណ៍ថា ករណីទន្ទ្រាន និងការរំលោភយកដីមានកាន់តែច្រើនឡើង នៅតាមកន្លែងឯទៀតៗក្នុងប្រទេសកម្ពុជា ។ រឿងនេះបង្ហាញអោយឃើញថា កំរិតនិងរូបភាពនៃទំនាស់ដីធ្លី អាចប្រែប្រួលខ្លាំងទៅតាមកន្លែងនិមួយៗ ។

គ្រួសារជាច្រើន បានប្រើវិធីសាស្ត្រផ្សេងៗដើម្បីដោះស្រាយទំនាស់ ហើយមានករណីជាច្រើន គឺត្រូវចរចាគ្នាជាច្រើនជំហាន ។ ឧទាហរណ៍ ក្នុងការដោះស្រាយនៅជុំទីមួយ ២១គ្រួសារថា បានចរចាដោយផ្ទាល់ជាមួយភាគីម្ខាងទៀត ហើយ

២៣គ្រួសារបានទៅរក មេភូមិ ៨គ្រួសារបានទៅរកមេឃុំ និង ៣គ្រួសារបានទៅរកគណៈកម្មាធិការដោះស្រាយវិវាទនៅថ្នាក់ស្រុក ។ ចំណូលចិត្តយ៉ាងច្បាស់ របស់ប្រជាជនក្នុងការព្យាយាមដោះស្រាយទំនាស់នៅថ្នាក់មូលដ្ឋាន អាចពន្យល់បានថា ទំនាស់ទាំងនោះច្រើនតែជាទំនាស់ក្នុងមូលដ្ឋាន ហើយការចំណាយក្នុងការលក់/ផ្ទេរដីពាក់ព័ន្ធនឹងការដោះស្រាយវិវាទ នឹងកើនឡើងនៅពេលដែលប្រជាជនចេញទៅក្រៅភូមិដើម្បីរកកិច្ចអន្តរាគមន៍ ។ នៅជុំទី១នេះ មាន ២៨ករណីដោះស្រាយបាន (ជិតពាក់កណ្តាល) និង ៣១ករណី ដោះស្រាយមិនបាន ។

២៧គ្រួសារ (៦២,៨%) ក្នុងចំណោម ៤៣គ្រួសារពាក់ព័ន្ធ បានបញ្ជាក់ថា ពួកគេបានពេញចិត្តចំពោះការដោះស្រាយទំនាស់ រីឯគ្រួសារនៅសល់ពីនេះគឺមិនពេញចិត្ត ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលមាន ២៦គ្រួសារយល់ថា លទ្ធផលដំណោះស្រាយមានភាពយុត្តិធម៌ រីឯគ្រួសារនៅសល់យល់ថា វាមិនយុត្តិធម៌ទេ ។ ដូច្នេះគេឃើញមានទំនាក់ទំនងយ៉ាងច្បាស់រវាងការពេញចិត្តរបស់គ្រួសារណាមួយចំពោះលទ្ធផលនៃដំណោះស្រាយ ហើយនិងអារម្មណ៍របស់គ្រួសារនោះពីភាពយុត្តិធម៌នៃលទ្ធផល ។

## សង្ខេប

ទំហំកាន់កាប់ដី និងភេទនៃមេគ្រួសារ មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងពលកម្ម ទ្រព្យសម្បត្តិ និងប្រាក់ចំណូលក្នុងគ្រួសារ ដូច្នេះវាអាចបង្ហាញបានយ៉ាងច្បាស់ពីសមត្ថភាពរបស់គ្រួសារ ដើម្បីទទួលបានអត្ថប្រយោជន៍ពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ។ ក្នុងចំណុចនេះ គ្រួសាររងផលប៉ះពាល់ជាសក្តានុពលខ្ពស់ (High Potential Impact Households: HPIs) គឺមានដីកាន់កាប់ធំ មានពលកម្មច្រើន មានទ្រព្យជាមូលធនច្រើន និងមានប្រាក់ចំណូលខ្ពស់ ។ រីឯគ្រួសាររងផលប៉ះពាល់ជាសក្តានុពលទាប (Low Potential Impact Households: LPIs) ច្រើនមានកំលាំងពលកម្មតិច ដីកាន់កាប់តូច ទ្រព្យជាមូលធនតិច និងមានប្រាក់ចំណូលទាប ។ ក្នុងចំណោម LPIs ក៏មានគ្រួសារងាយរងគ្រោះច្រើនផងដែរ ដូចជាគ្រួសារមានស្ត្រីជាមេគ្រួសារជាដើម ។ ជាទូទៅ គ្រួសារកាន់កាប់ដីធំៗ ច្រើនតែទទួលអត្ថប្រយោជន៍ពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីច្រើនជាងគ្រួសារកាន់កាប់ដីតូចៗ ។ ទន្ទឹមគ្នានេះ គ្រួសារមានបុរសជាមេគ្រួ ក៏ច្រើនតែមានស្ថានភាពល្អជាងគ្រួសារមានស្ត្រីជាមេគ្រួ ក្នុងការទទួលអត្ថប្រយោជន៍អំពីប័ណ្ណកម្មសិទ្ធិដីធ្លី ។

ទីតាំងភូមិនៅជិតផ្លូវក្រាលក្រួស/កៅស៊ូ មណ្ឌលពាណិជ្ជកម្ម និងមណ្ឌលរដ្ឋបាល ច្រើនតែជាសូចនាករមួយយ៉ាងល្អសំរាប់បង្ហាញពីភាពងាយស្វែងរកទីផ្សារ លទ្ធភាពទទួលឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ព្រមទាំងសេវាសង្គមកិច្ចផ្សេងៗទៀត ដូចជាការថែទាំសុខភាពជាដើម ។ ជាទូទៅ គ្រួសាររស់នៅជិតមណ្ឌលទាំងនេះ ស្ថិតក្នុងស្ថានភាពប្រសើរក្នុងការទទួលអត្ថប្រយោជន៍ពីគំរោងផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ LMAP ជាងគ្រួសាររស់នៅឆ្ងាយៗ ។ ភូមិមានដីល្អ មានប្រភពទឹក មានគំរូប្រើប្រាស់ដីប្លែកៗ មានការងារធ្វើច្រើន និងមានទុនផ្សេងៗច្រើនសំរាប់អភិវឌ្ឍន៍ គឺជាតំបន់មានសមត្ថភាពខ្ពស់ (High Capacity Areas: HCAs) ។ រីឯតំបន់មានសមត្ថភាពទាប (Low Capacity Areas: LCAs) មានភូមិស្ថិតនៅឆ្ងាយពីផ្លូវក្រាលក្រួស/កៅស៊ូ ឬនៅឆ្ងាយពីមណ្ឌលពាណិជ្ជកម្ម/មណ្ឌលរដ្ឋបាល មានដីគុណភាពអន់ ខ្វះប្រភពទឹក មានលំនាំប្រើប្រាស់ដីប្លែកៗតិច និងមានជំរើសការងារតិចក្រៅអំពីការធ្វើកសិកម្ម ។

សម្មតិកម្មនៃការស្រាវជ្រាវបានទស្សន៍ទាយថា គ្រួសារទទួលផលប៉ះពាល់ជាសក្តានុពលខ្ពស់ (HPI) នឹងទទួលបានអត្ថប្រយោជន៍ ច្រើនជាងគេអំពីប័ណ្ណកម្មសិទ្ធិដីនៅក្នុងភូមិនៃតំបន់មានសមត្ថភាពខ្ពស់ (HCA) ចំណែកឯគ្រួសារទទួលផលប៉ះពាល់ជាសក្តានុពលទាប (LPI) នឹងទទួលបានអត្ថប្រយោជន៍តិចជាងគេអំពីប័ណ្ណកម្មសិទ្ធិដីនៅក្នុងភូមិនៃតំបន់មានសមត្ថភាពទាប (LCA) ។ នៅក្នុងចន្លោះនេះ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ HPI នៅក្នុងតំបន់មានសមត្ថភាពទាប LCA មានស្ថានភាពកាន់តែប្រសើរក្នុងការប្រជែងទាញយកអត្ថប្រយោជន៍ពីការផ្តល់ប័ណ្ណកម្មសិទ្ធិដី នៅពេលដែលការអភិវឌ្ឍន៍វាកើតមានឡើង ។ ក្នុងពេលជាមួយគ្នានេះ គ្រួសារ LPI នឹងមានលទ្ធភាពកាន់តែតិចក្នុងការប្រជែងទាញយកអត្ថប្រយោជន៍ពីផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅក្នុងតំបន់ HCAs លើកលែងតែពួកគេអាចមានលទ្ធភាពប្រើប្រាស់ ឬអាចភ្ជាប់ទំនាក់ទំនងជាមួយកត្តាមានសមត្ថភាពខ្ពស់នានា ។

ការរួមចំណែករបស់ប័ណ្ណកម្មសិទ្ធិដី នៅក្នុងការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ច/សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ជនបទ អាចបានលទ្ធផលប្រសើរបំផុត តាមការផ្តោតកិច្ចប្រឹងប្រែងផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅក្នុងតំបន់ទាំងឡាយដែលស្ថាប័នរដ្ឋាភិបាល NGOs និងវិនិយោគិនឯកជន បានចូលរួមធ្វើសកម្មភាពយ៉ាងសកម្ម ដូចជា ក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការផ្តល់ឥណទាន សេវាថែទាំសុខភាព ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារសំរាប់កត្តាផលិតកម្មនិងផលិតផលកសិកម្ម ។ អត្ថប្រយោជន៍ចំពោះ គ្រួសារចាញ់ប្រៀបគេ ក៏អាចបង្កើនឡើងបានតាមរយៈគោលនយោបាយដែលផ្សារភ្ជាប់ការចេញប័ណ្ណកម្មសិទ្ធិដី ទៅនឹងគោលដៅអភិវឌ្ឍន៍នានា ដែលអំណោយផលដល់អ្នកក្រីក្រ ។ ក្នុងនេះការពិគ្រោះយោបល់ និងកិច្ចសហការយ៉ាងសកម្មរវាងតួអង្គអភិវឌ្ឍន៍ ទាំងអស់ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងនៃគំរោង LMAP នឹងជួយបង្កើនអត្ថប្រយោជន៍ដែលម្ចាស់ដីគ្រប់គ្នាទទួលបានពីប័ណ្ណកម្មសិទ្ធិដី ។

# ជំពូក ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាកំពុងដំណើរការកម្មវិធីកំណែទំរង់របស់ខ្លួន ដែលបានរៀបចំឡើងដើម្បីធ្វើឱ្យសំរេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយនិរន្តរភាព ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អ ។ រាជរដ្ឋាភិបាល កម្ពុជារួមជាមួយនឹងដៃគូរផ្តល់ជំនួយនានាទទួលស្គាល់ថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លីទាំងនៅតំបន់ជនបទ និងតំបន់ទីប្រជុំជន គឺជាមូលដ្ឋានគ្រឹះសំខាន់មួយដើម្បីសំរេចបាននូវគោលដៅទាំងនោះ ។ នៅក្នុងទិដ្ឋភាពនេះ សុវត្ថិភាពនៃសិទ្ធិ កាន់កាប់ដីធ្លីត្រូវបានសង្ឃឹមថា នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំនើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច ។ នៅក្នុងតំបន់ជនបទ សេចក្តីសង្ឃឹមទាំងនោះមានជាអាទិ៍ (ក) បង្កើនការលើកទឹកចិត្តដល់កសិករ ដើម្បីធ្វើការវិនិយោគលើផលិតកម្មកសិកម្ម (ខ) បង្កើនឱ្យកសិករកាន់តែអាចប្រើប្រាស់ស្ថាប័នឥណទានបាន និង (គ) បង្កើតទីផ្សារដី និងប្រព័ន្ធរដ្ឋបាលដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាព ។

ទាំងអស់នេះគឺជាការពិចារណា សំរាប់គាំទ្រដល់ការរំពឹងទុក ទាំងផ្នែកទ្រឹស្តី និងបទពិសោធន៍ពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យ និងសិទ្ធិកាន់កាប់ដីធ្លី ។ ឧទាហរណ៍ លោក Brandao និងលោក Feder (ឆ្នាំ១៩៩៦) អះអាងថា "សុវត្ថិភាពនៃការកាន់កាប់ទ្រព្យដោយបុគ្គល (ឬសាជីវកម្ម) គឺមានសារៈសំខាន់ណាស់ក្នុងការបង្កើតរចនាសម្ព័ន្ធសេដ្ឋកិច្ចលើកទឹកចិត្ត សំរាប់សកម្មភាពវិនិយោគដោយយកដីជាមូលដ្ឋាន" ។ មានអ្នកផ្សេងទៀតបានធ្វើការកត់សំគាល់ថា ប្រទេសជាច្រើនដែលវិនិយោគ ដើម្បីធ្វើឱ្យកាន់តែមានប្រសិទ្ធភាព និងសមភាពផ្នែករដ្ឋបាលដីធ្លី ប្រទេសទាំងនោះកាន់តែមានការអភិវឌ្ឍន៍លឿនជាងបណ្តាប្រទេសដែលមិនបានធ្វើការវិនិយោគលើផ្នែកនេះ ។ម្យ៉ាងទៀត ការខ្វះខាតសមភាពនៃការប្រើប្រាស់ដី និងការទទួលផលចំណេញពីសុវត្ថិភាពនៃការកាន់កាប់ដីធ្លី បានរួមចំណែកធ្វើឱ្យមានភាពក្រីក្រកាន់តែខ្លាំងឡើង ដែលគេមិនអាចពឹងផ្អែកលើខ្លួនឯងបាន និងគឺជាគំរូមួយដែលគ្មាននិរន្តរភាពនៃការធ្វើចំណាកស្រុកនៅតំបន់ជនបទ ។[២] ការសិក្សាអំពីផលប៉ះពាល់ពីការចុះបញ្ជីដីធ្លីនៅប្រទេសថៃ និងប្រទេសមួយចំនួនទៀតបានស្នើថា ការកត់សំគាល់លើផលប៉ះពាល់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងការលូតលាស់គឺមានសារៈសំខាន់ណាស់ (Onchan and Aungsumalin ២០០២) ។

ក៏វិតដែលលទ្ធភាពមានដីប្រើប្រាស់ និងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី អាចរួមចំណែកធ្វើឱ្យលូតលាស់ផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច និងការអភិវឌ្ឍន៍ វាពឹងផ្អែកជាសំខាន់នឹងសមត្ថភាពរបស់ស្ថាប័នសាធារណៈដើម្បីគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពនូវសិទ្ធិលើទ្រព្យ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពេលនេះកំពុងអនុវត្តកម្មវិធីរដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី ដែលស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី នៅក្នុងបរិបទនៃច្បាប់ភូមិបាលថ្មីខែសីហា ឆ្នាំ២០០១ ។ ធនាគារពិភពលោករួមជាមួយរដ្ឋាភិបាលនៃប្រទេសអាល្លឺម៉ង់ និងប្រទេសហ្វាំងឡង់ កំពុងគាំទ្រដំណើរការនេះតាមរយៈគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ។

---

[២] ឧទាហរណ៍ សូមមើល Munro-Faure, Paul (2003); "ការធ្វើប្បញ្ញតិកម្មលើសិទ្ធនៃភាពក្រីក្រ និងការអភិវឌ្ឍន៍នៅជនបទ ដែលជាការប្រឈមនៅក្នុង Latin America, http://www.for.nta.gob.nx/ponencias/Faure.PDF ។

គោលបំណងនៃគំរោង LMAP គឺធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី បង្កើតឱ្យមានការអភិវឌ្ឍន៍សមត្ថភាពទីផ្សារដី ។ នៅក្នុងចំណោមសកម្មភាពទាំងនេះ គំរោងនឹងជួយដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបង្កើតកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដែលដីចំនួន ១លានក្បាលដី នឹងត្រូវបានចុះបញ្ជីក្នុងរយៈពេល ៥ឆ្នាំនៃគំរោង ។[៣] សូចនាករគន្លឹះដើម្បីបំពេញការងារនេះ គឺពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពនៃការកាន់កាប់ដី បង្កើនលទ្ធភាពប្រើប្រាស់ឥណទាន បង្កើនការវិនិយោគលើវិស័យកសិកម្ម និងអាជីវកម្ម និងធ្វើឱ្យមានការលូតលាស់នៃផលិតផលកសិកម្ម ។ គំរោងក៏បញ្ចូលផងដែរនូវផែនការអភិវឌ្ឍទីផ្សារដី ក៏ដូចជាបង្កើនឱ្យមានការ ផ្ទេរដីតាមផ្លូវច្បាប់ដោយធ្វើការចុះបញ្ជីផ្លូវការ ។

ឯកសារវាយតំលៃគំរោង LMAP (Project Appraisal Document: PAD)[៤] នៃកម្មវិធីចុះបញ្ជីដីធ្លីបានចែងថា អង្កេតមូលដ្ឋាន គួរត្រូវបានធ្វើ មុនពេលអនុវត្តកម្មវិធីពេញលេញដើម្បីវាយតំលៃផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមពីកម្មវិធីចុះបញ្ជីដីធ្លី ។

គោលដៅបឋមនៃគំរោងអង្កេតមូលដ្ឋាន Baseline Survey Project (BSP) គឺដើម្បីប្រមូលទិន្នន័យវិភាគសំខាន់ៗ ដែលអាចប្រើជាមូលដ្ឋានសំរាប់ធ្វើការប្រៀបធៀបអំពីផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម ដើម្បីវាយតំលៃ នៅមុន និងក្រោយពេលកម្មវិធីចុះបញ្ជីដីធ្លី បន្ទាប់ពីបានអនុវត្តអស់រយៈពេល ៣ឆ្នាំ ។ ដោយហេតុថាគំរោង LMAP គឺជាដំណាក់កាលទី១នៃកម្មវិធីមួយមានរយៈពេលវែង ដូច្នេះ ការរកឃើញពីអង្កេតមូលដ្ឋាន និងការសិក្សាពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គមកិច្ច អាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីមូលហេតុត្រឹមត្រូវដែលអាចបន្តគំរោងទៅមុខទៀតបាន ។ នៅក្នុងចន្លោះពេលនេះ ការរកឃើញ និងការវិភាគបឋមលើទិន្នន័យអង្កេតមូលដ្ឋាន អាចជួយបង្ហាញផ្លូវដើម្បីឱ្យការអនុវត្តន៍ គំរោងកាន់តែមានប្រសិទ្ធភាព ។

ជាមួយនឹងប្រាក់កំចីពីធនាគារពិភពលោក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះកិច្ចសន្យាជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)[៥] ដើម្បីអនុវត្តអង្កេតមូលដ្ឋាននេះ ។ គំរោងនេះធ្វើឡើងដោយជួបសំភាសន៍លើគ្រួសារនៅជនបទចំនួន ១២៣២គ្រួសារ ក្នុងខេត្ត៥ ផ្សេងគ្នា នៅរវាងពីថ្ងៃទី១៩ មករា ដល់ ២៥ កុម្ភៈ ឆ្នាំ២០០៤ ក្នុងនោះមានខេត្តនៃគំរោង LMAP ចំនួន៤ គឺខេត្តកំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងខេត្តតាកែវ ដែលជាខេត្តអនុវត្តកម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងដំណាក់កាលទី១នៃគំរោង LMAP ។ ចំពោះខេត្តទី៥ គឺកំពង់ឆ្នាំង ដែលមិនស្ថិតនៅក្នុងគំរោង LMAP ទេ យើងបានប្រើប្រាស់ខេត្តនេះជាខេត្តត្រួតពិនិត្យសំរាប់ប្រៀបធៀប ជាមួយខេត្តគំរោងទាំង ៤ ខាងលើ ។[៦]

## ១.១ ដំណើរការនៃគំរោង LMAP

ដំណើរការនៃគំរោង LMAP ត្រូវបានអនុវត្តសាកល្បងជាលើកទី១នៅខេត្តតាកែវ និងខេត្តកំពង់ធំនៅក្នុងឆ្នាំ២០០១-២០០២ ។ គំរោងសាកល្បងរបស់ LMAP ត្រូវបានផ្តល់ហិរញ្ញវត្ថុដោយរដ្ឋាភិបាលអាឡឺម៉ង់ ហ្វាំងឡង់ និងបារាំង ។ គំរោងនេះ

---

៣ ខេត្តកំពង់ធំ តាកែវ កំពង់ស្ពឺ ព្រៃវែង ក្រុងព្រះសីហនុ កណ្តាល ភ្នំពេញ កំពត កំពង់ចាម បាត់ដំបង និងខេត្តសៀមរាប ដែលគំរោងនេះត្រូវគ្របដណ្តប់នៅក្នុងដំណាក់កាលដំបូង

៤ រៀបចំដោយធនាគារពិភពលោក ឆ្នាំ២០០២

៥ CDRI និង MLMUPC មុននេះបានសហការគ្នាដើម្បីធ្វើការវាយតំលៃផលប៉ះពាល់សង្គមពីកម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងឆ្នាំ២០០១-២០០២

៦ មាន ៩៩គ្រួសារ ត្រូវបានធ្វើសំភាសន៍ នៅសង្កាត់២ ក្នុងក្រុងព្រះសីហនុ ។ ការសរុបទិន្នន័យនេះ ជាមួយទិន្នន័យបានពីអង្កេតនៅទីក្រុងភ្នំពេញ នឹងបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីដំណាក់កាលអង្កេតបឋមនៅតំបន់ទីប្រជុំជនទីក្រុង ។

បានសាកល្បងរៀបចំផែនទី និងបច្ចេកវិទ្យាវិនិច្ឆ័យ ដែលគេធ្លាប់ប្រើវានៅកន្លែងផ្សេងទៀតក្នុងតំបន់នេះ ។ គំរោងសាកល្បងទាំងនោះបានធ្វើឡើងខុសៗគ្នា តែទោះបីជាយ៉ាងណាក៏ដោយគេបានបង្កើតនូវផែនទី Digital និងដាក់បញ្ចូលទិន្នន័យក្បាលដីទៅក្នុង Computer ពីដើមដំបូង ។ ក្នុងដំណាក់កាលសាកល្បង ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានចេញឱ្យដោយគ្មានគិតប្រាក់ តែនៅពេលនេះប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានចេញឱ្យដោយយកថ្លៃសេវាទាបបំផុតដោយផ្អែកទៅតាមតំបន់ និងប្រភេទនៃការប្រើប្រាស់ដី ។

ការងារគំរោង LMAP ត្រូវបានរៀបចំឡើងដោយមានតម្លាភាព និងការចូលរួមដោយឆ្លងកាត់នូវដំណាក់កាលស្មុគស្មាញជាច្រើន មុននឹងឈានទៅដល់ការចេញប័ណ្ណកម្មសិទ្ធិ ។ ជំហានដំបូងគឺពាក់ព័ន្ធនឹងការផ្សព្វផ្សាយដើម្បីឱ្យមានការយល់ដឹងជាសាធារណៈ ដោយក្រុមនៃមន្ត្រីគំរោងទៅជួបមេដឹកនាំសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីជូនដំណឹងអំពីកម្មវិធីចុះបញ្ជីដីធ្លីនេះ ។ ជំហានទី២ ពាក់ព័ន្ធនឹងការធ្វើសារពើភ័ណ្ឌទ្រព្យជាដីធ្លីនៅក្នុងគ្រួសារនីមួយៗ ក្នុងនោះរួមទាំងការវាស់វែងដល់កន្លែងលើក្បាលដីរបស់គ្រួសារនីមួយៗ ។ ការងារនេះធ្វើឡើងដោយមានរូបថតពីលើអាកាស ហើយបន្ទាប់មកមន្ត្រីនៃគំរោង LMAP ចាប់ផ្តើមការងារគូរដោយដៃនូវព្រំប្រទល់ឡូត៍នីមួយៗ ហើយចុះលេខឡូត៍នីមួយៗ ។ នៅក្នុងដំណាក់កាលនេះ ប្រជាពលរដ្ឋទទួលបានវិក្កយប័ត្រ ជាលេខរៀងសំរាប់គ្រប់ឡូត៍ទាំងអស់នៃដីរបស់ពួកគេ ។ ព្រំប្រទល់ក្បាលដីនីមួយៗក្រោយមកត្រូវបានផ្ទេរទៅក្នុងផែនទីដោយប្រើប្រាស់បច្ចេកវិទ្យា GIS ។ ផែនទីព្រំប្រទល់ក្បាលដី ក្រោយមកត្រូវបានបិទផ្សាយជាសាធារណៈនៅក្នុងភូមិរយៈពេល ៣០ថ្ងៃ ។ ករណីមានជំលោះអំពីព្រំដី ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន ។ ផែនទីព្រំប្រទល់ត្រូវបានធ្វើបញ្ចប់ ហើយប័ណ្ណកម្មសិទ្ធិត្រូវបានចេញឱ្យនៅគ្រប់លេខឡូត៍ នៅពេលណាដែលប្រជាពលរដ្ឋក្នុងសហគមន៍យល់ព្រមលើព្រំប្រទល់ដីឡូត៍ និងសិទ្ធនៃកម្មសិទ្ធិ ។ គ្រប់ប័ណ្ណកម្មសិទ្ធិដីបានពិពណ៌នាអំពីរូបរាងឡូត៍ ដោយភ្ជាប់ជាមួយលេខព្រំប្រទល់ឡូត៍នីមួយៗផងដែរ ។

## ១.២ រចនាសម្ព័ន្ធនៃរបាយការណ៍

ជំពូក ២ បង្ហាញដោយសង្ខេបពីប្រវត្តិនៃការងាររដ្ឋបាលដីធ្លីនៅក្នុងប្រទេសកម្ពុជា និងពិនិត្យពីលក្ខណៈពិសេសមួយចំនួននៃស្ថានភាពបច្ចុប្បន្ននៃដីធ្លីនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា ។ ជំពូក ៣ ពិភាក្សាអំពីក្របខ័ណ្ឌគំនិតដើម្បីអនុវត្តនៅក្នុងដំណាក់កាលនៃអង្កេតមូលដ្ឋាននៅតំបន់ជនបទ ក្នុងនោះរួមមាន សេចក្តីសង្ខេបអំពីការពិនិត្យឡើងវិញនូវការយល់ដឹងពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យ និងការងារអភិបាលកិច្ច ។ ជំពូក ៤ បង្ហាញនូវវិធីសាស្ត្រស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងពេលអង្កេតបឋម ។ ជំពូក ៥ ពិពណ៌នាពីការស្រាវជ្រាវលើប្រជាពលរដ្ឋនៅជនបទក្នុងតំបន់នៃគំរោង LMAP នៅក្នុងក្របខ័ណ្ឌពាក់ព័ន្ធនឹងការបែងចែកការកាន់កាប់ដីធ្លី និងយេនឌ័រ ។ ជំពូក ៦ នឹងធ្វើការបង្ហាញលំអិតអំពីការរកឃើញពាក់ព័ន្ធនឹងការស្រាវជ្រាវនៅជនបទនៃខេត្តគំរោង LMAP និងធ្វើការពិភាក្សាពីការគិតទុកជាមុននូវផលប៉ះពាល់ពីកម្មវិធីចុះបញ្ជីដីធ្លី ។ ជំពូក ៧ បង្ហាញពីការរកឃើញ នៅក្នុងតំបន់ត្រួតពិនិត្យនៃខេត្តកំពង់ឆ្នាំង និងធ្វើការប្រៀបធៀបទិន្នន័យទៅនឹងការរកឃើញក្នុងខេត្តនៃគំរោង LMAP ។ ជំពូក ៨ ធ្វើការបូកសរុបរបាយការណ៍ ដោយមានសេចក្តីសង្ខេបពីចំណុចសំខាន់ៗ និងធ្វើការពិភាក្សាពីផែនការ និងការអនុវត្តគំរោង LMAP ។

# ជំពូក ២. សាវតារៈ រដ្ឋបាលដីធ្លី និងសភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ន

ចំពោះសិទ្ធិលើដីធ្លី និងការងាររដ្ឋបាលដីធ្លីនៅក្នុងប្រទេសកម្ពុជា របាយការណ៍ភាគច្រើនបញ្ជាក់ថា ដើមឡើយដីធ្លី គឺជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ ហើយការកាប់ដីឆ្ការដាំដំណាំផ្សេងៗត្រូវមានការអនុញ្ញាតពីព្រះមហាក្សត្រ ។ ដោយសារប្រជាពលរដ្ឋមានចំនួនតិច បើប្រៀបធៀបជាមួយធនធានដែលមានប្រជាពលរដ្ឋក៏អាចប្រើប្រាស់ និងគ្រប់គ្រងដីទាំងនោះ ទៅតាមតំរូវការនិងលទ្ធភាពជាក់ស្តែង ដូច្នេះទំហំដីដែលប្រជាពលរដ្ឋធ្វើការបង្កបង្កើនផល គឺផ្អែកទៅលើកំលាំងពលកម្ម និងធនធាននៃគ្រួសារនីមួយៗ ដូចជាសត្វពាហនៈដែលប្រើប្រាស់ជាកំលាំងអូសទាញជាដើម ។ នៅក្នុងស្ថានភាពបែបនេះ ការអនុវត្តន៍ប្រព័ន្ធកសិកម្មយថាផល គឺមានលក្ខណៈសំគាល់មួយចំនួនដូចជា ដង់ស៊ីតេប្រជាពលរដ្ឋទាប សិទ្ធិប្រើប្រាស់ដី មានការគ្រប់គ្រងតាមរបៀបក្រៅផ្លូវការដោយផ្អែកទៅលើប្រពៃណី និងវប្បធម៌នៅមូលដ្ឋាន ។

ប្រព័ន្ធផ្លូវការនៃការគ្រប់គ្រងដីធ្លីដែលបានទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី ត្រូវបានអនុវត្តជាលើកដំបូង តាមរយៈការដាក់ឱ្យប្រើប្រាស់ ច្បាប់ភូមិបាលនៅឆ្នាំ១៨៨៤ នៅក្នុងអំឡុងពេលនៃរបបអាណានិគមបារាំង ប៉ុន្តែច្បាប់នេះមិនបានអនុវត្តពេញលេញនៅឡើយទេរហូតមកដល់ក្នុងរវាងឆ្នាំ១៩៣០ ។ របាយការណ៍នាពេលថ្មីៗមួយបានឱ្យដឹងថា ប្រព័ន្ធនេះនៅមានប្រសិទ្ធភាពអនុវត្តរហូតដល់ឆ្នាំ១៩៧៥ ដូច្នេះប្រទេសកម្ពុជាគឺមានច្បាប់ផ្លូវការមួយ អមដោយរបៀបរបបអនុវត្តន៍មួយចំនួនខាងផ្នែករដ្ឋបាលដីធ្លី ដែលបានដំណើរការជិះយូរប្រហែល ៤ជំនាន់មនុស្ស (ADB ២០០៣) ។ របាយការណ៍របស់ ADB បានបង្ហាញថា នេះជារយៈពេលវែងគ្រប់គ្រាន់ហើយសំរាប់ឱ្យប្រព័ន្ធមានភាពរឹងមាំឡើង មានលក្ខណៈជាស្ថាប័ន និងមានការទទួលយកនៅក្នុងស្មារតីចងចាំរបស់សង្គម ។ ទោះបីជាយ៉ាងណាក្តី ឯកសារវាយតំលៃគំរោង LMAP (PAD) របស់ធនាគារពិភពលោកបានស្នើថា ប្រព័ន្ធនេះអនុវត្តបានភាគច្រើននៅតាមតំបន់ធ្វើស្រែ ដែលមានប្រជាជនរស់នៅកកកុញ ។ លើសពីនេះទៀតបន្ទាប់ពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ រដ្ឋាភិបាលនៃប្រទេសកម្ពុជា អាចសំរេចបានការរីកចំរើនតែមួយគឺរិតលើការចុះបញ្ជីទ្រព្យមានលក្ខណៈផ្លូវការ ។[៧]

បញ្ហាសព្វថ្ងៃដែលជាប់ទាក់ទិននឹងសិទ្ធិកម្មសិទ្ធិដីធ្លី និងការងាររដ្ឋបាលដីធ្លីនៅកម្ពុជា ភាគច្រើនវាអាចជាស្នាមដែលបន្សល់ទុកពីវិបត្តិផ្ទៃក្នុងសង្គ្រាម និងគោលនយោបាយធ្វើសហករណ៍យ៉ាងក្រឡាប់ចក្រ ដែលខ្មែរក្រហមបានអនុវត្តនៅក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-៧៩ ។ បញ្ហាទាំងនេះក៏រួមបញ្ចូលផងដែរនូវការចាកចេញរបស់ប្រជាពលរដ្ឋយ៉ាងច្រើនទាំងនៅទីក្រុង និងនៅជនបទ ។ ទី១ នៅពេលដែលប្រជាពលរដ្ឋជាច្រើនត្រូវបានបង្ខំឱ្យបោះបង់ដី ដោយពួកគេ

---

[៧] ឯកសារវាយតំលៃរបស់ធនាគារពិភពលោក PAD ប្រើប្រាស់ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ រហូតមកដល់ពេលទទួលស្គាល់ទ្រព្យឯកជន ក៏ដូចជាការរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។

ភៀសខ្លួនមកស្នាក់នៅទីក្រុងភ្នំពេញក្នុងរយៈពេលនៃការវាយប្រហារដ៏តឹងតែងនៅឆ្នាំ១៩៧៥ ។ ទី២ គោលនយោបាយឃោរឃៅដោយធ្វើការជំលៀសប្រជាពលរដ្ឋដោយបង្ខំ និងទី៣ នៅពេលដែលប្រជាពលរដ្ឋភៀសខ្លួនទៅរស់នៅក្នុងជំរំប្រទេសថៃ និងនៅបរទេស ក្នុងពេលដែលរបបខ្មែរក្រហមទទួលបរាជ័យ ។

ប្រព័ន្ធគ្រប់គ្រងនិងរដ្ឋបាលដីធ្លី សៀវភៅចុះបញ្ជីដីធ្លីនិងផែនទីសុរិយោដី ត្រូវបានបំផ្លាញអ្នកជំនាញផ្នែកដីធ្លី ស្ទើរតែទាំងអស់ត្រូវបានស្លាប់ ឬក៏បានភៀសខ្លួនពីកម្ពុជា ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីគាំទ្រសិទ្ធិកម្មសិទ្ធិដីធ្លីឯកជន ត្រូវបានខូចខាត ឬបំផ្លាញចោលដើម្បីបើកផ្លូវសំរាប់ការអនុវត្តន៍ធ្វើកសិកម្មសមូហភាព ។ ឧទាហរណ៍ ដីសំរាប់ធ្វើស្រែវស្សានៅខេត្តកំពង់ធំ និងខេត្តកំពង់ចាម ភ្លឺស្រែតូច១ដែលគេធ្វើឡើងដើម្បីប្រើប្រាស់ទាំងជាព្រំប្រទល់សំគាល់ក្បាលដីនីមួយ១ និងសំរាប់ជារចនាសម្ព័ន្ធគ្រប់គ្រងទឹកត្រូវបានបំផ្លាញ ដើម្បីបង្កើតជាតំបន់មួយធំដែលគេបានធ្វើកសិកម្មជាលក្ខណៈសមូហភាព ។ ដីទាំងនោះ ក៏ត្រូវបានធ្វើកសិកម្មជាលក្ខណៈសមូហភាពជាក្រុមតូច១ (ក្រុមសាមគ្គី) បន្ទាប់ពីរបបខ្មែរក្រហមត្រូវបរាជ័យ ហើយប្រព័ន្ធភ្លឺស្រែត្រូវបានគេស្ថាបនាឡើងវិញ ឬក៏ជួសជុលក្នុងគោលបំណងបឋម ដើម្បីគ្រប់គ្រងទឹកនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ឧទាហរណ៍ នៅតំបន់ខ្លះនៃខេត្តកំពង់ធំ ភ្លឺស្រែត្រូវគេស្ថាបនាឡើងវិញដោយផ្អែកទៅលើព្រំប្រទល់ដីរបស់ក្រុមសាមគ្គីនានា ។[៨]

នៅក្រោយរបបខ្មែរក្រហម សិទ្ធិប្រើប្រាស់ដីលំនៅដ្ឋាន ត្រូវបានគេផ្តល់ជូនដោយផ្អែកទៅលើការកាន់កាប់ តែរដ្ឋនៅតែជាម្ចាស់កម្មសិទ្ធិលើដីដដែល ។ នៅឆ្នាំ១៩៨៩ រដ្ឋាភិបាលបានបើកឱ្យមានកម្មសិទ្ធិឯកជនលើទ្រព្យឡើងវិញ តាមរយៈសេចក្តីណែនាំលេខ ០៣ រួមជាមួយនឹងអនុក្រឹត្យលេខ ២៥ ហើយជាមួយគ្នានេះដែរបានធ្វើមោឃៈភាពរាល់កម្មសិទ្ធិដីធ្លីដែលមាននៅមុនឆ្នាំ១៩៧៩ ។ អនុក្រឹត្យនេះបានបង្កើតសិទ្ធិកម្មសិទ្ធិលើដីលំនៅដ្ឋានយ៉ាងច្រើនបំផុតត្រឹមទំហំ ២០០០ម៉ែត្រការ៉េ និងសិទ្ធិភោគៈលើដីកសិកម្មមិនឱ្យលើសពីទំហំ ៥ហិកតា ។ ចំពោះសិទ្ធិសម្បទានគឺសំរាប់ដីដាំដំណាំ លើសពីទំហំ ៥ហិកតា ។

ដីកសិកម្ម ត្រូវបានបែងចែកឱ្យគ្រួសារកសិករ ដែលទំហំដីនោះត្រូវផ្អែកទៅលើចំនួនអ្នកពេញវ័យ និងសមាជិក មានកំលាំងពលកម្មឯទៀតក្នុងគ្រួសារ ។ មានការខំប្រឹងប្រែងដើម្បីធ្វើការចែកដីឱ្យស្មើភាព និងមានការព្រមព្រៀងគ្នា ដូច្នេះប្រជាពលរដ្ឋទទួលបានចំណែកដីមានគុណភាពស្មើ១គ្នា ដូចជាស្រែជំរៅ ដែលដីមានជីជាតិនៅជិតប្រភពទឹក ។ គ្រួសារធំក៏បានទទួលដីបន្ថែមដែលនៅសល់ដែរ ប៉ុន្តែអាចជាដីមិនសូវមានជីជាតិ ឬក៏ទីតាំងមានលក្ខខណ្ឌមិនល្អ ។ តាមលក្ខខណ្ឌនៃតំបន់គ្រួសារធំអាចទទួលបានក្បាលដីច្រើន និងមានទំហំធំជាងគ្រួសារតូច ។ ក្នុងពេលជាមួយគ្នា នៅក្នុងតំបន់ធ្វើស្រែ ប្រព័ន្ធភ្លឺសំគាល់ឡូត៍នីមួយ១ និងសំរាប់គ្រប់គ្រងទឹក ត្រូវបានពង្រឹង និងពង្រីកបន្ថែម ។

បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានអនុម័ត ប្រជាពលរដ្ឋបានដាក់ស្នើសុំវិញ្ញាបនប័ត្រកាន់កាប់ដីធ្លី ដែលបញ្ជាក់ពីសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីនោះ តែច្បាប់នេះអនុញ្ញាតឱ្យមានត្រឹមតែសិទ្ធិភោគៈ ជាជាងមានសិទ្ធិកម្មសិទ្ធិលើដីនៅតំបន់ជនបទ ។ ពាក្យស្នើសុំកាន់កាប់ដីជាង ៤លាន ត្រូវបានដាក់ស្នើសុំជាបន្តបន្ទាប់ ប៉ុន្តែប្រព័ន្ធសុរិយោដីដែលមានឧបករណ៍ប្រើប្រាស់មិនគ្រប់គ្រាន់ និងមានធនធានតិចតួចដើម្បីគ្រប់គ្រងការងារដ៏ច្រើន អាចធ្វើបានតែតិចតួចប៉ុណ្ណោះនៅពេលនោះ ។ អវត្តមានប័ណ្ណកម្មសិទ្ធិផ្លូវការ ការកើតឡើងនូវទីផ្សារដី តំរូវឱ្យមានយន្តការដើម្បីសំរបសំរួលលើកិច្ចសន្យា ផ្លាស់ប្តូរសិទ្ធិលើ

---

[៨] ប៉ុន្តែដំណើរការនេះ មិនបានអនុវត្តឱ្យដូច១គ្នានៅគ្រប់តំបន់នោះទេ ជាឧទាហរណ៍ នៅតំបន់មួយចំនួនក្នុងខេត្តសៀមរាប ភ្លឺស្រែពីដើមមកសំរាប់សំគាល់ឡូត៍នីមួយ១ នៅរក្សាបាននៅក្នុងទីតាំងនោះ ហើយតំបន់ខ្លះទៀត ប្រជាពលរដ្ឋអាចត្រលប់ទៅធ្វើកសិកម្មនៅលើដីឡូត៍របស់គេ ដោយមិនប្រើប្រាស់ ប្រព័ន្ធក្រុមសាមគ្គីឡើយ ។

ទ្រព្យជាដីធ្លី ។ ការផ្ទេរលក់ដី ត្រូវបានធ្វើឡើងទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ហើយប្រជាពលរដ្ឋបានចាប់ផ្តើមផ្ទេរលក់ដីដោយសំអាងលើចុងសន្លឹក (វីស៊ុយ) និងឯកសារផ្សេងទៀត (ឧ. វិក្កយបត្រវាស់វែងដី) ដើម្បីឱ្យក្លាយជាឯកសារផ្ទេរកម្មសិទ្ធិដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានគឺមានមេភូមិ និងមេឃុំ ។ នៅពេលជាមួយគ្នានេះ ក៏មានតំរូវការចង់បានវិញ្ញាបនប័ត្រកាន់កាប់ដីផ្លូវការ ។ ជាលទ្ធផល ដោយសារតំរូវការនៃទីផ្សារដី ឯកសារបែបនេះត្រូវបានអភិវឌ្ឍនៅក្នុងប្រព័ន្ធចុះបញ្ជីផ្លូវការដើម្បីបំរើដល់ការចង់បានបែបនេះ ប៉ុន្តែគេត្រូវបង់សេវាក្រៅផ្លូវការ ដើម្បីទទួលបានវិញ្ញាបនប័ត្រនោះ ។

ច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ត្រូវបានអនុម័ត ដែលជាការទទួលស្គាល់មួយយ៉ាងធំថា ការរីកចំរើនឆ្ពោះទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ត្រូវមានជាចាំបាច់នូវការពង្រឹងប្រព័ន្ធកម្មសិទ្ធិដីធ្លី ក៏ដូចជាការធ្វើឱ្យប្រសើរឡើងលើផ្នែករៀបចំដែនដី និងរដ្ឋបាលដីធ្លី ។ ច្បាប់ភូមិបាលថ្មីទទួលស្គាល់កម្មសិទ្ធិដី ៣ប្រភេទ នៅក្នុងប្រទេសកម្ពុជាគឺ ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និងដីឯកជន ។ នៅក្នុងប្រភេទដីឯកជន គេអាចបែងចែកជាដីបុគ្គល ដីសហគមន៍ កម្មសិទ្ធិអវិភាគ (undivided ownership) និងសហកម្មសិទ្ធិ ។ សិទ្ធិផ្សេងទៀតលើដីធ្លី រួមមាន សិទ្ធិប្រើប្រាស់និងស្នាក់នៅ សិទ្ធិផលុបភោគ (សិទ្ធិអាស្រ័យផល) សិទ្ធិប្រើប្រាស់ដីអ្នកដទៃ ការដាក់បញ្ចាំ វត្ថុដាក់ធានា និងលក់ ក៏ដូចជាសិទ្ធិលើកិច្ចសន្យាជាក់លាក់ ដែលបានព្រមព្រៀងដោយភាគីមានផលប្រយោជន៍ ។

## ២.១. សភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ន

សភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាត្រូវបានកំនត់ដោយ ការកើនឡើងនៃសម្ពាធប្រជាសាស្ត្រ អសុវត្ថិភាពក្នុងការកាន់កាប់ និងសិទ្ធិកម្មសិទ្ធិដីធ្លី អសមភាពក្នុងការកាន់កាប់ដី ការកើនឡើងនៃភាពគ្មានដី និងភាពកាន់តែជិតគ្មានដី ហើយនិងកំរិតទាបនៃផលិតភាព និងការវិនិយោគ ។[៩] សភាពការណ៍បែបនេះធ្វើឱ្យមានការបារម្ភ ជាពិសេសដោយសារមានពី ៨០-៨៥% នៃប្រជាពលរដ្ឋកម្ពុជា គឺជាប់ពាក់ព័ន្ធនឹងការធ្វើកសិកម្មចិញ្ចឹមជីវិត ។ លើសពីនេះទៀត នៅក្នុងចំនួន ៣៦% នៃប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់ភាពក្រីក្រក្នុងប្រទេសកម្ពុជា ភាគច្រើន គឺរស់នៅតំបន់ជនបទ ។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើន នឹងបន្តប្រកបរបបចិញ្ចឹមជីវិត ដោយពឹងផ្អែកជាបឋមទៅលើរបបកសិកម្ម ពីព្រោះការរីកលូតលាស់លើវិស័យឧស្សាហកម្ម និងសេវាកម្ម មិនសង្ឃឹមថានឹងអាចស្រូបយកកំលាំងពលកម្ម ដែលនឹងរីកធំឡើងនាអនាគតបានទេ ។[១០]

បញ្ហាដែលជាប់ពាក់ព័ន្ធនឹងការកាន់កាប់ដីនៅជនបទ ក៏មានផលប៉ះពាល់ផងដែរទៅតំបន់ទីប្រជុំជន ទៅតាមច្រើនរូបភាព ។ ផលប៉ះពាល់ដែលគេមើលឃើញធំជាងគេ គឺពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើនទៅក្នុងទីក្រុងដើម្បីរកការងារធ្វើ ។ ការធ្វើចំណាកស្រុកនេះ រួមជាមួយនឹងកត្តាផ្សេងទៀត បានដាក់ឱ្យមានសំពាធយ៉ាងខ្លាំងទៅលើទីផ្សារលំនៅដ្ឋាន និងសេវាកម្មសាធារណៈ (ឧ. ប្រព័ន្ធទឹក ផ្នែកអនាម័យ) ហើយនេះក៏ជាប្រភពសក្តានុពលនៃអស្ថិរភាពសង្គមផងដែរ ។ ជំលោះដីធ្លីដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋគ្មានដី ការចូលទៅទន្ទ្រានកាន់កាប់ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ក៏មានការកើនឡើងផងដែរ ។ ភាពមិនច្បាស់លាស់អំពីសិទ្ធិលើដីធ្លីក៏បានរារាំងផងដែរ ដល់ការវិនិយោគលើផ្នែកអាជីវកម្ម

---

[៩] មើល ឧ. លោក Van Acker, Frank (1999) Biddulph Robin (Oxfam GB 2000); So et al (2001) Sophal et al (2003)

[១០] កង ច័ន្ទតារ័ត្ន និងច័ន្ទ សុផល ( CDRI 2003)

ឧស្សាហកម្ម ដែលអាចជួយផ្តល់ការងារធ្វើឱ្យអ្នកដែលមិនមែនជាកសិករ ។[១១] ទីផ្សារដីនៅទីក្រុង នឹងមិនមានប្រសិទ្ធភាពទេ បើសិនពុំមានការអភិវឌ្ឍន៍ផែនការមេ (Master Plan) និងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិស្តីពីការកំណត់តំបន់ ។ ជាលទ្ធផលនៃបញ្ហាទាំងអស់ខាងលើ រួមជាមួយនឹងបញ្ហាមួយចំនួនផ្សេងទៀត ការកែទំរង់អំពីសិទ្ធិលើដីធ្លី និងទ្រព្យទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង គឺជាចំនុចដ៏ធំមួយនៃកម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចលើកទី២ (២០០១-២០០៥) និងយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥) ។

នៅភាគខាងក្រោយនៃផ្នែកនេះ នឹងមានធ្វើការពិភាក្សាលំអិតពីលក្ខណៈសំខាន់ៗនៃសភាពការណ៍ដីធ្លីនាពេលបច្ចុប្បន្ន ទាំងនៅក្នុងតំបន់ជនបទ និងតំបន់ទីក្រុង ដែលជាប់ពាក់ព័ន្ធជាមួយនឹងអង្កេតមូលដ្ឋានអំពីកម្មវិធីចុះបញ្ជីដីធ្លី ក្នុងនោះនឹងរួមបញ្ចូលនូវបញ្ហាមួយចំនួនដូចជា ការវិនិយោគលើវិស័យកសិកម្ម និងផលិតកម្ម បញ្ហាអសមភាពក្នុងការកាន់កាប់ដីធ្លី សិទ្ធិក្នុងការកាន់កាប់ ការផ្ទេរដី និងបញ្ហាវិវាទដីធ្លី ។

## ២.១.១ ការវិនិយោគលើវិស័យកសិកម្ម និងផលិតកម្ម

ផលិតភាពដី គិតតាមទិន្នផលទទួលបាននៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបជាមួយប្រទេសនៅក្នុងតំបន់ គឺមានអត្រាទាបជាងគេ[១២] ហើយផលចំណូលដែលបានមកពីការធ្វើកសិកម្មជាទូទៅគឺនៅទាបផងដែរ ។ កសិករភាគច្រើន ខ្វះខាតនូវប្រភពទុនសំរាប់ធ្វើការវិនិយោគជាធាតុចូល (ឧ. ពូជ ជី ) ឧបករណ៍ប្រើប្រាស់ (ឧ. ម៉ាស៊ីនបូមទឹក ត្រាក់ទ័រ ភ្ជួរដោយដៃ) ឬការកែលំអដី (ឧ. ការធ្វើធារាសាស្ត្រខ្នាតតូច) ។ មានបញ្ហាមួយពាក់ព័ន្ធនឹងកង្វះខាតលទ្ធភាព ប្រើប្រាស់ឥណទានពីព្រោះ (ក) បញ្ហា ទីតាំង (ខ) អវត្តមានវត្ថុដាក់ធានាដើម្បីទទួលបានកំចីមានអត្រាការប្រាក់ទាប និង (គ) ព័ត៌មានមិនគ្រប់គ្រាន់អំពីបទដ្ឋាន និងនីតិវិធីដើម្បីគ្រប់គ្រងឥណទាន (ឧ. ពេលវេលានៃការបង់ប្រាក់ ការមិនគោរពកិច្ចសន្យាជាដើម) ។ ជាលទ្ធផល កសិករជារឿយៗខ្ចីប្រាក់ពីស្ថាប័នក្រៅផ្លូវការ ដែលនៅពេលខ្លះមានអត្រាការប្រាក់ខ្ពស់ ពីអ្នកកសិចងការប្រាក់សំរាប់ដោះស្រាយតំរូវការបន្ទាន់ (ឧ. ការថែទាំសុខភាព កង្វះម្ហូបអាហារ ) និង/ឬ ផ្គត់ផ្គង់ជាធាតុចូលសំរាប់ធ្វើកសិកម្មតាមរដូវ (ឧ. គ្រាប់ពូជ ជី) ។ នៅពេលដែលគេមានជំរើសតិចតួចដើម្បីរកឥណទាន តំរូវការខ្ចីប្រាក់ដើម្បីដោះស្រាយករណីបន្ទាន់ណាមួយ វាតែងពង្វាងប្រាក់នោះចេញពីការវិនិយោគ ។

កសិករជាច្រើនក៏ខ្វះខាតផងដែរនូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ដែលធ្វើឱ្យពួកគេងាយរងគ្រោះ និងការរំលោភយកដី ការទន្ទ្រានយកដី និងវិវាទប្រភេទផ្សេងទៀត ។ សភាពការណ៍បែបនេះត្រលប់ទៅជាកាត់បន្ថយការលើកទឹកចិត្តលើការវិនិយោគ ទោះបីជាគេមានប្រភពទុនច្រើនយ៉ាងណាក្តី ។ កសិករជាច្រើនមិនអាច ឬមានការស្ទាក់ស្ទើរ ដើម្បីប្រថុយប្រថានឹងហានិភ័យពាក់ព័ន្ធនឹងបំរែបំរួលលក្ខខណ្ឌដី និងអាកាសធាតុ ជាពិសេសភាពរាំងស្ងួត និងទឹកជំនន់ ។ កសិករក៏ជួបប្រទះផងដែរនូវថ្លៃលក់ចេញទាបលើផលិតផលដែលគេផលិតបាន ដោយសារចំណាយនៃការផលិត និងចំណាយនៃការផ្ទេរពាក់ព័ន្ធនឹងសកម្មភាពទីផ្សារសុទ្ធតែខ្ពស់ ។ ក្រៅពីនេះ កសិករជាច្រើនមិនបានទទួល សេវាកម្មទាក់ទងនឹងវិធីដាំដំណាំ ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រី ក៏ដូចជាព័ត៌មានអំពីលក្ខខណ្ឌទីផ្សារ និងចរន្តតំលៃទេ ។

---

[១១] ឧទាហរណ៍ នៅក្នុងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

[១២] ច័ន្ទ សុផល គឹម សេតារា និង Sarthi Achaya (CDRI 2003)

## ២.១.២. អសមភាពលើការកាន់កាប់ដីធ្លី

អង្កេតផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩ បានបង្ហាញថា យ៉ាងហោចណាស់មានក្បាលដីចំនួន ២,៨៨លានក្បាល ជាដីកសិកម្មនៅក្នុងប្រទេសកម្ពុជា ។ តាមរយៈតួលេខនេះកសិករអាចមានផ្ទៃដីកសិកម្មជាមធ្យម ១,៣៧ក្បាលដីក្នុងមួយគ្រួសារ ហើយមានទំហំជាមធ្យម ០,៩០ហិកតា ។ ការសិក្សាថ្មីៗជាច្រើនទៀតបានបង្ហាញថា[១៣] មានផ្ទៃដីកសិកម្មពី ០,៥០-០,៦១ហិកតា សំរាប់គ្រួសារនីមួយៗ ដែលបង្ហាញពីអសមភាពនៃការកាន់កាប់ដីនៅប្រទេសកម្ពុជា ។ មានហេតុផលមួយចំនួនក្នុងនោះមានកត្តាសម្ពាធប្រជាសាស្ត្រ អ្នកគ្មានទីលំនៅមានចំនួនច្រើន ទីផ្សារផលិតទាននៅខ្សោយ ហើយនិងមានការទិញដីបង្កកទុកដោយអ្នកមានធនធាននៅទីក្រុង ( So *et al.* 2001) ។

ទាំងអស់នេះ វាមានសារៈសំខាន់ណាស់ដើម្បីយកមកពិចារណានៅក្នុងក្របខ័ណ្ឌនៃអសមភាពក្នុងការកាន់កាប់ដីនៅក្នុងចំណោមគ្រួសារជាច្រើន ដូច្នេះការបែងចែកដីនៅក្នុងឆ្នាំ១៩៨៩ មិនមានសមភាពទេ ។ ដូចដែលបានញ្ជាក់នៅខាងដើម ដីត្រូវបានបែងចែកដោយផ្អែកទៅលើចំណែកនៃសមាជិកពេញកំលាំងធ្វើការនៅក្នុងគ្រួសារ ។ ជាលទ្ធផល គ្រួសារធំជាច្រើន បានទទួលដីធំ និងមានក្បាលដីច្រើនជាងគ្រួសារតូច ។ គ្រួសារតូចដែលមានកំលាំងពលកម្មតិច ជាពិសេសគ្រួសារមានស្ត្រីជាមេគ្រួ បន្ទាប់ពីការបែងចែកដីមកគឺពួកគេមានការចាញ់ប្រៀបយ៉ាងខ្លាំងនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ ការធ្វើកសិកម្មចិញ្ចឹមជីវិត ។ ជាលទ្ធផល ពួកគេកាន់តែងាយរងគ្រោះ នៅពេលមានគ្រោះអាសន្ន និងមានជំងឺត្រូវសង្គ្រោះបន្ទាន់ ហើយមានទំនោរទៅរកការបាត់បង់ដីធ្លីដែលមានអត្រាលឿនជាងគ្រួសារផ្សេងទៀត ដោយសារការលក់ដីជាបន្ទាន់ ។

### *ភាពគ្មានដី/ភាពជិតនឹងគ្មានដី*

តាមការស្រាវជ្រាវគេបានប៉ាន់ប្រមាណថា មានពី ១២-១៥% នៃចំនួនគ្រួសារនៅជនបទ គឺគ្មានដីកសិកម្មទេ ។ ហើយក៏មានការប៉ាន់ប្រមាណផងដែរថា អ្នកគ្មានដីនឹងកើនឡើង ២% ជារៀងរាល់ឆ្នាំ ក្នុងនោះ គ្រួសារមានស្ត្រីជាមេគ្រួ មានអត្រាភាពគ្មានដីខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួ (So *et al.* 2001) ។ ឧទាហរណ៍ តាមការស្រាវជ្រាវរបស់ Oxfam GB ( Biddulp 2000) ទៅលើ ៣០.០០០គ្រួសារ បានរកឃើញថា ២១% នៃគ្រួសារគ្មានដី គឺជាគ្រួសារមានស្ត្រីជាមេគ្រួ ទល់នឹងអត្រាគ្មានដីជាទូទៅចំនួន ១៣% ។ នៅក្នុងក្របខ័ណ្ឌអ្នកជិតនឹងគ្មានដី ការសិក្សាបានធ្វើការប៉ាន់ស្មានថា ២៥% ជាគ្រួសារមានដីតិចជាង ០,៥ហិកតា ដែលជាទំហំដីមិនគ្រប់គ្រាន់ទេ ដើម្បីធ្វើឱ្យមានចិរភាពនៅក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃ Acharya *et al.* (2001) ។ មានការកត់សំគាល់ថា ផ្ទៃដីតូច ស្របគ្នានឹងការអនុវត្តបច្ចេកវិទ្យាមិនទំនើប គឺជាមូលហេតុចំបងនៃភាពក្រីក្រ ។

ហេតុផលធ្វើឱ្យកើនឡើងនូវភាពគ្មានដី និងភាពជិតនឹងគ្មានដី គឺជាប់ពាក់ព័ន្ធនឹងកត្តាស្មុគស្មាញជាច្រើន ។ អ្នកគ្មានដីជាច្រើនមិនធ្លាប់មានដីកាន់កាប់ទេ យ៉ាងហោចណាស់តាំងពីទសវត្សរ៍១៩៩០ ។ ឧទាហរណ៍ អតីតជនភៀសខ្លួន ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីជំរុំនៅតាមព្រំដែនប្រទេសថៃ ហើយទៅរស់នៅតំបន់ជនបទនៅឆ្នាំ១៩៩២-១៩៩៣ គឺមិនបានទទួលដីធ្លីទេ ដោយសារដីរបស់ពួកគេមានការកាន់កាប់រួចហើយ ឬប៉ះពាល់ដោយសារគ្រាប់មីន ។ មានមនុស្ស ជាច្រើនទៀតធ្លាប់កាន់កាប់ដី តែត្រូវបាត់បង់ដីវិញដោយសារហេតុផលជាច្រើន ។ ហេតុផលមួយក្នុងចំណោមហេតុផលទាំងនេះ ជារឿយៗ គឺពាក់ព័ន្ធនឹងការ

---

[១៣] ច័ន្ទ សុផល គឹម សេតារា និង Sarthi Acharya (CDRI 2003)

ខ្វះខាតលទ្ធភាពទទួលឥណទាន ដែលរុញឱ្យប្រជាពលរដ្ឋខ្លះត្រូវលក់ដីធ្លី នៅក្នុងពេលដែលមានបញ្ហាជាបន្ទាន់នានា ។ ឧទាហរណ៍ គ្រួសារគ្មានដីក្នុងទីតាំងដែលអង្គការ Oxfam ធ្វើការសិក្សាបង្ហាញថា មាន ៤៣.៦% នៃគ្រួសារធ្លាប់កាប់កាន់ដី តែក្រោយមកត្រូវបាត់បង់ទៅវិញ ។ ក្នុងករណីទាំងនេះ មានជិត ៨៧% ត្រូវលក់ដីដោយសារមានធុរៈបន្ទាន់ ហើយស្ទើរតែពាក់កណ្ដាលនៃចំនួននេះពាក់ព័ន្ធនឹងការចំណាយលើការថែទាំសុខភាព ។

មានកត្តាផ្សេងទៀតដូចជា ផលិតភាព និងចំណូលទាប ដែលបង្ខំឱ្យកសិករខ្លះបោះបង់ចោលការងារកសិកម្ម ហើយធ្វើចំណាកស្រុកទៅកន្លែងផ្សេងដើម្បីលក់កំលាំងពលកម្ម ។ ការរំលោភយកដី និងការទិញដីបង្កកទុក ក៏ជាបញ្ហាធ្វើឱ្យមានភាពគ្មានដីខ្លះៗដែរ ។ ឧទាហរណ៍ នៅក្នុងការធ្វើសទ្ទស្សន៍របស់ Oxfam ១៣% នៃអ្នកគ្មានដី បានរាយការណ៍ថា ដីត្រូវបានគេដកហូតដោយពុំមានសំណង ។ សំពាធប្រជាសាស្ត្រ និងការបំបែកក្បាលដី ក៏ជាកត្តារួមចំណែកផងដែរ ។ ឧទាហរណ៍ Biddulph (2004) ធ្វើការកត់សំគាល់ថា ចំនួនគ្រួសារថ្មីបានកើនឡើងយ៉ាងឆាប់រហ័ស ជាងការកើនឡើងនៃចំនួនប្រជាពលរដ្ឋទូទៅ ដោយសារការប្រែប្រួលខុសធម្មតានៃកំនើនប្រជាជនដែលបណ្ដាលមកពីរបបប្រល័យពូជសាសន៍ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ការសិក្សានេះបានស្នើថា គ្រួសារត្រូវចែកក្បាលដីជាឡូត៍តូចៗ ក្នុងអត្រាលឿនបំផុតដើម្បីបំពេញសេចក្ដីត្រូវការផ្ដល់មរតកដល់កូនចៅ ។ នៅពេលដែលការបែងចែកនេះមិនអាចធ្វើបាន តទៅទៀត យុវជនក្មេងៗត្រូវស្វែងរកការងារនៅកន្លែងផ្សេងទៀត ។

## ២.១.៣ សិទ្ធិកាន់កាប់ដីធ្លី

របាយការណ៍ពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ បានបង្ហាញថា វិញ្ញាបនប័ត្រកាន់កាប់ដី តិចជាង ១៤% ត្រូវបានផ្ដល់ជូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យសុំកាន់កាប់ដីប្រមាណពី ៤-៥លានក្បាលដី តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ។ ការចុះបញ្ជីក្បាលដីមិនមានសមាមាត្រទេ គឺត្រូវបានចេញជូនច្រើនតែក្នុងខេត្តកណ្ដាល តាកែវ កំពត ក៏ដូចជាខេត្តឯទៀត ដែលមានប្រជាពលរដ្ឋច្រើនស្ថិតនៅភាគខាងត្បូងប្រទេស និងខេត្តសៀមរាប ។ នៅចន្លោះឆ្នាំ១៩៨៩-៩៥ មានចេញវិញ្ញាបនប័ត្រកាន់កាប់ដីច្រើនជាងនៅចន្លោះឆ្នាំ១៩៩៥-២000 មួយផ្នែកប្រហែលជាករណីងាយស្រួលជាងគេ (ឧ.ងាយនឹងចូលទៅវាស់វែង និងគ្មានវិវាទ) ត្រូវបានដោះស្រាយមុន ។[១៤] មានភស្ដុតាងមួយចំនួនបានបង្ហាញថា ស្ត្រីជាមេគ្រួសារមានភាគរយតិចជាងបុរសជាមេគ្រួសារ[១៥] ក្នុងការទទួលបានវិញ្ញាបនប័ត្រកាន់កាប់ដីធ្លី ។ទាំងអស់នេះ ត្រូវបានគេពិពណ៌នាម្យ៉ាងទៀតថា គ្រួសារក្រីក្រក្នុងនោះ រួមទាំងស្ត្រីជាមេគ្រួសារ មិនអាចមានលទ្ធភាពចំណាយលើថ្លៃធ្វើ វិញ្ញាបនប័ត្រកាន់កាប់ដីធ្លីបានទេ ( So *et al.* 2002) ។

តំរូវការក្នុងការរៀបចំឯកសារដីធ្លីផ្លូវការ អាចកើនឡើងខ្ពស់នៅក្នុងតំបន់មានទីតាំងនៅតាមដងផ្លូវក្បែរទីផ្សារ នៅតាមទីប្រជុំជននានា ដែលនៅទីនោះប័ណ្ណកម្មសិទ្ធដីធ្លីត្រូវបានគេប្រើប្រាស់សំរាប់ការសំរបសំរួលលើការផ្ទេរដី ធ្វើការបញ្ជាក់ពីព្រំប្រទល់ដី និងជៀសវាងវិវាទជាមួយអ្នកអាចទាមទារ ។ នៅតំបន់ទីក្រុង ប្រជាពលរដ្ឋត្រូវការប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីពួកគេអាចទទួលបានលិខិតអនុញ្ញាតសាសង់ ។ ទោះបីជាយ៉ាងណាក្ដី តំលៃនៃការផ្ទេរខ្ពស់ (ឧ. ពេលវេលា ថ្លៃសេវា ផ្លូវការ/ក្រៅផ្លូវការ) ជាប់ពាក់ព័ន្ធនឹងការទទួលបានប័ណ្ណកម្មសិទ្ធិ បានបិទច្រកដល់ប្រជាពលរដ្ឋភាគច្រើន ក្នុងការស្វែងរកប័ណ្ណនេះ ។ ក្រៅពីនេះមាន

[១៤] សុផល *et al.* ( CDRI 19: 2001)

[១៥] ស៊ិក បូរ៉ាក្ស (CDRI: 16-2000) ។ ទោះបីជាយ៉ាងណាក្ដី ទិន្នន័យនេះពាក់ព័ន្ធនឹងការធ្វើអង្កេតតូចតាច ។ តែយ៉ាងហោចណាស់វាទំនងជាអាចឆ្លើយតបទៅនឹងទិដ្ឋភាពដែលសាយទូទៅក្នុងចំណោមអ្នកសង្កេតការណ៍ ដែលថាមេគ្រួសារជាស្ត្រី ជាអ្នកងាយរងគ្រោះ ជាពិសេសនៅពេលរឿងនេះ ពាក់ព័ន្ធនឹងដីធ្លី ។

ប្រជាពលរដ្ឋខ្លះ ខ្វះជំនឿទុកចិត្តទៅលើសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល ដើម្បីអនុវត្តសិទ្ធិកម្មសិទ្ធិដីធ្លី ជាពិសេសនៅពេលដែលវាពាក់ព័ន្ធនឹងអ្នកមានអំណាច ។ ជាលទ្ធផល អ្នកមានទ្រព្យធន និងអ្នកមានបុណ្យសក្តិ អាចមានលទ្ធភាពធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីច្រើនជាងអ្នកគ្មានធនធាន ( So *et al.* 2001) ។

ជំនួសឱ្យវិញ្ញាបនប័ត្រ ប្រជាពលរដ្ឋភាគច្រើនបានប្រើប្រាស់ឯកសារផ្សេងទៀតដើម្បីបង្ហាញពីសិទ្ធិកម្មសិទ្ធិ ដូចជាវិក្ក័យប័ត្រ (វីស៊ុយ) ដាក់ពាក្យសុំវិញ្ញាបនប័ត្រកាន់កាប់ដីធ្លី និង/ឬ ឯកសារវាស់វែងដីធ្លីជាដើម ។ ឯកសារបែបនេះ ត្រូវបានគេប្រើប្រាស់ជារឿយៗសំរាប់សំរបសំរួលក្នុងការផ្ទេរលក់ដី ។ ប្រភេទឯកសារទាំងពីរ និងវិញ្ញាបនប័ត្រពិតប្រាកដ បានពាក់ព័ន្ធនឹងការផ្ទេរលក់ដី ហើយប្រជាពលរដ្ឋបានធ្វើការផ្ទេរពីមួយទៅមួយដោយគ្រាន់តែកោសឈ្មោះអ្នកចាស់ចេញ និងសរសេរឈ្មោះអ្នកថ្មីមួយផ្សេងទៀត ។ ប្រព័ន្ធបែបនេះអាចដំណើរការបាននៅតាមតំបន់ជាច្រើន ឱ្យតែភាគីនៃការផ្ទេរនោះព្រមទទួលយកឯកសារប្រភេទនេះ ។ ករណីនេះជារឿយៗ បានធ្វើឡើងនៅពេលដែលគេធ្វើការផ្ទេរដីនៅថ្នាក់មូលដ្ឋាន ដែលប្រជាពលរដ្ឋស្គាល់គ្នាទៅវិញទៅមក ឬបើមិនដូច្នេះទេគេធ្វើសំបុត្រធានាធម្មតា ។ ទោះជាយ៉ាងណាក្តី លទ្ធភាពមានការយល់ច្រឡំ និងវិវាទដីធ្លី តែងកើនឡើង នៅពេលដែលការផ្ទេរដីទាំងនោះត្រូវបានធ្វើឡើង ជាមួយប្រជាពលរដ្ឋនៅសហគមន៍ខាងក្រៅ ឬអ្នកនៅតំបន់ជិតខាង ។

## ២.១.៤ ការផ្ទេរដី / ទីផ្សារដី

ដោយផ្អែកទៅលើទិន្នន័យផ្លូវការ ចំនួនក្បាលដីដែលបានចុះបញ្ជីក្នុងការផ្ទេរទាំងដីលំនៅដ្ឋាន និងដីកសិកម្ម បានកើនឡើងខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ដែលជាឆ្នាំលូតលាស់ខ្ពស់បំផុតផ្នែកសេដ្ឋកិច្ច ។ ការកត់សំគាល់នេះ បានបង្ហាញថា ទំហំនៃការផ្ទេរដី យ៉ាងហោចណាស់វាក៏ជាផ្នែកមួយនៃមុខងារសកម្មភាពម៉ាក្រូសេដ្ឋកិច្ច (Sophal and Acharya, 2002a) ។

ទិន្នន័យបានបញ្ជាក់លើការចាប់អារម្មណ៍ថា ក្បាលដីមានតំលៃពាណិជ្ជកម្មខ្ពស់ ច្រើនតែត្រូវបានចុះបញ្ជី និងលក់ដូរ ។ លោក សុផល និងលោក Acharya (ibid) បានផ្តល់សម្មតិកម្មថា ខេត្តដែលមានទីក្រុងធំ តែងមានប្រជាពលរដ្ឋច្រើន និងមានសកម្មភាពសេដ្ឋកិច្ចខ្លាំង រីឯខេត្តមានទីក្រុងតូច ហាក់ដូចជាមានការអភិវឌ្ឍន៍តិចតួច ។ គេបានរកឃើញថា ៦២% នៃដីលំនៅដ្ឋានត្រូវបានផ្ទេរ ហើយ ៦៦% នៃការផ្ទេរដីត្រូវបានធ្វើឡើងនៅក្នុងខេត្តមានទីក្រុងធំ ។ ការផ្ទេរដីនេះពាក់ព័ន្ធជាចំបងទៅនឹងក្បាលដីមានទំហំធំ ក្បាលដីមានទីតាំងនៅជិតកន្លែងមានផលចំណេញ (ឧ. នៅជិតទីផ្សារ ក្នុងតំបន់ទីប្រជុំជន និងនៅតាមដងផ្លូវសំខាន់ៗ) ហើយដីទាំងនោះត្រូវបានទិញដោយអ្នកដែលមានលទ្ធភាពចំណាយលើ សេវាចុះបញ្ជីដីធ្លី និងពន្ធប្រថាប់ត្រា ។ នៅតំបន់ជនបទ ថ្លៃដីកសិកម្មប្រែប្រួលទៅតាមទីតាំងដីនោះ ។ ឧទាហរណ៍ ថ្លៃដីខ្ពស់បំផុត ត្រូវបានគេសង្កេតឃើញនៅក្រុងព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដែលជាដីមានការពេញនិយម និងមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ៤ ។

នៅចន្លោះឆ្នាំ១៩៩៥ និងឆ្នាំ២០០១ ក្បាលដីចំនួន ៦៦៣៧ ត្រូវជា ៨០% ត្រូវបានផ្ទេរចុះឡើងនៅក្រៅទីក្រុងភ្នំពេញដោយប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញជាអ្នកទិញ ។ នេះអាចជាចំណែកមួយនៃការពិពណ៌នាអំពីដំណើរហេតុថា អ្នកទីក្រុងភ្នំពេញជារឿយៗគេស្នាក់នៅឆ្ងាយពីដីដែលគេទិញ ហើយគេត្រូវការសុវត្ថិភាពកាន់កាប់ដីច្រើនជាង ។ នៅក្នុងករណីនេះ គេនឹងត្រូវ ឬអាចចំណាយខ្ពស់នៅពេលធ្វើការផ្ទេរដីតាមផ្លូវការ ។ ទោះជាយ៉ាងណាក្តី ចំនួនពិតប្រាកដ និងចង្វាក់នៃការផ្ទេរដីទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ គេជឿថាមានកំរិតខ្ពស់ជាងអ្វីដែលគេបានកត់ត្រាតាមផ្លូវការ ។ ប្រជាពលរដ្ឋមានទំនោរជៀស

រវាងការចុះបញ្ជីតាមប្រព័ន្ធផ្លូវការ ដោយសារតែថ្លៃខ្ពស់នៃការផ្ទេរ ដែលវាជាប់ពាក់ព័ន្ធនឹងសេវាក្រៅផ្លូវការ និងពេលវេលាលើដំណើរការផ្ទេរនោះ ក៏ដូចពន្ធប្រថាប់ត្រា ៤% ។ ដោយសារដីមិនបានចុះបញ្ជី ដូច្នេះការផ្ទេរជាច្រើនមិនត្រូវបានចុះបញ្ជីទេ ដែលធ្វើឱ្យបាត់បង់ចំណូលរបស់រដ្ឋាភិបាលយ៉ាងច្រើន (So *et al.* 2001) ។[១៦]

## ២.១.៥ វិវាទដីធ្លី

ភាពញឹកញាប់ និងធម្មជាតិនៃវិវាទដីធ្លីនៅពេលនេះបានកើនឡើងនៅតំបន់ជនបទដូចជា (១) ការផ្លាស់ប្តូរលំនាំប្រើប្រាស់ដីពីដីសំរាប់ធ្វើកសិកម្មចិញ្ចឹមជីវិត ទៅជាដីសំរាប់ធ្វើពាណិជ្ជកម្ម និង (២) អ្នកមានផលប្រយោជន៍ផ្សេងៗគ្នា កំពុងប្រកួតប្រជែងដណ្តើមប្រើប្រាស់ធនធានដីដ៏កម្រ ។ ឧទាហរណ៍ មានការកើនឡើងនូវវិវាទដីធ្លី ដែលជាប់ពាក់ព័ន្ធ ជាមួយនឹងប្រជាពលរដ្ឋក្នុងភូមិ និងប្រជាពលរដ្ឋមកពីខាងក្រៅ (ឧ. បុគ្គលម្នាក់ៗ ឬក្រុមហ៊ុននានា) នៅក្នុងតំបន់ជាប់នឹងទីប្រជុំជន និងមជ្ឈមណ្ឌលពាណិជ្ជកម្ម (So *et al.* ibid) ។ មានការរាយការណ៍ថា កសិករ និងប្រជាពលរដ្ឋជាច្រើន ទទួលរងនូវអំពើរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាចនៅក្នុងមូលដ្ឋាន និងពីកត្តាខាងក្រៅនានានៅក្នុងតំបន់ខ្លះ ។ នៅតំបន់ទីប្រជុំជន វិវាទដីធ្លីកើតឡើងរវាងប្រជាពលរដ្ឋ និងពាណិជ្ជករ ដោយសារការប្រកួតគ្នាដណ្តើមដីដែលមានតំលៃខាងពាណិជ្ជកម្ម ។ ប្រភពវិវាទផ្សេងទៀត គឺពាក់ព័ន្ធជាមួយបុគ្គលឯកជន ដូចជា ជនចំណាកស្រុកដែលបានចូលទៅទន្ទ្រានកាន់កាប់ដីឯកជន ឬដីសាធារណៈ ។

ឯកសារវាយតំលៃគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី PAD របស់ធនាគារពិភពលោក បានចង្អុលបង្ហាញថា វិវាទដីធ្លីជាច្រើនអាចបណ្តាលមកពីកង្វះខាតការកំណត់ច្បាស់លាស់អំពីព្រំប្រទល់រវាងដីឯកជនដែលកាន់កាប់ដោយបុគ្គលម្នាក់ៗ ជាមួយនឹងស្ថាប័ននានារបស់រដ្ឋ និងរវាងបុគ្គលឯកជនដែលជារឿយៗមានការប្រកួតប្រជែងគ្នាទាមទារកាន់កាប់លើដីតែមួយ ។ លើសពីនេះទៀត នៅពេលដែលតំលៃដីកើនឡើងនៅក្នុងក្របខ័ណ្ឌនៃការពង្រីកទីផ្សារដី ប្រជាពលរដ្ឋ ក៏ដូចជាស្ថាប័ននានាទទួលស្គាល់ថា ទោះដីមានទំហំតូចក្តី ក៏វាអាចមានតំលៃច្រើនគួរកត់សំគាល់ដែរ ។

បញ្ហាពាក់ព័ន្ធនឹងវិវាទដីធ្លី វាកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ដោយសារកង្វះខាតនូវយន្តការមានប្រសិទ្ធភាព សំរាប់ការដោះស្រាយវិវាទ និងការអនុវត្តន៏ច្បាប់ពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យសម្បត្តិ ។ ដោយសារបញ្ហាដីធ្លីក្លាយទៅជាបញ្ហាទំនាស់កាន់តែច្រើន និងពាក់ព័ន្ធជាមួយប្រជាពលរដ្ឋមកពីតំបន់ផ្សេងៗគ្នា ករណីវិវាទកាន់តែច្រើនឡើងៗត្រូវបានប្តឹងទៅតុលាការដើម្បីដោះស្រាយ ។ នៅពេលនេះ មានបញ្ហាកកស្ទះកំពុងកើនឡើងលើករណីវិវាទ ដែលតំរូវឱ្យធ្វើការពិចារណាលើពេលវេលាដើម្បីរៀបចំតាមប្រភេទនៃវិវាទនិមួយៗ ។ បញ្ហាវិវាទដីធ្លីជាឥទ្ធិពលមួយដែលធ្វើឱ្យទីផ្សារដីធ្លីដំណើរការ មិនមានប្រសិទ្ធភាពដោយសារប្រជាពលរដ្ឋ ឬពាណិជ្ជករអាចស្ទាក់ស្ទើរក្នុងការវិនិយោគទៅលើដីដែលកំពុងមានបញ្ហា ។ អ្នកមានអំណាច និងអ្នកមានទ្រព្យធនមានលទ្ធភាពច្រើនជាងក្នុងការរង់ចាំ ហើយករណីបែបនេះគេអាចដោះស្រាយបានងាយស្រួលជាងអ្នកមានធនធានតិចតួច ។ បញ្ហានេះបានរួមចំណែកធ្វើឱ្យ ***មានវិបត្តិនៃការជឿជាក់*** នៅក្នុងការងារអភិបាលកិច្ច ក្នុងចំណោមប្រជាពលរដ្ឋ ដែលគាត់មានអារម្មណ៏ថា ប្រព័ន្ធរដ្ឋបាលដីធ្លី ***គឺបំរើតែចំពោះអ្នកមានធនធាន និងអ្នកមានអំណាច នៅក្នុងខណៈដែលមានការច្រានចោលនូវការចូលរួមស្មើភាពគ្នា និងពញ្ញលេញពីសំណាក់ប្រជាពលរដ្ឋទន់ខ្សោយ*** (So *et al.*, ibid.: 41) ។

---

[១៦] ទោះបីការផ្ទេរ ត្រូវបានដំណើរការតាមរយៈប្រព័ន្ធចុះបញ្ជីផ្លូវការក្តី ក៏នៅមានការបាត់បង់ខ្លះៗទៀត លោក សុផល និង លោក Acharya (ibid) បានកត់សំគាល់ថា ដីត្រូវបានផ្ទេរនៅក្រោមតំលៃពិត ដែលមានប្រហែលជា ៦០% ដែលត្រូវបាត់បង់នូវប្រភពចំណូល ។

# ជំពូក ៣. ក្របខ័ណ្ឌគំនិត

ការប៉ាន់ស្មាន និងការទាយទុកមុន ដែលអ្នករៀបចំផែនការធ្វើឡើងចំពោះលទ្ធផលរំពឹងទុកមុននៃកម្មវិធីចុះបញ្ជីដីធ្លី បានមកពីទស្សនៈទូទៅនៃកម្មសិទ្ធិទ្រព្យសម្បត្តិ និងពីភស្តុតាងដោយសំអាងលើបទពិសោធន៍ដែលបានធ្វើការស្រាវជ្រាវពីប្រទេសមួយចំនួនដែលមានកម្មវិធីប្រហាក់ប្រហែលគ្នានេះត្រូវបានអនុវត្ត ។ ដូច្នេះវាមានប្រយោជន៍ណាស់ក្នុងការពិភាក្សាគ្នាដោយសង្ខេបលើបញ្ហាខ្លះដែលកើតមានកាន់តែច្រើនឡើង និងបានរកឃើញនៅក្នុងមេរៀននានាស្តីពីកម្មសិទ្ធិទ្រព្យសម្បត្តិ និងកម្មសិទ្ធិដីធ្លី មុននឹងធ្វើការពិភាក្សាលំអិតថែមទៀតនៅក្នុងក្របខ័ណ្ឌនៃគំរោងអង្កេតមូលដ្ឋាន BSP ដែលដាក់បញ្ចូលមេរៀនពីគំរោងផ្សេងទៀតទៅក្នុងវិធីសាស្ត្រនៃការស្រាវជ្រាវ ។

កម្មសិទ្ធិទ្រព្យសម្បត្តិ ជារឿយៗសំដៅទៅលើ ***បណ្តុំនៃសិទ្ធិ*** ដើម្បីប្រើប្រាស់ទទួលបានចំណូល និងទុកដាក់ទ្រព្យសកម្មជាក់លាក់ណាមួយ (Barzel ១៩៨៩) ។ តំលៃនៃទ្រព្យសម្បត្តិត្រូវបានបញ្ជាក់នៅក្នុងទំរង់ (១) ការរំពឹងទុកពីផលចំណេញនាពេលអនាគតដែលអាចនឹងទទួលបានពីទ្រព្យនោះ និង (២) សុវត្ថិភាពនៃការត្រួតពិនិត្យរបស់បុគ្គលម្នាក់ៗ ទៅលើសិទ្ធិដើម្បីទទួលបានជាបន្តបន្ទាប់នូវផលចំណេញដែលរំពឹងទុក (Alchian and Demsetz ១៩៧៣) ។ ទោះបីជាយ៉ាងណា ការប្រើប្រាស់ការគ្រប់គ្រង និងសិទ្ធិកម្មសិទ្ធិទៅលើទ្រព្យសម្បត្តិជាវត្ថុរូបី ដូចជាដីធ្លីជាដើម វាមិនចាំបាច់ត្រូវតែស្របគ្នានោះទេ ។ ឧទាហរណ៍យើងបានឃើញរួចហើយនូវបុគ្គលនៅក្នុងប្រទេសកម្ពុជាដែល មានសិទ្ធិប្រើប្រាស់ដីក្នុងគោលដៅផលិត ប៉ុន្តែគ្មានសិទ្ធិយកដីនោះជាទំនិញ សំរាប់ធ្វើពាណិជ្ជកម្មបានទេ ។

ប្រសិទ្ធភាពផ្នែកអភិបាលកិច្ចនៃកម្មសិទ្ធិលើទ្រព្យ តំរូវឱ្យមានប្រព័ន្ធច្បាប់មួយដើម្បីដាក់បញ្ញត្តិអំពីការចរចា និងពង្រឹងការអនុវត្តន៍សិទ្ធិកម្មសិទ្ធិ ការប្រើប្រាស់ និងការត្រួតពិនិត្យអំពីសិទ្ធិ ។ ដោយសារវាជាប្រភេទនៃទំនាក់ទំនងដែលមានកិច្ចសន្យា ការផ្លាស់ប្តូរសិទ្ធិលើទ្រព្យគឺត្រូវបានគ្រប់គ្រងទាំងដោយស្ថាប័នផ្លូវការ និងក្រៅផ្លូវការ ។ ស្ថាប័នក្រៅផ្លូវការ ដូចជាបទដ្ឋានសង្គម និងក្រឹត្យក្រមខាងវប្បធម៌ដែលកំណត់នូវអាកប្បកិរិយារំពឹងទុក អាចជាមធ្យោបាយមានប្រសិទ្ធភាពនៃអភិបាលកិច្ចល្អ នៅពេលដែលការដោះដូរមានលក្ខណៈជារឿងបុគ្គលច្រើន ដូចជានៅក្នុងភូមិបែបបុរាណៗនៅទីជនបទកម្ពុជា ។ ស្ថាប័នផ្លូវការ គឺមានយន្តការ និងវិធានកំនត់ដោយច្បាប់ដែលចងក្រងឡើងទៅតាមដំណើរការនយោបាយមួយ ហើយបង្ខំឱ្យអនុវត្តដោយរដ្ឋ ។ វាមានប្រសិទ្ធភាពខ្ពស់ក្នុងករណីដែលការដោះដូរមានភាពស្មុគស្មាញខ្លាំង និងមិនមែនជា រឿងបុគ្គល (North, 1991) ។ លក្ខណៈបែបនេះធ្វើឱ្យមានទីផ្សារដីកើតឡើងនៅក្នុងតំបន់ដែលមានប្រជាពលរដ្ឋរស់នៅច្រើន និងមានសកម្មភាពសេដ្ឋកិច្ចខ្ពស់ នៅក្នុង និងជុំវិញទីក្រុងធំៗនៅនៃប្រទេសកម្ពុជា ។

ស្ថាប័នផ្លូវការ និងក្រៅផ្លូវការនៃអភិបាលកិច្ច មិនមែនស្របគ្នាពីមួយទៅមួយទាំងអស់ទេ ដែលធ្វើឱ្យការផ្ទេរមានតំលៃខ្ពស់ ដោយសារតែភាពមិនច្បាស់លាស់ និងភាពតឹងតែងក្នុងការបង្កើត និងពង្រឹងការអនុវត្តន៍ច្បាប់ពាក់ព័ន្ធនឹង សិទ្ធិកម្មសិទ្ធិលើទ្រព្យរវាងស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ។ ភាពមិនច្បាស់លាស់នេះ កើនឡើងក្នុងចន្លោះពេលនៃការរីកលូតលាស់យ៉ាងលឿនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដែលមានលក្ខណៈជាការផ្លាស់ប្តូរខាងបច្ចេកវិទ្យា និង/ឬការផ្លាស់ប្តូរកំរិតថ្លៃនៅមូលដ្ឋាន ដែលធ្វើ

ឱ្យប៉ះពាល់ដល់តំលៃបានរំពឹងទុកនៃទ្រព្យសកម្មផលិត ដូចជា ដីធ្លីជាដើម (Libecap, 1989; North 1990) ។ ភាពតានតឹងជាប់ពាក់ព័ន្ធជាមួយនឹងភាពមិនច្បាស់លាស់ ដែលជារឿយៗ បង្កើតទាំងតំរូវការកំណត់ឡើងវិញឱ្យកាន់តែច្បាស់ និងការបែងចែកឡើងវិញឱ្យកាន់តែមានប្រសិទ្ធភាពឡើងនូវសិទ្ធិលើទ្រព្យសម្បត្តិក្នុងចំណោមសមាជិកសហគមន៍ ក៏ដូចជា ក្នុងចំណោមអ្នកទាមទារពីខាងក្រៅ ដែលពួកគេអាចត្រូវបានទាក់ទាញ ដើម្បីបង្កើតនូវទ្រព្យថ្មីៗ ។ មានឧទាហរណ៍ល្អមួយនៅប្រទេសកម្ពុជាពាក់ព័ន្ធនឹងប្រជាពលរដ្ឋ នៅតំបន់ទីប្រជុំជនដែលគាត់ទិញដីក្នុងតំបន់ជនបទ គឺគាត់ចង់បានវិញ្ញាបនប័ត្រកាន់កាប់ដី ឬប័ណ្ណកម្មសិទ្ធិដី សំរាប់ជាឯកសារសមស្រប ជាជាងមានតែវិក្កយប័ត្រដាក់ពាក្យសុំកាន់កាប់ដីនោះ ។

នៅតំបន់ជនបទ វិធីសាស្ត្រអនុវត្តផលិតកម្មកសិកម្មយថាផល អាចសំគាល់បានតាមកំរិតដង់ស៊ីតេប្រជាជនទាប និងភាពរង្វើល (ហ្វ្រេកង់ទាប) នៃការដាំដុះនៅក្នុងតំបន់ណាមួយ ។[១៧] នៅពេលដីមានច្រើនសំរាប់ប្រជាពលរដ្ឋ កម្មសិទ្ធិលើទ្រព្យអាចគ្រប់គ្រងបានយ៉ាងមានប្រសិទ្ធភាពដោយប្រព័ន្ធក្រៅផ្លូវការនៅថ្នាក់មូលដ្ឋាន ដោយផ្អែកទៅលើជាតិពិន្ទុ និងតក្កវិជ្ជានៃប្រពៃណី និងទំនៀមទំលាប់ ។ វិធីសាស្ត្រអនុវត្តបែបប្រពលវប្បកម្មនៃផលិតកម្មកសិកម្ម អាចសំគាល់បានតាមកំរិតដង់ស៊ីតេប្រជាជនខ្ពស់ និងភាពញឹកញាប់ (ហ្វ្រេកង់ខ្ពស់) នៃការដាំដុះ ។ ក្នុងតំបន់បែបនេះ ភាពកម្រនៃដីជាយថាហេតុ អាចទាមទារឱ្យមានការគ្រប់គ្រងដោយស្ថាប័នផ្លូវការឱ្យបានច្រើនឡើងដើម្បីធ្វើការងារត្រួតពិនិត្យ និងការប្រើប្រាស់សិទ្ធិ ក៏ដូចជាការផ្តល់នីតិវិធីដែលអាចទាយទុកមុនបានសំរាប់ការផ្ទេរកម្មសិទ្ធិលើទ្រព្យ (ឧ. ការលក់ ការផ្ទេរមរតកជាដើម) ។

នៅពេលតំលៃដីកើនឡើង ដោយសារវាជាទ្រព្យសំរាប់ផលិត រឺក៏នៅក្នុងតំបន់ទីក្រុងដែលមានទីផ្សារអចលនទ្រព្យ មានសកម្មភាពខ្លាំង តំរូវការនូវសិទ្ធិអចិន្ត្រៃយ៍និងអាចផ្ទេរបាន វាបង្កើនតំរូវការជារចនាសម្ព័ន្ធរដ្ឋបាលចំពុះ ដែលផ្អែកទៅលើសិទ្ធិអំណាចរបស់រដ្ឋ ។ សំរាប់គោលបំណងនៃការពិពណ៌នា និងការវិភាគ គេគួរពិចារណាអំពីទីផ្សារដីនៅជនបទ និងទីប្រជុំជននៅប្រទេសកម្ពុជា ក្នុងបរិបទនៃការធ្វើអន្តរកាលពីគំរូនៃការប្រើប្រាស់ដីតាមបែបយថាផល ទៅជាការប្រើប្រាស់ដីតាមបែបប្រពលវប្បកម្មកាន់តែច្រើនឡើង ។

ហេតុផលសំរាប់កម្មវិធីចុះបញ្ជីដីធ្លី គឺវាផ្អែកជាសំខាន់ទៅលើទ្រឹស្តីនៃការផ្សារភ្ជាប់គ្នារវាង ការលើកទឹកចិត្តវិនិយោគ និងសុវត្ថិភាពនៃកម្មសិទ្ធិលើទ្រព្យ ។ ហេតុផលជាមូលដ្ឋានគឺថា ប្រជាពលរដ្ឋគាត់មានបំណងវិនិយោគធនធាន នៅក្នុងសហគ្រាសផលិតកម្ម នៅពេលដែលគាត់មានការជឿជាក់ថា គាត់ ឬទាយាទរបស់គាត់ នឹងទទួលផលចំណេញ បានមកពីការវិនិយោគបែបនេះនាពេលអនាគត ។ ក្នុងវិស័យកសិកម្ម កសិករអាចទទួលបានឥណទានដើម្បីធ្វើវិនិយោគផ្សេងៗ ដូចជាសំរាប់ទិញសំភារៈប្រើប្រាស់ និងគ្រឿងចក្រ ក៏ដូចជាការធ្វើឱ្យប្រសើរឡើងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ។ នៅតំបន់ទីប្រជុំជន ប្រជាពលរដ្ឋអាចទទួលបានឥណទានសំរាប់វិនិយោគក្នុងការកែលំអលំនៅដ្ឋាន ឬក៏អាជីវកម្មសហគ្រាសខ្នាតតូច និងមធ្យម (SMEs) ។ ក្នុងវិស័យទាំងពីរនេះ ការកើនឡើងលើការវិនិយោគក្នុងសកម្មភាពផលិត ត្រូវបានរំពឹងថា នឹងបង្កើនចំនូលគ្រួសារ និងសុខុមាលភាព ក៏ដូចជារួមចំណែកធ្វើឱ្យមានការលូតលាស់ផ្នែកម៉ាក្រូសេដ្ឋកិច្ចនាពេលខាងមុខ ។

ការវិនិយោគបែបនេះ នឹងធ្វើឱ្យតំរូវការឥណទានកើនឡើង ។ ក្នុងទិដ្ឋភាពបែបនេះ មានការរំពឹងថា ប្រជាពលរដ្ឋ អាចប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីទទួលបានឥណទានពីស្ថាប័នផ្លូវការកាន់តែច្រើនឡើង ។ ការងារនេះមានសារៈសំខាន់ណាស់

---

[១៧] Boserup (1965) ផ្តល់នូវការពិភាក្សាចុងក្រោយបំផុតនៃប្រព័ន្ធកសិកម្មយថាផល និងប្រពលវប្បកម្ម ។

នៅក្នុងការកាត់បន្ថយភាពក្រីក្រ ដែលអាចឱ្យសមាជិកសហគមន៍ប្រជាពលរដ្ឋក្រីក្រប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីទទួលបានប្រាក់កំចីដែលមានការប្រាក់ទាបសំរាប់គោលបំណងនៃការផលិត ។ នៅពេលដែលតំរូវការឥណទានកើនឡើង ការផ្គត់ផ្គង់ផ្នែកឥណទានក៏ត្រូវធ្វើការពង្រីកផងដែរ ។ ក្នុងទិដ្ឋភាពនេះ កម្មវិធីចុះបញ្ជីដីធ្លី ក៏រំពឹងថានឹងជួយជំរុញឱ្យកាន់តែមានប្រសិទ្ធភាពច្រើនឡើងលើវិស័យសេវាកម្មហិរញ្ញវត្ថុ ដែលជាសមាសភាគគន្លឹះសំរាប់ការរីកលូតលាស់លើវិស័យម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង ។

កម្មវិធីចុះបញ្ជីដីធ្លី ក៏ពាក់ព័ន្ធផងដែរនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងទីផ្សារដីឱ្យកាន់តែមានប្រសិទ្ធភាពឡើង ដូច្នេះភាពកម្រនៃធនធាននេះ ជាយថាហេតុនឹងត្រូវបានបែងចែកសំរាប់ការប្រើប្រាស់ឱ្យមានផលិតភាពខ្ពស់បំផុត ។ ទីផ្សារដីធ្លីមានចំនុចខ្សោយមួយចំនួនដូចជា ព័ត៌មានគឺមានតិចតួចបំផុត នីតិវិធីមិនអាចធ្វើការទស្សន៍ទាយបាន ហើយមានវិវាទជាច្រើន ដោយសារប្រទេសកម្ពុជាមានលក្ខណៈសេដ្ឋកិច្ចមិនមានប្រសិទ្ធភាព ពីព្រោះការផ្ទេរមានតំលៃខ្ពស់ ដែលពាក់ព័ន្ធនឹងការចរចាគ្នា និងការពង្រឹងការអនុវត្តន៍កម្មសិទ្ធិលើទ្រព្យ និងកិច្ចសន្យានៃការដោះដូរ ។ សុវត្ថិភាព និងកម្មសិទ្ធិលើទ្រព្យដែលអាចធ្វើការទស្សន៍ទាយបានជាមុន វាអាចជួយកាត់បន្ថយនូវទំរង់ការមិនប្រាកដប្រជា ព្រមទាំងផ្តល់នូវព័ត៌មានជាក់លាក់ថែមទៀតអំពីតំលៃពិតរបស់ដី ។

ទីផ្សារដីត្រូវបានចាត់ទុកថា មានវិវាទជាច្រើន និងគ្មានប្រសិទ្ធភាពលើការគ្រប់គ្រងទេ ដែលជាកត្តានាំឱ្យគ្មានប្រសិទ្ធភាពលើផ្នែកសង្គមកិច្ច ។ រឿងនេះ មានចោទជាពិសេសក្នុងករណីដែលប្រជាពលរដ្ឋបាត់បង់ដីរបស់ពួកគេដោយអយុត្តិធម៌ និងគ្មានសំណងសមស្រប ដែលបង្ខំឱ្យពួកគេធ្វើចំនាកស្រុកទៅកន្លែងផ្សេងទៀតដើម្បីស្វែងរកឱកាសរកចំនួល ។ ក្នុងន័យនេះ ការចំនាយផ្នែកសង្គមកិច្ចជាសក្តានុពលមួយចំនួនទៀតពាក់ព័ន្ធនឹងការបែងចែកដីដើម្បីទទួលបានកម្មសិទ្ធិ ។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រសិទ្ធភាពនៃទីផ្សារដីអាចនាំឱ្យមានការប្រមូលដីទុកកាន់តែច្រើនឡើងនៅក្នុងដៃអ្នកកាន់កាប់មួយចំនួនតូច ។ ទោះជាយ៉ាងណាក្តី ការចំណាយលើផ្នែកសង្គមកិច្ចជាប់ពាក់ព័ន្ធនឹងការបែងចែកបែបនេះ អាចប៉ះប៉ូវវិញបានតាមការទូទាត់សំណងដោយយុត្តិធម៌និងសមស្របនូវដី គួបផ្សំនឹងការធ្វើវិនិយោគខាងផលិតកម្មដើម្បីបង្កើតឱកាសការងារដែលអាចចិញ្ចឹមជីវិតបាន ។

## ៣.១ សម្មតិកម្មនៃការស្រាវជ្រាវ

តាមរយៈទ្រឹស្តីទាំងឡាយ រួមជាមួយនឹងការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា និងនៅកន្លែងផ្សេងទៀត គេអាចបង្កើតជាសម្មតិកម្មដែលអាចសាកល្បងបាន ដើម្បីកសាងវិធីសាស្ត្រស្រាវជ្រាវសំរាប់ប្រើប្រាស់នៅក្នុងការស្រាវជ្រាវមូលដ្ឋាននេះ ។ សម្មតិកម្មទាំងនេះអាចសាកល្បងបានតាមវិធីសឹងដូចការដកពិសោធន៏ (quasi-experimental methods) ដែលធ្វើការប្រៀបធៀបទិន្នន័យគ្រួសារទទួលបានមកពីគំរោងអង្កេតបឋមនាពេលថ្មីៗ BSP ($T_0$) ជាមួយនឹងទិន្នន័យប្រមូលបាននៅចំណុចក្រោយទៀតនៅអំឡុងពេលអង្កេត ($T_3$) ទាំងតំបន់នៅក្នុងគំរោង និងតំបន់នៅក្រៅគំរោង ។ ចំណុចសេសសល់នៅក្នុងផ្នែកនេះ គឺជាការសង្ខេបនូវផលប៉ះពាល់សំខាន់ៗខាងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដែលគេគិតថា អាចទទួលបានពីគំរោងចុះបញ្ជីដីធ្លី និងការកំណត់នូវបញ្ហាគន្លឹះនានា និងសូចនាករដែលនឹងត្រូវប្រើប្រាស់នៅក្នុងការវាយតំលៃផលប៉ះពាល់ ។ ដំណើរការនៃការប្រមូលទិន្នន័យនឹងធ្វើការពិភាក្សាលំអិតនៅផ្នែកខាងក្រោយ ។

## ៣.១.១ ផលប៉ះពាល់សេដ្ឋកិច្ច

ផលប៉ះពាល់សេដ្ឋកិច្ចដែលបណ្ដាលមកពីកម្មវិធីចុះបញ្ជីដីធ្លីត្រូវបានកត់សំគាល់ឃើញ ទាំងនៅកំរិតសហគមន៍ និងបុគ្គលម្នាក់ៗ ។ ការប៉ះពាល់បែបនេះអាចប្រែប្រួលទៅតាមកត្តាជាច្រើនដូចជា ទំហំដីដែលកំពុងកាន់កាប់ និងប្រើប្រាស់ (ឧ. ប្រព័ន្ធធ្វើកសិកម្ម) យេនឌ័រនៃមេគ្រួសារ ទីតាំងភូមិ រចនាសម្ព័ន្ធរូបវន្ត ព្រមទាំងគំរោងអភិវឌ្ឍន៍នានាផង ។

### *៣.១.១.១. លទ្ធភាពទទួលបានឥណទាន*

ទ្រឹស្ដីនៃការស្រាវជ្រាវបានគិតទុកថា ប្រជាពលរដ្ឋទាំងនៅតំបន់ជនបទ និងតំបន់ទីប្រជុំជន នឹងប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីខ្ចីប្រាក់ពីស្ថាប័នឱ្យខ្ចីប្រាក់ផ្លូវការ ។ យើងអាចសង្កេតឃើញពី ការផ្លាស់ប្ដូរនៅក្នុងចរិតនៃការខ្ចីប្រាក់របស់កសិករពីស្ថាប័នក្រៅផ្លូវការ (ឧ. គ្រួសារអ្នករកស៊ីចងការប្រាក់) ទៅរកស្ថាប័នផ្លូវការវិញ (ឧ. MFIs, Acleda) ។ យើងក៏ធ្វើការកត់សំគាល់ផងដែរទៅលើការប្ដូរចំនួន ទំហំ និងគំរោងប្រើប្រាស់ប្រាក់កំចី ដោយប្រជាពលរដ្ឋខ្ចីប្រាក់កំចីកាន់តែញឹកញាប់ឡើង និងមានទឹកប្រាក់ច្រើនឡើង សំរាប់វិនិយោគលើការផលិត ។ ទ្រឹស្ដីនៃការស្រាវជ្រាវក៏បានគិតទុកដែរថា ការកើនឡើងនូវតំរូវការឥណទាននឹងធ្វើឱ្យការផ្គត់ផ្គង់ឥណទានកើនឡើង ។ ជាលទ្ធផល យើងសង្កេតឃើញថា មានការកើនឡើងនូវចំនួនសាខាការិយាល័យរបស់ស្ថាប័នផ្លូវការនៅក្នុងតំបន់ខេត្តគំរោង និង/ឬការកើនចំនួន និងទំហំនៃកំចីពីស្ថាប័នផ្ដល់ប្រាក់ឱ្យខ្ចី ។ ទ្រឹស្ដីបែបនេះបានសន្មតជាមុនថា ទីផ្សារឥណទានផ្លូវការ មានដំណើរការល្អគួរសមនៅក្នុងតំបន់ជាក់លាក់ណាមួយ (ឧ. តំលៃនៃការផ្ទេរទាប) ។

### *៣.១.១.២. ការវិនិយោគក្នុងវិស័យផលិតកម្មកសិកម្ម/ការកែប្រែដីធ្លីឱ្យប្រសើរឡើង*

ទ្រឹស្ដីបានគិតទុកថា កសិករនឹងបង្កើនការចំណាយទៅលើផលិតកម្មស្រូវ ការចិញ្ចឹមសត្វ និង/ឬដាំដំណាំផ្សេងទៀត នៅក្នុងតំបន់អនុវត្តគំរោង ។ ការចំណាយទៅលើការផលិតអាចរួមបញ្ចូលនូវធាតុចូលផ្សេងៗ ដូចជា ជី ថ្នាំសំលាប់សត្វល្អិត កំលាំងពលកម្ម គ្រឿងចក្រ និងការកែប្រែដីឱ្យប្រសើរឡើង (ឧ. ប្រព័ន្ធធារាសាស្ត្រ) ។ ការកើនឡើងនូវការចំណាយលើការវិនិយោគ អាចនឹងទទួលត្រលប់មកវិញនូវការកើនឡើងគួរកត់សំគាល់នូវទិន្នផល ក៏ដូចជាផលិតភាពដីធ្លី និងកំលាំងពលកម្ម ។ រឿងនេះផ្អែកលើការសន្មតទុកជាមុនថា លក្ខខណ្ឌទីផ្សារ (ឧ. ពាក់ព័ន្ធនឹងថ្លៃផលិត និងមធ្យោបាយសំរាប់ផលិត) គុណភាពដី និងអាកាសធាតុ (ឧ. មានទឹកភ្លៀងគ្រប់គ្រាន់ គ្មានទឹកជំនន់ និងភាពរាំងស្ងួត) មានស្ថិរភាពគួរសម ។ កត្តាផ្សេងទៀតដែលអាចប៉ះពាល់ដល់ការសំរេចចិត្តវិនិយោគ រួមមាន ទំហំកសិដ្ឋាន (ការកាន់កាប់ដី) និងវត្តមានកំលាំងពលកម្ម និងទ្រព្យដែលមានផលិតភាពផ្សេងៗទៀត ។ កំរិតនៃការផ្ដល់សេវាកម្មពីរបៀបដាំដំណាំ និងការចិញ្ចឹមសត្វ ជូនទៅកសិករនៅក្នុងតំបន់ជាក់លាក់ណាមួយ គឺជាកត្តាសំខាន់មួយទៀតដែលអាចមានឥទ្ធិពលលើការវិនិយោគ ។

### *៣.១.១.៣. ការប្រើប្រាស់ដី*

ទ្រឹស្ដីនៃការស្រាវជ្រាវបានគិតទុកថា សុវត្ថិភាពនៃការកាន់កាប់ដីក្នុងទំរង់ជាប័ណ្ណកម្មសិទ្ធិ នឹងធ្វើឱ្យការប្រើប្រាស់ដីតំរង់ទិសទៅរកការប្រើប្រាស់ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ ក្នុងទិដ្ឋភាពនេះ មានភស្ដុតាងបានមកពីប្រទេសថៃ (Onchan Aungsumalin, ២០០២) បានបង្ហាញថា ការចុះបញ្ជីកម្មសិទ្ធិដីធ្លីបង្កើតឱ្យមានការផ្លាស់ប្ដូរខ្លះៗក្នុងការប្រើប្រាស់ដី ដែលប្រែប្រួលចេញពីមុខដំណាំអស់ចំណាយតិចតែផ្ដល់ផលត្រលប់វិញតិច (ឧ. ការដាំស្រូវសំរាប់ប្រើប្រាស់ក្នុងគ្រួសារ) ទៅជាការដាំដំណាំ

សំរាប់បំរើឱ្យវិស័យពាណិជ្ជកម្ម និងនៅក្នុងករណីខ្លះទៀត គឺការដាំដំណាំហូបផ្លែ និងដំណាំឈើផ្សេងទៀតដែលអាចផ្តល់ផល ត្រលប់មកវិញខ្ពស់ជាង ។ ថ្វីបើលក្ខខណ្ឌកសិកម្ម និងទីផ្សារមានលក្ខណៈខុសគ្នានៅក្នុងប្រទេសកម្ពុជា ប៉ុន្តែយើងសង្ឃឹមថា កសិករនឹងចាប់ផ្តើមធ្វើចំរុះកម្មការប្រើប្រាស់ដី (ការធ្វើចំការ និងដំណាំឈើផ្សេងទៀត) ហើយផលប៉ះពាល់ពេញលេញនៃប័ណ្ណ កម្មសិទ្ធិដីនៅក្នុងរឿងនេះ អាចតំរូវឱ្យមានការធ្វើអង្កេតលើសពី ៣ឆ្នាំ ។ យើងក៏សង្ឃឹមផងដែរថា ទំហំ និងកំរិតនៃការធ្វើ ចំរុះកម្ម នឹងកើនឡើងកាន់តែលឿន គឺស្របគ្នានឹង ទំហំនៃការកាន់កាប់ដី ។

### *៣.១.១.៤. ទីផ្សារដីធ្លី*

ទ្រឹស្តីនៃការស្រាវជ្រាវបានទស្សន៍ទាយថា ក្បាលដីមានប័ណ្ណកម្មសិទ្ធិនឹងត្រូវបានផ្ទេរតាមរយៈទីផ្សារដី ទៅរកការប្រើប្រាស់ដែល មានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច ។ យើងអាចសង្ឃឹមថា នឹងបានឃើញជាបន្តបន្ទាប់នូវការប្រែប្រួលក្នុងលំនាំនៃការប្រើប្រាស់ដី ក៏ដូចជាការវិនិយោគដែលមានផលិតភាព ។

#### *ថ្លៃដី*

ដោយសារការប្រើប្រាស់ដីផ្លាស់ប្តូរទៅរកទិសដៅដែលកាន់តែមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច តំលៃក្បាលដីលំនៅដ្ឋាន និង/ឬ ដីកសិកម្មដែលអាចមើលឃើញតាមកំរិតថ្លៃដី (ឧ. ការលក់ ការជួល) នឹងកើនឡើង ។ យើងសង្ឃឹម នឹងឃើញថ្លៃដីកើនឡើង ក្នុងកំរិតយ៉ាងលឿនលើដីដែលមានទីតាំងនៅជិតទីផ្សារ/ជិតមជ្ឈមណ្ឌលរដ្ឋបាល និងនៅតាមដងផ្លូវសំខាន់ៗ ។ ប៉ុន្តែការកើន ឡើងនេះ នឹងមានកំរិតខ្ពស់ជាងនៅក្នុងតំបន់នៃគំរោង LMAP បើធៀបនឹងតំបន់សំរាប់ត្រួតពិនិត្យ ពីព្រោះដីដែលបានចុះបញ្ជី ច្រើនមានកំរិតថ្លៃខ្ពស់ជាង ដីដែលមិនទាន់ចុះបញ្ជី បើសិនដីទាំងពីរមានលក្ខណៈផ្សេងៗទៀតដូចគ្នា ។

#### *ការផ្ទេរ*

ទ្រឹស្តីនៃការស្រាវជ្រាវទស្សន៍ទាយថា ទីផ្សារដីដែលមានទីតាំងនៅជិតតំបន់ពាណិជ្ជកម្ម និងនៅជិតតំបន់រដ្ឋបាល និង/ឬនៅតាម ដងផ្លូវសំខាន់ៗ នឹងមានសកម្មភាពខ្លាំងជាង គិតតាមភាពញឹកញាប់និងទំហំនៃការផ្ទេរដី ហើយបើធៀបនឹងទីផ្សារដីដែលមាន ទីតាំងនៅឆ្ងាយពីតំបន់ពាណិជ្ជកម្ម និងមជ្ឈមណ្ឌលរដ្ឋបាល និង/ឬតំបន់មានផ្លូវល្អ ។ ការទស្សន៍ទាយនេះ សន្មតជាមុនថា លក្ខខណ្ឌខាងម៉ាក្រូសេដ្ឋកិច្ច គឺមានស្ថិរភាពគួរសម ។[១៨]

#### *ការកត់សំគាល់លើការបែងចែកដី*

ការផ្ទេរដីបែបនេះវាមានប្រសិទ្ធភាពតិចឬច្រើនខាងផ្នែកសង្គមកិច្ច លើការបែងចែកសិទ្ធិកម្មសិទ្ធិដី គឺជាបញ្ហាមួយដ៏សំខាន់ នៅក្នុងបរិបទនៃប្រទេសកម្ពុជា ។ បទពិសោធន៍នាពេលថ្មីៗបង្ហាញថា ដោយថ្លៃដីកសិកម្មវាកើនឡើង បើធៀបនឹងផលិតភាព និងចំណូលនៅជនបទ និងតំបន់នៅក្បែរទីប្រជុំជន ដូច្នេះកសិករខ្លះ អាចលក់ផ្នែកខ្លះ ឬទាំងអស់នៃដីកសិកម្មរបស់ខ្លួន ដើម្បីទៅ

---

[១៨] ដូចដែលបានពិភាក្សាខាងលើ Sophal and Acharya (2002) បានធ្វើការសង្កេតថា ទំហំនៃការផ្ទេរដីអាចជាកញ្ចក់ឆ្លុះបញ្ចាំងពីគំរូនៃការ វិកលូតលាស់ផ្នែកម៉ាក្រូសេដ្ឋកិច្ច ។

ប្រកបរបរមិនមែនកសិកម្មវិញ ។ កសិករពេលខ្លះក៏ត្រូវលក់ដីដែរ ដើម្បីដោះស្រាយធុរៈបន្ទាន់ នៅក្នុងគ្រួសារ នៅពេលដែលពុំមានលទ្ធភាពទទួលបានឥណទានផ្សេងទៀត ។

### *៣.១.១.៥. រដ្ឋបាលដីធ្លី*

ទ្រឹស្តីនៃការស្រាវជ្រាវទស្សន៍ទាយថា ការកើនឡើងគិតជាភាគរយនៃការផ្ទេរដី (ឧ. ការលក់ ការផ្ទេរមរតក) ត្រូវបានសំរួលតាមរយៈប្រព័ន្ធចុះបញ្ជីដី ជាពិសេសនៅតំបន់ដែលមានសកម្មភាពទីផ្សារដី និងមានតំលៃដី កំពុងកើនឡើង ។ ប៉ុន្តែកំរិតដែលប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធផ្លូវការគឺអាចខុសគ្នា ដោយផ្អែកទៅលើសមត្ថភាព និងការសុខចិត្តចំណាយលើថ្លៃសេវា និងពន្ធ ។ ជាលទ្ធផល គ្រួសារដែលមានចំណូល និងមានធនធានច្រើន គេមានចំណូលចិត្តប្រើប្រាស់ការចុះបញ្ជីផ្លូវការ ច្រើនជាងអ្នកដែលមានធនធានតិចតួច និងមិនសូវមានចំណូល ។ ការទស្សន៍ទាយបានសន្មតជាមុនថា (១) តំលៃនៃការផ្ទេរជាប់ពាក់ព័ន្ធនឹងការចុះបញ្ជីផ្លូវការ នឹងចុះទាបជាងតំលៃសព្វថ្ងៃ (២) ប្រជាពលរដ្ឋមានការជឿទុកចិត្តកាន់តែច្រើនឡើងទៅលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ជាងពេលសព្វថ្ងៃ (៣) ប្រជាពលរដ្ឋមានចំណេះដឹងគ្រប់គ្រាន់អំពីនីតិវិធីសមស្រប និងមានសមត្ថភាពដើម្បីប្រើប្រាស់ប្រព័ន្ធនេះ និង (៤) ប្រជាពលរដ្ឋមានការជឿទុកចិត្តថា ចំណូលពន្ធនឹងត្រូវបានប្រើប្រាស់សមស្រប ។

### *៣.១.១.៦. វិវាទដីធ្លី/ជំលោះដីធ្លី*

ទ្រឹស្តីនៃការស្រាវជ្រាវបានទស្សន៍ទាយថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លី នឹងកាត់បន្ថយពីមួយឆ្នាំទៅមួយឆ្នាំនូវទំហំ និងភាពញឹកញាប់នៃវិវាទដីធ្លី តាមរយៈការបញ្ជាក់បំភ្លឺពីកម្មសិទ្ធិ ការកំណត់ព្រំប្រទល់ក្បាលដី និងនីតិវិធីនៃការផ្ទេរដី ។ ប៉ុន្តែបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា (So *et al.,* 2002) និងបទពិសោធន៍នៅប្រទេសថៃ (Onchan Aungsumalin, 2002) បានបង្ហាញថា សកម្មភាព និងដំណើរការនានា ដើម្បីធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីព្រំប្រទល់ អំពីសិទ្ធិកម្មសិទ្ធិ នឹងអាចបង្កើនក្នុងរយៈពេលដំបូងនូវចំនួនវិវាទ និងជំលោះដីធ្លី ។ នៅក្នុងរយៈពេលខ្លី និងមធ្យម គេរំពឹងថា ចំនួននៃជំលោះ ជាពិសេសពាក់ព័ន្ធនឹងព្រំប្រទល់ និងការផ្ទេរដីពីគ្រួសារមួយទៅគ្រួសារមួយទៀត នឹងកើនឡើង ។ ចំនួនវិវាទនឹងថយចុះទៅតាមដំណាក់កាល វាជាប់ពាក់ព័ន្ធផងដែរ ទៅនឹងសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងពង្រឹងការអនុវត្តន៍សិទ្ធកម្មសិទ្ធិយ៉ាងមានប្រសិទ្ធភាព ។

### ៣.១.២. ផលប៉ះពាល់សង្គម

ផលប៉ះពាល់សង្គមដែលបណ្តាលមកពីកម្មវិធីចុះបញ្ជីដីធ្លី ក៏អាចសង្កេតឃើញដែរទាំងនៅកំរិត សហគមន៍ និងនៅតាមគ្រួសារនីមួយៗ ។ នៅកំរិតសហគមន៍ ការចុះបញ្ជីដីធ្លីអាចធ្វើឱ្យប៉ះពាល់ទៅដល់គំរូនៃការបែងចែកដីធ្លី ក៏ដូចជាគំរូនៃការធ្វើចំណាកស្រុក ។ ប៉ុន្តែទិសនៃការផ្លាស់ប្តូរបែបនេះ អាចជាប់ទាក់ទិននឹងស្ថានភាពជាក់លាក់នីមួយៗ ។ នៅថ្នាក់បុគ្គលនីមួយៗ យើងរំពឹងថា នឹងឃើញមានការផ្លាស់ប្តូរ ក្នុងចំណូល និងចំណាយរបស់គ្រួសារនៅលើផ្នែកខ្លះដូចជា ខាងអប់រំ និងថែទាំសុខភាព ទោះបីការផ្លាស់ប្តូរនេះអាចផ្អែកទៅលើកត្តាប្រជាសាស្ត្រផងដែរ ដូចជាទំហំ និងសមាសភាពនៃគ្រួសារ និងយេនឌ័រនៃមេគ្រួសារក្តី ។ នៅក្នុងការគ្រប់គ្រង យើងរំពឹងថា នឹងបានឃើញនូវការផ្លាស់ប្តូរជាវិជ្ជមាននូវអាកប្បកិរិយា ចំពោះការងារផ្នែករដ្ឋបាល និងគ្រប់គ្រងដីធ្លីរបស់រដ្ឋាភិបាល ។

### *៣.១.២.១. ចំណូល / ចំណាយរបស់គ្រួសារ*

ទ្រឹស្តីនៃការស្រាវជ្រាវទស្សន៍ទាយថា ដីដែលមានផលិតភាពច្រើន នឹងនាំឱ្យមានកំនើនចំណូលពីការដាំដុះ ដែលបានពីកំនើនទិន្នផលនៃសកម្មភាពកសិកម្ម ឬសកម្មភាពផ្ទេរដី (ឧ. ជួល លក់) ។ចំណូលរបស់គ្រួសារពីសកម្មភាពដែលមិនមែនកសិកម្ម (ឧ. អាជីវកម្មខ្នាតតូច) អាចកើនឡើងដោយគ្រួសារខ្លះអាចទទួលបានឥណទានសំរាប់ធ្វើការវិនិយោគ ។

ការកើនឡើងនូវកំរិតចំណូល អាចនាំឱ្យមានកំនើនការចំណាយរបស់គ្រួសារលើសកម្មភាពខ្លះ ដូចជា ការថែរក្សាសុខភាព ការអប់រំ ការកែលំអលំនៅដ្ឋាន និងសកម្មភាពផ្នែកសង្គម (ឧ. ពិធីបុណ្យផ្សេងៗ) ជាដើម ។ កំនើនប្រាក់ចំណូលគ្រួសារ ក៏អាចមានផលប៉ះពាល់វិជ្ជមានទៅលើការចំណាយផ្នែកសង្គមកិច្ចដែរ ។ ហេតុការណ៍សំខាន់ៗខ្លះ (ឧ. ធុរៈបន្ទាន់ វិបត្តិក្នុងគ្រួសារ) ក៏អាចប៉ះពាល់ដល់គ្រួសារ និងធ្វើឱ្យប្រែប្រួលដល់ " ***ផលប៉ះពាល់ពីការចុះបញ្ជីដី*** " ។

### *៣.១.២.២. យេនឌ័រ*

ប័ណ្ណកម្មសិទ្ធិដីធ្លីក៏មានផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់ទៅលើស្ត្រី ជាពិសេសស្ត្រីជាមេគ្រួសារ ពីព្រោះវាជួយដល់ប្រជាពលរដ្ឋងាយរងគ្រោះ ដើម្បីការពារដីធ្លីរបស់ពួកគេពីការបាត់បង់ដែលបណ្តាលមកពីការរំលោភយក ឬទំរង់នៃអស្សាមិករផ្សេងទៀត (ការដកហូត) ។

ប្រសិនបើធ្វើបានដូច្នេះ យើងនឹងអាចពិនិត្យឃើញ ការថយចុះជាបន្តបន្ទាប់នូវអត្រាកំណើនភាពគ្មានដីនៅក្នុងចំនោមស្ត្រីជាមេគ្រួសារ ។ កម្មសិទ្ធិដីធ្លីក៏មានសារៈសំខាន់ចំពោះស្ត្រីផងដែរ ក្នុងការជួយឱ្យពួកគេអាចរកបានកំចីសំរាប់ធ្វើវិនិយោគលើផលិតកម្មកសិកម្ម ឬក៏សកម្មភាពរកចំនូលផ្សេងទៀត (ឧ. អាជីវកម្មខ្នាតតូច) ។ ម្យ៉ាងទៀត ដោយសារកំនើនចំណូលគ្រួសារតែងនាំឱ្យមានចំនើនចំណាយលើការអប់រំ ដូច្នេះយើងអាចរំពឹងថា នឹងឃើញការចុះឈ្មោះចូលរៀនក្នុងចំណោមសិស្សជានារីកើនឡើង ។

ស្ត្រីខ្លះមានបំណងវិនិយោគទៅលើសកម្មភាពផ្សេងទៀតដើម្បីបង្កើតចំណូលបន្ថែមពីលើការធ្វើកសិកម្ម ឬប្តូររបរចេញពីកសិកម្មតែម្តង ។ នៅក្នុងករណីនេះ កម្មសិទ្ធដីធ្លីអាចធ្វើឱ្យស្ត្រីជាមេគ្រួសារ មានលទ្ធភាពទទួលបានឥណទានកាន់តែធំឡើង ដែលមានលក្ខខណ្ឌកាន់តែអំណោយផលឡើង ប៉ុន្តែវាមិនមែនសុទ្ធតែនាំឱ្យមានកំនើនការវិនិយោគក្នុងវិស័យកសិកម្មនោះទេ ។ ក្នុងពេលជាមួយគ្នា កម្មសិទ្ធិដីធ្លី អាចឱ្យស្ត្រីផ្សេងទៀតលក់ដីរបស់គេបានងាយស្រួល និងបានថ្លៃល្អ នៅពេលគេផ្លាស់ប្តូរទៅប្រកបរបរមិនមែនកសិកម្មវិញ ។ ការធ្វើបែបនេះអាចបង្ហាញឱ្យឃើញពីការកើនឡើងនូវភាពគ្មានដីក្នុងចំណោមស្ត្រី ប៉ុន្តែវាមិនមែនសុទ្ធតែបង្ហាញនូវលទ្ធផលអវិជ្ជមាននោះទេ ប្រសិនបើអាចរកបានការងារផ្សេងទៀត ដែលអាចចិញ្ចឹមជីវិតបាន ។

### *៣.១.២.៣. ចំណាកស្រុក*

វាមិនទំនងថា កម្មសិទ្ធិដីធ្លីតែឯងនឹងអាចប៉ះពាល់ទៅលើគំរូនៃការធ្វើចំណាកស្រុក ។ ផលប៉ះពាល់ទៅលើគំរូនៃការធ្វើអន្តោប្រវេសន៍ វាផ្អែកភាគច្រើនទៅលើបែបបទដែលប័ណ្ណកម្មដីធ្លីចូលពាក់ព័ន្ធជាមួយកត្តាផ្សេងទៀត ដូចជា សមាសភាពនៃគ្រួសារ (ឧ.កំលាំងពលកម្ម ដែលអាចរកចំណូល) និងការប្រើប្រាស់ដី (ឧ.ការដាំដំណាំ រឺដើមឈើហូបផ្លែ) ។ការកត់សំគាល់នេះត្រូវបានគាំទ្រដោយភស្តុតាងពីប្រទេសថៃដែលបង្ហាញថា ពីការថយចុះ ឬកើនឡើងនៃការធ្វើចំណាកស្រុក វាប្រែប្រួលដោយផ្អែកទៅតាមកាលៈទេសៈ ។

សភាពការណ៍នៅក្នុងប្រទេសកម្ពុជាមានភាពស្មុគស្មាញដោយសារទំហំ កំរិត និងចរិតនៃភាពក្រីក្រនៅតំបន់ជនបទ ។ ឧទាហរណ៍ នៅក្នុងសភាពការណ៍ដែលមានកំនើនវិនិយោគលើដីធ្លី និង/ឬចំណូលដែលជាលទ្ធផលនៃការចុះបញ្ជីដីធ្លី ឬក្នុងករណីដែលការរំលោភយកដីត្រូវបានកាត់បន្ថយ គេអាចកត់សំគាល់ឃើញថា អត្រានៃការធ្វើចំណាកស្រុកមានការថយចុះ ។ នៅពេលជាមួយគ្នានេះដែរ ប្រាក់ដែលបានផ្ញើពីកម្មករធ្វើការនៅតាមរោងចក្រកាត់ដេរ និងនៅកន្លែងផ្សេងទៀត អាចជាប្រភពទុនមួយដែលគ្រួសារអាចប្រើប្រាស់សំរាប់វិនិយោគក្នុងវិស័យកសិកម្ម នៅពេលដែលដីរបស់គេមានសុវត្ថិភាព ដោយសារមានប័ណ្ណកម្មសិទ្ធិ ។ នៅក្នុងសភាពការណ៍ដែលប័ណ្ណកម្មសិទ្ធិវាជួយសំរួលដល់ការផ្ទេរ ដូចជា ការលក់ដីដោយគ្រោះអាសន្ន គេអាចពិនិត្យឃើញនូវការកើនឡើងនៃការធ្វើចំណាកស្រុក ។ ផលប៉ះពាល់ទាំងពីរអាចប្រែប្រួលខុសលំនាំដើម ដោយគ្រោះអាសន្ននានា ឬវិបត្តិនានានៅក្នុងគ្រួសារ ។

### ៣.១.២.៤. ការគ្រប់គ្រង

ការយល់ឃើញរបស់ប្រជាពលរដ្ឋ និងការវាយតំលៃទៅលើការអនុវត្តន៍របស់វិស័យសាធារណៈ អាចមានការខុសគ្នាទៅតាមលក្ខណៈ និងពេលវេលានៃការដោះស្រាយទំនាស់ និងការចេញប័ណ្ណកម្មសិទ្ធដីធ្លី ។ នៅក្នុងសភាពការណ៍នេះ នៅកន្លែងណាដែលទំនាស់ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយការចេញប័ណ្ណកម្មសិទ្ធិអាចធ្វើបានលឿន ការជឿជាក់ និងសេចក្តីទុកចិត្ត ទៅលើរដ្ឋាភិបាលអាចត្រូវបានពង្រឹងឡើង ។ ទិដ្ឋភាពជាគន្លឹះនៃការជឿជាក់ និងសេចក្តីទុកចិត្តទៅលើការគ្រប់គ្រងគឺជាប់ពាក់ព័ន្ធនឹងការយល់ដឹង និងចំណាប់អារម្មណ៍របស់ពួកគេ ពីភាពមិនលំអៀង ។ សមាសភាគគន្លឹះនៃភាពមិនលំអៀងនៅក្នុងរឿងនេះ គឺពាក់ព័ន្ធនឹងតំលៃ និងគុណភាពនៃការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋទូទៅ ។ កត្តាសំខាន់ផ្សេងទៀតពាក់ព័ន្ធនឹងការជឿជាក់ និងសេចក្តីទុកចិត្ត គឺតំលាភាពដែលការចុះបញ្ជីដីបានអនុវត្តតាមរយៈគំរោង ។ រឿងនេះដាក់ការទទួលខុសត្រូវច្រើនណាស់ទៅលើមន្ត្រីនៅក្នុងគំរោង LMAP ដែលកំពុងអនុវត្តគំរោងនៅថ្នាក់ភូមិ ។

# ជំពូក ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

របៀបរៀបចំជាមូលដ្ឋាននៃគំរោងអង្កេតមូលដ្ឋាន បានយកមកអនុវត្តយ៉ាងច្រើននូវក្របខ័ណ្ឌនៃការស្រាវជ្រាវដែលគេបានប្រើនៅពេលសិក្សាពីការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសថៃ [១៩] ដោយមានការកែច្នៃគំរូនេះ ដើម្បីអាចឱ្យធ្វើការសាកល្បងនូវសកម្មភាពជាក់លាក់មួយចំនួនដែលទាក់ទងទៅនឹងកម្ពុជា ។ គំរោង BSP បានប្រើប្រាស់របៀបរៀបចំសឹងតែការដកពិសោធន៍ (quasi-experimental design) ដើម្បីធ្វើការវាយតំលៃពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គម ពីការចុះបញ្ជីដីទៅលើគ្រួសារនីមួយៗ ដែលនេះជាផ្នែកនៃការវិភាគបឋម ។ ផ្នែកទី២នៃការវិភាគគឺ សហគមន៍ ហើយទិន្នន័យបន្ថែមទៀត ត្រូវបានប្រមូល ដើម្បីធ្វើការវាស់វែងផលប៉ះពាល់នៅថ្នាក់សហគមន៍ ។ ការស្រាវជ្រាវនេះត្រូវបានរៀបចំ ដើម្បីផ្តល់ជាមធ្យោបាយសំរាប់ធ្វើការប្រៀបធៀបដោយវិភាគពីការផ្លាស់ប្តូរនៅក្នុងក្រុមពិសោធន៍ និងក្រុមត្រួតពិនិត្យនៅ ២ ចំនុចពេលផ្សេងគ្នា (គឺមុនពេលចាប់ផ្តើមគំរោង និងក្រោយពេលបញ្ចប់គំរោង) មានដូចខាងក្រោម:

OCt0 = តំលៃនៃសូចនាករ/ការវាស់ស្ទង់នៃក្រុមត្រួតពិនិត្យនៅមុនពេលចុះបញ្ជីកម្មសិទ្ធិដីធ្លី

OCt3 = តំលៃនៃសូចនាករ/ការវាស់ស្ទង់នៃក្រុមត្រួតពិនិត្យនៅក្រោយពេលចុះបញ្ជីកម្មសិទ្ធិដីធ្លី

OEt0 = តំលៃនៃសូចនាករ/ការវាស់ស្ទង់នៃក្រុមធ្វើការពិសោធន៍នៅមុនពេលចុះបញ្ជីកម្មសិទ្ធិដីធ្លី

OEt3 = តំលៃនៃសូចនាករ/ការវាស់ស្ទង់នៃក្រុមធ្វើការពិសោធន៍ក្រោយពេលចុះបញ្ជីកម្មសិទ្ធិដីធ្លី

ដូចក្នុងការសិក្សានៅប្រទេសថៃដែរ វិធីសាស្ត្រជាមូលដ្ឋានដើម្បីវិភាគ គឺធ្វើការប្រៀបធៀបពីភាគរយនៃការផ្លាស់ប្តូររវាងក្រុមពិសោធន៍ និងក្រុមត្រួតពិនិត្យដូចខាងក្រោម:

$$\frac{O^{E}{}_{t3} - O^{E}{}_{t0}}{O^{E}{}_{t0}} \times 100 \quad \text{ជាមួយ} \quad \frac{O^{C}{}_{t3} - O^{C}{}_{t0}}{O^{C}{}_{t0}} \times 100$$

នៅក្នុងករណីខ្លះយើងក៏មានបំណងធ្វើការវិភាគទិន្នន័យទៅតាម:

$$\frac{OEt3}{O^{C}{}_{t3}} \quad \text{មានការខុសគ្នាគួរឱ្យចាប់អារម្មណ៍ទេពី} \quad \frac{OEt0}{O^{C}{}_{t0}}$$

ការសិក្សានៅប្រទេសថៃបានលើកជាសម្មតិកម្មថា "ការផ្លាស់ប្តូរនៅក្នុងក្រុមធ្វើការពិសោធន៍ ដែលខុសអំពីក្រុមធ្វើការត្រួតពិនិត្យ គឺត្រូវចាត់ទុកជាផលប៉ះពាល់នៃគំរោង" ។ ប៉ុន្តែវាហាក់ដូចជា មិនសូវទំនងសោះដែលប័ណ្ណកម្មសិទ្ធិដីធ្លីតែឯងនឹងមានផលប៉ះពាល់ខ្លាំងនៅក្នុងរឿងនានាដែលបានលើកឡើងនៅខាងលើនោះទេ ដូច្នេះគេចាំបាច់ត្រូវធ្វើការពិចារណាថា តើប័ណ្ណកម្មសិទ្ធិវាជាប់ទាក់ទង ឬបំពេញបន្ថែមយ៉ាងណាជាមួយកត្តាផ្សេងទៀត ដើម្បីបង្កើតឱ្យមានផលប៉ះពាល់គួរឱ្យកត់សំគាល់ ។

---

[១៩] Ibid

ឧទាហរណ៍ ដើម្បីឱ្យកម្មសិទ្ធិដីធ្លីអាចជួយបង្កើនសមត្ថភាពប្រជាពលរដ្ឋដើម្បីទទួលបានឥណទានផ្លូវការ ស្ថាប័នបែបនេះត្រូវតែមាន និងអាចទាក់ទងបាន ។ ឥទ្ធិពលនៃផលប៉ះពាល់ពីប័ណ្ណកម្មសិទ្ធិដីធ្លីទៅលើ ការវិនិយោគលើវិស័យកសិកម្ម ក៏កើនឡើងផងដែរ ទៅតាមលទ្ធភាពទទួលបានកាន់តែប្រសើរនូវ ព័ត៌មានខាងបច្ចេកទេស និងទីផ្សារដី ។ នៅក្នុងករណីនេះ ការទទួលបានសេវាកម្មផ្សព្វផ្សាយបច្ចេកទេសខាងការដាំដុះ ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រី គឺជាកត្តាមួយដ៏សំខាន់ ។ ដោយផ្អែកចំណុចនេះ ប័ណ្ណកម្មសិទ្ធិដីធ្លីអាចដើរតួនាទីជាកាតាលីករសំរាប់ការផ្លាស់ប្តូរ នៅពេលដែលវាបានគួបផ្សំមួយនឹងកត្តាផ្សេងទៀត ហើយកាលទេសៈអំណោយផលល្អ ។

គំរូជាមូលដ្ឋាននៅក្នុងប្រទេសថៃ ក៏ត្រូវបានច្នៃយកមកប្រើប្រាស់នៅក្នុងកាលៈទេសៈសេដ្ឋកិច្ច-សង្គមកិច្ចដ៏ជាក់លាក់នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ព្រមទាំងគោលដៅអភិវឌ្ឍន៍នានាដែលជាប់ពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងផ្នែកយេនឌ័រ ។ យោងតាមកំនើនគំលាតនៃលទ្ធភាពអាចប្រើប្រាស់ និងត្រួតត្រាទៅលើធនធានធម្មជាតិ ការវិភាគអំពីផលប៉ះពាល់ពីការចុះបញ្ជីដី ត្រូវតែមានជាប់ទាក់ទងច្រើនទៅនឹង ការបែងចែកផលចំណេញ ។ ដើម្បីបំរើគោលបំណងនៃការធ្វើវិភាគ ទិន្នន័យគ្រួសារត្រូវតែមានរាយលំអិតទៅតាមទំហំដីដែលកំពុងកាន់កាប់ និងយេនឌ័រនៃមេគ្រួសារ ។

## ៤.១. ការជ្រើសរើសតំបន់អង្កេត និងតំបន់បាន់គំរូ

ផ្នែកនេះមានរៀបរាប់លំអិតពីវិធីសាស្ត្រសំរាប់ការជ្រើសរើសទីតាំង និងគ្រួសារធ្វើជាគំរូ ក៏ដូចជារៀបរាប់សង្ខេបពី យុទ្ធសាស្ត្រក្នុងការអនុវត្តន៍ ។

### ៤.១.១. ការជ្រើសរើសទីតាំង

ខេត្ត៤ ត្រូវបានជ្រើសរើសក្នុងចំនោមខេត្តដែលកំពុងអនុវត្តគំរោង LMAP ដោយធ្វើការពិភាក្សាជាមួយអ្នកពាក់ព័ន្ធនឹងគំរោង ។ ការជ្រើសរើសចុងក្រោយបានផ្អែកទៅលើកត្តាជាច្រើន ក្នុងនោះមានទីតាំងជាយុទ្ធសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ (ឧ. ផ្លូវ) ប្រព័ន្ធធ្វើកសិកម្ម និងសក្តានុពលនៃការអភិវឌ្ឍន៍ ដែលអាចមានផលប៉ះពាល់ទៅលើទីផ្សារដី និងលំនាំនៃការប្រើប្រាស់ដី ។

#### *៤.១.១.១. ការជ្រើសរើសខេត្ត*

ក្រុងព្រះសីហនុត្រូវបានជ្រើសរើស ពីព្រោះមានទីតាំងជាយុទ្ធសាស្ត្រ តាមបណ្តោយផ្លូវជាតិលេខ ៤ ដែលជាច្រកនៃការអភិវឌ្ឍន៍ និងជាកន្លែងដែលការអភិវឌ្ឍន៍ផ្នែកទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ (ឧ. គំរោង អភិវឌ្ឍកំពង់ផែ) នឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើទីផ្សារដីនៅក្នុងតំបន់នោះ ។ ខេត្តតាកែវត្រូវបានជ្រើសរើស ពីព្រោះមានប្រពៃណីធ្វើស្រែសឹងតែ ដូចគ្នាជាទូទៅ និងមានទីតាំងជិតទៅនឹងទីក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ ២ ដែលអាចជាប្រភពនៃតំរូវការដែលជួយជំរុញឱ្យមានប្រព័ន្ធផលិតកម្មកសិកម្មកាន់តែចំរុះ និងមានផលិតភាពខ្ពស់នាពេលអនាគត ប្រសិនបើកសិករទទួលបានការគាំទ្រទាន់ពេលវេលា និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ខេត្តកំពង់ចាមត្រូវបានជ្រើសរើស ព្រោះមានទីតាំងជាយុទ្ធសាស្ត្រនៅតាមបណ្តោយផ្លូវជាតិលេខ ៦ និងមានស្ពានមិត្តភាពកម្ពុជា-ជប៉ុន ឆ្លងកាត់ទន្លេមេគង្គ ដែលជាការតភ្ជាប់រវាងភាគឥសាន្តនៃប្រទេសកម្ពុជាទៅនឹងផ្ទៃប្រទេសទាំងមូល ក៏ដូចជាការនាំចេញផលិតផលកម្ពុជាជាច្រើនទៅទីផ្សារវៀតណាម ។ ខេត្តកំពង់ធំត្រូវបានជ្រើសរើស ព្រោះនៅមិនសូវឆ្ងាយពីទីក្រុងភ្នំពេញ និងមានទីតាំងជាយុទ្ធសាស្ត្រ នៅតាមបណ្តោយផ្លូវជាតិលេខ៦ ដែលភ្ជាប់ទីក្រុង

សៀមរាប និងទីក្រុងភ្នំពេញ ។ ទាំងសកម្មភាពទេសចរណ៍ និងចរាចរផ្នែកពាណិជ្ជកម្មនៅតាមផ្លូវនេះ ប្រហែលនឹងកើនឡើង នៅពេលផ្លូវជាតិលេខ៦ត្រូវបានកែលំអនាពេលអនាគត ។

ខេត្តកំពង់ឆ្នាំងជាខេត្តទី៥ដែលត្រូវបានជ្រើសរើសធ្វើជាខេត្តសំរាប់ត្រួតពិនិត្យ ដើម្បីធ្វើការប្រៀបធៀប និងធ្វើឱ្យឃើញភាពខុសគ្នាពីខេត្តក្នុងគំរោង LMAP ។ ខេត្តកំពង់ឆ្នាំងត្រូវបានជ្រើសរើស ព្រោះមានទីតាំងជាយុទ្ធសាស្ត្រនៅតាមបណ្តោយផ្លូវជាតិលេខ៥ និងនៅជិតទីក្រុងភ្នំពេញ ។ម្យ៉ាងទៀត មានការប្រឹងប្រែងជ្រើសយកភូមិ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងភូមិត្រូវធ្វើអង្កេតឯទៀត។ ។

## *៤.១.១.២. ការជ្រើសរើសឃុំ*

ការជ្រើសរើសទីតាំងឃុំត្រូវបានធ្វើនៅតាមកន្លែងដែលគំរោង LMAP កំពុងដំណើរការ រឺមានផែនការនឹងដំណើរការ ។ នៅក្នុងទីតាំងធ្វើការងារ ឧទាហរណ៍ LMAP គំរោងនៅខេត្តកំពង់ធំ យើងធ្វើការតែនៅក្នុងឃុំ២ប៉ុណ្ណោះ ដូច្នេះការជ្រើសរើសឃុំត្រូវបានកំណត់សំខាន់ដោយកត្តានេះ ។ នៅខេត្តកំពង់ចាម LMAP កំពុងធ្វើការក្នុងឃុំមួយ (ឃុំស្រម៉ៃ) និងមានផែនការបន្ថែមក្រុមមួយទៀតឱ្យទៅធ្វើការនៅក្នុងឃុំទី២ (ឃុំសំបូរ) នៅពេលអនាគត ។ ការជ្រើសរើសឃុំក៏ទទួលឥទ្ធិពលផងដែរអំពីកម្មវិធីការងាររបស់ LMAP ។ ឧទាហរណ៍ នៅខេត្តតាកែវ ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានចេញនៅក្នុងភូមិជាច្រើននៃឃុំគំរោង ដោយនៅសល់តែភូមិដាច់ស្រយាលមួយចំនួនប៉ុណ្ណោះដែលនឹងត្រូវបញ្ចប់ ។ ដោយ BSP ចង់ជៀសវាងតំបន់ដែលទទួលបានប័ណ្ណកម្មសិទ្ធិ មួយរយៈពេលមកហើយ BSP បានជ្រើសរើសឃុំវរៀង ដែលនឹងមានកម្មវិធីធ្វើបន្តបន្ទាប់ពីឃុំជំរះពេន ។ សភាពការណ៍ដូចគ្នានេះដែរបានកើតមាននៅក្រុងព្រះសីហនុ ដែលការងាររបស់គំរោង LMAP ត្រូវបានបញ្ចប់នៅក្នុងកន្លែងខ្លះនៃតំបន់ដែលមានសក្តានុពលខ្លាំងនៅតាមដងផ្លូវជាតិលេខ ៤ រួមបញ្ចូលទាំងកន្លែងសាកល្បងនៅខ័ណ្ឌព្រៃនប់ផងដែរ ។ ក្នុងគោលបំណងបញ្ចូលភូមិនៅតាមផ្លូវជាតិលេខ ៤ ក្នុងគំរូនោះដែរ BSP បានជ្រើសរើសឃុំមួយដែល LMAP បានធ្វើការវាស់វែងចប់ (ខ័ណ្ឌព្រៃនប់) និងឃុំ២ទៀតដែលគំរោង LMAP កំពុងធ្វើការ (ឃុំជើងគោ និងឃុំទឹកល្អក់) ។

នៅខេត្តកំពង់ឆ្នាំង ឃុំសំរាប់ធ្វើការត្រួតពិនិត្យ២ ត្រូវបានជ្រើសរើសដោយផ្អែកទៅលើទីតាំង ។ ឃុំរលាប្អៀរ ត្រូវបានជ្រើសរើសដោយសារមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ៥ នៅជិតទីប្រជុំជនខេត្ត គឺប្រហាក់ប្រហែលគ្នានឹងឃុំស្រយូវនៅក្នុងខេត្តកំពង់ធំ រឺក៏ខ័ណ្ឌព្រៃនប់នៃក្រុងព្រះសីហនុ ។ ឃុំច្រេសត្រូវបានជ្រើសរើសដោយសារវាមានទីតាំង និងលក្ខណៈផ្សេងទៀតប្រហាក់ប្រហែលនឹងសង្កាត់ទឹកល្អក់នៅក្រុងព្រះសីហនុ និងឃុំស្រែញ៉ែ នៅខេត្តកំពង់ចាម ហើយនិងឃុំ២ទៀត គឺឃុំត្រពាំងសាប និងឃុំវរៀង នៅខេត្តកំពង់ធំ ។

## *៤.១.១.៣. ការជ្រើសរើសភូមិ*

លើកលែងតែនៅក្រុងព្រះសីហនុ BSP ជ្រើសរើសភូមិចំនួន៤ នៅក្នុងឃុំនីមួយ។ ។ ការជ្រើសរើសនេះគឺផ្អែកលើការពិភាក្សាគ្នាជាមួយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏ដូចជាការសង្កេតឃើញដោយផ្ទាល់ភ្នែក ។ ការសំរេចចុងក្រោយត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាជាច្រើនជាមួយមេភូមិ និង/ឬសមាជិកនានាក្នុងសហគមន៍ ។ គោលបំណងនៃ BSP គឺជ្រើសរើសឱ្យ

បានលក្ខណៈចំរុះគ្នាច្រើននៅក្នុងភូមិគំរូតាង ដោយផ្តល់ឱ្យតំបន់ដែលមានសក្តានុពលច្រើននូវអាទិភាព ខ្ពស់ជាងតំបន់ដែលមានសក្តានុពលតិចជាង ។

លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសភូមិរួមមាន ការអភិវឌ្ឍន៍និងសកម្មភាពទីផ្សារដីធ្លី ការប្រើប្រាស់ដីនិងប្រព័ន្ធធ្វើកសិកម្ម (ឧ.ការធ្វើស្រែនៅរដូវវស្សា/ប្រាំង ការធ្វើចំការ និងការដាំដំណាំដើមឈើ) ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ ធារាសាស្ត្រ) ដង់ស៊ីតេប្រជាជន ភាពនៅជិតទីផ្សារនិងទីតាំងរដ្ឋបាល និងសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត (ឧ. មុខរបរ) ។ ម្យ៉ាងទៀតមានកិច្ចប្រឹងប្រែងជៀសវាងការធ្វើអង្កេតនៅភូមិជាប់គ្នា ដើម្បីឱ្យមានភាពចំរុះខាងភូមិសាស្ត្រនៅក្នុងឃុំនោះ ។ ការជ្រើសរើសរបស់ BSP ក៏ពាក់ព័ន្ធផងដែរនឹងកម្មវិធីការងារនៅក្នុងតំបន់នៃគំរោង LMAP នៅកន្លែងណាដែលមានការងារជាន់គ្នាជាមួយការងារ BSP ។

## ៤.២. ការជ្រើសរើសគំរូនៃគ្រួសារ

ជារឿយៗ BSP បានជ្រើសរើស ៣០គ្រួសារ ដែលមានដីកសិកម្មក្នុងភូមិនៅជនបទមួយភូមិៗ ប៉ុន្តែចំនួននេះពេលខ្លះក៏ប្រែប្រួលដែរទៅតាមទំហំនៃភូមិ ។ ឧទាហរណ៍ មាន ៤០គ្រួសារ ត្រូវបានជ្រើស នៅភូមិដែលមានគ្រួសារច្រើន (ឧ. ភូមិសំបូរមាន ៨០០ គ្រួសារ) ហើយភូមិខ្លះយកតែ ២០គ្រួសារ ព្រោះជាភូមិដែលមានគ្រួសារតិច (ភូមិសំរោងមានតែ ៥០គ្រួសារ) ។

វិធីសាស្ត្រ ៤ ខុសៗគ្នាត្រូវបានប្រើប្រាស់សំរាប់ជ្រើសរើសគ្រួសារតាមវិធីចៃដន្យ ដោយផ្អែកតាមបរិមាណ និងគុណភាពនៃព័តិមានដែលអាចទទួលបាននៅថ្នាក់ភូមិ ។ នៅភូមិភាគច្រើនគ្រួសារត្រូវបានជ្រើសរើសដោយផ្អែកទៅលើផ្ទៃដីកាន់កាប់ ។ នៅភូមិចំនួន ៨ ដែលក្រុមការងារ LMAP បានធ្វើការចប់សព្វគ្រប់ហើយ គ្រួសារត្រូវបានជ្រើសរើសដោយផ្អែកទៅលើចំនួនក្បាលដីកសិកម្មដែលគេមាន ។ នៅក្នុងភូមិមួយដែលគ្មានព័តិមានអ្វីសោះពីការកាន់កាប់ដី ឬចំនួនក្បាលដី គ្រួសារត្រូវបានជ្រើសរើសដោយចៃដន្យតាមវិធីរាប់ហើយស្រង់ចេញបញ្ជីរាយឈ្មោះអ្នកភូមិនូវឈ្មោះណាដែលរាប់ឃើញថាជាគ្រួសារទី $n^{th}$ ។ នៅក្នុងភូមិចំនួន ៩ គឺគ្មានព័តិមាននៃការកាន់កាប់ដី ក៏ដូចជាចំនួនក្បាលដី និងគ្មានបញ្ជីឈ្មោះអ្នកភូមិទេ ដូច្នេះហើយអ្នកចុះអង្កេតបានដើររាប់យកផ្ទះតាមរបៀបគ្រួសារទី $n^{th}$ ដូចគ្នា ។

### ៤.២.១. គ្រួសារគ្មានដីធ្លី

BSP បានផ្តោតជាបឋមទៅលើគ្រួសារដែលមានទាំងដីកសិកម្ម និងដីលំនៅដ្ឋាន ។ ប៉ុន្តែដោយហេតុថា ភាពគ្មានដីកំពុងបង្កើនការព្រួយបារម្ភក្នុងចំណោមអ្នកធ្វើផែនការរបស់រដ្ឋាភិបាល ក៏ដូចជាស្ថាប័នអភិវឌ្ឍន៍នានានៅក្នុងប្រទេសកម្ពុជា BSP ក៏បានធ្វើការសំភាសន៍ផងដែរ ជាមួយគ្រួសារគ្មានដីកសិកម្មឱ្យបានច្រើនតាមអាចធ្វើបានផ្អែកតាមក៏រិតពេលវេលាដែលអាចលៃលក បាននៅក្នុងកម្មវិធីការងារ ។ តាមនេះមានសរុប ៧៦ គ្រួសារគ្មានដីកសិកម្មត្រូវបានសំភាសន៍ ។[២០] ថ្វីបើអនុក្រុមនៃគ្រួសារនេះ គឺមិនអាចតំណាងឱ្យគ្រួសារគ្មានដីជាទូទៅក្តី ប៉ុន្តែវាអាចប្រើប្រាស់ជាមធ្យោបាយសំរាប់ត្រួតពិនិត្យផ្ទៃក្នុងមួយបែប ដើម្បីធ្វើការប្រៀបធៀប ។

[២០] នៅក្នុងភូមិខ្លះ គ្រួសារដែលពីដើមឡើយបានធ្វើអត្តសញ្ញាណថាគ្មានដី បានត្រលប់ទៅជាមានក្បាលដីកសិកម្ម ១ ឬ ២ក្បាលវិញ ។

### ៤.២.៣. ស្ត្រីមេម៉ាយជាមេគ្រួសារ

ដោយហេតុថា ស្ត្រីមេម៉ាយជាមេគ្រួសារ ស្ថិតនៅក្នុងក្រុម អ្នកងាយរងគ្រោះជាងគេនៅក្នុងប្រទេសកម្ពុជា ដូច្នេះយើងបានប្រឹងប្រែងជាពិសេសដើម្បីឱ្យមានអ្នកតំណាងគ្រប់គ្រាន់នៅក្នុងគំរូនៃអង្កេតនៅជនបទ ។ ដោយផ្អែកលើរបាយការណ៍ចំនួនស្ត្រីមេម៉ាយជាមេគ្រួសារនៅក្នុងភូមិនីមួយៗ យើងបានកំនត់នូវសមាមាត្រដែលត្រូវជ្រើសរើសមកធ្វើសំភាសន៍ ។ តាមនេះមានសរុប ៣២៤ ស្ត្រីមេម៉ាយជាមេគ្រួសារ ដែលត្រូវបានធ្វើសំភាសន៍នៅក្នុងអង្កេតគ្រួសារនៅជនបទនេះ ដែលតំណាងឱ្យប្រហែល ២៦.៣% នៃប៉ាន់គំរូសរុប ។ ក្នុងចំណោមស្ត្រី ៣២៤នាក់ មានស្ត្រី ៣៨នាក់ដែលគ្មានដីកសិកម្ម ។

## ៤.៣. ការអនុវត្តន៍

អ្នកអង្កេត ២៤នាក់ ក្នុងនេះមានស្ត្រី ១០នាក់ និងបុរស ១៤នាក់ បានចុះធ្វើសំភាសន៍ នៅថ្នាក់ភូមិ នៅចន្លោះខែ មករា-កុម្ភៈ ឆ្នាំ២០០៤ ។ BSP បានប្រើប្រាស់ឧបករណ៍អង្កេត ២ ខុសគ្នា គឺកំរងសំនួរសំរាប់គ្រួសារនៅជនបទ និងកំរងសំណួរសំរាប់អង្កេតលើមេភូមិ ។ កំរងសំណួរសំរាប់គ្រួសារ ត្រូវបានធ្វើការសាកល្បងជាមុននៅស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ។[២១] ឧបករណ៍ទី៣ ដែលបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធជាមួយមេភូមិ/ក្រុមប្រឹក្សាឃុំសង្កាត់ គឺការពិភាក្សាគ្នាជាក្រុម ។ (សូមមើលឧបសម្ព័ន្ធ ក) ។

ការធ្វើសំភាសន៍នីមួយៗត្រូវចំនាយពេលជាមធ្យម ១,៧៥ម៉ោង យោងទៅតាមលទ្ធភាពរបស់គ្រួសារក្នុងការរកនឹកឃើញឡើងវិញពីពេលវេលានិងតួលេខផ្សេងៗ និងទៅតាមភាពស្មុគស្មាញនៃការកាន់កាប់ដីរបស់ពួកគេ និងកត្តាផ្សេងទៀត ។ អ្នកចុះអង្កេតដល់កន្លែង បានដាក់ពិន្ទុឱ្យសំភាសន៍នីមួយៗដោយផ្អែកទៅលើការយល់ឃើញរបស់ខ្លួនពីគុណភាពភាពព័ត៌មាន និងដំណើរការធ្វើសំភាសន៍ (តារាង ៤.៣ក) ។ អ្នកធ្វើសំភាសន៍ភាគច្រើន បានដាក់ពិន្ទុថា "ល្អណាស់" បាន ៤.៤%, "ល្អ" ៥៦.៣%, "មធ្យម" ៣៥.៤% និង "ខ្សោយ" ៤.៧% ។

**តារាង ៤.៣ក. ការវាយតំលៃគុណភាពនៃការធ្វើសំភាសន៍**

| មេគ្រួសារ | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | សរុប * |
|---|---|---|---|---|---|
| | | | | | |
| បុរស | 41 | 535 | 302 | 33 | 911 |
| ស្ត្រី | 13 | 158 | 123 | 25 | 319 |
| សរុប | 54 | 693 | 425 | 58 | 1,230 |

* N = 2 missing

[២១] BSP សូមថ្លែងអំណរគុណមន្ត្រីនៃអង្គការ World Vision នៅស្រុកកំពង់ត្រឡាច ដោយបានជួយធ្វើការសាកល្បង ក៏ដូចជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ និងប្រជាពលរដ្ឋនៅភូមិត្រពាំងព្រាល ភូមិស្វាយបាគូ និងភូមិស្វាយក្រោម ។

# ជំពូក ៥. អង្កេតប្រជាពលរដ្ឋនៅជនបទៈ
# ការកត់សំគាល់បឋមនិងការពិភាក្សា

ផ្នែកនេះ នឹងធ្វើការពិភាក្សាពីការកត់សំគាល់បឋមនៃគ្រួសារនៅជនបទ និងទិន្នន័យនៃ អង្កេតនៅភូមិក្នុង ៤ខេត្ត/ក្រុងអនុវត្តគំរោង LMAP ។ ទិន្នន័យនៃអង្កេតគ្របដណ្តប់ លើការសំភាសន៍លើ ៩៧០គ្រួសារ ក្នុង ៣២ភូមិ ។ ការពិភាក្សាទៅលើទិន្នន័យគ្រួសារនេះ ផ្តោតលើទំហំដីកាន់កាប់ និងយេនឌ័រ រីឯការពិភាក្សាអំពីទិន្នន័យភូមិបានផ្តោតទៅលើទីតាំង និងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាកម្មដែលអាចជះឥទ្ធិពលទៅលើផលប៉ះពាល់នៃការចុះបញ្ជីដីធ្លីនៅក្នុងភូមិទាំងមូល ។

## ៥.១. លក្ខណៈនៃគ្រួសារ

### *ការកាន់កាប់ដីលំនៅដ្ឋាន*

នៅក្នុងចំណោម ៩៧០ គ្រួសារនៃខេត្តគំរោង LMAP មាន ៩១៧ គ្រួសារ (ប្រហែលជា ៩៤,៥%) មានដីចំនួន ១.០១៨ក្បាលដីជាដីលំនៅដ្ឋាន ក្នុងនេះ ៤៩គ្រួសារគ្មាន ដីកសិកម្មទេ (រឺ ៧៩% នៃអ្នកគ្មានដីកសិកម្មដែលមានទាំងអស់ ៥៨គ្រួសារ) ។ គិតក្នុងចំណោម អ្នកស្នាក់នៅដែលជាម្ចាស់ដី អត្រាកាន់កាប់ដី គឺ ១,១ក្បាលដីក្នុងមួយគ្រួសារ ។ ក្នុងចំណោម ៥៣គ្រួសារដែលគ្មានដីលំនៅដ្ឋាន គឺមាន ១៣គ្រួសារដែលគ្មានដីកសិកម្ម ២១គ្រួសារកំពុងកាន់កាប់ដីកសិកម្មតិចជាង ០,៥ហិកតា និង ១១គ្រួសារមានដីកសិកម្ម ១ហិកតា ឬតិចជាង ។ នៅក្នុងករណីនេះ ភាគរយនៃគ្រួសារអ្នកមានដីលំនៅដ្ឋាន កើនឡើងយ៉ាងទៀងទាត់ស្របតាមទំហំនៃការកាន់កាប់ដីកសិកម្ម ។ ភាគរយនៃស្ត្រី និងបុរសជាមេគ្រួ កាន់កាប់ដីលំនៅដ្ឋាន មានភាពស្មើគ្នា ស្របទៅនឹងទំហំលើការកាន់កាប់ដីនីមួយៗ ។

មានគ្រួសារប្រហែល ៣៩,៣% ទទួលបានដីលំនៅដ្ឋានពីរដ្ឋ និង ៣៤,៨% ទទួលបាន ដីលំនៅដ្ឋានពីការផ្ទេរមរតក ។ មាន ១៧,៦% ផ្សេងទៀត បានទិញដីលំនៅដ្ឋាន ហើយមាន ៦,៨% បានទទួលដីលំនៅដ្ឋានដោយធ្វើការគាស់រានដី ។ ភាគរយនៃក្បាលដីលំនៅដ្ឋានដែលបានទទួលពីរដ្ឋ ជាទូទៅវាកើនឡើងស្របតាមទំហំដីកាន់កាប់ ប៉ុន្តែភាគរយនៃដីដែលទទួលបានតាមរយៈការផ្ទេរមរកត វាថយចុះ ។ ភាគរយនៃដីទទួលបានតាមរយៈការទិញ គឺមិនមានការប្រែប្រួលទេ ពីចន្លោះដីកាន់កាប់មួយថ្នាក់ទៅមួយថ្នាក់ទៀត លើកលែងតែចំពោះគ្រួសារគ្មានដីកសិកម្ម ដែលបានទិញ ៤៦,២% នៃក្បាលដីលំនៅដ្ឋានរបស់ខ្លួន ។ ចំណុចនេះបង្ហាញថា មានអ្នកគ្មានដីច្រើនគ្រួសារ (គឺគ្មានដីកសិកម្ម) នៅក្នុងតំបន់នៃគំរោង LMAP ដែលមិនបានទទួលដីលំនៅដ្ឋានពីរដ្ឋ ឬក៏បានបាត់បង់ក្បាលដីដើមរបស់ខ្លួន ហើយក្រោយមកបានទិញក្បាលដីមួយផ្សេងទៀត ។ ភាគរយនៃក្បាលដីលំនៅដ្ឋានដែលបានមកពី ការគាស់រានដី គឺមានអត្រាខ្ពស់បំផុតក្នុងចំណោមគ្រួសារដែលកំពុងកាន់កាប់ដីធំបំផុត (១១,១%) ។

ចំពោះយេនឌ័រនៃមេគ្រួសារ មានស្ត្រីជាមេគ្រួសារ ៥១,៦% និងបុរសជាមេគ្រួសារ ៣៥,៣% បានទទួលដីលំនៅដ្ឋានពីរដ្ឋ ។ ចំនួនភាគរយនៃមេគ្រួសារជាស្ត្រី គឺខ្ពស់ជាងមេគ្រួសារជាបុរស នៅតាមចន្លោះនីមួយៗនៃការកាន់កាប់ដី ។ ពាក់ព័ន្ធនឹង

ដីលំនៅដ្ឋានដែលទទួលបានពីការផ្ទេរមរតក មានលក្ខណៈផ្ទុយពីនេះ ដោយបុរសនិងស្ត្រីជាមេគ្រួសារ បានទទួលដី ៣៧.៧% និង ២៥.៨% នៃដីលំនៅដ្ឋាន ពីការផ្ទេរមរតក ហើយនិន្នាការនេះមានដូចគ្នានៅតាមចន្លោះនៃការកាន់កាប់ដីនីមួយៗ ។ គំរូដូចគ្នានេះដែរ ក៏បានកើតឡើងចំពោះដីលំនៅដ្ឋានដែលទទួលបានតាមរយៈការទិញ (លើកលែងតែទំហំដីកាន់កាប់ធំបំផុត ដែលមានការខុសគ្នាបន្តិចបន្តួច) ។ អ្វីដែលចំលែកនោះគឺចំនួនភាគរយនៃស្ត្រីជាមេគ្រួដែលទទួលបានដីតាមរយៈការគាស់រានដី គឺខ្ពស់ជាងបុរសជាមេគ្រួ ។ យើងបានគិតថា គ្រួសារមានបុរសជាមេគ្រួដែលទទួលបានដីលំនៅដ្ឋានតាមរយៈការគាស់រាន គួរមានអត្រាខ្ពស់ជាង គ្រួសារមានស្ត្រីជាមេគ្រួ ពីព្រោះពួកគេហាក់ដូចមានសក្តានុពលខាងកំលាំងពលកម្មច្រើនជាង ។

## ការកាន់កាប់ដីកសិកម្ម

គំរូនៃអង្កេតនៅក្នុងតំបន់នៃគំរោង LMAP បង្ហាញថា ពួកអ្នកកាន់កាប់ដីធំៗ មានចំណែកច្រើនពេកលើដីកសិកម្ម ។ ឧទាហរណ៍ គ្រួសារកាន់កាប់ដីតិចជាង ១.៥ ហិកតា មានចំនួន ២១.៩% នៃចំនួនគ្រួសារក្នុងគំរូអង្កេត ប៉ុន្តែដីដែលពួកគេកាន់កាប់មានទំហំតែ ៣.៨% នៃផ្ទៃដីទាំងអស់តែប៉ុណ្ណោះ ។ អ្នកមានដីតិចជាង ១ ហិកតា មានចំនួនរហូតទៅដល់ ៤៦.២% នៃគ្រួសារប៉ាន់គំរូ ប៉ុន្តែកាន់កាប់ផ្ទៃដីតែ ១៤.៥% នៃទំហំដីទាំងអស់ នៅខណៈដែលគ្រួសារកាន់កាប់ដី ៣ហិកតា ឬ ច្រើនជាងនេះមានចំនួន ១៤.៤% នៃគ្រួសារសរុប ប៉ុន្តែបានកាន់កាប់រហូតដល់ ៤៣.៨% នៃទំហំដីទាំងអស់ ។ គ្រួសារដែលកាន់កាប់ដី ២ ហិកតា ឬច្រើនជាងនេះ មានចំនួន ២៧.៧% នៃគ្រួសារដែលអង្កេត តែកាន់កាប់ដីរហូតដល់ ៦៣.៥% នៃដីកសិកម្ម ។

ទិន្នន័យអង្កេតបង្ហាញចំនុចសំខាន់មួយទៀតថា គ្រួសារកាន់កាប់ដីតូច គេមានក្បាលដីកសិកម្ម ទំហំតូចជាង និងចំនួនតិចជាង បើប្រៀបធៀបទៅនឹងគ្រួសារកាន់កាប់ដីធំ ដែលមានក្បាលដីធំជាង និងចំនួនច្រើនជាង ។ តារាង ៥.១ក បង្ហាញថា ចំនួន និងទំហំក្បាលដីបានកើនឡើងយ៉ាងទៀងទាត់ ពីចន្លោះនៃការកាន់កាប់មួយ ទៅចន្លោះមួយផ្សេងទៀត ។ លំនាំនេះឃើញមានដូចគ្នា នៅក្នុង ២៧ភូមិ នៃ ៣២ភូមិនៅក្នុងគំរោង LMAP ហើយសំរាប់ ៥ភូមិទៀតគឺមានគំលាតតិចតួចណាស់ពីលំនាំទូទៅ ។

**តារាង ៥.១ក. សេចក្តីសង្ខេបការកាន់កាប់ដីកសិកម្មតាមគ្រួសារ (ហ.ត)**

| ទំហំកាន់កាប់ដី | ចំនួនគ្រួសារ | ក្បាលដីសរុប | ផ្ទៃសរុប | ផ្ទៃដី/មួយគ្រួសារ | ក្បាលដី/មួយគ្រួសារ | ផ្ទៃដី/មួយក្បាលដី |
|---|---|---|---|---|---|---|
| | | | | | | |
| < 0.5 (ហ.ត) | 201 | 465 | 55.37 | 0.27 | 2.31 | 0.11 |
| 0.5 – 0.9 (ហ.ត) | 223 | 843 | 156.11 | 0.70 | 3.78 | 0.18 |
| 1.0 – 1.9 (ហ.ត) | 229 | 1,092 | 322.66 | 1.41 | 4.76 | 0.29 |
| 2.0 – 2.9 (ហ.ត) | 122 | 653 | 294.25 | 2.41 | 5.35 | 0.45 |
| > 3.0 (ហ.ត) | 132 | 826 | 634.50 | 4.80 | 6.25 | 0.76 |
| | | | | | | |
| សរុប | 907 | 3,879 | 1,462.8 | 1.59 | 4.23 | 0.37 |

ការពន្យល់ជារឿយៗជាងគេអំពីលំនាំនេះ ជាប់ទាក់ទងនឹងការបែងចែកដីធ្លីនៅឆ្នាំ១៩៨៩ ដែល មានការប្រឹងប្រែងធ្វើការបែងចែកឱ្យបានស្មើគ្នានូវដីមានគុណភាពល្អ (កំនត់តាមផលិតភាព និងទីតាំង) ដោយផ្អែកទៅលើចំនួនសមាជិកគ្រួសារដែលស្ថិតក្នុងអាយុបញ្ចេញកំលាំងធ្វើការបាន ។ ផ្អែកលើរូបមន្តនេះ គ្រួសារដែលមានកំលាំងពលកម្មច្រើន គឺបានទទួលក្បាលដី

បន្ថែម ក្នុងនេះក្បាលដីខ្លះអាចមានគុណភាពអន់ជាង ទោះបីជាវាមានទំហំធំក៏ដោយ ។ ជាលទ្ធផល វាមានការខុសគ្នារួចជាស្រេចទៅហើយ នៅក្នុងការបែងចែកដីឆ្នាំ១៩៨៩ បើសិនគេគិតពីទំហំដីកាន់កាប់ដោយគ្រួសារ ។[២២]

ជាកេរ្តិ៍ដំណែលពីការបែងចែកដីឆ្នាំ១៩៨៩ គឺមានជាង ៩៥% នៃគ្រួសារអង្កេត បានទទួលដីកសិកម្មពីរដ្ឋ ។ ប៉ុន្តែទិន្នន័យពាក់ព័ន្ធនឹងបែបបទនៃការទទួលបានដី ក៏បានបំភ្លឺពីវិធីដែលគ្រួសារកាន់កាប់ដីធំពីដំបូង អាចទទួលបានដីបន្ថែមទៀត ។ ឧទាហរណ៍ ទិន្នន័យបង្ហាញថា គ្រួសារធំមានកំលាំងពលកម្មច្រើន អាចមានលទ្ធភាពល្អជាងក្នុងការពង្រីកការកាន់កាប់ដីជាបន្តបន្ទាប់ ដោយធ្វើការគាស់រានដីបន្ថែមទៀត (តារាង៥.១គ)។ មតិនេះត្រូវបានគាំទ្រដោយទិន្នន័យនៅក្នុងតារាង ៥.១ខ ដែលបង្ហាញថា គ្រួសារដែល កាន់កាប់ដីធំៗ តែងមានកំលាំងពលកម្មច្រើន និងទ្រព្យផ្សេងទៀតសំរាប់ធ្វើការគាស់រានដីបន្ថែម ។

**តារាង ៥.១ខ. បែបបទនៃការទទួលបានដី (% នៃក្បាលដីសរុប)**

| ទំហំដី | រដ្ឋ | មរតក | ទិញ | ការគាស់រាន | ចំនួនសរុប |
|---|---|---|---|---|---|
| | | | | | |
| < 0.5 | 52.9 | 33.6 | 11.6 | 1.9 | 467 |
| 0.5 – 0.99 | 57.2 | 23.5 | 15.9 | 3.2 | 844 |
| 1.0 – 1.9 | 62.5 | 18.6 | 13.6 | 5.3 | 1,095 |
| 2.0 – 2.9 | 55.2 | 17.5 | 16.4 | 10.8 | 659 |
| > 3.0 | 46.6 | 20.8 | 17.5 | 15.2 | 824 |
| | | | | | |
| ចំនួនសរុប | 2,162 | 845 | 589 | 29 | 3,886 * |
| % នៃក្បាលដីសរុប | 55.6 | 21.7 | 15.2 | 7.4 | |

* Missing n = 3

តារាង ៥.១គ ក៏បានបង្ហាញដែរថា ជាមធ្យម គ្រួសារធំៗតែងមានទ្រព្យជាមូលធនច្រើន មានចំណូលខ្ពស់ និងមានកំលាំងពលកម្មជាសក្តានុពលច្រើនជាង ។ រឿងនេះបង្ហាញតទៅទៀតថា គ្រួសារដែលមានធនធានច្រើន គឺមានលទ្ធភាពខ្ពស់ជាងគ្រួសារតូចៗ ក្នុងការទិញដីបន្ថែម ។ មតិនេះក៏ ត្រូវបានគាំទ្រដោយទិន្នន័យនៅក្នុងតារាង ៥.១ខ ដែលបង្ហាញថា គ្រួសារកាន់កាប់ដីធំ គឺមានកំរិតភាគរយនៃដីធ្លីដែលទទួលបានតាមរយៈការទិញខ្ពស់ជាងគ្រួសារតូចៗ ។ ដូច្នេះ ការផ្ទេរដីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សា និងពង្រីកនូវគំលាតដើមនៃការកាន់កាប់ដីឱ្យកាន់តែធំឡើង រវាងគ្រួសារកាន់កាប់ដីតូច និងគ្រួសារកាន់កាប់ដីធំ ។

**តារាង ៥.១គ. ទ្រព្យសកម្ម និង កំលាំងពលកម្មរបស់គ្រួសារ***

| ទំហំកាន់កាប់ដី | ការចិញ្ចឹមសត្វ | ទ្រព្យសកម្មប្រើប្រាស់បានយូរ | ទ្រព្យសកម្មជាប់លាប់មិនមែនកសិកម្ម | ទ្រព្យសកម្មកសិកម្មមិនមែនម៉ាស៊ីន | ទ្រព្យសកម្មកសិកម្មជាម៉ាស៊ីន | កំលាំងពលកម្មរបស់គ្រួសារ |
|---|---|---|---|---|---|---|
| 0 | | | | | | (4.3) |
| < 0.5 | 85.69 | 33.31 | 18.31 | 3.58 | 6.65 | 3.3 |
| 0.5 – 0.9 | 149.22 | 39.96 | 8.82 | 9.86 | 17.87 | 4.1 |
| 1.0 – 1.9 | 186.88 | 52.47 | 18.90 | 13.67 | 30.72 | 4.0 |
| 2.0 – 2.9 | 220.04 | 47.78 | 11.46 | 21.98 | 37.21 | 4.8 |
| > 3.0 | 318.83 | 58.38 | 24.34 | 37.59 | 43.61 | 5.0 |
| សរុប | 179.45 | 45.49 | 16.63 | 15.75 | 25.78 | 4.1 |

** កំលាំងពលកម្មជាសក្តានុពលក្នុងគ្រួសាររួមមាន បុរស និងស្ត្រី ដែលមានអាយុពី ១០-៦០ឆ្នាំ យោងតាមអង្កេត SES នៅកម្ពុជា*

[២២] ការបកស្រាយនេះគឺផ្អែកទៅលើក្រុមពិភាក្សាបង្គោល ជាមួយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ ក៏ដូចជាមន្ត្រីនៃគំរោង LMAP ។

ការបកស្រាយផ្សេងទៀតសំរាប់លំនាំនៃការបែងចែកក្បាលដី ដែលបានពិនិត្យឃើញ គឺពាក់ព័ន្ធនឹងការបំបែកក្បាលដីតាមរយៈការលក់ និង/ឬផ្ទេរមរតក ដូចមានចុះបញ្ជាក់ក្នុងការសិក្សាផ្សេងៗទៀត (ឧ. Biddulph, ២០០៤) ។ នៅកំរិតភូមិ គ្រួសារធំៗបានទិញក្បាលដីបន្ថែមពីគ្រួសារតូច ដែលបានលក់ដីដើម្បីដោះស្រាយវិបត្តិគ្រួសារ ឬដោយហេតុផលផ្សេងទៀត ។ នៅក្នុងចំណោមគ្រួសារមានដីតូច ទំហំនិងចំនួនក្បាលដី ក៏បានថយចុះដែរ ដោយសារការបំបែកក្បាលដីសំរាប់ផ្តល់ឱ្យកូនចៅរបស់ពួកគេ ។ មតិនេះត្រូវបានគាំទ្រដោយទិន្នន័យនៅក្នុងតារាង ៥.១ខ ដែលបង្ហាញពីភាពញឹកញាប់នៃការទទួលបានដី តាមរយៈការបន្តមរតក នៅក្នុងចំណោមគ្រួសារកាន់កាប់ដីតូច ។

យុទ្ធសាស្ត្រដែលប្រជាពលរដ្ឋប្រើ នៅពេលដែលគេទិញ និងលក់ដី ក៏ដូចជាការសំរេចចិត្តផ្ទេរមរតក ត្រូវមានការសិក្សាបន្ថែមទៀត ។ ការពិនិត្យមើលមួយភ្លែតដំបូងក៏ហាក់ដូចបង្ហាញថា គ្រួសារមានដីធំៗ ច្រើនទិញដីពីអ្នកមានដីតូច ដើម្បីពង្រីកក្បាលដីចូលគ្នា ចំណែកឯអ្នកទិញមកពីក្រៅសហគមន៍ចូលចិត្តទិញដីដោយផ្អែកទៅលើទីផ្សារ និងទីតាំងដី (ឧ. មានផ្លូវល្អ) ។ នៅពេលជាមួយគ្នា អ្នកមានដីតូចធ្វើការលក់ដីដើម្បីទទួលបានប្រាក់ដែលគេត្រូវការ ។ ដីកសិកម្មជារឿយៗ គឺជាទ្រព្យចុងក្រោយដែលត្រូវលក់ (លើកលែងតែដីភូមិ) ហើយចំពោះការសំរេចចិត្តថា ត្រូវលក់ក្បាលដីណា ឬបំបែកក្បាលដីណាដើម្បីលក់ ជារឿយៗគឺផ្អែកទៅលើចំនួនប្រាក់ដែលគេត្រូវការចាំបាច់នៅពេលលក់នោះ ។ ជាលទ្ធផល អ្នកមានដីតូចលក់ក្បាលដីម្តងមួយឡូត៍ៗ ហើយបានកាត់បន្ថយសមត្ថភាពផលិតរបស់ខ្លួន ដូច្នេះក៏ឈានទៅរកភាពគ្មានដីធ្លីកាន់តែលឿនឡើងៗ ។

## ៥.១.១. យេនឌ័រ

ទិន្នន័យមានចំនុចគួរកត់សំគាល់មួយទៀតពាក់ព័ន្ធនឹងទំនាក់ទំនងរវាង (ក) ទំហំដីកាន់កាប់ ការទទួលបានដី ទ្រព្យសកម្មនិងចំណូលរបស់គ្រួសារ និងកំលាំងពលកម្ម ហើយនិង (ខ) យេនឌ័រនៃមេគ្រួសារ ។ ជាទូទៅ លំនាំដែលបានកត់សំគាល់ខាងលើពាក់ព័ន្ធនឹងការបែងចែកក្បាលដី នៅក្នុងអង្កេតនៅនៃតំបន់គំរោង LMAP គឺមានដូចគ្នាទាំងសំរាប់បុរសជាមេគ្រួសារ និងស្ត្រីជាមេគ្រួសារ ។ ប៉ុន្តែ ចំនួននិងទំហំជាមធ្យមនៃក្បាលដីរបស់ស្ត្រីជាមេគ្រួ គឺមានតិចជាងបុរសជាមេគ្រួ ។ បុរសជាមេគ្រួមានដីជាមធ្យម ៤,៤ក្បាលដីក្នុងមួយគ្រួសារ ដែលមានទំហំ ០,៣៩ហិកតាក្នុងមួយក្បាលដី រីឯស្ត្រីជាមេគ្រួមានដីជាមធ្យម ៣,៧៨ក្បាលដី ដែលមានទំហំជាមធ្យម ០,៣០ហិកតា ក្នុងមួយក្បាលដី (តារាង ៥.១ខ) ។

**តារាង ៥.១ឃ. សេចក្តីសង្ខេបការកាន់កាប់ដីកសិកម្មបែងចែកតាមយេនឌ័រ**

| ទំហំដី | ចំនួនគ្រួសារ | | ក្បាលដី | | ផ្ទៃដី | | ផ្ទៃដី/គ្រួសារ | | ក្បាលដី/គ្រួសារ | | ផ្ទៃដី/ក្បាលដី | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | |
| < 0.5 | 123 | 78 | 281 | 184 | 34.9 | 20.5 | 0.28 | 0.26 | 2.28 | 2.36 | 0.12 | 0.11 |
| 0.5 – 0.99 | 164 | 59 | 616 | 227 | 114.9 | 41.2 | 0.70 | 0.69 | 3.78 | 3.89 | 0.18 | 0.18 |
| 1.0 – 1.99 | 180 | 49 | 876 | 216 | 253.7 | 69.0 | 1.40 | 1.40 | 4.86 | 4.40 | 0.28 | 0.31 |
| 2.0 – 2.99 | 102 | 20 | 540 | 113 | 248.4 | 45.9 | 2.43 | 2.29 | 5.29 | 5.65 | 0.46 | 0.40 |
| > 3.0 | 113 | 19 | 714 | 112 | 547.3 | 87.2 | 5.36 | 4.59 | 6.32 | 5.89 | 0.76 | 0.77 |
| | | | | | | | | | | | | |
| សរុប | 682 | 225 | 3,027 | 852 | 1,199 | 263.8 | 1.75 | 1.17 | 4.44 | 3.78 | 0.39 | 0.30 |

ទិន្នន័យក៏បានបង្ហាញដែរថា ៣៨% នៃស្ត្រីជាមេគ្រួ កាន់កាប់ដីកសិកម្មតិចជាងកន្លះហិកតា ហើយមានតែ ១៨% នៃបុរសជាមេគ្រួប៉ុណ្ណោះដែលកាន់កាប់ដីតិចជាងកន្លះហិកតា ។ លើសពីនេះទៀត ស្ត្រីជាមេគ្រួ ៦0% បានកាន់កាប់ដីតិចជាងមួយហិកតា ហើយមានបុរសជាមេគ្រួតែ ៤២% ដែលកាន់កាប់ដីតិចជាងមួយហិកតា ។ ផ្ទុយទៅវិញមាន ១៧% នៃស្ត្រីជាមេគ្រួបានកាន់កាប់ដីធំជាង ២ហិកតា និងមាន ៣១% នៃបុរសជាមេគ្រួ ដែលកាន់កាប់ដីធំជាង ២ហិកតា ។

បែបបទនៃការទទួលបានដី ក៏បង្ហាញផងដែរពីកត្តាសំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងយេនឌ័រ និងកម្មសិទ្ធិដីធ្លី ។ ឧទាហរណ៍ ស្ត្រីជាមេគ្រួមានចំនួនភាគរយ (៧0,៩%) នៃ ដីឡូត៍ដែលទទួលបានពីរដ្ឋ ខ្ពស់ជាងបុរសជាមេគ្រួ (៥១,៣%) ។ នៅពេលជាមួយគ្នា ចំនួនភាគរយនៃ ក្បាលដីដែលទទួលបានតាមរយៈការផ្ទេរមរតក គឺមានតួលេខទាបណាស់ចំពោះស្ត្រីជាមេគ្រួ (១១,២%) បើប្រៀបធៀបជាមួយ បុរសជាមេគ្រួ (២៤,៦%) ។ ភាពខុសគ្នានេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ពីព្រោះតាមរបៀបរបបជាប្រពៃណី ប្រជាពលរដ្ឋនៅជនបទកម្ពុជាតែងផ្តល់ដីមរតកឱ្យកូនប្រុសច្រើនជាងកូនស្រី ។

**តារាង ៥.១ង. ការទទួលបានដីបែងចែកតាមយេនឌ័រ**

| ទំហំ | រដ្ឋ | | បន្តមរតក | | ទិញ | | ការគាស់រានដី | |
|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | |
| < 0.5 | 39.5 | 73.1 | 43.1 | 19.4 | 14.9 | 6.5 | 2.5 | 1.1 |
| 0.5 – 0.9 | 52.0 | 71.6 | 29.6 | 6.7 | 15.7 | 16.4 | 2.6 | 4.9 |
| 1.0 – 1.9 | 58.7 | 77.9 | 21.5 | 6.9 | 14.9 | 8.3 | 4.9 | 6.9 |
| 2.0 – 2.9 | 51.5 | 73.5 | 18.5 | 12.4 | 18.5 | 6.2 | 11.4 | 8.0 |
| > 3.0 | 46.1 | 50.0 | 22.1 | 12.5 | 16.7 | 22.3 | 15.2 | 15.2 |
| | | | | | | | | |
| សរុប | 51.3 | 70.9 | 24.7 | 11.0 | 16.1 | 11.6 | 7.8 | 6.3 |

តារាង ៥.១ង ខាងលើក៏បង្ហាញដែរថា ចំនួនភាគរយនៃក្បាលដីដែលស្ត្រីជាមេគ្រួទទួលបានតាមរយៈការទិញ និងការគាស់រាន វាមានកំរិតទាបជាងបុរសជាមេគ្រួ ។ សរុបមកយើងឃើញថា ចំនួនភាគរយទាប ទាំងការផ្ទេរមរតក ការទិញ ការគាស់រានដី បង្ហាញថា ស្ត្រីជាមេគ្រួមានលទ្ធភាពតិចជាងបុរសជាមេគ្រួក្នុងការទទួលបានក្បាលដីបន្ថែម ។ តារាង ៥.១ច នឹងជួយបកស្រាយពីរឿងនេះ ។ ទិន្នន័យ បង្ហាញថា ស្ត្រីជាមេគ្រួនៅគ្រប់ចន្លោះកាន់កាប់ដីនីមួយៗ ជាមធ្យមមានទ្រព្យនិងចំណូលតិចជាងបុរសជាមេគ្រួ ។ ទ្រព្យសកម្មតិចតួចនេះ ជាពិសេសធនធានសំរាប់ធ្វើកសិកម្ម និងកំលាំងពលកម្ម ជាកំហិតមួយ ចំពោះទំហំដីធ្លីដែលអាចធ្វើការបង្កបង្កើនផល រីឯចំណូលតិចគឺជាឧបសគ្គចំពោះការទិញដីបន្ថែមថ្មី ។

**តារាង ៥.១ច. ទ្រព្យ និង កំលាំងពលកម្មរបស់គ្រួសារ**

| ទំហំដី (ហ.ត) | ការចិញ្ចឹមសត្វ | | ទ្រព្យសកម្ម ប្រើប្រាស់បានយូរ | | ទ្រព្យសកម្មជាប់លាប់មិនមែនកសិកម្ម | | ទ្រព្យសកម្ម មិនមែនម៉ាស៊ីន | | ទ្រព្យសកម្ម ជាម៉ាស៊ីន | | កំលាំងពលកម្ម គ្រួសារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| 0 | | | | | | | | | | | 4.1 | 4.6 |
| < 0.5 | 110.9 | 74.3 | 36.4 | 28.1 | 29.9 | 2.4 | 3.7 | 3.4 | 9.2 | 2.0 | 3.6 | 2.9 |
| 0.5 – 0.99 | 158.4 | 134.6 | 40.7 | 37.8 | 10.4 | 3.3 | 11.2 | 5.8 | 22.1 | 3.4 | 4.2 | 3.8 |
| 1.0 – 1.99 | 204.9 | 117.5 | 62.4 | 14.1 | 23.9 | 0.8 | 14.8 | 9.5 | 36.7 | 5.2 | 4.5 | 2.2 |
| 2.0 – 2.99 | 240.2 | 127.6 | 51.7 | 27.8 | 12.8 | 5.3 | 23.5 | 13.2 | 41.5 | 11.6 | 4.9 | 4.4 |
| > 3.0 | 30.9 | 273.8 | 60.6 | 43.5 | 24.6 | 22.3 | 40.2 | 20.2 | 45.9 | 29.6 | 5.1 | 4.4 |
| សរុប | 198.2 | 121.9 | 50.7 | 28.8 | 20.4 | 4.1 | 18.2 | 7.8 | 31.4 | 6.7 | 4.4 | 3.4 |

លំនាំទាំងនេះវាស្របគ្នានឹងការសិក្សាផ្សេងទៀត ដែលគូសបញ្ជាក់ពីការចាញ់ប្រៀបជាច្រើនរបស់ស្ត្រីជាមេគ្រួ ក្នុងការកាន់កាប់ដីធ្លី និងការដោះស្រាយជីវភាពឱ្យមានចីរភាព ។[២៣] ប៉ុន្តែទិន្នន័យនេះ មានមិនទាន់គ្រប់គ្រាន់ទេ ដើម្បីតាមដានការវិវត្តន៍នៃលំនាំបែបនេះពីមួយឆ្នាំទៅមួយឆ្នាំ ។ ឧទាហរណ៍ តើនៅពេលណាពួកគេក្លាយទៅជាស្ត្រីមេម៉ាយ ហើយតើមានអ្វីកើតឡើងចំពោះការកាន់កាប់ដីធ្លីរបស់ពួកគេ? យើងអាចសន្និដ្ឋានថា ស្ត្រីជាមេគ្រួប្រហែលជាទទួលបានដីតិចជាងនៅក្នុងពេលបែងចែកដីនៅឆ្នាំ១៩៨៩ ដោយផ្អែកទៅលើទិន្នន័យនៃអង្កេតស្តីពីកំលាំងពលកម្មនៅក្នុងគ្រួសារមានបុរសជាមេគ្រួ និងស្ត្រីជាមេគ្រួ ប៉ុន្តែតើមានអ្វីបានកើតឡើងចំពោះស្ត្រីដែលក្លាយជាមេម៉ាយ ឬត្រូវប្តីបោះបង់ចោល នៅក្រោយពេលនោះ?

## ៥.១.២. ភាពគ្រប់គ្រាន់នៃផលស្រូវ

សូចនាករដែលគេតែងប្រើប្រាស់ដើម្បីវាស់ស្ទង់ពីសុខុមាលភាពនៃគ្រួសារនៅជនបទគឺ សន្តិសុខស្បៀងដែលកំនត់ជាចំនួនខែដែលគ្រួសារមានផលស្រូវសំរាប់ដោះស្រាយការហូបចុកក្នុងផ្ទះ ឬក៏ផលស្រូវលើសអាចយកទៅលក់ដូរបាន ។ ជារួម គ្រួសារណាដែលផលិតស្រូវបានគ្រប់គ្រាន់សំរាប់លក់ ត្រូវបានចាត់ទុកថា ធូរធារជាងគ្រួសារ ដែលផលិតស្រូវបានសំរាប់តែហូបចុករយៈពេល ៣ខែ ។ ទិន្នន័យលើភាពគ្រប់គ្រាន់នៃផលស្រូវ ក៏អាចប្រើការផងដែរជាសូចនាករដ៏ល្អនៃវិបត្តិនានានៅក្នុងគ្រួសារ ដូចជាភាពរាំងស្ងួត ឬទឹកជំនន់ ដែលអាចបំផ្លាញផលដំណាំ ។

អង្កេតទៅលើក្រុមនៅក្នុងតំបន់នៃគំរោង LMAP បង្ហាញថា ២៨,២% នៃគ្រួសារបានផលិតលើស ហើយអាចធ្វើការលក់ដូរបាន នៅពេលដែល ១២,៩% ផលិតបានសំរាប់តែការប្រើប្រាស់នៅក្នុងគ្រួសារ ។ ប្រហែលជា ១៨,៩% ផលិតបានគ្រប់គ្រាន់តែសំរាប់ប្រើប្រាស់ក្នុងគ្រួសាររយៈពេលតែពី ៧-១០ខែ គឺបានន័យថាពួកគេត្រូវការ ទិញស្រូវសំរាប់ពី ២-៥ ខែបន្ថែមរីឯ ១៥,៣% ផ្សេងទៀត ផលិតបានគ្រប់គ្រាន់សំរាប់ប្រើប្រាស់រយៈពេល ៣-៦ ខែប៉ុណ្ណោះ ។ ប្រហែលជា ១០% នៃគ្រួសារដែលផលិតស្រូវបានសំរាប់ការប្រើប្រាស់រយៈពេលតែ ៣ខែ ឬតិចជាង ហើយមាន ១៤,៥% ត្រូវការទិញស្រូវ សំរាប់ប្រើប្រាស់ក្នុងពេញមួយឆ្នាំតែម្តង (តារាង ៥.១ឃ) ។

**តារាង ៥.១ឃ. ភាពគ្រប់គ្រាន់នៃការផលិតស្រូវ**

| ទំហំដី (ហ.ត) | អតិរេក | | គ្រប់គ្រាន់ | | គ្រប់ ៧ - ១០ខែ | | គ្រប់ ៣ - ៦ខែ | | គ្រប់តិចជាង ៣ខែ | | ខ្វះពេញមួយឆ្នាំ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | | | |
| 0 | 5 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 1 | 32 | 20 | 40 | 21 |
| < 0.5 | 9 | 5 | 13 | 4 | 32 | 21 | 33 | 20 | 19 | 17 | 17 | 11 | 123 | 78 |
| 0.5 – 0.9 | 52 | 12 | 17 | 13 | 45 | 16 | 25 | 9 | 14 | 3 | 11 | 5 | 164 | 58 |
| 1.0 – 1.9 | 65 | 12 | 33 | 7 | 30 | 7 | 24 | 9 | 15 | 8 | 13 | 6 | 180 | 49 |
| 2.0 – 2.9 | 40 | 10 | 15 | 1 | 13 | 3 | 13 | 0 | 7 | 3 | 14 | 3 | 102 | 20 |
| > 3.0 | 56 | 7 | 17 | 2 | 15 | 1 | 11 | 4 | 9 | 2 | 5 | 3 | 113 | 19 |
| | | | | | | | | | | | | | | |
| សរុបចំនួន | 227 | 46 | 98 | 27 | 135 | 48 | 106 | 42 | 64 | 34 | 92 | 48 | 722 | 245 |
| សរុប | 273 | | 125 | | 183 | | 148 | | 98 | | 140 | | 967 | |

[២៣] បានលើកឡើងដោយ Biddulph, Robin (2000) and So *et al.* (2001)

ដូចការរំពឹងទុក ភាពគ្រប់គ្រាន់នៃការផលិតស្រូវជាប់ទាក់ទងជិតស្និតទៅនឹងទំហំដីដែលកំពុងកាន់កាប់ ។ ជាទូទៅ ចំណែកជាភាគរយនៃគ្រួសារដែលផលិតស្រូវគ្រប់គ្រាន់ ឬលើស គឺមាននិន្នាការកើនឡើង ស្របតាមកំនើននៃទំហំដីកំពុងកាន់កាប់ រីឯចំណែកភាគរយនៃគ្រួសារដែលទិញស្រូវសំរាប់ រយៈ ៩ខែ ឬច្រើនជាងនេះក្នុងមួយឆ្នាំ ថយចុះយ៉ាងខ្លាំងនៅពេលទំហំដីកាន់កាប់កើនឡើង ។ គ្រួសារដែលកាន់កាប់ដីធំ ក៏ហាក់ដូចកំពុងមានប្រៀបជាច្រើនបែបទៀត ទៅលើគ្រួសារដែលកាន់កាប់ដីតូចដែរ ។ ឧទាហរណ៍ គ្រួសារដែលមានដីចាប់ពី ៣ហិកតាឡើងទៅ តំណាងឱ្យ ២៣% នៃគ្រួសារដែលផលិតបានលើស ទោះបីជាពួកគេមានចំនួនតែ ១៣% នៃគ្រួសារនៅក្នុងតំបន់ដែលអង្កេតក្តី ។ គ្រួសារដែលមានដីកន្លះហិកតា ឬតិចជាងនេះ (រួមទាំងអ្នកគ្មានដីផង) តំណាងឱ្យ ៦,៨% នៃអ្នកដែលផលិតលើស ប៉ុន្តែពួកគេមានចំនួនច្រើនរហូតដល់ ២៧% នៃគ្រួសារទាំងអស់ ។ គ្រួសារគ្មានដីតំណាងឱ្យ ៣៧% នៃគ្រួសារដែលបានទិញស្រូវពេញមួយឆ្នាំ ប៉ុន្តែពួកគេមានតែ ៦,៣% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ។

គួរចាប់អារម្មណ៍ថា គ្រួសារដែលមានដី ២ហិកតា ឬច្រើនជាងនេះមានចំនួន ២៤% នៃគ្រួសារ ទាំងអស់ដែលត្រូវទិញស្រូវទាំងអស់ ។ បើមើលមួយភ្លែត រឿងនេះហាក់ដូចមិនត្រឹមត្រូវទេ ព្រោះគេរំពឹងថា គ្រួសារដែលមានដីច្រើនទោះយ៉ាងណាក៏អាចផលិតស្រូវបានខ្លះដែរ ។ ការបកស្រាយមួយបែប គឺការខូចខាតផលដំណាំបណ្តាលមកពីសត្វល្អិត ទឹកជំនន់ ឬការរាំងស្ងួត ។ រឿងនេះក៏អាចជួយពន្យល់ថា ហេតុអ្វីបានជាគ្រួសារដែលមានដីតូចជាង ក៏ត្រូវទិញស្រូវសំរាប់ពេញមួយឆ្នាំដែរ ។ មតិនេះត្រូវបានគាំទ្រ ដោយទិន្នន័យស្តីពីវិបត្តិ និងការប៉ះទង្គិចផ្សេងៗនៅក្នុងគ្រួសារ ដែលបង្ហាញថា ៦៧គ្រួសារនៅក្នុងក្រុមអង្កេតនៃតំបន់គំរោង LMAP ធ្លាប់ទទួលការបំផ្លាញផលដំណាំដោយសត្វល្អិតយ៉ាងហោចណាស់មួយលើក ក្នុងនេះគឺមាន ១៣គ្រួសារដែលមានដីកសិកម្ម ៣ហិកតា ឬច្រើនជាង ។ មានសរុប ៣៩៨គ្រួសារ ក៏បានរាយការណ៍ផងដែរថា ផលដំណាំរបស់គេត្រូវខូចខាតដោយសារទឹកជំនន់ រឺការរាំងស្ងួត ក្នុងនេះមាន ៧១គ្រួសារដែលមានដី ៣ហិកតា ឬច្រើនជាង ។[២៤]

ទិន្នន័យដែលបង្ហាញពីភាពគ្រប់គ្រាន់នៃការផលិតស្រូវគិតតាមយេនឌ័រនៃមេគ្រួសារបង្ហាញថា បុរសជាមេគ្រួមានប្រៀបជាងស្ត្រីជាមេគ្រួ ។ ឧទាហរណ៍ បុរសជាមេគ្រួតំណាងឱ្យ ៨៣,២% នៃគ្រួសារដែលផលិតបានផលលើស ប៉ុន្តែមានចំនួនត្រឹម ៧៤,៦% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ។ ស្ត្រីជាមេគ្រួតំណាងឱ្យ ៣៤% នៃគ្រួសារដែលត្រូវតែទិញស្រូវសំរាប់ហូបពេញមួយឆ្នាំ ប៉ុន្តែពួកគេមានចំនួនតែ ២៥% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ។ ស្ត្រីជាមេគ្រួមានចំនួន ៥៣,១% នៃគ្រួសារដែលអាចផលិតបានស្រូវសំរាប់ប្រើប្រាស់រយៈពេល ៣ ខែ ឬក៏តិចជាង និង ៣៩,៦% នៃគ្រួសារដែលអាច ផលិតស្រូវប្រើប្រាស់បានពី ៣-៦ ខែ ។

## ៥.១.៣ សេចក្តីសង្ខេប

ទំហំនៃការកាន់កាប់ដី និងយេនឌ័រនៃមេគ្រួសារ ជួយឱ្យយើងអាចទស្សន៍ទាយបានល្អអំពី កំលាំងពលកម្ម ទ្រព្យសម្បត្តិ ចំណូល និងភាពគ្រប់គ្រាន់នៃការផលិតស្រូវ ។ ជាលទ្ធផល ទំហំនៃការកាន់កាប់ដី គឺជាសន្ទស្សន៍ដ៏ល្អនៃសក្តានុពលសមត្ថភាពរបស់គ្រួសារក្នុងការទទួលបានផលចំណេញពី កម្មវិធីចុះបញ្ជីដីធ្លី ។ យើងកត់សំគាល់ថា គ្រួសារកាន់កាប់ដីធំជាទូទៅច្រើនមានស្ថានភាពពីដើមទី អំណោយផលជាងគ្រួសារកាន់កាប់ដីតូច ក្នុងការទទួលបានផលចំណេញពីការចុះបញ្ជីដី ។ ដូច្នេះយើងអាចហៅគ្រួសារដែលកាន់កាប់ដីធំ មានទ្រព្យមូលធន កំលាំងពលកម្ម និងចំណូលច្រើនថាជាគ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់

[២៤] ប៉ុន្តែដីទាំងនេះមិនមែនសុទ្ធតែជាដីសំរាប់ធ្វើស្រែទាំងអស់នោះទេ ។

(High Potential Impacts: HPIs) ។ ផ្ទុយទៅវិញ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលទាប (Low Potential Impacts: LPIs) គឺមានដីកសិកម្មតូច ចំនួនក្បាលដីតិច ចំណូលតិច កំលាំងពលកម្មតិច និងទ្រព្យធនតិច ហើយក្នុងនេះក៏មានទាំង គ្រួសារងាយរងគ្រោះជាងគេ ដូចជាគ្រួសារមានស្ត្រីមេម៉ាយជាមេគ្រួ ជាដើម ។

## ៥.២. លក្ខណៈភូមិ

ដូចបានពិភាក្សាខាងលើ ការទទួលបានឥណទាន ទីផ្សារធាតុចូល និងចេញ សេវាកម្មរដ្ឋបាល គឺជាកត្តាដ៏សំខាន់ដែលជះឥទ្ធិផលលើផលប៉ះពាល់នៃការចុះបញ្ជីដីធ្លីនៅក្នុងតំបន់ណាមួយ ។ តាមនេះ ទីតាំងនៅជិតផ្លូវថ្នល់ និងទីផ្សារ គឺជាសូចនាករដ៏ល្អនៃការទទួលបានឥណទាន និងសេវាកម្មផ្សព្វផ្សាយបច្ចេកទេស ទីផ្សារ និងមជ្ឈមណ្ឌលរដ្ឋបាល ។ ទីតាំងក៏ជាសូចនាករល្អផងដែរនៃកំរិតថ្លៃដីធ្លី និងការអភិវឌ្ឍន៍ទីផ្សារដី ។[២៥] បើសិនកត្តាផ្សេងៗទៀតមានស្មើគ្នា ផលប៉ះពាល់នៃការចុះបញ្ជីដីធ្លីនៅក្នុងភូមិមានទីតាំងនៅតាមដងផ្លូវជាតិ និងនៅជិតទីផ្សារ និងមជ្ឈមណ្ឌលរដ្ឋបាល គឺប្រហែលមានច្រើនជាង នៅក្នុងភូមិមានទីតាំងនៅឆ្ងាយពីផ្លូវជាតិ ឆ្ងាយពីទីផ្សារ និងឆ្ងាយពីមជ្ឈមណ្ឌលរដ្ឋបាល ។

**តារាង ៥.២ក. លទ្ធភាពទទួលបានឥណទាននៅតាមឃុំ**

| ឃុំ | អេស៊ីលីដា | ស្ថាប័ន មីក្រូហិរញ្ញវត្ថុ,NGO | ផ្សេងទៀត | ចំងាយមធ្យម |
|---|---|---|---|---|
| | | | | |
| ត្រពាំងសាប | yes | two reported | one SHG | 5 |
| រវៀង | yes | two reported | one source reported | 7.5 |
| ជើងគោ | yes | yes | | 10 |
| ព្រៃទប់ | yes | yes | | 13 |
| ទឹកល្អក់ | | yes | | 13.5 |
| ស្រយ៉ូវ | yes | | yes | 7 |
| ទីពោធិ៍ | | | | ~ 25 |
| សំបូរ | yes | yes | one SHG reported | 18.75 |
| ស្រង៉ែ | | | | 12 |
| រលាប្អៀរ * | yes | one reported | one source report | 10 |
| ច្រេស * | | yes | one source report | ~ 5.0 |

* *ខេត្តកំពង់ឆ្នាំងសំរាប់ត្រួតពិនិត្យ*

ឧទាហរណ៍ដ៏ល្អមួយក្នុងរឿងនេះ គឺពីភាពផ្ទុយគ្នាដែលបានពិនិត្យឃើញរវាងឃុំ២ នៃគំរោង LMAP នៅក្នុងខេត្តកំពង់ធំ (សូមមើលតារាង ៥.២ក ខាងលើ) ។ ឃុំស្រយ៉ូវ ស្ថិតនៅតាមដងផ្លូវជាតិលេខ ៦ ចំងាយប្រហែល ៥គ.ម ពីទីរួមខេត្ត ។ យោងតាមលទ្ធភាពទទួលបានសេវាកម្មឥណទានផ្លូវការ (ដូចជា ធនាគារអេស៊ីលីដា និងស្ថាប័នផ្សេងទៀត) សេវាកម្មផ្សព្វផ្សាយបច្ចេកទេស មួយចំនួន និងស្ថានភាពនៅជិតទីផ្សារក្នុងតំបន់ ភូមិចំនួន៤ ក្នុងឃុំស្រយ៉ូវ ត្រូវបានចាត់ទុកថា ស្ថិតក្នុងតំបន់មានសមត្ថភាពខ្ពស់ (High Capacity Area: HCA) ។ ចំនែកឯឃុំទីប៉ូ វិញ គឺមានទីតាំងនៅឆ្ងាយពីផ្លូវធំ មានការលំបាកក្នុងការទទួលបានសេវាកម្មឥណទាន និងទីផ្សារ ហើយអាចទទួលបានសេវាកម្មផ្សព្វផ្សាយបច្ចេទេសតែម្តងម្កាលប៉ុណ្ណោះ ។ ថ្វីបើនៅ

[២៥] Sophal and Acharya (2002) ធ្វើការពិភាក្សាទៅលើការផ្ទេរដី នៅក្នុងបរិបទ នៃទីក្រុងតូច ឬធំនៅតាមខេត្តមួយចំនួន ។

ឃុំទីប៉ូ មានផ្លូវជនបទល្អក្តី ប៉ុន្តែស្ថានភាពនៅឆ្ងាយ គឺជាចំណុចចាញ់ប្រៀបក្នុងការទទួលបានសេវាកម្មអភិវឌ្ឍន៍ជនបទ ។ រឿងនេះធ្វើឱ្យភូមិចំនួន ៤ នៅឃុំទីប៉ូ[២៦] ស្ថិតក្នុងតំបន់មានសមត្ថភាពទាប ( Low Capacity Area: LCA) ។

មានឧទាហរណ៍មួយចំនួនទៀតពាក់ព័ន្ធជាមួយឃុំចំនួន៣ នៅកំពង់សោម ក្នុងនេះមានឃុំពីរគឺ ជើងគោ និងព្រៃនប់ ដែលមានទីតាំងនៅតាមដងផ្លូវជាតិលេខ ៤ និងនៅជិតតំបន់ទីផ្សារ។ ឃុំជើងគោ នៅជិតទីប្រជុំជនវាលរិញ ដែលមានទីផ្សាររស់រវើក និងដែលនៅទីនោះមានសាខាធនាគារ ACLEDA រីឯឃុំព្រៃនប់គឺមានទីផ្សារក្នុងមូលដ្ឋានផ្ទាល់ដែលកំពុងរីកដុះដាល ។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ GRET ក៏បានផ្តល់បច្ចេកទេសដាំដំណាំ និងសេវាកម្មផ្សព្វផ្សាយបច្ចេកទេសមួយចំនួននៅក្នុងតំបន់នេះ ហើយបានជួយបង្កើត EMT ដែលជាស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) ដ៏ល្អមួយសំរាប់បំរើប្រជាពលរដ្ឋក្នុងតំបន់ ។[២៧] ឃុំទាំងពីរនេះត្រូវបានចាត់ទុកជាតំបន់សមត្ថភាពខ្ពស់ (HCA) ។[២៨] ឃុំទឹកល្អក់ស្ថិតនៅតាមដងផ្លូវទើបជួសជុលកែលំអមួយ ដែលភ្ជាប់ពីវាលរិញទៅកំពត ។ ជាលទ្ធផល ប្រជាពលរដ្ឋនៅភូមិទួល និងភូមិកំពង់ស្មាច់តូច សព្វថ្ងៃអាចទៅមកទីផ្សារបានងាយស្រួលជាងមុន និងបានប្រើប្រាស់សេវាកម្មឥណទាននៅវាលរិញ ថ្វីបើភូមិកំពង់ស្មាច់តូចមានទីតាំងនៅឆ្ងាយបន្តិចពីផ្លូវធំក្តី ។

**តារាង ៥.២ខ. ការអភិវឌ្ឍន៍ និងសេវាកម្មផ្អែកសង្គមកិច្ចនៅតាមឃុំ**

| ភូមិ | ពិន្ទុសេវាបច្ចេកទេសកសិកម្ម | សេវាសុខាភិបាល នឹងត្រូវបង្ហើយ | NGOs/ភូមិ | ផ្លូវថ្នល់ |
|---|---|---|---|---|
| ត្រពាំងសាប | 2.0 | | 2.0 | HW-3, 2nd |
| រវៀង | 4.5 | | 2.0 | HW-3, 2nd |
| ជើងគោ | 5.0 | | 2.5 | HW-4 |
| ព្រៃនប់ | 3.5 | | 3.0 | HW-4, 2nd, Canal |
| ទឹកល្អក់ | 5.5 | | .75 | HW, 2nd |
| ស្រយ៉ូវ | 8.25 | | 3.0 | HW-6, 2nd |
| ទីពោធិ៍ | 3.5 | | 6.25 | 2nd, 3rd |
| សំបូរ | 5.85 | | 1.5 | HW, 2nd |
| ស្រង៉ែ | 3.0 | | 2.7 | HW-6, 2nd |
| រលាប្អៀរ * | 2.75 | | 2.0 | HW-5, 2nd, 3rd |
| ច្រេះ * | 5.75 | | 3.0 | HW-5, 2nd, 3rd |

* *ខេត្តកំពង់ឆ្នាំងសំរាប់ត្រួតពិនិត្យ*

ការវាយតំលៃជាទូទៅនេះ ក៏ត្រូវពាក់ព័ន្ធនឹងកត្តាជាច្រើនទៀតដូចជា គុណភាពដី ប្រភពទឹក ការប្រើប្រាស់ដី ឱកាសមានការងារធ្វើ លក្ខណៈប្រជាសាស្ត្រនៅមូលដ្ឋាន និងធាតុចូលសំរាប់ការអភិវឌ្ឍន៍ ។ ឧទាហរណ៍ ដីមានជីជាតិ និងប្រភពទឹក គឺជាកត្តាចំបងដែលបង្កើនផលិតភាពដី ។ ជាទូទៅ ម្ចាស់ដីចូលចិត្តធ្វើវិនិយោគច្រើនជាង ទៅលើដីដែលអាចមានផលិតភាពខ្ពស់ ។ តាមនេះ ភូមិនៅដីទំនាប ដែលលទ្ធភាពខ្លះខាងធារាសាស្ត្រ (និងមានប្រព័ន្ធការពារពីទឹកជំនន់) អាចទទួលផលប្រយោជន៍ពីគំរោងចុះបញ្ជីដីធ្លី បានច្រើនជាងភូមិឯទៀត ។ ប៉ុន្តែរឿងនេះ ក៏អាចជាប់ទាក់ទងនឹងថ្លៃធាតុចូល និងថ្លៃធាតុចេញនៃផលិតកម្ម

[២៦] ត្រភាក ឈូករំដួល សំរោង និងផ្លុង ។
[២៧] EMT ត្រូវបានគេស្គាល់ជាស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត
[២៨] ចំការកៅស៊ូ ត្រពាំងគៀ ព្រៃនប់ ១ និងបាយក្រាំង

ផងដែរ ។ ឧទាហរណ៍ នៅឃុំទីប៉ូ ម្ចាស់ដីអាចផ្លាស់ប្តូរពីការធ្វើស្រែ ទៅដាំដើមស្វាយចន្ទីវិញ បើសិនគ្រាប់ស្វាយចន្ទីឡើងថ្លៃច្រើនជាងស្រូវអង្ករ ។ ដូច្នេះ ការចុះបញ្ជីដីធ្លីអាចមាន ផលប៉ះពាល់គួរកត់សំគាល់បានមួយចំនួនពីមួយឆ្នាំទៅមួយឆ្នាំ ថ្វីបើឃុំទីប៉ូមានទីតាំងចាញ់ប្រៀបគេក្តី ។

ភាពចំរុះមុខនៃប្រាក់ចំនូល និងឱកាសការងារ ក៏ជាកត្តាសំខាន់មួយដែរ ។ ប្រជាពលរដ្ឋដែលមានចំណូលពីច្រើនប្រភពគេអាចគ្រប់គ្រងលើកំចីធំៗ បានល្អជាង អ្នកដែលពឹងផ្អែកទៅលើការធ្វើស្រូវតែមួយមុខ ហើយក៏អាចធ្វើវិនិយោគបានច្រើនជាងនៅក្នុងផលិតកម្ម ។ ឧទាហរណ៍ មានប្រជាពលរដ្ឋជាច្រើន នៅភូមិក្រុងថាណុងនៃឃុំរវៀង (ខេត្តតាកែវ) បានធ្វើការត្បាញក្រណាត់សូត្រ ដែលជាប្រភពចំណូលបន្ថែមមួយ អាចយកទៅធ្វើវិនិយោគក្នុងផលិតកម្មកសិកម្មបាន ។ ប័ណ្ណកម្មសិទ្ធិដីធ្លី ក៏អាចយកទៅប្រើប្រាស់ដើម្បីទទួលបានប្រាក់កំចីសំរាប់ធ្វើវិនិយោគនៅក្នុងផលិតកម្មសូត្រ ។ ដូចគ្នាដែរ នៅភូមិកំពង់ស្នាច់តូច (ឃុំទឹកល្អក់) គ្រួសារភាគច្រើនបានយកការនេសាទ ធ្វើជាមុខរបរបឋម ឬបន្ទាប់បន្សំ ។ ប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងភូមិនេះអាចជួយឱ្យប្រជានេសាទទទួលបានឥណទានសំរាប់វិនិយោគបង្កើន សមត្ថភាពធ្វើនេសាទរបស់ខ្លួន ។

ទាក់ទិននឹងលក្ខណៈប្រជាសាស្ត្រ និងលំនាំប្រើប្រាស់ដី ភូមិគំរូនានា មានកំរិតដង់ស៊ីតេប្រជាពលរដ្ឋខុសគ្នាច្រើន បើគិតតាមការកាន់កាប់ដីកសិកម្មជាមធ្យមក្នុងមួយគ្រួសារ ដោយនៅភូមិខ្លះ ការកាន់កាប់ដីមានកំរិតទាបត្រឹម ០,៤ហិកតា ក្នុងមួយគ្រួសារ ឯភូមិខ្លះទៀតមានកំរិតខ្ពស់រហូតដល់ ៦,២ហិកតាក្នុងមួយគ្រួសារ ។ ទិន្នន័យអង្កេតបឋម បានបញ្ជាក់គាំទ្រលើការកត់សំគាល់ពីខាងដើមដែលថា កសិដ្ឋានតូចៗនៅកម្ពុជា ច្រើនមានផលិតភាពខ្ពស់ជាង បើគិតតាមទិន្នផលក្នុងមួយហិកតា ។ រឿងនេះប្រហែលមកពីពួកគេមានដីល្អជាង ប៉ុន្តែលក្ខណៈនេះមិនមែនសុទ្ធតែនាំឱ្យមានសន្តិសុខស្បៀងនោះទេ (បង្ហាញនៅក្នុងផ្នែក ៦.២ ខាងក្រោម) ។ ជាលទ្ធផល កសិករតូចៗមួយចំនួន អាចមានការស្ទាក់ស្ទើរក្នុងការធ្វើវិនិយោគច្រើនទៀតទៅលើផលិតកម្មកសិកម្ម ដើម្បីបង្កើនចំនួនប្រភពប្រាក់ចំនូល សំរាប់ទិញម្ហូបអាហារបន្ថែម និងដោះស្រាយតំរូវការបន្ទាន់ក្នុងគ្រួសារ ។ ផ្ទុយទៅវិញ គ្រួសារកាន់កាប់ដីធំ អាចមានលំនាំប្រើប្រាស់ដីច្រើនបែបយ៉ាង ដូច្នេះចំណូលបានពីសកម្មភាពកសិកម្មរបស់ពួកគេអាចមានមូលដ្ឋានចំរុះច្រើនមុខជាង ។ ឧទាហរណ៍ នៅឃុំទីប៉ូ ដែលមានអត្រាកាន់កាប់ដីជាមធ្យមក្នុង មួយគ្រួសារកំរិតខ្ពស់ មានគ្រួសារមួយចំនួនបានធ្វើការដាំដុះស្វាយចន្ទី ជាបន្ថែមលើការធ្វើស្រែវស្សា ។ នៅភូមិពុកយ៉ុក មានគ្រួសារមួយចំនួនបានបង្កបង្កើនផលនៅលើដីស្រែលិចទឹកដែលនៅឆ្ងាយពីភូមិ ។ ភូមិនានាដែលមានផ្ទៃដីធំ អាចមានដីចំការខ្លះ ដែលអាចដាំដំណាំពាណិជ្ជកម្មបាន (បង្ហាញក្នុង ផ្នែក ៦.២ ខាងក្រោម) ។

ធាតុចូលសំរាប់អភិវឌ្ឍន៍ ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងសំភារៈជាមូលធន គឺជាកត្តាមួយទៀត ដែលអាចមានឥទ្ធិពលទៅលើវិសាលភាព និងកំរិតនៃផលប៉ះពាល់ពីការចុះបញ្ជីដីធ្លីនៅក្នុងតំបន់ខ្លះ ។ នៅក្នុងតំបន់យកធ្វើជាគំរូ ឃុំសំបូរក្នុងខេត្តកំពង់ចាមអាចជាកន្លែងមានសន្ទុះខ្លាំងជាងគេខាងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនាពេលបច្ចុប្បន្ន ។ ឃុំនេះស្ថិតនៅអមសងខាងផ្លូវ ដែលតភ្ជាប់ផ្លូវជាតិលេខ ៦ (ត្រង់ចន្លោះពីភ្នំពេញ ទៅខេត្តកំពង់ចាម) ទៅនឹងកំពង់ចំលងព្រែកក្តាម ដើម្បីឆ្លងកាត់ទន្លេសាបទៅកាន់ផ្លូវជាតិលេខ ៥ ។ ផ្លូវនេះបានធ្វើការកែលំអឡើងវិញ ហើយបច្ចុប្បន្នគឺមានការពិភាក្សាមួយចំនួនពីលទ្ធភាពឱ្យអ្នកខាងក្រៅមកវិនិយោគធ្វើទំនប់ធំមួយ ដើម្បីការពារទឹកជំនន់ ។

វត្ថុមានសំភារៈបរិក្ខារកសិកម្ម និងចំនួនសត្វសំរាប់អូសទាញនៅក្នុងភូមិ គឺសូចនាករក៏ល្អមួយ សំរាប់បង្ហាញពី កំរិតធ្វើយន្តកម្មលើផលិតកម្មកសិកម្ម ។ ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដែលមានការវិនិយោគទុនច្រើនរួចហើយក្នុងផលិតកម្មកសិកម្ម អាចមានប្រើប្រាស់ច្រើននូវប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីទទួលបានឥណទានសំរាប់ធ្វើវិនិយោគថែមទៀត ។ ក្នុងនេះ ភូមិមួយនៅក្នុងឃុំស្រង៉ែ អាចត្រូវបានចាត់ទុកជា ភូមិមានសក្តានុពលខ្ពស់ ។ ប៉ុន្តែ តំបន់ដែលមានចំនួនសត្វចិញ្ចឹមច្រើនក្នុងមួយគ្រួសារក៏អាចមានសមត្ថភាពផលិតកម្មជាសក្តានុពលខ្ពស់ដែរ ពីព្រោះមានកំលាំងអូសទាញគ្រប់គ្រាន់ដើម្បីធ្វើកសិកម្ម ព្រមទាំងទ្រព្យសកម្មសំរាប់ប្រើការនៅពេលមានវិបត្តិ និងតំរូវការបន្ទាន់ផ្សេងៗ ។

## ៥.២.១. សេចក្តីសង្ខេប

ទីតាំងភូមិដែលនៅជិតផ្លូវថ្នល់ក្រាលកៅស៊ូ និងនៅជិតមជ្ឈមណ្ឌលពាណិជ្ជកម្ម និងរដ្ឋបាលក្នុងមូលដ្ឋាន គឺជាសូចនាករដ៏ល្អមួយបង្ហាញពីលទ្ធភាពមានទីផ្សារ ក៏ដូចជាឥណទាន សេវាកម្មផ្សព្វផ្សាយបច្ចេកទេស និងសេវាកម្មសង្គម ។ យើងកត់សំគាល់ថាគ្រួសារមានទីតាំងនៅជិតមជ្ឈមណ្ឌលទាំងនេះ ហាក់មានប្រៀបក្នុងការទទួលបានផលប្រយោជន៍ពីប័ណ្ណកម្មសិទ្ធដីធ្លី ជាងគ្រួសារដែលមានទីតាំងនៅឆ្ងាយ ។ ប៉ុន្តែនៅមានកត្តាមួយចំនួនទៀត ដែលត្រូវយកមកពិចារណា ។ ដូច្នេះ ភូមិដែលមានទីតាំងល្អ មានប្រភពទឹក មានលំនាំប្រើប្រាស់ដីច្រើនបែប និងមានឱកាសការងារធ្វើច្រើនមុខ ក៏ដូចជាធាតុចូលផ្សេងៗដើម្បីអភិវឌ្ឍ យើងចាត់ជាតំបន់មានផលប៉ះពាល់ជាសក្តានុពលខ្ពស់ (High Potential Impact areas: HPIs) ។ ផ្ទុយទៅវិញ តំបន់មានផលប៉ះពាល់ជាសក្តានុពលទាប (Low Potential Impact areas: LPIs) សំដៅដល់ភូមិដែលមានទីតាំងនៅឆ្ងាយពីផ្លូវថ្នល់ និង/ឬ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងរដ្ឋបាល ខ្វះប្រភពទឹក មានលំនាំប្រើប្រាស់ដីតែមួយមុខ ព្រមទាំងឱកាសការងារធ្វើដ៏តិចតួចក្រៅពីការធ្វើស្រែ ។

# ជំពូក ៦. ការរកឃើញ និងការវិភាគលើគ្រួសារនៅជនបទ (តំបន់អង្កេតនៃគំរោង LMAP)

នៅពេលដែលកត្តាភូមិ និងគ្រួសារត្រូវបានដាក់រួមបញ្ចូលគ្នា គំរូសាមញ្ញមួយត្រូវបានរចនាឡើងដែលអាចធ្វើការទស្សន៍ទាយអំពីផលប៉ះពាល់ជាសក្តានុពលនៃការចុះបញ្ជីដីធ្លី ។ ដោយផ្អែកលើគំរូនេះ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ នឹងទទួលបានផលចំណេញយ៉ាងច្រើននៅក្នុងតំបន់មានសមត្ថភាពខ្ពស់ ដោយសារការធ្វើកសិកម្មជាលក្ខណៈប្រពលវប្បកម្ម និង/ឬទីផ្សារដីកំពុងមានតំរូវការ ។ ផ្ទុយទៅវិញ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលទាប នឹងទទួលបានផលចំណេញតិចនៅក្នុងតំបន់សមត្ថភាពទាប ដោយសារការធ្វើកសិកម្មតាមបែបយថាផល ហើយទីផ្សារដី មានតំរូវការតិចតួច ។ នៅក្នុងចន្លោះប្រភេទទាំងពីរខាងលើ គឺសំដៅលើគ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ ស្ថិតក្នុងតំបន់សមត្ថភាពទាប ហើយនិងគ្រួសារមានផលប៉ះពាល់ជាសក្តានុពលទាប ស្ថិតក្នុងតំបន់សមត្ថភាពខ្ពស់ ។ កំរិតនៃផលប៉ះពាល់ក្នុងប្រភេទថ្មីទាំងពីរនេះ អាចផ្អែកទៅលើអត្រានៃការផ្លាស់ប្តូរ ឬការវិវត្តន៍របស់កត្តាគន្លឹះផ្សេងៗ ។ ឧទាហរណ៍ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ ស្ថិតក្នុងតំបន់សមត្ថភាពទាប អាចឈរនៅទីតាំងមានប្រៀប ដើម្បីធ្វើការប្រកួតប្រជែងក្នុងការទទួលបានផលចំណេញពីការចុះបញ្ជីដីធ្លី នៅពេលដែលមានការអភិវឌ្ឍន៍កើតឡើង ។ នៅខណៈនេះដែរ គ្រួសារមានប៉ះពាល់ជាសក្តានុពលទាបមានលទ្ធភាពប្រកួតប្រជែងតិចតួច ក្នុងការទទួលបានផលចំណេញ នៅក្នុងតំបន់សមត្ថភាពខ្ពស់ លើកលែងតែពួកអាចមានលទ្ធភាពប្រើប្រាស់កត្តានានាដែលមានសមត្ថភាពខ្ពស់ (ឧ. ឥណទាន និងសេវាកម្មបច្ចេកទេស) ។

ក្របខ័ណ្ឌនៃការវិភាគ ដែលកើតឡើងពីការពិចារណាទៅលើគ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ និងទាបនៅក្នុងបរិបទនៃភូមិមានសមត្ថភាពខ្ពស់ និងទាប វាផ្តល់នូវមធ្យោបាយដ៏ល្អមួយ សំរាប់ធ្វើការវាយតំលៃពីផលប៉ះពាល់ជាសក្តានុពលនៃប័ណ្ណកម្មសិទ្ធិដីធ្លីលើសេដ្ឋកិច្ច និងសង្គម ដូចបានទស្សន៍ទាយតាមទ្រឹស្តី និងការស្រាវជ្រាវជាក់ស្តែងកន្លងមក ។ ដើម្បីធ្វើឱ្យមានភាពងាយស្រួល និងស៊ីសង្វាក់គ្នា ការពិភាក្សាជាបន្តបន្ទាប់នឹងអនុវត្តតាមចំណុចទូទៅ ដូចដែលបានប្រើប្រាស់នៅក្នុងផ្នែកខាងដើម (ផ្នែក ៤.២.១.) ដើម្បីពិភាក្សាអំពីទ្រឹស្តីនៃការស្រាវជ្រាវ ។

## ៦.១. ឥណទាន: សកម្មភាពខ្ចីប្រាក់ និងការផ្តល់ប្រាក់ឱ្យខ្ចីនៅថ្នាក់គ្រួសារនីមួយៗ

តាមរយៈក្រុមអង្កេតនៃគំរោង LMAP ៥៣១គ្រួសារ (ប្រហែលជា ៥៤.៧% នៃគ្រួសារអង្កេត) បានរាយការណ៍ថា បានខ្ចីប្រាក់ចំនួន ៧៤៣ ករណីនៅក្នុងរយៈពេល ៦ខែ មុនពេលការធ្វើអង្កេត ។ តួលេខនេះបង្ហាញថា កំចីប្រហែលជា ១.៤០ករណីត្រូវបានខ្ចីក្នុងចំណោមគ្រួសារនីមួយៗ ។ បុរស និងស្ត្រីជាមេគ្រួសារបានខ្ចីប្រាក់ចំនួន ៧៩% និង ២១% រៀងគ្នានៃប្រាក់កំចី ។ តាមតារាង (តារាង៦.១ក) បង្ហាញថា ប្រហែលជា ៦០% នៃកំចី ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធក្រៅផ្លូវការ ដែលក្នុងនោះមានសាច់ញាតិ និងមិត្តភ័ក្តិ (៤៣.៧%) និងអ្នករកស៊ីចងការប្រាក់ (១៦.០%) ។ ចំនែកនៅសល់ ៣១% នៃកំចីបានទទួលពីប្រព័ន្ធ

ផ្លូវការ ក្នុងនោះមានធនាគារ ACLEDA (៦,១%) និង MFI (២៤,៩%) ។ ប្រហែល ៩% នៃកំចីបានទទួលពីស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល ពាក់កណ្តាលផ្លូវការ "semi-formal" ។

**តារាង ៦.១ក. ប្រភពឥណទាន (% នៃចំនួនកំចីសរុប)**

| ទំហំដី (ហ.ត) | សាច់ញាតិ/មិត្តភក្តិ | | អ្នកចងការ | | អង្គការ NGOs | | អេស៊ីលីដា | | ស្ថាប័នមីក្រូហិរញ្ញវត្ថុ | | កំចីសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | |
| 0 | 13.3 | 25.0 | 26.7 | 33.3 | 10.0 | 0 | 10.0 | 25.0 | 4 0.0 | 16.7 | 30 | 12 |
| < 0.5 | 43.5 | 41.5 | 20.2 | 13.2 | 4.8 | 15.1 | 4.0 | 1.9 | 29.4 | 28.3 | 124 | 53 |
| 0.5 – 0.99 | 53.7 | 38.9 | 13.6 | 11.1 | 8.6 | 25.0 | 8.6 | 2.8 | 5.4 | 22.2 | 162 | 36 |
| 1.0 – 1.99 | 48.1 | 46.9 | 15.3 | 15.6 | 5.3 | 3.1 | 3.8 | 0 | 27.4 | 34.4 | 131 | 32 |
| 2.0 – 2.99 | 36.0 | 30.0 | 12.5 | 40.0 | 15.6 | 10.0 | 9.4 | 0 | 27.6 | 20.0 | 64 | 10 |
| > 3.0 | 43.2 | 28.6 | 10.8 | 28.6 | 12.2 | 7.1 | 8.1 | 7.1 | 25.8 | 28.5 | 74 | 14 |
| | | | | | | | | | | | | |
| % សរុប | 45.0 | 38.9 | 15.6 | 17.8 | 8.4 | 12.7 | 6.7 | 3.8 | 24.5 | 26.7 | 585 | 157 |
| កំចីសរុប | 263 | 61 | 91 | 28 | 49 | 20 | 39 | 6 | 143 | 42 | 585 | 157 |
| | | | | | | | | | | | | |
| សរុប | 324 | | 119 | | 69 | | 45 | | 185 | | 742 | |
| % កំចីសរុប | 43.7 | | 16.0 | | 9.3 | | 6.1 | | 24.9 | | | |

តារាង ៦.១ខ ខាងក្រោមបង្ហាញថា កំចីសំរាប់វិនិយោគលើការផលិតមានចំនួន ៣៦% នៃឥណទានទាំងអស់នៅក្នុងក្រុមអង្កេតនៃតំបន់គំរោង LMAP ក្នុងនោះមានអាជីវកម្មខ្នាតតូច (១២%) ផលិតកម្មកសិកម្ម (១៤,៤%) និងការចិញ្ចឹមសត្វ (៩,៦%) ។ ភាគច្រើនបុរសជាមេគ្រួបានខ្ចីប្រាក់ សំរាប់ធ្វើកសិកម្ម និងអាជីវកម្ម រីឯស្ត្រីជាមេគ្រួ ខ្ចីប្រាក់សំរាប់ការចិញ្ចឹមសត្វ ។

ទោះជាយ៉ាងណា ការចំណាយលើការថែទាំសុខភាព (២១,៧%) និងម្ហូបអាហារ (១៧,៩%) មានតួលេខ ជិតដល់ ៤0% នៃឥណទានទាំងអស់នៅក្នុងចំណោមក្រុមអង្កេត ។ មានភាគរយប្រហាក់ប្រហែលគ្នា ចំពោះបុរស និងស្ត្រីជាមេគ្រួក្នុងការខ្ចីប្រាក់ដើម្បីថែទាំសុខភាព ប៉ុន្តែការខ្ចីប្រាក់ដើម្បីបំពេញកង្វះខាតម្ហូបអាហារ ស្ត្រីជាមេគ្រួមានភាគរយខ្ពស់ជាង ។ តាមតួលេខនេះ បុរសនិងស្ត្រីជាមេគ្រួរងផលប៉ះពាល់ដោយជំងឺដូចគ្នា ប៉ុន្តែស្ត្រីជាមេគ្រួមានសមត្ថភាពតិចជាងបុរសក្នុងការផលិតម្ហូបអាហារឱ្យបានគ្រប់គ្រាន់ ។ មានកំចី ២៤,៥% សំរាប់ប្រើប្រាស់នៅក្នុង សកម្មភាពផ្សេងទៀត ដូចជា ពិធីបុណ្យសង្គម ការសង់លំនៅដ្ឋាន និងការធ្វើដំណើរ ។ រីឯចំនួនភាគរយនៃកំចីផ្សេងទៀត មានតិច ឬច្រើន វាអាស្រ័យទៅលើយេនឌ័រ និងទំហំនៃការកាន់កាប់ដី ។

គ្រួសារស្ថិតនៅចន្លោះកាន់កាប់ដី ២ថ្នាក់ ធំជាងគេ មានបំណងខ្ចីប្រាក់តិចដងជាងគ្រួសារផ្សេងទៀត នេះប្រហែលជាពួកគេមានសមត្ថភាពល្អជាងមុន ក្នុងការពឹងផ្អែកទៅលើធនធានរបស់ខ្លួនដើម្បីបង្កបង្កើនផល ។ គ្រួសារស្ថិតនៅចន្លោះកាន់កាប់ដី ៣ថ្នាក់ធំជាងគេ មានបំណងខ្ចីប្រាក់ច្រើនសំរាប់គោលបំណងផលិតកម្មនានា ជាងក្រុមកាន់កាប់ដីតូច ។ កំរិតនៃការខ្ចីប្រាក់សំរាប់កង្វះខាតម្ហូបអាហារ ហាក់ដូចជាមានច្រើនដដែលនៅក្នុងចំណោមគ្រួសារទាំងអស់ ប៉ុន្តែគ្រួសារកាន់កាប់ដីតូច មានបំណងខ្ចីប្រាក់សំរាប់ការថែទាំសុខភាពច្រើនជាងគ្រួសារកាន់កាប់ដីធំ ។

**តារាង៦.១ខ. ការប្រើប្រាស់ឥណទានដោយគ្រួសារ**

| ទំហំដី | កសិកម្ម | | ជំនួញ | | កង្វះស្បៀង | | ថែទាំសុខភាព | | ការចិញ្ចឹមសត្វ | | ផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| 0 | 3.3 | 0 | 33.3 | 33.3 | 20.0 | 8.3 | 10.0 | 33.3 | 10.0 | 8.3 | 23.3 | 16.8 | 30 | 12 |
| < 0.5 | 9.5 | 3.8 | 8.7 | 9.6 | 15.9 | 25.0 | 31.7 | 19.2 | 7.9 | 15.4 | 26.3 | 27.0 | 126 | 52 |
| 0.5 – 0.99 | 12.3 | 19.4 | 13.0 | 2.8 | 15.4 | 30.6 | 18.5 | 11.1 | 9.3 | 16.7 | 31.5 | 19.4 | 162 | 36 |
| 1.0 – 1.99 | 15.8 | 0 | 10.5 | 0 | 21.8 | 28.1 | 27.1 | 31.3 | 5.3 | 21.9 | 19.5 | 18.7 | 133 | 32 |
| 2.0 – 2.99 | 28.1 | 20.0 | 10.9 | 0 | 20.3 | 10.0 | 15.6 | 10.0 | 4.7 | 20.0 | 20.4 | 40.0 | 64 | 10 |
| > 3.0 | 25.0 | 42.9 | 20.8 | 7.1 | 6.9 | 0 | 15.3 | 14.3 | 12.5 | 0 | 19.5 | 35.7 | 72 | 14 |
| | | | | | | | | | | | | | | |
| % សរុប | 15.3 | 10.9 | 13.3 | 7.1 | 16.7 | 22.4 | 22.1 | 19.9 | 8.0 | 15.4 | 24.6 | 24.3 | | |
| កំចីសរុប | 90 | 17 | 78 | 11 | 98 | 35 | 130 | 31 | 47 | 24 | 144 | 38 | 587 | 156 |
| សរុប/គោលបំនង | 107 | | 89 | | 133 | | 161 | | 71 | | 182 | | 743 | |
| % សរុប | 14.4 | | 12.0 | | 17.9 | | 21.7 | | 9.6 | | 24.5 | | 743 | |

តារាង ៦.១គ ខាងក្រោមបង្ហាញថា ទំហំកំចីជាមធ្យមពីធនាគារ ACLEDA មានប្រហែល ៨៩ម៉ឺនរៀល ដែល គេគិតថាវាខ្ពស់ជាងប្រភពផ្សេងទៀត ។ មានប្រភពគួរឱ្យភ្ញាក់ផ្អើលមួយទៀតគឺ MFIs អនុញ្ញាតឱ្យខ្ចីជាមធ្យម ២៨,១៣ម៉ឺនរៀល ដែលជាតួលេខមួយជិតស្មើទំហំកំចីជាមធ្យមពីបងប្អូន និងមិត្តភ័ក្តិ ២៩,៥ម៉ឺនរៀល ។ ទំហំកំចីជា មធ្យមពីអ្នកចងការប្រាក់ និង NGOs មានប្រហាក់ប្រហែលគ្នាគឺ ២៣,៧៧ម៉ឺនរៀល និង ២៥,១៩ម៉ឺនរៀលរៀងគ្នា ។ ជាទូទៅ គេកត់សំគាល់ថា ទំហំកំចីជាមធ្យមសំរាប់សកម្មភាពផលិតកម្ម (ឧ. ការធ្វើជំនួញ ការធ្វើកសិកម្ម ការចិញ្ចឹមសត្វ) មានកំរិតខ្ពស់ជាងទំហំកំចីជាមធ្យមប្រើប្រាស់សំរាប់កង្វះខាតម្ហូបអាហារ និងការថែទាំសុខភាព ។ ប៉ុន្តែ ទំហំកំចីជាមធ្យមផ្សេងទៀត (៤២,៧២ម៉ឺនរៀល) ជាកំរិតទី២ បើធៀបនឹងទំហំកំចីជាមធ្យម សំរាប់សកម្មភាពជំនួញ (៥៣,២៦ម៉ឺនរៀល) ។

**តារាង ៦.១គ. ប្រភពឥណទាន**

| គោលបំណង | សាច់ញ្ញាតិ/មិត្តភក្តិ | | អ្នកចងការ | | អង្គការ NGOs | | អេស៊ីលីដា | | ស្ថាប័ន MFIs | | កំចីសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ប្រាក់មធ្យម | ចំនួន | ប្រាក់មធ្យម | ចំនួន | ប្រាក់មធ្យម | ចំនួន | ប្រាក់មធ្យម | ចំនួន | ប្រាក់មធ្យម | ចំនួន | ប្រាក់មធ្យម |
| កសិកម្ម | 36 | 21.97 | 22 | 22.39 | 14 | 20.71 | 6 | 59.2 | 28 | 33.07 | 106 | 26.9 |
| ជំនួញ | 18 | 72.57 | 14 | 24.46 | 14 | 20.79 | 14 | 137.9 | 28 | 29.14 | 88 | 53.26 |
| កង្វះស្បៀង | 70 | 13.61 | 25 | 19.98 | 3 | 10.67 | 10 | 27.7 | 26 | 12.36 | 134 | 15.55 |
| សុខុមាលភាព | 82 | 24.88 | 22 | 21.05 | 7 | 24.00 | 7 | 45.0 | 42 | 15.16 | 160 | 22.65 |
| ការចិញ្ចឹមសត្វ | 15 | 36.53 | 5 | 14.8 | 17 | 19.82 | 4 | 140.0 | 34 | 28.59 | 75 | 33.23 |
| ផ្សេងទៀត | 103 | 38.07 | 31 | 30.87 | 14 | 44.22 | 6 | 124.2 | 30 | 53.93 | 184 | 42.72 |
| សរុប | 324 | 29.5 | 119 | 23.77 | 69 | 25.19 | 47 | 89.00 | 188 | 28.13 | 747 | 31.60 |
| % សរុប | 43.40 | | 15.9 | | 9.2 | | 6.3 | | 25.2 | | | |

ទិន្នន័យនេះ មានសារៈសំខាន់ណាស់ក្នុងការប្រៀបធៀប ជាមួយនឹងការសិក្សាផ្សេងទៀត ។ ឧទាហរណ៍ សុផល និង Acharya (2002) បានរកឃើញថា ប្រភពឥណទានធំជាងគេ គឺបានមកពីសាច់ញ្ញាតិ និងមិត្តភ័ក្តិ (៤៤,៥%) បន្ទាប់មកពីអ្នក

ចងការប្រាក់ (៣៣,១%) ពីស្ថាប័នផ្លូវការ (១៥,៧%) និងភាគរយនៅសល់បានមកពីប្រភពផ្សេងទៀត ។ ទោះបីភាគរយនៃប្រាក់កំចីពីសាច់ញាតិ និងមិត្តភ័ក្តិ អាចកត់សំគាល់ថាមានទំហំប្រហាក់ប្រហែលគ្នាក្តី ប៉ុន្តែភាគរយនៃប្រាក់កំចីពីអ្នកចងការប្រាក់នានា (១៦%) និងស្ថាប័នផ្លូវការ (៣១%) គឺជាក់ស្តែងណាស់ មានភាពបញ្ច្រាសនឹងគំរូអង្កេតមូលដ្ឋាន ។ ការពន្យល់សមរម្យមួយចំពោះបញ្ហានេះ អាចដោយសារវត្តមានដ៏ច្រើន នៃស្ថាប័នឥណទានផ្លូវការនៅក្នុងតំបន់នានានៃគំរោងអង្កេតមូលដ្ឋាន (សូមមើលតារាង ៥.២ក ខាងលើ) បើធៀបនឹងតំបន់ដែលលោក សុផល និង Acharya ធ្វើការសិក្សា ។ ក្នុងករណីនេះ ទិន្នន័យអង្កេតមូលដ្ឋាន អាចឆ្លុះបញ្ចាំងទៅលើការរីកធំឡើងជាទូទៅនៃ MFIs នៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជាតាំងពីឆ្នាំ២០០១ ។ មានការស្នើផងដែរថា នៅតំបន់មានវត្តមានឥណទាន ប្រជាពលរដ្ឋអាចមានទំនោរប្រើប្រាស់ស្ថាប័នផ្លូវការជាងទៅរកអ្នកចងការប្រាក់ បើសិនជាគេអាចទប់ទល់នឹងការប្រាក់បាន ហើយអាចបំពេញតំរូវការផ្លូវច្បាប់សំរាប់ធ្វើការដាក់បញ្ចាំ ។

ទិន្នន័យពីទំហំកំចីជាមធ្យមដែលរកឃើញតាមរយៈអង្កេតមូលដ្ឋាននេះ ត្រូវគ្នានឹងទិន្នន័យពីជីវភាពប្រចាំថ្ងៃនៅតាមជនបទ ។ នៅក្នុងការសិក្សាទាំងពីរ ទំហំកំចីជាមធ្យម គឺច្រើនបំផុតបានពីធនាគារ ACLEDA ដែលជាស្ថាប័នមីក្រូហិរញ្ញវត្ថុរឹងមាំបំផុត កំពុងដំណើរការនៅកម្ពុជាក្នុងរយៈពេលមានការសិក្សាអំពីជីវភាពប្រចាំថ្ងៃនៅជនបទ (លោក សុផល និង Acharya ២០០២) បន្ទាប់មកជាកំចីបានពីអ្នកចងការប្រាក់ និងពីសាច់ញាតិ និងមិត្តភ័ក្តិ ។ ភាពខុសគ្នាចំបងគឺថា ស្ថាប័ន MFIs ផ្សេងទៀតមិនបានធ្វើការបញ្ជាក់នៅក្នុងការសិក្សានោះទេ ។ ដូច្នេះយើងរំពឹងថា ទំហំកំចីជាមធ្យមទាំងនេះ អាចធ្លាក់ចុះខ្លះរវាងធនាគារ ACLEDA និងអ្នកចងការប្រាក់ ប៉ុន្តែអង្កេតមូលដ្ឋាន បានរកឃើញថា ទំហំកំចីជាមធ្យម បានពី MFIs ពិតជាតិចជាងទំហំកំចីជាមធ្យមបានពីសាច់ញាតិ និងមិត្តភ័ក្តិមែន ។

ទ្រឹស្តីនៃការស្រាវជ្រាវបានទស្សន៍ទាយថា ចំនួន និងទំហំកំចីជាមធ្យមសំរាប់ធ្វើការវិនិយោគទៅលើផលិតកម្មកសិកម្ម និងសកម្មភាពបង្កើតចំណូលផ្សេងទៀត (ឧ.ការចិញ្ចឹមសត្វ អាជីវកម្មខ្នាតតូច) មានការកើនឡើងបើប្រៀបធៀបជាមួយកំចីសំរាប់ចំណាយប្រើប្រាស់ និងសំរាប់សកម្មភាពផ្សេងទៀត ។ ទ្រឹស្តីនៃការស្រាវជ្រាវ ក៏បានធ្វើការទស្សន៍ទាយផងដែរថា នៅពេលបរិមាណ និងទំហំកំចីកើនឡើង ប្រភពនៃប្រាក់កំចីនឹងប្តូររូបរាងពីស្ថាប័នក្រៅផ្លូវការទៅជាស្ថាប័នផ្លូវការវិញ ។ រឿងនេះសន្មតថា តំរូវការ នៃកំចីសំរាប់ថែទាំសុខភាព និងទិញម្ហូបអាហារ នឹងថយចុះធៀបជាមួយកំចីសំរាប់ផលិតកម្ម ។

កំរងសកម្មភាពទាំងនេះក៏បានសន្មតផងដែរថា ទីផ្សារឥណទាន មានដំណើរការល្អនៅក្នុងតំបន់ជាក់លាក់ណាមួយ (ឧ. មានវត្តមានឥណទាន រឺងតំលៃប្រតិបត្តិការទាប) ហើយថា ប្រជាពលរដ្ឋមានចំណូលចិត្ត និងសមត្ថភាពក្នុងការខ្ចី ។ មានការសន្មតដែរថា អត្រាការប្រាក់របស់ស្ថាប័នផ្លូវការ អាចមានលក្ខណៈល្អជាងអត្រាការប្រាក់របស់អ្នកចងការប្រាក់នៅមូលដ្ឋាន ។ បើកត្តាផ្សេងទៀតមានលក្ខណៈដូចគ្នា យើងសង្ឃឹមថានឹងឃើញបរិមាណធំឡើងៗនៃសកម្មភាពឥណទាន នៅក្នុងតំបន់ដែលស្ថាប័នផ្លូវការកាន់តែមានភាពងាយស្រួល ចំពោះកសិករនៅមូលដ្ឋាន ។ បញ្ហានេះបានស្នើថា ប្រជាកសិករដែលមានទីតាំងកាន់តែជិតតំបន់ទីប្រជុំជនស្រុក និង/ឬមជ្ឈមណ្ឌលទីផ្សារនៅតាមដងផ្លូវ ហាក់ដូចជាទទួលបានឥណទានផ្លូវការច្រើនជាងអ្នកដែលមានទីតាំងនៅឆ្ងាយ រឺនៅតំបន់ដាច់ស្រយាល ។

យើងក៏សង្ឃឹមផងដែរថានឹងបានឃើញនូវសកម្មភាពឥណទានខុសៗគ្នាមួយចំនួន អាស្រ័យទៅលើទំហំកាន់កាប់ដី និងយេនឌ័រនៃមេគ្រួសារទាក់ទងនឹងភាពញឹកញាប់នៃការខ្ចី បរិមាណ និងការប្រើប្រាស់ឥណទាន ។ ឧទាហរណ៍ ការបែងចែក

ឥណទានអាចមានភាពខុសគ្នា អាស្រ័យទៅលើសមត្ថភាពនៃគ្រួសារក្នុងការគ្រប់គ្រង និងប្រើប្រាស់ឥណទានដែលមានទំហំផ្សេងៗគ្នា ។ គ្រួសារក្រីក្រអាច គ្រប់គ្រងបានតែឥណទានតូចៗប៉ុណ្ណោះ ដោយសារការដាក់បញ្ចាំ (ឧ. ទំហំដីឡូត៍) រឺលទ្ធភាពសងត្រលប់វិញតាមតារាងសំណងថេរ ហើយពួកគេអាចបន្តប្រើប្រាស់នូវប្រភពឥណទានផ្សេងទៀត ។ នៅខណៈនេះដែរ គ្រួសារដែលមានដីច្រើន ផលទុនច្រើន និងចំណូលច្រើន អាចប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីទទួលបានឥណទានកាន់តែធំ សំរាប់ពង្រីកសកម្មភាព អាជីវកម្មផ្សេងៗ និង/រឺ ធ្វើកសិកម្មពហុវប្បកម្ម របស់ពួកគេ ។

## ៦.២. ការវិនិយោគលើការងារកសិកម្ម ផលិតភាព និងការប្រើប្រាស់ដី

តារាង ៦.២ក ខាងក្រោមបង្ហាញថា ការចំណាយសំរាប់ផលិតកម្មស្រូវក្នុងរដូវប្រមូលផលយោងតាមអង្កេត គឺភាគច្រើនទៅលើកំលាំងពលកម្មសំរាប់ការរៀបចំដី ការដាំដុះ និងការច្រូតកាត់ ក៏ដូចជាលើការប្រើប្រាស់ជីគីមី ។ បន្ទាប់មកគឺ មានការចំណាយលើធាតុចូលផ្សេងទៀតដូចជា ការបូមទឹកបញ្ចូលស្រែ ការបោកបែន និងការជួលដី ។ ចំណាយជាមធ្យមក្នុងមួយគ្រួសារ អាចនឹងកើនឡើងទៅតាមទំហំនៃការកាន់កាប់ដី ។ ឧទាហរណ៍ ក្នុងចន្លោះនៃការកាន់កាប់ដី ២ តូចជាងគេ មានចំណាយជាមធ្យមពី ១៣,០៣ ទៅ ២១,៥៧ម៉ឺនរៀលក្នុងមួយគ្រួសារ រៀងគ្នា ចំណែកឯចន្លោះនៃកាន់កាប់ដី ២ ធំជាងមានពី ៣១,៦ ទៅ ៥១,៩៨ម៉ឺនរៀលរៀងគ្នា ។ ចន្លោះនៃការកាប់ដីនៅកណ្តាល មានចំណាយជាមធ្យម ៣១,៧៧ម៉ឺនរៀល ។ គ្រួសារកាន់កាប់ដីធំមិនត្រឹមតែមានដីច្រើនប៉ុណ្ណោះទេ ថែមទាំងមានធនធានច្រើនសំរាប់វិនិយោគលើផលិតកម្មកសិកម្មរបស់គេទៀតផង ។

**តារាង ៦.២ក. ធាតុចូលសំរាប់ទិន្នផលស្រូវ (គិតជា ម៉ឺនរៀល ក្នុងមួយហិកតា)**

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | មធ្យមភាគ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | |
| ជីគីមី | 5.8 | 5.7 | 10.6 | 8.7 | 12.0 | 8.3 | 13.6 | 8.9 | 17.6 | 32.7 | 11.21 | |
| ថ្នាំកំចាត់សត្វល្អិត | 1.4 | .8 | 2.1 | 1.2 | 2.0 | 1.1 | 1.5 | 1.5 | 3.1 | 3.1 | 2.06 | |
| ការបូមទឹក | 3.2 | 2.7 | 4.0 | 4.0 | 5.1 | 4.1 | 7.5 | 3.0 | 11.5 | 15.0 | 5.59 | |
| ពលកម្មធ្វើដី | 4.6 | 3.1 | 6.7 | 5.2 | 11.6 | 7.1 | 10.6 | 5.5 | 18.4 | 17.3 | 9.01 | |
| ពលកម្មដាំដុះ | 6.8 | 5.7 | 9.2 | 8.3 | 11.8 | 8.8 | 14.5 | 11.1 | 22.5 | 33.5 | 12.2 | |
| ពលកម្មច្រូតកាត់ | 5.3 | 3.4 | 6.2 | 4.0 | 8.3 | 5.4 | 12.1 | 9.9 | 13.5 | 18.3 | 8.46 | |
| ពលកម្មបោកបែន | 2.7 | 2.3 | 2.8 | 2.3 | 3.9 | 3.2 | 5.8 | 3.6 | 6.7 | 9.3 | 4.2 | |
| ជួសជុល | 1.5 | 1.1 | 2.2 | 1.6 | 2.3 | 2.4 | 1.7 | .95 | 1.9 | 15.0 | 2.07 | |
| ដឹកជញ្ជូន | 1.8 | 2.0 | 2.7 | 2.6 | 3.2 | 2.6 | 3.5 | 1.9 | 6.6 | 3.9 | 3.23 | |
| ជួលដី | 7.5 | | 6.1 | 1.7 | 10.8 | | 6.0 | | 10.9 | | 7.7 | |
| ជួលសត្វពាហនៈ | .2 | 5.0 | 4.9 | | 3.2 | 5.0 | | 6.0 | 10.0 | 1.5 | 4.48 | |
| ផ្សេងៗ | 4.6 | .97 | 4.4 | 5.5 | 10.6 | 20.0 | 3.1 | 10.0 | 7.4 | 6.3 | 7.2 | |
| **សរុប** | 14.4 | 10.8 | 23.1 | 17.0 | 34.4 | 20.0 | 32.8 | 25.0 | 50.7 | 60.2 | 30.7 | 19.8 |
| | | | | | | | | | | | | |
| **សរុប** | 13.03 | | 21.57 | | 31.77 | | 31.6 | | 51.98 | | 28.2 | |

លំនាំការចំណាយ ក៏មានការទាក់ទងនឹងភេទអ៊ុំរបស់មេគ្រួសារផងដែរ ។ ជាមធ្យម បុរសជាមេគ្រួ ចំណាយច្រើនជាងស្ត្រីជាមេគ្រួប្រហែល ៥០% សំរាប់ផលិតកម្មស្រូវ។ ជាងនេះទៅទៀត បុរសជាមេគ្រួ ចំណាយច្រើនជាងស្ត្រីជាមេគ្រួ ស្ទើរតែ

គ្រប់ចន្លោះនៃការកាន់កាប់ដី ។ កត្តានេះអាចឱ្យយើងកំណត់បានថា (១) ស្ត្រីជាមេគ្រួ ជាទូទៅមាន ដីតូច (តារាង ៥.១ឃ ខាងលើ) និង (២) មានភាពខុសគ្នាលើចំនួនធនធាន រាប់ទាំងកំលាំងពលកម្មដែលមាន ចំពោះបុរសជាមេគ្រួ និងស្ត្រីជាមេគ្រួ (តារាង ៥.១ច ខាងលើ) ។ មានភាពខុសគ្នាមួយ នៅក្នុងចន្លោះនៃការកាន់កាប់ដីធំជាងគេ គឺស្ត្រីជាមេគ្រួ មានការចំណាយច្រើនជាងបុរសជាមេគ្រួ ។ ភាគច្រើននៃភាពខុសគ្នានេះ គឺបណ្តាលមកពីការចំណាយលើជីគីមី និងកំលាំងពលកម្ម សំរាប់ការដាំដុះ និងការច្រូតកាត់ ។ ការពន្យល់សមរម្យគឺថា ស្ត្រីជាមេគ្រួ ប្រើចំណាយទាំងនេះ ដើម្បីប៉ះប៉ូវការខ្វះខាតកំលាំងពលកម្ម ។

## ៦.២.១ ប្រភពហិរញ្ញវត្ថុសំរាប់ការចំណាយ

តារាង ៦.២ខ ខាងក្រោមបង្ហាញថា ចំណាយលើការងារកសិកម្មសំរាប់ដាំដុះស្រូវប្រហែល ៩0% គឺត្រូវបានទូទាត់ដោយហិរញ្ញវត្ថុផ្ទាល់ខ្លួន បន្ទាប់មកដោយកំចីពីសាច់ញាតិ និងមិត្តភក្តិ (៨,៣%) និងដោយឥណទានបានតាមរយៈកម្មវិធី រួមមានក្រុមសន្សំ និងកំចីពាក់កណ្តាលផ្លូវការពី MFIs និងធនាគាពាណិជ្ជកម្ម (២,៣%) ។ ចំនុចលើកលែងសំខាន់មួយ ចំពោះនិន្នាការទូទៅ គឺទាក់ទងនឹងការប្រើជីគីមី ដោយត្រូវប្រើថវិកាផ្ទាល់ខ្លួនដល់ ៧៩% និងកំចី ២១% ដែលបានខ្ចីពីគ្រួសារ មិត្តភក្តិ និងកម្មវិធីឥណទានផ្សេងៗ ។ កំលាំងពលកម្មសំរាប់ការរៀបចំដី ការដាំដុះ និងការច្រូតកាត់ មានពី ៩២% ទៅ ៩៦% បានទូទាត់ដោយប្រភពហិរញ្ញវត្ថុផ្ទាល់ខ្លួន ។

**តារាង ៦.២ខ. ប្រភពចំណាយសំរាប់ធាតុចូលផ្នែកកសិកម្ម**

| ធាតុចូល | ប្រភពផ្ទាល់ខ្លួន | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន |
| ជីគីមី | 473 | 79.0 | 106 | 17.7 | 20 | 3.3 | 599 |
| ថ្នាំសំលាប់សត្វល្អិត | 195 | 96.1 | 4 | 2.0 | 4 | 2.0 | 203 |
| ការបូមទឹក | 250 | 89.6 | 24 | 8.6 | 5 | 1.8 | 279 |
| ការរៀបចំដី | 355 | 92.4 | 19 | 4.9 | 10 | 2.6 | 384 |
| ការដាំដុះ | 387 | 92.6 | 23 | 5.5 | 8 | 1.9 | 418 |
| ការច្រូតកាត់ | 357 | 95.5 | 12 | 3.2 | 5 | 1.3 | 374 |
| | | | | | | | |
| សរុប | 2,017 | 89.4 | 188 | 8.3 | 52 | 2.3 | 2,257 |

ទោះជាយ៉ាងណាក្តី មានភាពខុសប្លែកគ្នាខ្លះនៅពេលយើងពិចារណាពីការបែងចែកប្រភពថវិកា សំរាប់ធាតុចូលនានាទៅតាមទំហំកាន់កាប់ដី ។ ឧទាហរណ៍ ដើម្បីទូទាត់លើកំលាំងពលកម្ម គ្រួសារមានដីធំបំផុតពីរក្រុម បានខ្ចីថវិកាពីគ្រួសារ មិត្តភក្តិ និងពីកម្មវិធីឥណទាន ច្រើនជាងគ្រួសារមានដីតូចបានធ្វើ ។ ការសង្កេតនេះបញ្ជាក់ថា ការទទួលឥណទានអាចចាប់ផ្តើមពីការខ្ចីបុលគ្រួសារ និងមិត្តភក្តិ មុននឹងចាប់ផ្តើមខ្ចីពីស្ថាប័នឥណទានផ្លូវការ (មើលជំពូក ៧.១ ខាងក្រោម) ។ ការសង្កេតក៏បញ្ជាក់ដែរថា និន្នាការបែបនេះអាចផ្តួចផ្តើមពីគ្រួសារមានដីធំ ។

តារាង ៦.២គ ខាងក្រោមបង្ហាញថា ទាំងក្រុមមានទំហំដីធំបំផុត និងតូចបំផុត គឺផ្អែកលើថវិកាគ្រួសារ និងមិត្តភក្តិច្រើនជាង ២0% សំរាប់ចំណាយលើជីគីមី រីឯក្រុមមានទំហំដីធំបន្ទាប់ ប្រើកម្មវិធីឥណទានចំនួន ៧,៧% ។ ការពន្យល់ មួយផ្នែកផ្សេងពីបញ្ហានេះ គឺពាក់ពន្ធ័នឹងការចំណាយខ្ពស់លើជីគីមី ដែលជាមធ្យមមានប្រហែល ១១,២១ម៉ឺនរៀលក្នុងមួយគ្រួសារ

(រាប់ទាំង ៥,៨ម៉ឺនរៀល សំរាប់គ្រួសារកាន់កាប់ដីតូច) ។ គ្រួសារកាន់កាប់ដីតូច អាចមានធនធាន ផ្ទាល់ខ្លួនតិចសំរាប់ការចំណាយលើធាតុចូល ដូច្នេះ ពួកគេសង្ឃឹមច្រើនលើឥរិកាខ្ចីពីគ្រួសារ និងមិត្តភក្តិ ។ គ្រួសារកាន់កាប់ដីធំ អាចមានធនធានច្រើន ប៉ុន្តែពួកគេក៏មានដីច្រើនដែរ ដូច្នេះពួកគេប្រហែលជាត្រូវការខ្ចីបុលពីប្រភពផ្សេងៗដែរ ។

**តារាង ៦.២គ. ប្រភពចំណាយសំរាប់ជីគីមី**

| ធាតុចូល | ប្រភពផ្ទាល់ខ្លួន | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន |
| | | | | | | | |
| < 0.5 | 99 | 75.0 | 30 | 22.7 | 3 | 2.3 | 132 |
| 0.5 – 0.99 | 131 | 82.4 | 23 | 14.5 | 5 | 3.1 | 159 |
| 1.0 – 1.99 | 112 | 78.9 | 26 | 18.3 | 4 | 2.8 | 142 |
| 2.0 – 2.99 | 64 | 82.1 | 8 | 10.3 | 6 | 7.7 | 78 |
| > 3.0 | 67 | 76.1 | 19 | 21.6 | 2 | 2.3 | 88 |
| | | | | | | | |
| សរុប | 473 | 79.0 | 106 | 17.7 | 20 | 3.3 | 599 |

## ៦.២.២ ផលិតភាព

ទ្រឹស្តីនៃការសិក្សាស្រាវជ្រាវបានព្យាករណ៍ថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លីនឹងជំរុញឱ្យមានកំណើនការចំណាយសំរាប់ការផលិតស្រូវ និង/ឬផលិតផលផ្សេងៗទៀតនៅក្នុងតំបន់គំរោង LMAP ហើយការចំណាយនេះ អាចបង្កើនផលិតភាពខាងទិន្នផលស្រូវ ។

ទិន្នន័យក្នុងតារាង ៦.២ឃ បញ្ជាក់ពីទំនាក់ទំនងរវាងទំហំដី និងផលិតភាពដែលបានពីអង្កេតនៅអាស៊ី និងកម្ពុជា (Sophal និង Acharya, 2002) ។ កសិដ្ឋានតូចអាចផ្តល់ផលស្រូវច្រើនជាងកសិដ្ឋានធំ ដោយមិននិយាយអំពីភេទនៃមេគ្រួសារទេ ។ មូលហេតុនៃកត្តានេះគឺថា ដីឡូត៍តូចជាទូទៅជាចំណែកនៃដីដែលមានជីជាតិ ។ ករណីនេះហាក់ដូចជាសមនឹងលំនាំទូទៅនៃការបែងចែកដីនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៨៩ ដូចបានលើកឡើងខាងលើ ។ មូលហេតុមួយទៀតគឺ កសិករកាន់កាប់ដីតូចអាចមានបច្ចេកទេស និងការគ្រប់គ្រងល្អនៅពេលដែលពុំមានវិធីសាស្ត្រកសិកម្មទំនើប ។ កសិករកាន់កាប់ដីតូច អាចអនុវត្តការងារគ្រួសារ និងធាតុចូលដោយមានប្រសិទ្ធភាពជាង ។

**តារាង ៦.២ឃ. ទិន្នផលស្រូវជាមធ្យម លើផ្ទៃដីបានប្រមូលផលសរុប (គ.ក/ហ.ត)**

| ទំហំដី (ហ.ត) | បុរស | | ស្ត្រី | | សរុប | |
|---|---|---|---|---|---|---|
| | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល |
| < 0.5 | 107 | 2,138 | 70 | 1,918 | 177 | 2,051 |
| 0.5 – 0.99 | 156 | 1,660 | 51 | 1,724 | 207 | 1,676 |
| 1.0 – 1.99 | 169 | 1,516 | 41 | 1,247 | 210 | 1,464 |
| 2.0 – 2.99 | 98 | 1,189 | 19 | 920 | 117 | 1,145 |
| ≥ 3.0 | 110 | 1,013 | 17 | 1,041 | 127 | 1,016 |
| សរុប | 640 | 1,519 | 198 | 1,558 | 838 | 1,528 |

កសិករកាន់កាប់ដីតូចនៅប្រទេសកម្ពុជា ក៏មានការដាក់ធាតុចូលក្នុងមួយហិកតាច្រើនជាងកសិករកាន់កាប់ដីធំ ។ តារាង ៦.២ង ខាងក្រោមផ្តល់ការសង្ខេបលំអិតអំពីចំណាយលើធាតុចូលបានជ្រើសរើស សំរាប់ដីក្នុងមួយហិកតា ។ ជាទូទៅ គ្រួសារកាន់កាប់ដីតូចពីរក្រុម ចំណាយលើធាតុចូលក្នុងមួយហិកតា ច្រើនជាងគ្រួសារកាន់កាប់ដីធំពីរក្រុម ។ បើនិយាយអំពីធាតុចូលក្នុង

មួយហិកតា គ្រួសារកាន់កាប់ដីតូចពីរក្រុមនេះចំណាយ ៥១,៣ម៉ឺនរៀល និង ៣២,៤ម៉ឺនរៀល រៀងគ្នា រីឯគ្រួសារកាន់កាប់ដីធំពីរក្រុមវិញចំណាយតែ ១៨,៥ម៉ឺនរៀល និង ១៩,៥ម៉ឺនរៀល រៀងគ្នាប៉ុណ្ណោះ ។

**តារាង ៦.២ង. ធាតុចូលសំរាប់ផលិតផលស្រូវ ( ម៉ឺនរៀល/ហ.ត)**

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | មធ្យម | ចំនួន | មធ្យម | ចំនួន | មធ្យម | ចំនួន | មធ្យម | ចំនួន | មធ្យម | ចំនួន | មធ្យម |
| ជីគីមី | 131 | 23.0 | 159 | 15.7 | 139 | 10.7 | 77 | 8.5 | 87 | 8.4 | 593 | 14.1 |
| ថ្នាំកំចាត់សត្វល្អិត | 23 | 3.1 | 45 | 4.4 | 53 | 1.6 | 35 | 0.9 | 46 | 1.4 | 202 | 2.23 |
| ការបូមទឹក | 54 | 17.2 | 74 | 5.6 | 74 | 4.6 | 29 | 4.5 | 45 | 5.1 | 276 | 7.4 |
| ពលកម្មធ្វើដី | 91 | 14.8 | 90 | 9.9 | 88 | 9.7 | 55 | 5.1 | 54 | 6.1 | 378 | 9.8 |
| ការដាំដុះ | 51 | 27.8 | 83 | 12.2 | 99 | 11.0 | 35 | 7.4 | 51 | 8.7 | 319 | 13.2 |
| សរុប | 169 | 51.3 | 202 | 32.4 | 185 | 29.4 | 104 | 18.5 | 121 | 19.5 | 781 | 31.9 |

ទោះបីជាកសិដ្ឋានខ្នាតតូច អាចផ្តល់ផល (គីឡូក្រាម/ហិកតា) ខ្ពស់ជាងកសិដ្ឋានខ្នាតធំក្តី កសិដ្ឋានខ្នាតតូច មិនមានផលិតភាពល្អសំរាប់ធ្វើការវិនិយោគទេ (គីឡូក្រាម/ម៉ឺនរៀល) ។ តារាង ៦.២ច បង្ហាញថា កសិដ្ឋានទំហំតូចជាងកន្លះហិកតាផ្តល់ផលស្រូវ ៣៩,៩៨គ.ក សំរាប់ការចំណាយមួយម៉ឺនរៀល រីឯកសិដ្ឋានទំហំ ២-២,៩៩ហ.ត និងធំជាង ៣ហ.ត ផ្តល់ផលស្រូវ ៦១,៨៩គ.ក និង ៥២,១គ.ក រៀងគ្នា ។ ចំពោះការជួយគ្រួសារក្រីក្រដើម្បីបង្កើនជីវភាពរស់នៅ និងចាកផុតពីភាពក្រីក្រ មានការស្នើថា ប្រសិទ្ធភាពនៃការវិនិយោគគឺមានសារៈសំខាន់ដូចក៏រិតនៃការវិនិយោគដែរ ។ ចំពោះឥទ្ធិពលនៃការចុះបញ្ជីដីធ្លី លទ្ធភាពទទួលបានឥណទានប្រើសំរាប់ការវិនិយោគ ត្រូវតែបំពេញឱ្យគ្នាទៅវិញទៅមក ជាមួយនឹងសេវាកម្មបច្ចេកទេស ដើម្បីកែលំអផលិតភាពនៃមូលធន ។

**តារាង ៦.២ច .ផលិតភាព និងតំលៃ***

| ទំហំដី ( ហ.ត) | ទិន្នផល ( គ.ក/ហ.ត) | ការចំណាយ ( ម៉ឺនរៀល/ហ.ត) | តំលៃ ( គ.ក/ម៉ឺនរៀល) | ការចំណាយ ( ម៉ឺនរៀល/ហ.ត) |
|---|---|---|---|---|
| | | | | |
| < 0.5 | 2,051 | 51.3 | 39.98 | 16.01 |
| 0.5 – 0.99 | 1,676 | 32.4 | 51.72 | 22.81 |
| 1.0 – 1.99 | 1,464 | 29.4 | 49.80 | 34.31 |
| 2.0 – 2.99 | 1,145 | 18.5 | 61.89 | 33.37 |
| ≥ 3.0 | 1,016 | 19.5 | 52.10 | 62.81 |

* *រដូវប្រមូលផលថ្មីៗ ( ២០០៣) មុនការចុះអង្កេតក្នុងខែមករា និងកុម្ភៈ ២០០៤*

កសិដ្ឋានតូចដែលមានផលិតភាពខ្ពស់ មិនមែនមានន័យថាមានផលិតផលជាមធ្យមខ្ពស់សំរាប់គ្រួសារនីមួយៗឡើយ ។ ទោះបីកសិដ្ឋានតូចផ្តល់ទិន្នផលខ្ពស់ក្តី ប៉ុន្តែវាមានដីតូចណាស់ ។ តារាង ៦.២ឆ បង្ហាញថា គ្រួសារកាន់កាប់ ដីតូចជាងកន្លះហិកតាអាចផលិតស្រូវបានតែ ៦៤០,៣គ.ក ប៉ុណ្ណោះ ទោះជាវាមានផលិតភាពខ្ពស់ក៏ដោយ ។ ទន្ទឹមនឹងនេះ គ្រួសារកាន់កាប់ដីធំផលិតស្រូវបានដល់ ៣,២៧តោន ទោះជាផលិតភាពមានត្រឹមតែពាក់កណ្តាលនៃកសិដ្ឋានតូចក៏ដោយ ។

គំលាតនៃផលិតផលទាំងនេះកើតឡើង ទោះជាមានអាត្រាការប្រើប្រាស់ដីខ្ពស់ជាងក្នុងចំណោមកសិដ្ឋានតូចក៏ដោយ ។ ឧ. កសិដ្ឋានតូចបំផុតមានដី ០,២៧ហ.ត ជាមធ្យមក្នុងមួយគ្រួសារ ប៉ុន្តែប្រមូលផលបានជាង ០,៣១២ហ.ត ដែលមានអាត្រាប្រើប្រាស់ ១១៦% (នេះបញ្ជាក់អំពីកំរិតនៃការជួលដី) ។ ចន្លោះដីដែលធំបំផុតមានជាមធ្យម ៤,៨៤ហ.ត ប៉ុន្តែប្រមូលផលបាន ៣,២២ហ.ត ដោយមានកំរិតនៃការប្រើប្រាស់ប្រហែល ៦៦.៥% ។ ទោះជាយ៉ាងណាក៏ដោយ ចន្លោះរវាងការកាន់កាប់ដីតូច និងដីធំ គឺមានគំលាតខ្លាំងស្មើនឹង ៨០,៤ ។[២៩] នេះបញ្ជាក់អំពីភាពខុសគ្នានៃសមត្ថភាពផលិត និងលក្ខខណ្ឌនៅក្នុងតំបន់ LMAP ។

លើសពីនេះ ផលិតភាពខ្ពស់របស់ដីនៃកសិដ្ឋានតូច មិនមែនមានន័យថា មានកំរិតផលិតផលជាមធ្យមខ្ពស់ក្នុងមនុស្សម្នាក់ពេញកំលាំងពលកម្មឡើយ ។ នៅពេលយើងពិនិត្យលើផលិតភាព ដែលវាស់វែងតាមផលិតផលក្នុងមនុស្សម្នាក់ពេញកំលាំងពលកម្ម យើងឃើញថា ទិន្នផលជាមធ្យមក្នុងមនុស្សម្នាក់ពេញកំលាំងពលកម្មនៃគ្រួសារកាន់កាប់ដីតូច គឺតិចជាងគ្រួសារកាន់កាប់ដីធំខ្លាំងណាស់ ។ ឧទាហរណ៍ គ្រួសារកាន់កាប់ដីតូចជាងកន្លះហិកតា ផលិតបាន ១៩៤គ.ក ក្នុងមនុស្សម្នាក់ពេញកំលាំងពលកម្ម រីឯគ្រួសារកាន់កាប់ដីធំជាង ៣ហ.ត ផលិតបាន ៦៩៤គ.ក ក្នុងមនុស្សម្នាក់ ។

ចំពោះសមត្ថភាពវិនិយោគ មានការស្នើថា ដីស្រែទំហំតូចពុំមានភាពប្រសើរសំរាប់រយៈពេលវែងទេ ដោយកសិករត្រូវបន្តប្រើធនធានកំររបស់គ្រួសារដើម្បីផលិតអាហារបំពេញការខ្វះខាត[៣០] ជាជាងវិនិយោគក្នុងការផលិត ឬសកម្មភាពសំខាន់នានា ដូចជាការអប់រំកូនចៅជាដើម ។ វាក៏បង្ហាញអំពីបញ្ហា ដែលជាប់ទាក់ទងនឹងការចំណាយមិនសមរម្យ ដូចបានលើកឡើងខាងលើ ។ ប្រសិនបើកសិករខ្ចីបុលដើម្បីធ្វើការវិនិយោគលើផលិតកម្ម ដែលមិនបានផលិតគ្រប់គ្រាន់ និងលើសសំរាប់លក់ទេ កសិករនឹងជំពាក់បំណុលគេកាន់តែច្រើន ។ រឿងនេះបង្ហាញម្តងទៀត ពីតំរូវការសេវាកម្មបច្ចេកទេស និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ សំរាប់ពង្រីកអត្ថប្រយោជន៍នៃការចុះបញ្ជីដីធ្លីក្នុងតំបន់ជាក់លាក់ណាមួយ ។

ផលប៉ះពាល់នៃការចុះបញ្ជីដីធ្លីទៅលើទំហំដី គឺមានសារៈសំខាន់ណាស់សំរាប់ពិចារណា ។ ភស្តុតាងបានពីប្រទេសថៃបង្ហាញថា ចំនួន និងទំហំដីឡូត៍ក្នុងមួយគ្រួសារមានការថយចុះជាមួយនឹងការចុះបញ្ជី ។ ដូចដែលបានលើកឡើងខាងលើ ទំហំដីដែលបានកាន់កាប់ជាមធ្យមប្រហែលជាមិនគ្រប់គ្រាន់សំរាប់សុវត្ថិភាពម្ហូបអាហារនៅប្រទេសកម្ពុជាទេ ។ នៅពេលដែលកសិករបន្តដាក់ទុនលើធាតុចូលសំរាប់ដីតូចៗ ទំហំដីតូចនេះអាចនឹងរារាំងការវិនិយោគធំៗបាន ដូចជាការទិញគ្រឿងចក្រ និងកែលំអហេដ្ឋារចនាសម្ពន្ធ័ជាដើម ។

---

[២៩] តួលេខនេះ ផ្ទុយគ្នាជាមួយតួលេខ សំរាប់ចំណាយជាម៉ឺនរៀល/ហិកតា ដែលបានបង្ហាញនៅក្នុងតារាង ៦.២ក ខាងលើ ។ តារាង៦.២ក ត្រូវបានដកស្រង់ដោយផ្ទាល់ពីការធ្វើសំភាសន៍ដែលគេឆ្លើយទៅនឹងសំនួរអំពីចំណាយនៅខណៈដែលនៅក្នុងតារាង ៦.២ច ត្រូវបានគិតគូរដោយផ្អែកទៅលើការធ្វើសំភាសន៍ ដែលគេឆ្លើយទៅនឹងសំនួរអំពីតំបន់ និងទិន្នផលសរុប ។ តួលេខទាំងពីរនេះ បង្ហាញលទ្ធផលដែលអាចឱ្យមានការពិនិត្យដោយផ្អែកលើគ្នាទៅវិញទៅមក ទៅលើភាពត្រឹមត្រូវនៃទិន្នន័យ ។ ប្រសិនបើមានអ្វីផ្សេងទៀតមានភាពខុសគ្នា គេអាចស្នើថា អ្នកឆ្លើយតបមានទំនោរទៅរកការប៉ាន់ស្មានទាបពេកអំពីទិន្នន័យ ឬការប៉ាន់ស្មានខ្ពស់ពេកលើការចំណាយ ។ នេះវាជារឿងធម្មតាទេនៅតំបន់ជនបទនៅកម្ពុជា ។

[៣០] គំលាតផលិតកម្ម ត្រូវបានគេគណនាដោយយក ១ ដកភាគរយផលិតផលសរុបជាមធ្យមក្នុងមួយគ្រួសារ សំរាប់ចន្លោះកាន់កាប់ដីតូច និងធំ បំផុត ។

**តារាង ៦.២ឆ. ផលិតផលប្រចាំគ្រួសារ**

| ទំហំដី (ហ.ត) | កំលាំងពលកម្មក្នុងគ្រួសារ | ទិន្នផល (គ.ក/ហ.ត) | ផ្ទៃដី (ហ.ត/គ្រួសារ) | | ផលិតផលសរុប (គ.ក/គ្រួសារ) និង គ.ក/កំលាំងពលកម្ម | |
|---|---|---|---|---|---|---|
| | | | កម្មសិទ្ធិ | បានប្រមូល | ទិន្នផល x ផ្ទៃដីប្រមូលផល | គ.ក/គ្រួសារ/ពលកម្ម/ហ.ត |
| | | | | | | |
| < 0.5 | 3.3 | 2,051 | 0.27 | .3122 | 640.3 | 194.0 |
| 0.5 – 0.99 | 4.1 | 1,676 | 0.70 | .704 | 1,180.0 | 287.8 |
| 1.0 – 1.99 | 4.0 | 1,464 | 1.41 | 1.167 | 1,708.5 | 427.1 |
| 2.0 – 2.99 | 4.8 | 1,145 | 2.41 | 1.8037 | 2,065.2 | 430.0 |
| ≥ 3.0 | 5.0 | 1,016 | 4.80 | 3.2208 | 3,272.3 | 654.4 |

## ៦.២.៣ ការប្រើប្រាស់ដី

ដូចកន្លែងផ្សេងៗទៀតនៅប្រទេសកម្ពុជា ដីនៅក្នុងតំបន់អង្កេតរបស់គំរោង LMAP និងតំបន់សំរាប់សិក្សាប្រៀបធៀបនៅខេត្តកំពង់ឆ្នាំង គឺត្រូវបានបែងចែកជា: (១) ដីលំនៅដ្ឋាន (២) ដីដាំដុះ និងដីកសិកម្ម និង(៣) ដីរួម-ដីរដ្ឋ ដែលរួមទាំងព្រៃឈើ និងតំបន់ទឹកលិចកំពុងមានការនេសាទ និងការដាំដំណាំ ។ បញ្ហាប្រឈមមុខដ៏សំខាន់មួយ នៃការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា គឺត្រូវរៀបចំវិធីសាស្ត្រមានចីរភាព ដើម្បីបែងចែកការប្រើប្រាស់ដី ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច ។ ការប្រើប្រាស់ដីបែបចំរុះ អាចជាសូចនាករមួយនៃប្រសិទ្ធភាព សំរាប់ទាំងដីលំនៅដ្ឋាន និងដីកសិកម្ម ។

**តារាង ៦.២ឈ. ការប្រើប្រាស់ដីលំនៅដ្ឋាន (ភាគរយនៃដីឡូត៍)**

| ដីលំនៅដ្ឋាននៅក្នុងតំបន់សិក្សា LMAP | | | | | | | |
|---|---|---|---|---|---|---|---|
| ការប្រើប្រាស់ដីលំនៅដ្ឋាន | 0 | < 0.5 | 0.5-0.99 | 1-1.99 | 2-2.99 | > 3.0 | សរុប |
| ទុកចោល | 6.0 | 2. | 4.0 | 3.0 | 5.0 | 7.0 | 4.0 |
| ជួលឱ្យគេ ឬជួលផ្ទះ | 0.0 | 0.0 | 1.0 | 0.0 | 0.0 | 0.0 | 0.0 |
| បងប្អូននៅបណ្តោះអាសន្នដោយមិនគិតថ្លៃ | 2.0 | 1.0 | 0.0 | 2.0 | 3.0 | 2.0 | 2.0 |
| រស់នៅ និង ដាំដំណាំ | 37.0 | 44.0 | 50.0 | 54.0 | 53.0 | 53.0 | 50.0 |
| ដាំដំណាំ បន្លែ (មិនរស់នៅ) | 4.0 | 3.0 | 3.0 | 6.0 | 7.0 | 6.0 | 5.0 |
| រស់នៅ និង រកស៊ី | 8.0 | 13.0 | 16.0 | 15.0 | 14.0 | 14.0 | 14.0% |
| រកស៊ីសុទ្ធសាធ | 0.0 | 0.0 | 0.0 | 0.0 | 1.0 | 0.0 | 0.0% |
| រស់នៅសុទ្ធសាធ | 43.0 | 37.0 | 26.0 | 20.0 | 17.0 | 18.0 | 25.0 |
| ផ្សេងៗ | 0.0 | 1.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ចំនួនដីឡូត៍សរុប | 51 | 187 | 227 | 256 | 139 | 153 | 1,013 |

***ដីលំនៅដ្ឋាន:*** សារៈសំខាន់នៃដីលំនៅដ្ឋាន ត្រូវបានពិភាក្សាផ្អែកលើផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិ និងការចុះបញ្ជីដីធ្លី ពីព្រោះនៅក្នុងសង្គមកម្ពុជា ដីលំនៅដ្ឋានមិនត្រឹមតែប្រើសំរាប់សង់ផ្ទះប៉ុណ្ណោះទេ គឺប្រើសំរាប់ដាំដំណាំ និងប្រកបមុខរបរតូចតាចទៀតផង ដូចជា ការចិញ្ចឹមសត្វ ការដាំបន្លែ ដើម្បីរកចំណូលបន្ថែមដល់គ្រួសារ ។ តារាង ៦.២ឈ សង្ខេបអំពីការប្រើប្រាស់ដីលំនៅដ្ឋាននៅក្នុងតំបន់នៃគំរោង LMAP ។ ប្រហែល ៩២% នៃប្រជាជននៅក្នុងតំបន់នៃគំរោង LMAP រស់នៅលើដីលំនៅដ្ឋានរបស់ខ្លួន ។ ប្រហែល ២៤.៩% ប្រើប្រាស់ដីលំនៅដ្ឋានសំរាប់តែការរស់នៅប៉ុណ្ណោះ រីឯ ៦៤.២% ប្រើប្រាស់ដីទាំងនេះ

សំរាប់ការរស់នៅ និងសកម្មភាពផ្សេងទៀត ដូចជា ការដាំដំណាំ (៥០%) ការរកស៊ី (៩.៨%) និងការលក់ដូរផលដំណាំ (៤.៤%) ។ ប្រហែល ៣.៨% នៃប្រជាពលរដ្ឋ ទុកដីលំនៅដ្ឋានរបស់ខ្លួនឱ្យទំនេរ ។

ការប្រើប្រាស់ដីលំនៅដ្ឋានបែបចំរុះ មានការកើនឡើងទៅតាមទំហំកាន់កាប់ដី ប៉ុន្តែក្រុមគ្រួសារកាន់កាប់ដីទំហំធំ ហាក់ដូចជាប្រើប្រាស់ដីលំនៅដ្ឋានតិចតួចប៉ុណ្ណោះសំរាប់ការរស់នៅ ។ ឧទាហរណ៍ ១៨% និង ១៧%នៃក្រុមកាន់កាប់ដីធំជាងគេចំនួនពីររៀងគ្នា ប្រើប្រាស់ដីលំនៅស្ថានសំរាប់តែការរស់នៅ រីឯក្រុមកាន់កាប់ដីតូចជាងគេចំនួនពីរ មានដល់ទៅ ៣៧% និង ២៦% រៀងគ្នា ។

***ដីកសិកម្ម:*** ទិន្នន័យអង្កេត បញ្ជាក់យ៉ាងច្បាស់អំពីសម្មតិកម្មស្រាវជ្រាវដែលថា លំនាំប្រើប្រាស់ដីកាន់តែមានលក្ខណៈចំរុះនៅពេលទំហំកាន់កាប់ដីមានការកើនឡើង ។ ឧទាហរណ៍ ភាគរយនៃដីឡូត៍ដែលបានបំរុងទុកសំរាប់ដំណាំស្រូវវស្សា បានថយចុះជាលំដាប់ពី ៨៩.១% សំរាប់គ្រួសារកាន់កាប់ដីតិចជាងកន្លះហិកតាទៅ ៧០% សំរាប់គ្រួសារ កាន់កាប់ដីធំជាង ៣ហ.ត ។ នៅពេលដូចគ្នា ភាគរយនៃដីឡូត៍បានបំរុងទុកសំរាប់ដំណាំស្រូវប្រាំង បានកើនឡើងជាលំដាប់ តាមទំហំដីកាន់កាប់ពី ២៨.៨% សំរាប់គ្រួសារកាន់កាប់ដីតិចជាងកន្លះហិកតាទៅ ១២.៧% សំរាប់គ្រួសារដែលមានដីធំជាង ៣ហ.ត ។ ភាគរយនៃដីឡូត៍ដែលបានទុកសំរាប់ធ្វើចំការដំណាំដូវ (៦.៧%) គឺមានលំនឹងក្នុងគ្រប់ទំហំដីកាន់កាប់ រីឯភាគរយនៃដីឡូត៍ដែលបានទុកសំរាប់ធ្វើចំការដំណាំយូរអង្វែង និងដំណាំគ្រប់ប្រភេទ គឺថាមានតិចសំរាប់រាល់ករណី គឺ ០.១% ។ មានការបង្ហាញឱ្យឃើញនូវលក្ខខណ្ឌជាច្រើនសំរាប់ដំណាំចំរុះ នាពេលអនាគតក្នុងតំបន់ LMAP ។

ចំពោះការប្រើប្រាស់ក្បាលដីជាក់ស្តែង ប្រហែល ៩០% គឺបានប្រើសំរាប់ការដាំដុះ ទោះជាមានភាគរយថយចុះ តាមទំហំដីក៏ដោយ ។ ភាគរយនៃក្បាលដីដែលបានដាំដំណាំសំរាប់បុរសជាមេគ្រួ និងស្ត្រីជាមេគ្រួ គឺមានប្រហាក់ប្រហែលគ្នា ។ ភាគរយនៃក្បាលដីបានជួលឱ្យគេ (១.៦%) គឺមិនប្រែប្រួលក្នុងគ្រប់ករណីនៃការកាន់កាប់ដី ។ មិនគួរអោយភ្ញាក់ផ្អើលនោះទេ នៅពេលភាគរយនៃក្បាលដីនៅទំនេរ (៧.៦%) បានកើនឡើងស្របជាមួយនឹងទំហំដី ពី ៣.២% សំរាប់ គ្រួសារកាន់កាប់ដីតូចជាង ០.៥ហ.ត ទៅ ១១.៥% សំរាប់គ្រួសារកាន់កាប់ដីច្រើនជាង ៣ហ.ត ។ ស្ត្រីជាមេគ្រួ មានដីទំនេរ និងជួលដីឱ្យគេច្រើនជាងបុរសជាមេគ្រួ ។

ក្នុងចំណោមដីដាំដុះ ៣.៨៩១ក្បាលដី មានដីចំនួន ២៩៩ ត្រូវបានគ្រួសារចំនួន ១៧៥ ទុកទំនេរចោលក្នុងរដូវធ្វើស្រែឆ្នាំមុន ។ នៅមានមូលហេតុចំបងបីបានលើកឡើងគឺ ខ្វះកំលាំងពលកម្ម (៣៤%) មិនចំណេញ (១៦%) និងខ្វះទុនវិនិយោគ (៩%) ។ រីឯ ៤២% ទៀត បានលើកឡើងនូវមូលហេតុផ្សេងៗទៀត ។ ស្ត្រីជាមេគ្រួ (៣៨%) ច្រើនជាងបុរសជាមេគ្រួ (៣៣%) បានលើកឡើងថា ខ្វះកំលាំងពលកម្ម ។ ម្យ៉ាងទៀត បុរសជាមេគ្រួ (១៨%) ច្រើនជាងស្ត្រីជាគ្រួ (៩%) បានលើកឡើងថា មិនចំណេញ ។ ភាគរយរបស់ស្ត្រីជាមេគ្រួ និងបុរសជាមេគ្រួ មានចំនួនស្មើគ្នា បានលើកឡើងថា ខ្វះទុនវិនិយោគ ។ ចំលើយទទួលបានពីគ្រួសារនីមួយៗ ហាក់ដូចជាមានភាពស៊ីគ្នា ជាមួយមូលហេតុដែលលើកឡើងនៅក្នុងការពិភាក្សាជាក្រុមដែលថា ការខូចខាតនៃផលដំណាំបណ្តាលមកពីបញ្ហាអាកាសធាតុ ហើយវាជាមូលហេតុចំបងនាំឱ្យគេទុកដីទំនេរចោល ។ ការទុកដីទំនេរចោល ក៏អាចដោយសារការប្រែប្រួល មិនសមហេតុផលនៃទីផ្សារ និងតំលៃផលដំណាំ រួមផ្សំនឹងទិន្នផលតិចពីព្រោះដីខ្វះជីជាតិ និងដាក់វិនិយោគតិចលើធាតុចូលនៃកសិកម្មទំនើប ជាពិសេស ជីគីមី (Chan and Acharya, 2002) ។

ការជួញដូរដីធ្លីជាបញ្ហាសំខាន់មួយទៀត ដែលទុកដីឱ្យនៅទំនេរ ជាពិសេសក្នុងករណីដែលដីនោះមានម្ចាស់មិនមែនជាអ្នកនៅក្នុងភូមិ ។

ចំពោះលំនាំការដាំដំណាំ ប្រហែល ៧៩% នៃក្បាលដី បានប្រើសំរាប់ធ្វើស្រូវវស្សាតែមួយលើកក្នុងមួយឆ្នាំ ខណៈ ៧,៣% បានប្រើសំរាប់ធ្វើស្រូវប្រាំង ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ពេលលំនាំការដាំដំណាំនេះ មានការស៊ីគ្នានឹងលំនាំ បែងចែកដីដូចបានលើកឡើងខាងលើ ។ រឿងនេះគឺថាភាគរយនៃក្បាលដីសំរាប់ធ្វើស្រូវវស្សា បានថយចុះ នៅពេលដែលទំហំកាន់កាប់ដីបានកើនឡើង ប៉ុន្តែភាគរយនៃក្បាលដីសំរាប់ធ្វើស្រូវប្រាំង បានកើនឡើងតាមទំហំកាន់កាប់ដី ។ ប្រហែល ៤% នៃក្បាលដី បានប្រើសំរាប់ធ្វើស្រូវវស្សាចំនួនពីរដងក្នុងមួយឆ្នាំ និង ៣,៨% សំរាប់ដាំដំណាំហូបផ្លែ និងដំណាំផ្សេងទៀត ។

ដូចបានលើកឡើងខាងលើ ទ្រឹស្តីនៃការស្រាវជ្រាវបានព្យាករណ៍ថា វិសាលភាព និងកំរិតនៃប្រើប្រាស់ដីបែបចំរុះ នឹងកើនឡើងលឿនទៅតាមទំហំកាន់កាប់ដី ។ អត្រានៃការប្រើប្រាស់ដី ក៏អាចកើនឡើងដែរ នៅពេលកសិករចាប់ផ្តើម ដាក់ទុនវិនិយោគកាន់តែច្រើនលើការងារកសិកម្ម ទោះបីជាពុំមានគោលនយោបាយណាមួយ លើកកំពស់អត្រានៃការប្រើប្រាស់ដីក៏ដោយ (ឧ. ការយកពន្ធលើដីធំៗទំនេរចោល) ។ ទោះជាយ៉ាងណាក្តី ផលប៉ះពាល់នៃការចុះបញ្ជីដីធ្លី មានភាពខុសគ្នាទៅតាមទីតាំង និងស្ថានភាពនានា ដូចជា វត្តមានឥណទាន និងសេវាកម្មបច្ចេកទេស និងការឈានចូលទៅក្នុងទីផ្សារ (ឧ. ចំណាយលើការដឹកជញ្ជូន និងតំលៃផ្ទេរ ក៏ដូចជា ពន្ធផ្សេងៗ) និងតំលៃផលិតផល ។[៣១]

**មូលហេតុដែលនាំឱ្យគ្មានដីក្នុងតំបន់ LMAP និងតំបន់សំរាប់ប្រៀបធៀបនៅខេត្តកំពង់ឆ្នាំង**




[៣១] សូមអានឯកសាររបស់លោក កង ច័ន្ទតារ៉ាវុត្ថ និង ច័ន្ទ សុផល (២០០៣) សំរាប់ការពិភាក្សាទាក់ទិកនឹងចំណាយលើការលក់ដូរខាងកសិកម្ម ។

***ការកត់សំគាល់លើភាពគ្មានដី:*** គ្រួសារគ្មានដី ៨០គ្រួសារ (៦២% ក្នុងតំបន់ LMAP និង ១៨គ្រួសារក្នុងខេត្តកំពង់ឆ្នាំង) បានលើកឡើងនូវមូលហេតុចំបងបីដែលនាំឱ្យគ្មានដី គឺការលក់បន្ទាន់/ព្យាបាលជំងឺ ការផ្លាស់ប្តូរទីកន្លែងរស់នៅ និងការមិនធ្លាប់មានដីសោះ ។ ស្ត្រីជាមេគ្រួ ហាក់ដូចជាងាយទទួលរងនូវភាពគ្មានដីពីការលក់បន្ទាន់/ព្យាបាលជំងឺ (ជាងបុរសជាមេគ្រួ) ដោយសារកង្វះខាតទ្រព្យ និងចំណូល ។ ទោះបីជាគំរូវាតូចពេកសំរាប់ធ្វើការសន្មតជាទូទៅ ក៏ទិន្នន័យបានបង្ហាញថា អ្នកមានដីតូចជាង ១ហ.ត គឺអាចទទួលរងនូវភាពគ្មានដី បើសិនជាពួកគេមានវិបត្តិក្នុងគ្រួសារ ។ ករណីនេះកើតឡើងជាពិសេសនៅក្នុងតំបន់ ដែលការអភិវឌ្ឍន៍ និងសេវាកម្មសង្គម ពុំមានវត្តមាន រឺមានតំលៃថ្លៃ ។

***ការកត់សំគាល់លើដីរដ្ឋ:*** ក្នុងអំឡុងពេលចុះសិក្សា យើងអង្កេតឃើញមានការទន្ទ្រានយកដីរដ្ឋ និងផ្លាស់ប្តូរទៅជាដីកសិកម្ម ។ ទោះបីជាយើងពុំបានដឹងពីទំហំជាក់លាក់នៅក្នុងតំបន់អង្កេតក៏ដោយ យើងពុំឃើញមានដីរដ្ឋ ឬដីរួមណាមួយទុកសំរាប់សកម្មភាពសហគមន៍ឡើយ លើកលែងនៅឃុំទីពោធិ៍ ខេត្តកំពង់ធំ ។ ដីព្រៃធំៗនៅតាមផ្លូវជនបទថ្មីៗ និងកន្លែងមានគំរោងធារាសាស្ត្រ ត្រូវបានកាប់ឆ្ការទុកសំរាប់គោលដៅផ្សេងៗ ។ ឧទាហរណ៍ ដីព្រៃយ៉ាងធំ នៅឃុំទីពោធិ៍ បានផ្លាស់ប្តូរទៅជាចំការ ដំណាំស្វាយចន្ទី ឬទុកទំនេរចោល ។

នៅឃុំច្រេះ ខេត្តកំពង់ឆ្នាំង (តំបន់អង្កេតសំរាប់ប្រៀបធៀប) ព្រៃលិចទឹកជាច្រើនត្រូវបានប្តូរទៅជាដីធ្វើស្រូវប្រាំងនាឆ្នាំថ្មីៗកន្លងមក ។ ករណីនេះមូលហេតុមួយចំនួន គឺមានដីសំរាប់កាន់កាប់មិនគ្រប់គ្រាន់ និងផលិតភាពទាប គួបផ្សំនឹងអត្រាកំនើនប្រជាជនបច្ចុប្បន្ន ។ ដោយប្រជាជនមានជំនឿថា គំរោង LMAP តំណាងឱ្យដំណើរការចុងក្រោយនៃការទទួលស្គាល់កម្មសិទ្ធិដីឯកជន ពួកគេព្យាយាមទន្ទ្រានយកដីរដ្ឋ ឱ្យបានមុនការអនុវត្តគំរោង ។ ករណីនេះហាក់ដូចជាកើតឡើងនៅឃុំទីពោធិ៍ ខេត្តកំពង់ធំ ។ ទោះយ៉ាងណា សកម្មភាពទាំងនេះអាចនឹងថយចុះនៅពេលដែលដីឯកជន និងដីរដ្ឋទាំងអស់បានចុះបញ្ជី ឬកំណត់ព្រំរួច ។

## ៦.៣. ទីផ្សារដីធ្លី: តំលៃ ថ្លៃ និងការផ្ទេរដីធ្លី

តារាង ៦.៣ក បង្ហាញថា តំលៃដី (ម៉ឺនរៀល/ហិកតា)[៣២] បានធ្លាក់ចុះនៅពេលដែលទំហំកាន់កាប់ដីកើនឡើង ។ ករណីនេះមានទាំងស្ត្រីជាមេគ្រួ និងបុរសជាមេគ្រួ ។ បើរំលឹកឡើងវិញអំពីករណីពិភាក្សាដែលទាក់ទងនឹងការបែងចែកដីក្នុងឆ្នាំ១៩៨៩ យើងអាចពន្យល់ថា កសិដ្ឋានតូចៗតែងមានដីគុណភាពខ្ពស់ ។ ទំនាក់ទំនងរវាងដីមានគុណភាពខ្ពស់ និងដីមានតំលៃខ្ពស់ក្នុងកសិដ្ឋានតូចៗ គឺឆ្លុះបញ្ចាំងអំពីកំរិតខ្ពស់នៃផលិតកម្ម (តារាង ៦.២ឃ) ។ កសិដ្ឋានតូចៗ អាចមានការប្រជុំនូវក្បាលដី ដែលមានទីតាំងអំណោយផល ចំណែកឯកសិដ្ឋានធំៗ អាចមានដី ដែលមិនសូវមានជីជាតិ និងស្ថិតនៅក្នុងទីតាំងដែលមិនសូវអំណោយផល ។

ទោះបីជាដីមានតំលៃក្នុងមួយហិកតាខ្ពស់ក៏ដោយ តំលៃជាមធ្យមនៃក្បាលដីនីមួយៗ គឺមានកំរិតទាបក្នុងចំណោមកសិដ្ឋានតូចៗ និងមានកំរិខ្ពស់ក្នុងចំណោមកសិដ្ឋានធំៗ ។ រឿងនេះ គឺជាមុខងារផ្ទាល់របស់ទំហំមធ្យម នៃក្បាលដីរបស់កសិដ្ឋានតូច និងកសិដ្ឋានធំ ។ លទ្ធផលមួយនៃលំនាំនេះ គឺជាប់ទាក់ទងនឹងការទទួលបានឥណទាន ។ ប្រសិនបើទំហំកំចី ផ្អែកមួយផ្នែកលើ

[៣២] ទិន្នន័យនៅក្នុងរបាយការណ៍តំលៃដី គឺផ្អែកលើការវាយតំលៃផ្ទាល់ខ្លួនរបស់អ្នកឆ្លើយសំភាសន៍ ។

របស់ធានាដែលមាន (បណ្ណ័កម្មសិទ្ធិ ដែលបានចេញជាផ្លូវការ ដោយឡែកពីគ្នាសំរាប់ក្បាលដីនីមួយៗ) នោះកសិដ្ឋានធំៗ នឹងអាចទទួលបានប្រាក់កំចីច្រើនជាងកសិដ្ឋានតូចៗ បើសិនអ្វីៗទាំងអស់ដូចៗគ្នា ។ ក្រៅពីផលប៉ះពាល់នៃអត្រាការប្រាក់ រឿងនេះអាចធ្វើឱ្យកសិករតូចតាចរួចផុតពី ទីផ្សារឥណទានតូចចង្អៀតនេះ ។

**តារាង ៦.៣ក. តំលៃដីគិតតាមទំហំហិកតា និងក្បាលដី (ម៉ឺនរៀល/ហ.ត)**

| ទំហំដី (ហ.ត) | ចំនួនក្បាលដី | ទំហំមធ្យម | បុរសជាមេគ្រួសារ | ស្ត្រីជាមេគ្រួសារ | សរុបមធ្យម | តំលៃ/ក្បាលដី |
|---|---|---|---|---|---|---|
| | | | | | | |
| < 0.5 | 467 | 0.11 | 1,077 | 866 | 993 | 109.2 |
| 0.5 – 0.9 | 836 | 0.18 | 691 | 702 | 694 | 124.9 |
| 1.0 – 1.9 | 1,089 | 0.29 | 511 | 347 | 478 | 138.6 |
| 2.0 – 2.9 | 660 | 0.45 | 324 | 345 | 328 | 147.6 |
| > 3.0 | 824 | 0.76 | 238 | 220 | 223 | 169.5 |
| | | | | | | |
| សរុប | 3,876 | 0.37 | 502 | 536 | 510 | 188.7 |

## ៦.៣.១ ការផ្ទេរដីធ្លី

តារាង ៦.៣ខ បង្ហាញថា គ្រួសារចំនួន ២០១ បានលក់ដីកសិកម្មចំនួន ៣០៣ក្បាលដី ចាប់តាំងពីឆ្នាំ១៩៨៩ គឺប្រហែលនឹង ៧,៨% នៃដីកសិកម្មទាំងអស់ក្នុងតំបន់អង្កេត LMAP ។ មានតួលេខការលក់ដីមិនត្រឹមត្រូវក្នុងចំណោមគ្រួសារកាន់កាប់ដីតូចជាងគេចំនួនពីរក្រុម ប្រៀបធៀបនឹងគ្រួសារកាន់កាប់ដីធំជាងគេចំនួនបីក្រុម ។ មានរបាយការណ៍ថា គ្រួសារកាន់កាប់ដីតូចជាងគេចំនួនពីរ ក្រុមមានក្បាលដីសរុបចំនួន ១.៣០៨ រឺ ៣៣,៧២% នៃក្បាលដីទាំងអស់ (៣.៨៧៩) បានជ្រើសជាគំរូសំរាប់ការសិក្សា ។ ទោះជាយ៉ាងណាក្តី មានរបាយការណ៍ថា ពួកគេបានលក់អស់ ១២៨ក្បាលដី រឺ ៥០,៧៩% នៃចំនួនក្បាលដីសរុបបានលក់ ។ ចំណែកឯគ្រួសារកាន់កាប់ដីធំជាងគេចំនួនពីរក្រុម មាន ៣៨,១៣% នៃក្បាលដីសរុប ប៉ុន្តែបានលក់ក្បាលដីអស់តែ ២៤,១% ។ ប្រហែលមួយភាគបីនៃក្បាលដីបានលក់ ក្នុងចំណោមក្រុមគ្រួសារកាន់កាប់ដីតូចជាងគេចំនួនពីរ គឺស្ត្រីជាមេគ្រួ ទោះបីជាស្ត្រីជាមេគ្រួមានដីសរុបប្រហែល ៥៤% នៃក្បាលដីទាំងអស់ក្នុងចន្លោះក្រុមមានដីតូចជាងគេទាំងពីរ ។ ការបែងចែកការលក់ដី និងកម្មសិទ្ធិក្បាលដីក្នុងចំណោមស្ត្រីជាមេគ្រួ មានភាពស៊ីគ្នាទៅនឹងចន្លោះក្រុមមានដីធំជាងគេទាំងពីរ ។

**តារាង ៦.៣ខ. ការលក់ដីកសិកម្មគិតតាមទំហំកាន់កាប់ដី និងយេនឌ័រ**

| ទំហំដី (ហ.ត) | ចំនួនក្បាលដី | ចំនួនលក់សរុប | ចំនួនលក់ | | ទំហំមធ្យម | | តំលៃ (ម៉ឺនរៀល/ហ.ត) | | ផ្ទៃដីសរុប (ហ.ត) | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ប | ស | ប | ស | ប | ស | តំលៃ | ផ្ទៃដី |
| | | | | | | | | | | |
| 0 | | 50 | 33 | 17 | .50 | .21 | 698 | 1,618 | 1.011 | .40 |
| < 0.5 | 465 | 65 | 43 | 22 | .17 | .14 | 727 | 1,750 | 1,074 | .16 |
| 0.5 – 0.9 | 843 | 63 | 42 | 21 | .21 | .32 | 5,605 | 1,276 | 4,162 | .24 |
| 1.0 – 1.9 | 1,092 | 52 | 37 | 15 | .27 | .32 | 1,061 | 224 | 819 | .28 |
| 2.0 – 2.9 | 653 | 29 | 25 | 4 | .39 | .25 | 337 | 6,373 | 1,169 | .37 |
| > 3.0 | 826 | 44 | 38 | 6 | .57 | .41 | 211 | 692 | 277 | .55 |
| | | | | | | | | | | |
| សរុប | 3,879 | 303 | 218 | 85 | .34 | .25 | 1,585 | 1,480 | 1,555 | .34 |

របាយនៃការលក់ដីតាមឃុំ នឹងបង្ហាញក្នុងតារាង ៦.៣គ ខាងក្រោម គាំទ្រការព្យាករណ៍ដែលថា ការលក់ដី គឺជាប់ពាក់ព័ន្ធនឹងទីតាំង និងសកម្មភាពអភិវឌ្ឍន៍ ។ ឧទាហរណ៍ ប្រហែល ២៩% នៃការផ្ទេរកម្មសិទ្ធិដីបានរាយការណ៍ទាំងអស់ គឺធ្វើឡើង នៅឃុំសំបួរ ជិតក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិទៅកាន់ខេត្តកំពង់ចាម ។ មានគំរោងកសាងហេដ្ឋារចនាសម្ព័ន្ធធំៗ កំពុងត្រូវបានលើកឡើង និងអនុវត្តន៍ ។ នៅខេត្តតាកែវ ឃុំត្រពាំងសាប និងឃុំរវៀង មានក្បាលដីចំនួន ២៩% ត្រូវបានលក់ដូរបន្ថែមទៀត ។ ទីតាំងឃុំទាំងពីរនេះ ក៏នៅជិតក្រុងភ្នំពេញដែរ ហើយជាប់នឹងផ្លូវជាតិ ទៅកាន់ខេត្តតាកែវ ។ ឃុំស្រយ៉ូវស្ថិតនៅក្បែរ ទីរួមខេត្តកំពង់ធំ តាមបណ្តោយផ្លូវជាតិលេខ ៦ ។ ចំណែកឯឃុំពីរទៀត ពុំសូវមានការលក់ដី (ឃុំទឹកល្អក់ និងឃុំទីពោធិ៍) គឺស្ថិតនៅឆ្ងាយពីផ្លូវជាតិ និងហាក់ដូចជានៅដាច់ស្រយាល បើធៀបនឹងឃុំផ្សេងៗ ។ ប៉ុន្តែ ការលក់ដីអាចកើនឡើងនៅឃុំទឹកល្អក់ ព្រោះមានផ្លូវថ្មីមួយដែលភ្ជាប់ក្រុងព្រះសីហនុ និងខេត្តកំពត ទើបតែសង់រួច និងឆ្លងកាត់ឃុំនេះ ។

**តារាង ៦.៣គ. ការលក់ដី គិតតាមឃុំ**

| ឃុំ | ចំនួនលក់ | ទំហំដីមធ្យម (ហ.ត) | តំលៃ (ម៉ឺនរៀល/ហ.ត) | ខេត្ត |
|---|---|---|---|---|
| ត្រពាំងសាប | 39 | .151 | 1,535 | តាកែវ *** |
| រវៀង | 48 | .120 | 6,088 | តាកែវ |
| ជើងគោ | 18 | .461 | 333 | ក្រុងព្រះសីហនុ |
| ព្រៃនប់ | 19 | .697 | 728 | ក្រុងព្រះសីហនុ |
| ទឹកល្អក់ | 7 | .515 | 153 | ក្រុងព្រះសីហនុ |
| ស្រយ៉ូវ | 35 | .314 | 910 | កំពង់ធំ |
| ទីពោធិ៍ | 14 | .400 | 130 | កំពង់ធំ |
| សំបួរ | 90 | .405 | 382 | កំពង់ចាម |
| ស្រង៉ែ | 33 | .162 | 911 | កំពង់ចាម |
| សរុប | 303 | .314 | 1,555 | |

ទិន្នន័យដែលទាក់ទងនឹងតំលៃនៃការលក់ដី [៣៣] ក៏គាំទ្រទំនាក់ទំនងរវាងកំណើនទីផ្សារដី ទីតាំង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ តំបន់ចំនួនបួនដែលមានតំលៃដីខ្ពស់បំផុត គឺស្ថិតនៅ ជិតទីក្រុងភ្នំពេញ ក្នុងទីរួមខេត្ត និង/ឬ ជាតំបន់មានរីកំពុងអនុវត្ត គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ឃុំស្រង៉ែមានការប្រើប្រាស់ដីបែបប្រពលវប្បកម្មដែលបច្ចុប្បន្ន ដីខ្លះអាចធ្វើកសិកម្ម បានបីដងក្នុងមួយឆ្នាំ ។ តំលៃដី នឹងកើនឡើងក្នុងតំបន់ទាំងនេះ នៅពេលមានការផ្តល់បណ្ណ័កម្មសិទ្ធិដីធ្លី ។ ជាងនេះទៅទៀត ឃុំពីរបានលើកឡើងខាងលើ (ឃុំទីពោធិ៍ និងឃុំទឹកល្អក់) ដែលស្ថិត នៅឆ្ងាយពីផ្លូវជាតិ ផ្សារ និងមជ្ឈមណ្ឌលរដ្ឋបាល មានថ្លៃដីថោកបំផុត ។ យើងសង្ឃឹមថាតំលៃដីយ៉ាងហោចណាស់ នឹងកើនឡើងនៅឃុំទឹកល្អក់ បន្ទាប់ពីសំណង់ផ្លូវជាតិថ្មី ត្រូវបានសង់រួច ។ ទោះជាយ៉ាងណាក្តី តំលៃដីលក់ជាមធ្យម នៅឃុំសំបួរ ទាបជាងតំលៃដែលយើងបានរំពឹងទុក ។ តួលេខនេះអាចខុស ឬក៏ប្រជាជនកំពុងលក់ដីមានផលិតភាពទាប (ឧ. ដីគ្មានជីជាតិ ដីលិចទឹក) ។ យើងរំពឹងថា យ៉ាងហោចណាស់ ថ្លៃដីគួរតែមានកំរិតប្រហែលនឹង ថ្លៃដីនៅឃុំស្រង៉ែ ។

ទំនាក់ទំនងរវាងការកើតឡើងទីផ្សារដី ទីតាំង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ គឺគាំទ្រដោយទិន្នន័យនៅក្នុងតារាង ៦.៣ឃ ខាងក្រោម ។ តារាងនេះបង្ហាញថា ៦២% នៃការលក់ដីបានរាយការណ៍ បានធ្វើឡើងតាំងពីឆ្នាំ១៩៩៨ ។ ចំនុចគួឱ្យចាប់

[៣៣] ទិន្នន័យដែលបានរាយការណ៍ពីតំលៃដីគឺផ្អែកទៅលើការវាយតំលៃពីអ្នកឆ្លើយសំភាសន៍ខ្លួនឯងផ្ទាល់ ។

អារម្មណ៍គឺថា ៦៧%នៃការលក់ដីនៅឃុំសំបួរ និងជិត ៧៨% នៃការលក់ដីនៅឃុំរវៀង (ខេត្តតាកែវ) បានកើតឡើងតាំងពីឆ្នាំ១៩៩៨ ម្ល៉េះ ហើយពាក់កណ្តាលនៃចំនួននេះ ត្រូវបានលក់នៅឆ្នាំ២០០២ ។ មានការចាប់អារម្មណ៍ធ្វើការសង្កេតថា ការផ្ទេរកម្មសិទ្ធិដីធ្លី មានការកើនឡើង រឹបន្តកើនយឺតៗ នៅតាមបណ្តោយ ផ្លូវជាតិលេខ ៤ ក្នុងសង្កាត់ជើងគោ និងសង្កាត់ព្រៃនប់ ។ ដោយដីទាំងនោះមានទីតាំងជាយុទ្ធសាស្ត្រ យើងធ្វើការទស្សន៍ទាយថា ការលក់ដីអាចនឹងកើនឡើងនៅប៉ុន្មានឆ្នាំខាងមុខទៀត ដោយសារមានប្រជាពលរដ្ឋច្រើនពីភ្នំពេញ ឬពីកន្លែងផ្សេងទៀត (ឧ.អ្នកទីក្រុងព្រះសីហនុ) ពិចារណាធ្វើការវិនិយោគបង្កើតឱ្យមានទីផ្សារដី ។

**តារាង ៦.៣ឃ. ការលក់ដីនៅតាមឆ្នាំ**

| ឃុំ | < 1989 | 1989-93 | 1994-97 | 1998-2001 | 2002-2004 | សរុប |
|---|---|---|---|---|---|---|
| ត្រពាំងសាប | 0 | 7 | 16 | 8 | 5 | 36 |
| រវៀង | 0 | 3 | 9 | 22 | 14 | 48 |
| ជើងគោ | 0 | 4 | 1 | 7 | 6 | 18 |
| ព្រៃនប់ | 0 | 2 | 9 | 6 | 2 | 19 |
| ទឹកល្អក់ | 1 | 2 | 1 | 3 | 0 | 7 |
| ស្រែយ៉ូវ | 0 | 5 | 9 | 18 | 3 | 35 |
| ទីពោធិ៍ | 0 | 1 | 5 | 6 | 2 | 14 |
| សំបួរ | 0 | 16 | 13 | 33 | 28 | 90 |
| ស្រែង៉ែ | 0 | 4 | 7 | 18 | 4 | 33 |
| សរុប | 1 | 44 | 70 | 121 | 64 | 300 |

ជាចុងក្រោយ តារាង ៦.៣ង ខាងក្រោមបង្ហាញថា គ្រួសារបានលក់ដីដោយសារហេតុផលផ្សេងៗ ។ វាមិនមានការភ្ញាក់ផ្អើលទេដែលថា ហេតុផលជារឿយៗទីមួយ គឺទាក់ទងនឹងបញ្ហាថែទាំសុខភាព (២៤.៩%) ។ ប្រសិនបើចំណាយលើការថែទាំសុខភាពមិនធ្លាក់មកនៅក៏រឹតទាបនៅក្នុងតំបន់នៃគំរោង LMAP នោះយើងនឹងឃើញមានអត្រាដូចគ្នានៃ ការលក់ដីដោយសារហេតុផលនេះ ។ ហេតុផលទីពីរ គឺពាក់ព័ន្ធទៅនឹងការវិនិយោគលើមុខរបរ (១៨.៦%) ។ នៅពេលខាងមុខ ប្រសិនបើប្រជាពលរដ្ឋប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីទទួលបានកំចីសំរាប់វិនិយោគលើមុខរបរ ឬសកម្មភាពផ្សេងទៀត នោះយើងអាចនឹងឃើញការធ្លាក់ចុះនៃការលក់ដី ។ ចំលើយរបស់គ្រួសារចំនួន ២៤ (៩.៧%) ពីលក្ខណៈនៃក្បាលដីមានជាអាទិ៍ ក្បាលដីតូចពេក/ដីមិនសូវផ្តល់ផលដីគ្មានគុណភាព ឬដីមានទីតាំងនៅឆ្ងាយពេក ។ ចំនួន ៨.៥%ផ្សេងទៀត ពាក់ព័ន្ធនឹងការលក់ដី គឺដោយសារកង្វះខាតម្ហូបអាហារ ។ យើងរំពឹងថា ការលក់ដីដោយសារហេតុផលទាំងនេះ នឹងនៅតែបន្តក្នុងអត្រាដូចគ្នា រឺខ្ពស់ជាងនេះនៅតំបន់ដែលការផ្តល់សេវាកម្មបច្ចេកទេស និងសេវាឥណទាននៅមានការខ្វះខាត ។ កត្តារួមផ្សំផ្សេងទៀត គឺការសងបំណុល ការធ្វើបុណ្យសព ការធ្វើអន្តោប្រវេសន៍ និងវិបត្តិក្នុងគ្រួសារ ។

**តារាង ៦.៣ង. ការលក់ដី និងហេតុផលនៃការលក់ដី**

| ឃុំ | ជំនួញ | ថែទាំសុខភាព | ទិញស្បៀង | លក្ខណៈឡូតិ៍ | ផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| ត្រពាំងសាប | 4 | 7 | 1 | 8 | 13 | 33 |
| រវៀង | 5 | 6 | 8 | 7 | 12 | 38 |
| ជើងគោ | 2 | 5 | 2 | 1 | 7 | 17 |
| ព្រៃនប់ | 3 | 4 | 0 | 0 | 11 | 18 |
| ទឹកល្អក់ | 1 | 0 | 1 | 0 | 4 | 6 |
| ស្រែយ៉ូវ | 5 | 10 | 4 | 1 | 7 | 27 |
| ទីពោធិ៍ | 5 | 5 | 1 | 1 | 1 | 13 |
| សំបូរ | 13 | 19 | 4 | 6 | 30 | 72 |
| ស្រែង៉ែ | 8 | 5 | 0 | 0 | 10 | 23 |
| | | | | | | |
| សរុប | 46 | 61 | 21 | 24 | 95 | 247 |

ប័ណ្ណកម្មសិទ្ធិដីធ្លីតែឯង ទោះបីជាយ៉ាងណាក្តី មិនអាចធ្វើអោយអត្រានៃការលក់ដីយឺត រឺលឿននៅក្នុងចំណោមអ្នកកាន់កាប់ដីនោះទេ ។ ដូចបានកត់សំគាល់ យើងរំពឹងថា ការលក់ដីដោយសារហេតុផលខាងលើនឹងបន្តក្នុងអត្រាដូចគ្នា ឬអាចឡើងខ្ពស់ជាងនេះនៅក្នុងតំបន់ ប្រសិនបើការផ្តល់សេវាកម្មសុខាភិបាល សេវាកម្មបច្ចេកទេស និងសេវាកម្មឥណទានមានការខ្វះខាត ។ ក្រៅពីនេះ ប្រសិនបើប្រជាពលរដ្ឋប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងបំណងយកប្រាក់កំចី ដើម្បីវិនិយោគលើមុខរបប និងសកម្មភាពផ្សេងទៀត យើងអាចនឹងឃើញ ការថយចុះនៃការលក់ដីដោយសារហេតុផលនេះ លើកលែងតែជំនួញត្រូវបង់ខាត ហើយប្រជាជនត្រូវលក់ដីសងបំណុល ។ នៅក្នុងករណីបែបនេះ ប័ណ្ណកម្មសិទ្ធិដីធ្លីអាចឱ្យប្រជាពលរដ្ឋទទួលបានតំលៃដីល្អប្រសើរជាងមុន ។ ដូច្នេះប័ណ្ណកម្មសិទ្ធិដីធ្លីនេះ អាចជារង្វាន់លួងចិត្តតិចតួចសំរាប់អ្នកទាំងឡាយណាដែលគ្មានជំរើសផ្សេងក្រៅពីការដាំដុះ ។

នៅពេលក្រោយ ប័ណ្ណកម្មសិទ្ធិដីធ្លី អាចបង្កើនប្រសិទ្ធភាពនៃទីផ្សារដី ដោយកាត់បន្ថយតំលៃនៃការផ្ទេរពាក់ព័ន្ធនឹងកិច្ចសន្យានៃការផ្ទេរសិទ្ធិ (ឧ. ព័ត៌មាន តំលៃលើការពង្រឹងការអនុវត្ត) ។ នៅពេលតំលៃជាប់ពាក់ព័ន្ធនឹង អសុវត្ថិភាពនៃការផ្ទេរសិទ្ធិត្រូវបានកាត់បន្ថយ ចំនួន និងភាពញឹកញាប់នៃការផ្ទេរដីនឹងបានកើនឡើង ជាពិសេសនៅក្នុងតំបន់ដែលដីមានផលិតភាពខ្ពស់ និង/ឬ តំលៃប៉ាន់ស្មាននៃដីកើនឡើង ។ ដូចបានកត់សំគាល់ខាងលើក៏រឹតដែលទីផ្សារដី ធ្វើឱ្យការប្រើប្រាស់ដី តំរង់ទៅរកទិសដៅឱ្យកាន់តែមានប្រសិទ្ធភាព គឺវាផ្អែកទៅលើកត្តាជាច្រើន ។ វាមិនអាស្រ័យតែទៅលើ ក៏រឹតដែលប្រជាពលរដ្ឋមានការជឿទុកចិត្តទៅលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលបានផ្តល់ជូន និងពង្រឹងការអនុវត្ត ដោយរដ្ឋាភិបាលនោះទេ ។

## ៦.៤ រដ្ឋបាល និងការគ្រប់គ្រងដីធ្លី

នៅក្នុងចំណោម ១.០១៨ក្បាលដីលំនៅដ្ឋាន នៅក្នុងតំបន់អង្កេតមាន ៦៦៧ក្បាលដី (៦៥.៦%) មិនធ្លាប់មានប្លង់ ឬលិខិតស្នាមអ្វីទេ ។ ភាគរយនៃបុរសជាមេគ្រួ (៦៧%) ច្រើនជាងភាគរយនៃស្ត្រីជាមេគ្រួ (៦១.៣%) មិនធ្លាប់មានឯកសារលិខិត

ស្នាមអ្វីទេ ។ មានប្រហែលជា ៣% នៃក្បាលដី ធ្លាប់មានឯកសារ ប៉ុន្តែឯកសារទាំងនោះ បានបាត់បង់ទៅហើយ ។ និយាយពីឯកសារក្បាលដីលំនៅដ្ឋាន ចំនួន ២២,២% មានវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី រីឯ ៤,៩% ផ្សេងទៀត មានឯកសារវាស់វែងក្បាលដី ។ មានតែ ៤,២% ប៉ុណ្ណោះ ដែលមានវិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លីពិតប្រាកដ ។ អវត្តមាននូវឯកសារ និងការប្រើប្រាស់វិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដីជំនួស តែងឃើញកើតមានតិច ឬច្រើននៅគ្រប់ចន្លោះក្រុមកាន់កាប់ដី ។

***ដីកសិកម្ម:*** នៅក្នុងចំណោម ៣.៨៧៩ ក្បាលដីកសិកម្ម នៅក្នុងតំបន់អង្កេត មាន ២.៤២៦ក្បាលដី (៦២,៥%) មិនធ្លាប់មានប្លង់ ឬលិខិតស្នាមអ្វីទេ ។ ក្បាលដីដែលបានចុះបញ្ជីតាមមធ្យោបាយផ្សេងៗ មានចំនួន ១.២៧៤ក្បាលដី (៣២,៨%) ដែលនាពេលថ្មីៗនេះមានឯកសារខ្លះៗ ។ រីឯ ១៧៨ក្បាលដី ផ្សេងទៀត (៤,៧%) បានបាត់បង់ ឯកសារក្បាលដី (ទាំងផ្លូវការ និងក្រៅផ្លូវការ) ។ រឿងនេះ មានន័យថា ក្នុងពេលតែមួយ ៣៧,៥% នៃក្បាលដីផ្សេងទៀត មានឯកសារបញ្ជាក់ខ្លះៗ ឬក៏មានការស្នើថាជាម្ចាស់កម្មសិទ្ធិ ។

នៅក្នុងចំណោម ១.២៨៦ ក្បាលដីមានឯកសារ ៦៧,៣% មានវិក័យប័ត្រដាក់ពាក់សុំកាន់កាប់ដី រីឯ ១៦,៧% មានឯកសារវាស់វែងដី ។ ៩% តែប៉ុណ្ណោះ មានវិញ្ញាបនប័ត្រ ឬប័ណ្ណកម្មសិទ្ធិដីធ្លីពិតប្រាកដ រីឯ ៦,៩% ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រភេទឯកសារផ្សេងទៀត ។ តារាង ៦.៤ក ខាងក្រោមបង្ហាញថា ចំនួនស្មើគ្នាគួរអោយភ្ញាក់ផ្អើល រវាងស្ត្រី និងបុរសជាមេគ្រួបានទុកចិត្តទៅលើវិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លី ប៉ុន្តែ ភាគរយខ្ពស់ចំពោះបុរសជាមេគ្រួ បានទុកចិត្តលើវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី ។ មានការភ្ញាក់ផ្អើលផងដែរថា ទំហំកាន់កាប់ដី ហាក់មិនមានឥទ្ធិលខ្លាំងក្លាទៅលើប្រភេទនៃឯកសារដីធ្លីនោះទេ ។ ក្នុងន័យនេះ ការយកវិក័យប័ត្រដាក់ពាក់សុំកាន់កាប់ដី មកប្រើប្រាស់ជាឯកសារសំអាង ត្រូវបានអនុវត្តដោយគ្រួសារនៅគ្រប់ចន្លោះក្រុមកាន់កាប់ដី ។

**តារាង ៦.៤ក. ឯកសារដីកសិកម្ម**

| ទំហំដី (ហ.ត) | វិក័យប័ត្រសុំកាន់កាប់ដី | | ឯកសារអង្កេត | | ប័ណ្ណកម្មសិទ្ធិ | | ផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | |
| < 0.5 | 74 | 39 | 18 | 15 | 5 | 1 | 5 | 9 | 102 | 64 |
| 0.5 – 0.9 | 177 | 54 | 43 | 19 | 3 | 20 | 7 | 1 | 230 | 94 |
| 1.0 – 1.9 | 210 | 50 | 46 | 7 | 28 | 28 | 12 | 8 | 296 | 93 |
| 2.0 – 2.9 | 112 | 33 | 23 | 11 | 6 | 8 | 22 | 1 | 163 | 53 |
| > 3.0 | 101 | 17 | 29 | 4 | 16 | 1 | 23 | 1 | 169 | 23 |
| | | | | | | | | | | |
| សរុប | 673 | 193 | 159 | 56 | 58 | 58 | 69 | 20 | 959 | 327 |
| សរុប * | 866 | | 215 | | 116 | | 89 | | 1,286 | |

* Missing n = 126 (response = ‘no’)

ពាក់ព័ន្ធនឹងរដ្ឋបាលដីធ្លី ទិន្នន័យនេះផ្តោតលើហេតុផល ដែលអ្នកឆ្លើយតបបានផ្តល់សំរាប់ការមិនបានចុះបញ្ជីក្បាលដីកសិកម្មរបស់ពួកគេ ។ តារាង ៦.៤ខ ខាងក្រោមបង្ហាញថា ២២,១% នៃក្បាលដីមិនបានទាន់ចុះបញ្ជី ពួកគេនិយាយថា ដោយសារពួកគេមិនបានដឹងពីនិតិវិធីនៃការចុះបញ្ជី ១៩,៨% ថា ដោយសារគេពួកគិតថា វាមិនចាំបាច់ ៧,២% ថាដោយសារតែប្រព័ន្ធចុះបញ្ជីវាមានភាពស្មុគស្មាញពេក ហើយនិង ៤,៩% ថា ពីព្រោះតែដីមានវិវាទ ។ ទាំងអស់នេះគឺ បង្ហាញនូវហេតុផល

ពាក់ព័ន្ធនឹងដំណើរការដែលជាការស្នើថា  មានការភាន់ច្រឡំកំរិតខ្ពស់ក្នុងចំណោមប្រជាពលរដ្ឋពាក់ព័ន្ធនឹងទិដ្ឋភាពផ្សេងទៀតនៃប្រព័ន្ធចុះបញ្ជីដីធ្លី ។ បញ្ហាទាំងនេះស្នើត្រលប់មកវិញថា ការកើនឡើងនូវក្នុងការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីដី គឺវាផ្អែកមួយភាគធំទៅលើបិរមាណ និងគុណភាពនៃព័ត៌មានដែលផ្សព្វផ្សាយ ជូនប្រជាពលរដ្ឋ និងកំរិតដែលគេយល់ដឹងពីនីតិវិធីនៃការចុះបញ្ជីដីធ្លី ។ រឿងនេះ គឺវាអាស្រ័យផងដែរទៅលើភាពអាចទទួលបាន និងប្រសិទ្ធភាពនៃប្រព័ន្ធ ។

មានតួលេខគួរឱ្យភ្ញាក់ផ្អើលមួយថា មានតែ ២,៦% ប៉ុណ្ណោះនៃក្បាលដីមិនបានចុះបញ្ជី ពីព្រោះតែមកពីតំលៃសេវាក្រៅផ្លូវការ រីឯ ៣,២% ពីព្រោះតែគេគិតថា ដំណើរការវាមិនយុត្តិធមិ ។ មានប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះ ដែលបាននិយាយយោងទៅលើកត្តាពន្ធដារ ឬសោហ៊ុយសេវា ថាជាហេតុផល ដែលគេមិនបានចុះបញ្ជីដីធ្លីរបស់ខ្លួន ។ ដោយផ្អែកទៅលើការសិក្សាផ្សេងទៀត (*So et al.* 2001) គេរំពឹងថានឹងមានអ្នកឆ្លើយតបច្រើនជាងនេះ សំដៅទៅលើចំណាយពាក់ព័ន្ធនឹងថ្លៃសេវាក្រៅផ្លូវការ និងការយកពន្ធ ដែលបណ្តាលអោយមិនបានចុះបញ្ជីដីធ្លី ។ យើងអាចបន្ថែមតួលេខបែបនេះក្នុងប្រភេទ “Other” ដែលគ្រប់ដណ្តប់ស្មើតែ ៤៦% នៃក្បាលដីអង្កេតគំរូ ។

**តារាង ៦.៤ខ. ហេតុផលបណ្តាលអោយមិនបានចុះបញ្ជីដីកសិកម្ម**

| ទំហំដី (ហ.ត) | មិនត្រូវការ | | មិនដឹងពីនិតិវិធី | | ទំនាស់ | | ប្រព័ន្ធស្មុគស្មាញ | | ផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | |
| < 0.5 | 38 | 28 | 49 | 23 | 6 | 10 | 10 | 3 | 71 | 38 | 174 | 102 |
| 0.5 – 0.9 | 86 | 29 | 66 | 28 | 17 | 9 | 35 | 5 | 162 | 45 | 366 | 116 |
| 1.0 – 1.9 | 99 | 25 | 112 | 38 | 17 | 2 | 56 | 8 | 259 | 39 | 543 | 112 |
| 2.0 – 2.9 | 42 | 15 | 91 | 18 | 35 | 1 | 24 | 2 | 181 | 24 | 373 | 60 |
| > 3.0 | 98 | 30 | 107 | 14 | 23 | 0 | 18 | 18 | 290 | 28 | 536 | 90 |
| | | | | | | | | | | | | |
| សរុប | 363 | 127 | 425 | 121 | 98 | 22 | 143 | 36 | 963 | 174 | 1192 | 480 |
| សរុប | 490 | | 546 | | 120 | | 179 | | 1,137 | | 2,472 | |

## ៦.៤.១ ការផ្ទេរដី

តារាង ៦.៤គ ខាងក្រោមបង្ហាញថា មានភាគរយតិចបំផុតនៃការលក់ដីកសិកម្ម បានចុះបញ្ជីដោយមានការផ្លាស់ប្តូរឈ្មោះនៅលើវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី ។ ចំនួនការលក់បានរាយការណ៍ ដែលបានធ្វើឡើងដោយមិនចុះបញ្ជីផ្លូវការ វាមិនបាច់សង្ស័យអ្វីទេ គឺមានកំរិតខ្ពស់ ដូចជាប្រភេទ “Other” មានចំនួនសរុបដល់ ១០១ករណី ដែលប្រហែលជារួមបញ្ចូលជាមួយនូវលិខិតព្រមព្រៀង និងវិធីសាស្ត្រក្រៅផ្លូវការផ្សេងទៀត ។ មានការកត់សំគាល់គួរអោយចាប់អារម្មណ៍ថា ចំនួនការផ្លាស់ប្តូរឈ្មោះនៅលើវិក័យប័ត្របានរាយការណ៍ មានការថយចុះ ធៀបនឹងចំងាយ ។ ឧទាហរណ៍ ច្រើនជាពាក់កណ្តាល (៥១,៧៦%) នៃការលក់ដី បានចុះបញ្ជីដោយមានការផ្លាស់ប្តូរឈ្មោះ នៅថ្នាក់ភូមិ រីឯ ១១,៧៦% បានចុះបញ្ជីនៅថ្នាក់ឃុំ ។ មានតែការលក់ដី ៣ករណី ប៉ុណ្ណោះបានចុះបញ្ជីនៅថ្នាក់ស្រុក និង ១ករណី បានធ្វើឡើងដល់ថ្នាក់ខេត្ត ។ រឿងនេះស្នើថា តំលៃលើការផ្ទេរដី រួមផ្សំនឹងការធ្វើដំណើរ និងពេលវេលា គឺជាឧបសគ្គដ៏ធំ ដល់ការទទួលបានប្រព័ន្ធចុះបញ្ជីដីផ្លូវការ ។

ទ្រឹស្តីនៃការស្រាវជ្រាវ បានព្យាករណ៍ថាមានកំនើនភាគរយនៃការផ្ទេរដី (ឧ. ការលក់ ការផ្ទេរមរតក) ដែលត្រូវបានធ្វើការកែសំរួល និងកត់ត្រាទុក ដោយប្រព័ន្ធចុះបញ្ជីផ្លូវការ ជាពិសេសនៅក្នុងតំបន់ទីផ្សារដីមានសកម្មភាពខ្លាំង ដែលតំលៃដី

កំពុងកើនឡើង ។ ការព្យាករណ៍ទាំងនេះគឺថា (១)តំលៃលើការផ្ទេរដី ពាក់ព័ន្ធនឹងការចុះបញ្ជីផ្លូវការ នឹងទាបជាងតំលៃនាពេលបច្ចុប្បន្ន (២) ប្រជាពលរដ្ឋមានការជឿជាក់កាន់តែច្រើនឡើង ទៅលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លីជាងពេលបច្ចុប្បន្ន និង (៣) ប្រជាពលរដ្ឋមានចំណេះដឹងគ្រប់គ្រាន់លើនីតិវិធី និងសមត្ថភាព សមស្របក្នុងការប្រើប្រាស់ប្រព័ន្ធ ។

**តារាង ៦.៤គ. ការលក់ដី និងការរៀបចំឯកសារ**

| ឃុំ | ប្តូរឈ្មោះកិរិតភូមិ | ប្តូរឈ្មោះកិរិតឃុំ | ប្តូរឈ្មោះកិរិតស្រុក | ប្តូរឈ្មោះកិរិតខេត្ត | ផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| ត្រពាំងសាប | 25 | 5 | 0 | 0 | 10 | 33 |
| រវៀង | 30 | 4 | 3 | 0 | 11 | 40 |
| ជើងគោក | 7 | 9 | 0 | 0 | 2 | 17 |
| ព្រៃនប់ | 14 | 2 | 0 | 0 | 3 | 17 |
| ទឹកល្អក់ | 1 | 0 | 0 | 0 | 6 | 18 |
| ស្រែយ៉ូវ | 19 | 0 | 0 | 1 | 14 | 27 |
| ទីពោធិ៍ | 8 | 0 | 0 | 0 | 5 | 14 |
| សំបូរ | 44 | 5 | 0 | 0 | 40 | 73 |
| ស្រែង៉ែ | 13 | 8 | 0 | 0 | 11 | 25 |
| | | | | | | |
| សរុប | 161 | 33 | 3 | 1 | 101 | 300 |

ទោះបីយ៉ាងណា កិរិតដែលប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធផ្លូវការ អាចមានការខុសគ្នាដោយផ្អែកទៅលើសមត្ថភាព និងសុច្ឆន្ទៈនៃគ្រួសារក្នុងការចំណាយលើសោហ៊ុយសេវា និងពន្ធប្រថាប់ត្រា ។ និយាយជាទូទៅ គ្រួសារដែលមានចំណូល និងទ្រព្យច្រើនអាចមាននិន្នាការទៅរកការប្រើប្រាស់ប្រព័ន្ធផ្លូវការច្រើនជាងគ្រួសារដែលមានចំណូល និងទ្រព្យតិចតួចនៅក្នុងផ្នែកនេះ ពីព្រោះតែគេមានដីច្រើនដើម្បីធ្វើឱ្យមានសុវត្ថិភាពតាមរយៈការចុះបញ្ជីផ្លូវការ ។ នៅពេលជាមួយគ្នានេះ គ្រួសារតូចៗអាចមាននិន្នាការទៅរកការគេចវេសក្នុងការបង់ពន្ធដារផងដែរប្រសិនបើគេមានអារម្មណ៍ថា អត្រាតំលៃនោះវាខ្ពស់ខ្លាំង ហើយវិធានការយកពន្ធមិនមានភាពសមស្រប ឬអនុវត្តមិនមានភាពយុត្តិធម៌ ។

## *ការកត់សំគាល់ទៅលើផ្នែកអភិបាលកិច្ច ការយល់ឃើញរបស់ប្រជាពលរដ្ឋលើផលចំណេញពីការចុះបញ្ជីដីធ្លី*

ជាទូទៅ ប្រជាពលរដ្ឋនៅក្នុងតំបន់អង្កេត មានការយល់ឃើញជាវិជ្ជមានច្រើន ចំពោះដំណើរការនៃគំរោង LMAP ។ ហេតុផលមួយគឺថា មន្ត្រីជំនាញនៃគំរោង LMAP នៅក្នុងតំបន់របស់ពួកគេ ហាក់ធ្វើការដោយចរិតលក្ខណៈមានតំលាភាព និងមានគោលដៅច្បាស់លាស់ ។ ប្រជាពលរដ្ឋក៏មានអារម្មណ៍ផងដែរថា ដំណើរការក្នុងការដោះស្រាយវិវាទដែលបានកើតឡើង គឺមានភាពយុត្តិធម៌ ។ ជាលទ្ធផល ប្រជាពលរដ្ឋ ហាក់ដូចជាមានសេចក្តីទុកចិត្តយ៉ាងខ្លាំង លើប័ណ្ណកម្មសិទ្ធិដីធ្លីដែលគេសង្ឃឹមថានឹងបានទទួល ។

គ្រួសារចំនួន ៧៩.៦% ដែលជាភាគរយច្រើនគួរឱ្យកត់សំគាល់ មានអារម្មណ៍ថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លី គឺមានសារៈសំខាន់បំផុត លើផលចំណេញបានពីប័ណ្ណកម្មសិទ្ធិដីធ្លី ។ ឆ្លើយតបទៅនឹងអ្វីដែលជាការយល់ឃើញថាមានសារៈសំខាន់

ទីពីរលើផលចំណេញនោះ គ្រួសារចំនួន ៥៣,៧% បានគូសបញ្ជាក់ពីការកាត់បន្ថយវិវាទដីធ្លី ។ ទាក់ទិននឹងផលចំណេញមានសារៈសំខាន់ទីបី គ្រួសារចំនួន ៤០,៣% បានគូសបញ្ជាក់ថា ប័ណ្ណកម្មសិទ្ធិដី អាចធ្វើឱ្យពួកគេមានភាពងាយស្រួលក្នុងការខ្ចីប្រាក់ នៅខណៈដែល ៤០,៣% ផ្សេងទៀតបាននិយាយថា ប័ណ្ណកម្មសិទ្ធិដីធ្លីក៏អាចធ្វើឱ្យមានភាពងាយស្រួលផងដែរទៅលើការផ្ទេរដី ។

## ៦.៥. វិវាទដីធ្លី និងការដោះស្រាយ

មានវិវាទដីធ្លីសរុបចំនួន ៦១ករណី ត្រូវបានរាយការណ៍ថា បានកើតឡើងនៅក្នុងតំបន់អង្កេតនៃគំរោង LMAP តាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ។ នៅក្នុងចំណោម ៦០ ករណីវិវាទពាក់ព័ន្ធនឹងការកាន់កាប់ដីកសិកម្ម ៤៨ករណី (៨០%) គឺពាក់ព័ន្ធនឹងបុរសជាមេគ្រួសារ រីឯ ១២ ករណី (២០%) ពាក់ព័ន្ធនឹងស្ត្រីជាមេគ្រួសារ ។ ប្រហែលជា ៤៨% នៃវិវាទ (២៩ករណី) ត្រូវបានរាយការណ៍ថា គឺពាក់ព័ន្ធជាមួយគ្រួសារដែលមានដីកសិកម្មមួយហិកតា ឬតិចជាងនេះ រីឯ ២៨% (១៧ករណី) គឺពាក់ព័ន្ធនឹងគ្រួសារដែលមានដី ២ហិកតា ឬច្រើនជាងនេះ (សូមមើលនៅក្នុងតារាង ៦.៥ក) ។ ប្រភេទដីពាក់ព័ន្ធនឹងវិវាទ ជារឿយៗ គឺបានបែងចែកជា ដីកសិកម្ម (៣១ ករណី) និងដីលំនៅដ្ឋាន (២៩ករណី) ។

**តារាង ៦.៥ក. របាយការណ៍នៃវិវាទដីធ្លី**

| យ៉េនឌ័រ | < 0.5 | 0.5-.99 | 1.0 – 1.99 | 2.0 – 2.99 | ≥ 3 | សរុប |
|---|---|---|---|---|---|---|
| បុរស | 8 | 14 | 11 | 9 | 6 | 48 |
| ស្ត្រី | 6 | 1 | 3 | 1 | 1 | 12 |
| | | | | | | |
| សរុប | 14 | 15 | 14 | 10 | 7 | 60 |

វិវាទព្រំប្រទល់ដីជាមួយអ្នកជិតខាងមានចំនួន ២៣ករណី (៣៨,៣%) បន្ទាប់មកគឺ ១៣ករណី ជាប់ពាក់ព័ន្ធនឹងភូមិផ្សេងទៀត (២១,៦%) និង ១២ករណី ជាវិវាទជាមួយសាច់ញាតិ (២០%) ។ ៦ករណី (១០%) ត្រូវបានរាយការណ៍ថា មានការទន្ទ្រានកាន់កាប់ដី ដែលមួយផ្នែកជាអាជ្ញាធរ ឬអ្នកមានអំណាច និងមាន ៦ករណី ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត ។ ការបែងចែកប្រភេទវិវាទដីធ្លី គឺសំអាងលើការកត់សំគាល់ដោយការសិក្សាពីមុន (*So et al.* ២០០១) ដែលបានស្នើថា ស្ទើរតែគ្រប់ករណីវិវាទ គឺមាននៅថ្នាក់មូលដ្ឋាន ដែលក្នុងនោះពាក់ព័ន្ធទៅនឹងជំលោះព្រំប្រទល់ជាមួយអ្នកជិតខាង ឬអ្នកផ្សេងទៀតនៅក្នុងភូមិ ឬជំលោះកម្មសិទ្ធិនៅក្នុងចំណោមសាច់ញាតិ ។ មានការសិក្សាផ្សេងទៀត បានរាយការណ៍ថា កំរិតដ៏ខ្ពស់នៃការដណ្តើមយកដី និងការទន្ទ្រានកាន់កាប់ដី មានស្ទើរតែគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ហើយក៏បានស្នើផងដែរថា វិសាលភាព និងកំរិតនៃវិវាទដីធ្លីជារឿយៗ គឺផ្អែកទៅតាមសភាពការណ៍ជាក់ស្តែង ។ ក្នុងន័យនេះ វាអាចធ្វើឱ្យយើងពិចារណាថា ការជ្រើសរើសតំបន់នៃគំរោង LMAP សំរាប់អនុវត្តដំណើរការចុះបញ្ជីដីធ្លី គឺសំដៅទៅរកតំបន់ណាដែលមានស្ថិរភាព ។ ពោលគឺជាតំបន់បង្កបង្កើនផលស្រូវតាមលក្ខណៈយថាផល ដែលជារបៀបធ្វើកសិកម្មបែបសាមញ្ញបំផុត ។ ជាលទ្ធផល ចំនួន រឺប្រភេទវិវាទដីធ្លីនៅតំបន់អង្កេតនៃគំរោងLMAP បានរាយការណ៍មក គឺមិនគួរឱ្យមានការភ្ញាក់ផ្អើលនោះទេ ។

## ៦.៥.១ ការដោះស្រាយវិវាទដីធ្លី

តាមរបាយការណ៍ ៦១គ្រួសារ ដែលពាក់ព័ន្ធនឹងវិវាទដីធ្លី បានប្រើប្រាស់វិធីសាស្រ្តផ្សេងៗគ្នាក្នុងការដោះស្រាយ ហើយមានករណីវិវាទជាច្រើន បានដំណើរការដោះស្រាយដោយច្រើនជំហាន ។ នៅក្នុងជំហានទី១ មាន ២១គ្រួសារ ព្យាយាមចរចាដើម្បីរកដំណោះស្រាយដោយផ្ទាល់ ជាមួយភាគីជំលោះ រីឯ ២៣គ្រួសារ បានឡើងទៅដល់ប្រធានភូមិ ។ មាន ៨គ្រួសារ បានឡើងទៅដល់មេឃុំ និង ៣គ្រួសារ ឡើងទៅដល់គណៈកម្មការដោះស្រាយវិវាទថ្នាក់ស្រុក ។ ២គ្រួសារ បានទៅរកអ្នកណាម្នាក់នៅក្នុងភូមិដើម្បីឱ្យជួយដោះស្រាយ (ឧ.អ្នកជិតខាង ព្រះសង្ឃ) ហើយនឹង ៤គ្រួសារទៀត បានប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីដោះស្រាយ ។ ដោយសារស្ទើរតែគ្រប់វិវាទពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋ នៅក្នុងភូមិតែមួយ ការពញនិយមដោះស្រាយវិវាទនៅថ្នាក់ភូមិ គឺមិនគួរអោយភ្ញាក់ផ្អើលទេ ។ កត្តាផ្សេងទៀតពាក់ព័ន្ធ នឹងការដោះស្រាយវិវាទ គឺមានទំនាក់ទំនងជាមួយពេលវេលា ការធ្វើដំណើរ និងថ្លៃសេវាផ្សេងៗ ពាក់ព័ន្ធនឹងការប្រើប្រាស់អាជ្ញាធរប្រយោល (សូមមើលផ្នែក ៧.៤) ។ ទោះយ៉ាងណា ករណីវិវាទតិចជាងពាក់កណ្តាល (២៨ករណី) ត្រូវបានដោះស្រាយនៅក្នុងពេលធ្វើការចរចាលើកទី១ រីឯ ៣១ករណី មិនអាចដោះស្រាយបាន ។

នៅក្នុងចំណោម ៣១ករណី មាន២១ករណី បានរាយការណ៍ថា ស្ថិតនៅក្នុងជំហានទី២ នៃការចរចា និង ១០ករណីមិនអាចដោះស្រាយបាន ។ វាក៏អាចទៅរួចដែរថា គ្រួសារមួយចំនួនក្នុងចំណោម ១០គ្រួសារទាំងនេះ អាចចាកចេញពីវិវាទដោយហេតុផលផ្សេងៗគ្នា ឬក៏មិនបានរបាយការណ៍ពីជំហានបន្តបន្ទាប់ទៅអ្នកធ្វើសំភាសន៍ ។ ក្នុងចំណោម ២១ករណី នៅក្នុងជំហានទី២ មាន ៧ករណី ត្រូវបានរាយការណ៍ថាឡើងដល់មេភូមិ នៅខណៈដែលមានមួយករណីពាក់ព័ន្ធជាមួយអ្នកជិតខាង ។ នៅសល់ ១១ករណី ពាក់ព័ន្ធជាមួយអាជ្ញាធរខាងក្រៅ ក្នុងនោះ រួមមាន មេឃុំ (៨ករណី) គណៈកម្មការដោះស្រាយវិវាទដីថ្នាក់ខេត្ត (២ករណី) និងមួយករណីនៅគណៈកម្មការដោះស្រាយវិវាទដីធ្លីថ្នាក់ជាតិ ។ ថ្វីបើចំនួននៃករណីវិវាទ គឺជាជំលោះបន្តិចបន្តួច ប៉ុន្តែមានការស្នើថា ប្រជាពលរដ្ឋមានបំណងប្តឹងឧទ្ធរណ៍ទៅអាជ្ញាធរថ្នាក់ខ្ពស់ជាងនេះ នៅពេលដែលគេមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋាន ។ ទោះបីជាយ៉ាងណាក្តី ក្នុងចំណោម ២១ករណី មានតែ ៥គ្រួសារប៉ុណ្ណោះ បានរាយការណ៍ថាករណីរបស់ពួកគេ ត្រូវបានដោះស្រាយហើយ រីឯ ១៦ករណី មិនអាចដោះស្រាយបាននៅក្នុងជំហានទី ២នៃការចរចានោះទេ ។

នៅក្នុងចំណោម ១៦ករណី មាន ១០គ្រួសារ បានរាយការណ៍ថា បានធ្វើការចរចានៅជំហានទី ៣ ។ មានមួយករណីពាក់ព័ន្ធនឹងការចរចាគ្នាដោយផ្ទាល់ រីឯ ៨ករណី ពាក់ព័ន្ធជាមួយអាជ្ញាធរខាងក្រៅ ក្នុងនោះមាន មេឃុំ (២ករណី) គណៈកម្មការដោះស្រាយវិវាទថ្នាក់ស្រុក (៣ករណី) និងគណៈកម្មការដោះស្រាយវិវាទថ្នាក់ជាតិ (២ករណី) ។ នៅសល់ ២ករណីទៀតពាក់ព័ន្ធនឹងការដោះស្រាយតាមមធ្យោបាយផ្សេងទៀត ។ មានករណីវិវាទចំនួន ៦ ត្រូវបានដោះស្រាយ នៅជំហានទី៣ រីឯ ៤ករណីមិនអាចដោះស្រាយបាន ។

ទាក់ទិននឹងចំណាយលើការចរចាដើម្បីដោះស្រាយវិវាទបានរាយការណ៍ មាន ៥៨គ្រួសារពាក់ព័ន្ធនឹងការចរចាដោះស្រាយវិវាទនៅជំហានទី១ ត្រូវចំណាយជាមធ្យមចំនួន ០,៧៩៧ ម៉ឺនរៀល នៅខណៈដែល ២១គ្រួសារ បានចំណាយជាមធ្យមចំនួន ២,២១៤ម៉ឺនរៀល នៅក្នុងការចរចាជំហានទី២ និងមាន ១០គ្រួសារ បានចំណាយជាមធ្យមចំនួន ៣,៥ម៉ឺនរៀល នៅក្នុងការចរចាជំហានទី ៣ ។ ជាថ្មីម្តងទៀត ទោះបីជាចំនួនករណីវិវាទនេះមានតិចតួច ទិន្នន័យនេះបានស្នើថា គ្រប់លំដាប់

ជំហានទីមួយៗក្នុងការចរចា មានការចំណាយកើនឡើងជាលំដាប់ ។ នេះវាប្រហែលមកពីជំហានបន្តបន្ទាប់ គឺមានការពាក់ព័ន្ធច្រើន ជាមួយអាជ្ញាធរខាងក្រៅ (ឧ. ការធ្វើដំណើរ និងចំណាយផ្សេងៗទៀត) ។ ជាលទ្ធផល ១០គ្រួសារ ដែលឡើងទៅដល់ការចរចាដោះស្រាយវិវាទគ្រប់ជំហានទាំង៣បានរាយការណ៍ បានចំណាយជាមធ្យម ៦,៥ម៉ឺនរៀល ។ មានគ្រួសារខ្លះយើងគិតថាអាចចំណាយច្រើនជាងនេះ ។

គ្រួសារមួយចំនួនត្រូវបានសួរពីការបាត់បង់ដីរបស់ពួកគេ បន្ទាប់ពីលទ្ធផលនៃការដោះស្រាយវិវាទ ។ នៅក្នុងចំណោម ៥៥គ្រួសារ ដែលដាក់បញ្ចូលទៅក្នុងកំរងទិន្នន័យ មាន ១៤ គ្រួសារ បានបញ្ជាក់ដោយគ្មានយោបល់/មិនឆ្លើយ ។ ជិត ៣៩ករណីវិវាទ ដែលលើកឡើងខាងលើ មានការដោះស្រាយខ្លះៗ ។ នៅក្នុងចំណោម ៤១គ្រួសារ មាន ១៨គ្រួសារ ត្រូវបានរាយការណ៍ថាមិនមានការបាត់បង់ដីទេ រីឯ ១៤ គ្រួសារ មានការបាត់បង់ដីខ្លះ និង ៩គ្រួសារ បានបាត់បង់ដីទាំងស្រុង ។

គ្រួសារទាំងនោះក្រោយមក ត្រូវបានសួរពីការពេញចិត្តនឹងការដោះស្រាយវិវាទ និងអង្គភាពជួយដោះស្រាយករណីវិវាទដែលត្រូវបានដោះស្រាយ ។ ២៧គ្រួសារ នៅក្នុងចំណោម ៤៣គ្រួសារ (៦២,៨%) បានបញ្ជាក់ថា គេមានការពេញចិត្តនៅខណៈដែលនៅសល់ ១៦ គ្រួសារ (៣៧,២%) ឆ្លើយថាមិនពេញចិត្ត ។ វាមិនមែនជាការភ្ញាក់ផ្អើលអ្វីទេដែល ២៦គ្រួសារនិយាយថាការដោះស្រាយនេះគឺមានយុត្តិធម៌ នៅខណៈដែល ១៣គ្រួសារ គិតថាអយុត្តិធម៌ និង ៤គ្រួសារឆ្លើយថា មិនដឹង ។ ជាក់ស្តែង គឺមានភាពច្បាស់លាស់នៃទំនាក់ទំនងរវាងការពេញចិត្តរបស់នរណាម្នាក់ពីលទ្ធផលដែលចេញមក និងអារម្មណ៍របស់នរណាម្នាក់ទៀតពីភាពយុត្តិធម៌ នៃដំណោះស្រាយ ឬដំណើរការដោះស្រាយ ។

## សេចក្តីសង្ខេប

និយាយជាទូទៅ យើងរំពឹងថា ប័ណ្ណកម្មសិទ្ធិដីធ្លី នឹងនាំទៅរកភាពយូរអង្វែង ក្នុងការកាត់បន្ថយចំនួនជំលោះដីធ្លីយ៉ាងច្រើននៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ មានហេតុផលមួយ គឺថាដំណើរការចុះបញ្ជីដីធ្លីខ្លួនឯង តំរូវឱ្យមានការដោះស្រាយវិវាទដីធ្លីចប់សព្វគ្រប់ជាមុនសិន ។ ទោះបីជាយ៉ាងណាក្តី ដោយសារប្រជាពលរដ្ឋជាច្រើន យល់ឃើញថាដំណើរការចុះបញ្ជីដីធ្លីរបស់គំរោង LMAP ជាដំណើរការចុងក្រោយ បញ្ហាអសកម្មភាពរយៈយូរ ឬវិវាទមិនអាចដោះស្រាយបាន អាចនឹងកើតឡើង នៅពេលកម្មវិធីចុះបញ្ជីដីធ្លី ត្រូវបានប្រកាសជាលើកទី១ នៅតំបន់ជាក់លាក់ណាមួយ ។ ប្រជាពលរដ្ឋខ្លះ អាចប្រើប្រាស់ឱកាសនេះទៅទន្ទ្រាន ឬទៅរំលោភយកដី មុនពេលចាប់ផ្តើមដំណើរការគំរោង LMAP ។ នៅក្នុងករណីនេះ ដំណើរការរបស់គំរោងអាចធ្វើឱ្យមានកាន់តែច្រើនឡើងនូវចំនួននៃ របាយការណ៍វិវាទនៅក្នុងពេលដំណើរការចុះបញ្ជីធ្លីនៃគំរោង LMAP ។ ប៉ុន្តែនៅពេលដែលប័ណ្ណកម្មសិទ្ធិត្រូវបានចេញជូន យើងរំពឹងថា ចំនួនវិវាទនឹងមានការធ្លាក់ចុះ ជាពិសេសពាក់ព័ន្ធទៅជំលោះព្រំប្រទល់ជាមួយអ្នកជិតខាង ។ ជំលោះលើកម្មសិទ្ធិដី ក៏អាចថយចុះផងដែរ ប៉ុន្តែប្រហែលមិនទាំងស្រុងនោះទេ ជាពិសេសករណីវិវាទពាក់ព័ន្ធនឹងការផ្ទេរមរតក និងបញ្ហាគ្រួសារផ្សេងទៀត ។

បញ្ហាទាំងនេះក៏អាចធ្វើការកត់សំគាល់ផងដែរថា គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅជនបទនាពេលថ្មីៗនេះ ធ្វើឱ្យមានផលប៉ះពាល់ខ្លាំងលើសេដ្ឋកិច្ចនៅជនបទ ហើយបង្កើនសក្តានុពលតំលៃផលិតកម្មនៃដី ។ ឆ្លើយតបនឹងបញ្ហានេះ អ្នកមកពីខាងក្រៅ (ភាគច្រើនមកពីតំបន់ទីក្រុង) បានធ្វើការទិញដីជនបទនៅតាមដងផ្លូវសំខាន់ៗ និងនៅជិតមជ្ឈមណ្ឌលទីផ្សារមុនពេល និងក្រោយពេលអនុវត្តគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ គ្រួសារក្រីក្រជាច្រើនបានលក់ដី លំនៅដ្ឋានរបស់ពួកគេក្នុង

នោះក៏មានអ្នករៀបការថ្មីៗបានប្តូរទៅរស់នៅ ឬបើមិនដូច្នេះទេធ្វើការផ្លាស់ប្តូរពីដីកសិកម្ម ដែលនៅឆ្ងាយពីដងផ្លូវសំខាន់ៗ របស់គេឱ្យទៅជាដីលំនៅដ្ឋាន ។

គេមិនឃើញមានចំនួននៃករណីវិវាទកើតឡើងច្រើននៅក្នុងតំបន់អង្កេតទេ ដោយសារអ្នកខាងក្រៅបានទុកដីទំនេរចោល ក្នុងខណៈដែលធ្វើការបដិសេធការប្រើប្រាស់របស់ប្រជាពលរដ្ឋ ។ ប៉ុន្តែ ករណីវិវាទនេះ ជាក្តីបារម្ភចំបងរបស់ក្រុមប្រឹក្សាឃុំ ។ នៅក្នុងករណីនេះ សមាជិកក្រុមប្រឹក្សាឃុំដែលបានធ្វើសំភាសន៍នៅក្នុងពេលធ្វើការសិក្សា មានការជឿជាក់ថា ប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការ និងនីតិវិធីនៃការចុះបញ្ជីនឹងសំរួលដល់ការពង្រឹងការអនុវត្តន៏ច្បាប់ និងបទប្បញ្ញត្តិមានស្រាប់ ព្រមទាំងជួយកាត់បន្ថយនូវវិវាទដីធ្លីនៅក្នុងតំបន់យុត្តាធិការរបស់ពួកគេ ។ ទោះជាយ៉ាងណាក្តី កំរិតនៃការទទួលខុសត្រូវជាក់ស្តែងរបស់សមាជិកក្រុមប្រឹក្សាឃុំជាច្រើន គឺមិនមានភាពច្បាស់លាស់ទេ ។

# ជំពូក ៧.
# ខេត្តកំពង់ឆ្នាំងៈ តំបន់សិក្សា

## ៧.១ លក្ខណៈរបស់គ្រួសារ

***ដីលំនៅដ្ឋាន:*** ក្នុងចំណោម ២៦០គ្រួសារ ក្នុងតំបន់ដែលយកធ្វើជាគំរូសំរាប់ត្រួតពិនិត្យ មាន ២៥០គ្រួសារកាន់កាប់ដីលំនៅដ្ឋាន ចំនួន ២៥១ ក្នុងនោះមាន ១៨គ្រួសារ គ្មានដីកសិកម្ម ។ វាតំណាងឱ្យ ៩៦,២% នៃគ្រួសារនៅក្នុងតំបន់ត្រួតពិនិត្យដោយធៀបនឹង ៩៤,៥% នៃគ្រួសារនៅក្នុងតំបន់អង្កេត LMAP ។ ក្បាលដីកសិកម្មប្រហែល ៥៦,៧% (១៦៥ក្បាលដី) បានទទួលពីរដ្ឋចែកឱ្យ រីឯ ៣០,២% (៨៨ក្បាលដី) ផ្សេងទៀត បានមកតាមរយៈការធ្វើមរតក បើប្រៀបធៀបចំនួន ៣៩,៣% បានទទួលពីរដ្ឋចែកឱ្យ និង ៣៤,៨% បានមកតាមរយៈការធ្វើមរតក នៅក្នុងតំបន់អង្កេត LMAP ។ ក្បាលដីបានមកតាមរយៈការទិញប្រហែល ៧,៩% និង ៤,៨% បានមកដោយសារការកាប់រាន បើប្រៀបធៀបជាមួយនឹង ១៧,៦% បានមកពីការទិញ និង៦,៨% បានមកពីការកាប់រានដីនៅក្នុងតំបន់អង្កេត LMAP ។

បើគិតតាមយេនឌ័រនៃមេគ្រួសារ ៥៣% នៃក្បាលដីលំនៅដ្ឋានកាន់កាប់ដោយបុរសជាមេគ្រួ បានទទួលពីរដ្ឋចែកឱ្យ រីឯ ៦៧,១% នៃក្បាលដីកាន់កាប់ដោយស្ត្រីជាមេគ្រួ បានទទួលពីរដ្ឋចែកឱ្យដូចគ្នា ។ ប្រហែល ២៦,៣% នៃក្បាលដីកាន់កាប់ដោយស្ត្រីជាមេគ្រួ និង ៣១,៦% នៃក្បាលដីកាន់កាប់ដោយបុរសជាមេគ្រួ បានមកតាមរយៈការធ្វើមរតក ។ ប្រហែល ៨,៨% នៃក្បាលដីកាន់កាប់ដោយបុរសជាមេគ្រួសារ និង ៥,៣% នៃក្បាលដីកាន់កាប់ ដោយស្ត្រីជាមេគ្រួសារ បានមកតាមរយៈការទិញ ។ ជាចុងក្រោយមាន ៦% នៃក្បាលដីកាន់កាប់ដោយបុរសជាមេគ្រួ និង ១,៣% នៃក្បាលដីកាន់កាប់ដោយស្ត្រីជាមេគ្រួសារ បានតាមរយៈការកាប់រាន ។ ជាទូទៅ គំរូនៃការទទួលបានដី ជាប់ទាក់ទងនឹងកត្តាយេនឌ័រនៃមេគ្រួសារ គឺដូចគ្នានឹងគំរូដែលបានរកឃើញនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។

***ការកាន់កាប់ដីកសិកម្ម***

ការបែងចែកកម្មសិទ្ធិនៅក្នុងតំបន់ត្រួតពិនិត្យ គឺប្រហាក់ប្រហែលគ្នានឹងតំបន់អង្កេត LMAP ដែលអ្នកកាប់កាប់ដីទំហំធំ មានដីកសិកម្មធំលើសពីធម្មតា ។ ឧទាហរណ៍ គ្រួសារកាន់កាប់ដីតិចជាង ០,៥ហ.ត មានចំនួន ២៦,៩% នៃគំរូអង្កេត ប៉ុន្តែមានដីតែ ៦,៦% ប៉ុណ្ណោះ ។ គ្រួសារកាន់កាប់ដីតិចជាង ១ហ.ត មានប្រហែលជា ៦០% នៃគំរូអង្កេត ប៉ុន្តែមានដីតែ ២៧,១% ប៉ុណ្ណោះ រីឯគ្រួសារកាន់កាប់ដីចាប់ពី ៣ហ.ត ឡើងទៅ មានប្រហែលជា ៧,៤% នៃគំរូអង្កេត ប៉ុន្តែ មានដីរហូតដល់ ២៦,៥% ។ គ្រួសារកាន់កាប់ដី ២ហ.ត ឬច្រើនជាងនេះ មានប្រហែលជា ១៥% នៃគំរូអង្កេត ប៉ុន្តែមានដីកសិកម្មរហូតដល់ ៤៣% ។

តារាង ៧.១ក ខាងក្រោមបង្ហាញពីគំរូដូចគ្នានេះដែរនូវទំនាក់ទំនងរវាងទំហំដី ចំនួនក្បាលដី និងតំបន់នៃក្បាលដីនៅក្នុងខេត្តកំពង់ឆ្នាំង ដែលដូចគ្នានៅក្នុងគំរូនៃគំរោង LMAP ។ គ្រួសារកាន់កាប់ដីតូច មានក្បាលដីតិចតួច និងមានទំហំដីតូច

ធៀបនឹងគ្រួសារកាន់កាប់ដីធំ ដែលមានក្បាលដីច្រើន និងមានទំហំដីធំ ។ ទិន្នន័យបង្ហាញថា ចំនួន និងទំហំក្បាលដី បានកើនឡើងបន្តិចម្តងៗពីប្រភេទនៃការកាន់កាប់ដីមួយ ទៅប្រភេទនៃការកាន់កាប់ដីមួយផ្សេងទៀត ដូចដែលមាននៅក្នុងតារាង ៥.១ក ខាងលើ ដែលពាក់ព័ន្ធនឹងទីតាំងនៃគំរោង LMAP ។

**តារាង ៧.១ក. សង្ខេបគ្រួសារកាន់កាប់ដីកសិកម្ម**

| ទំហំដី (ហ.ត) | ចំនួនគ្រួសារ | ចំនួនឡូត៍សរុប | ផ្ទៃដីសរុប | ផ្ទៃដី/គ្រួសារ | ឡូត៍/គ្រួសារ | ផ្ទៃដី/ឡូត៍ |
|---|---|---|---|---|---|---|
| | | | | | | |
| < 0.5 | 65 | 167 | 18.18 | 0.280 | 2.569 | 0.109 |
| 0.5 – 0.9 | 81 | 368 | 56.29 | 0.695 | 4.543 | 0.153 |
| 1.0 – 1.9 | 59 | 376 | 81.08 | 1.374 | 6.373 | 0.216 |
| 2.0 – 2.9 | 19 | 144 | 46.21 | 2.432 | 7.579 | 0.321 |
| > 3.0 | 18 | 177 | 72.66 | 4.037 | 9.833 | 0.411 |
| | | | | | | |
| សរុប | 242 | 1,232 | 274.42 | 1.13 | 5.09 | .2200 |

ទោះជាតួលេខនេះ មានការខុសគ្នាពីចន្លោះនៃការកាន់កាប់ដីមួយ ទៅចន្លោះនៃការកាន់កាប់ដីមួយផ្សេងទៀតក៏ដោយ គំរូដែលហាក់ប្រហែលទៅនឹងគំរូនៃតំបន់គំរោង LMAP បានបង្ហាញពីការពាក់ព័ន្ធនឹងរបៀបនៃការទទួលបានដី នៅក្នុងតំបន់ត្រួតពិនិត្យ (សូមមើលតារាង ៧.១ខ) ។ គ្រួសារកាន់កាប់ដីតូច មានភាគរយក្បាលដីរបស់ពួកគេ ទទួលបានពីរដ្ឋចែកឱ្យ និងពីការផ្ទេរមរតក ធំជាងគ្រួសារកាន់កាប់ដីធំ ។ ដូចនៅក្នុងតំបន់នៃគំរោង LMAP ដែរ ចន្លោះនៃការកាន់កាប់ដីនៅកណ្តាលមានភាគរយក្បាលដីទទួលបានពីរដ្ឋច្រើនជាង គ្រប់ចន្លោះនៃការកាន់កាប់ដីផ្សេងទៀត ។ នៅពេលជាមួយគ្នានេះដែរ គ្រួសារកាន់កាប់ដីធំ មានភាគរយនៃក្បាលដីបានមកតាមរយៈការទិញខ្ពស់ជាងគ្រួសារកាន់កាប់ដីតូច ។ លើសពីនេះ ២២,៧% នៃក្បាលដីរបស់គ្រួសារកាន់កាប់ដីមានទំហំ ៣ហ.ត ឬច្រើនជាងនេះ គឺបានទទួលតាមរយៈការកាប់រាន ដែលផ្ទុយនឹង ៥.៣% និង៤.៨% នៃក្បាលដីរបស់ក្រុមគ្រួសារកាន់កាប់ដីតូចជាងគេចំនួនពីរ ។

**តារាង ៧.១ខ. ប្រភេទនៃការទទួលបានដីកសិកម្ម តាមការកាន់កាប់ ដី**

| ទំហំដី (ហ.ត) | រដ្ឋ | កេរ្តិ៍មរតក | ទិញ | ការរានព្រៃ | ចំនួនសរុប |
|---|---|---|---|---|---|
| | | | | | |
| < 0.5 | 45.0 | 44.4 | 5.3 | 5.3 | 169 |
| 0.5 – 0.9 | 55.3 | 26.9 | 13.0 | 4.8 | 376 |
| 1.0 – 1.9 | 62.0 | 14.2 | 14.2 | 9.6 | 324 |
| 2.0 – 2.9 | 44.0 | 21.1 | 25.3 | 9.6 | 166 |
| > 3.0 | 38.7 | 14.9 | 23.8 | 22.7 | 181 |
| | | | | | |
| ចំនួនសរុប=ឡូត៍ | 628 | 284 | 189 | 115 | 1,216 |
| % នៃសរុប | 51.6 | 23.4 | 15.5 | 9.5 | 100 |

គ្រួសារនៅក្នុងតំបន់ត្រួតពិនិត្យខេត្តកំពង់ឆ្នាំង និងតំបន់អង្កេត LMAP ក៏មានចរិកលក្ខណៈដូចគ្នាផ្សេងទៀតដែរ ។ ឧទាហរណ៍ តារាង ៧.១គ បង្ហាញថា អ្នកកាន់កាប់ដីធំនៅក្នុងខេត្តកំពង់ឆ្នាំង ចង់កាន់កាប់ទ្រព្យសកម្មមានលក្ខណៈមិនមែនកសិកម្ម និងលក្ខណៈកសិកម្មច្រើនជាង ។ រឿងនេះ ពាក់ព័ន្ធជាពិសេសនឹងសត្វចិញ្ចឹម (សត្វសំរាប់អូសទាញ) ទ្រព្យសកម្មធ្វើ

កសិកម្មមិនមែនគ្រឿងម៉ាស៊ីន និងគ្រឿងម៉ាស៊ីនធ្វើកសិកម្ម ។ កត្តាទាំងនេះនឹងជួយពន្យល់ពីហេតុផល និងមធ្យោបាយ ដែលបណ្តាលអោយកំរិតនៃចំណូលរបស់គ្រួសារ មានកំនើនទន្ទឹមគ្នាជាមួយនឹងការកាន់កាប់ដី ដូចដែលមាននៅក្នុងតំបន់ LMAP ។ គេអាចសន្មតបានថា កំនើនកម្មសិទ្ធិនៃកត្តាគន្លឹះនានារបស់ផលិតកម្ម (នៅក្នុងករណីដីធ្លី និងទ្រព្យសកម្មធ្វើកសិកម្ម) អាចនាំទៅដល់ការរកចំណូលបានខ្ពស់ ។ កំរិតនៃចំណូលខ្ពស់នៅក្នុងក្រុមចន្លោះនៃការកាន់កាប់ដីធំបំផុត ២ ក៏អាចជួយឱ្យគេទទួលបានចំណែកដីរបស់ពួកគេ ខ្ពស់តាមរយៈការទិញដែរ ។ ដូចមាននៅក្នុងតំបន់អង្កេត LMAP គំរូនៃវដ្តនេះ បានអះអាងថា អ្នកមានដីកាន់តែច្រើន ពួកគេកាន់តែទទួលបានដីច្រើនដែរ ។

**តារាង ៧.១គ. កំលាំងពលកម្ម និង មូលធនរបស់គ្រួសារ**

| ទំហំដី (ហ.ត) | កំលាំងពលកម្ម ជាមធ្យម | ការចិញ្ចឹម ជាមធ្យម | ទ្រព្យសកម្ម ប្រើបានយូរ | ទ្រព្យសកម្ម ជាប់លាប់ មិនមែនកសិកម្ម | ទ្រព្យសកម្ម កសិកម្ម មិនមែនម៉ាស៊ីន | ទ្រព្យសកម្ម កសិកម្ម ជាម៉ាស៊ីន | ចំណូល គ្រួសារ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| < 0.5 | 3.1 | 112.5 | 27.0 | 5.1 | 11.4 | 25.7 | 80.3 |
| 0.5 – 0.99 | 4.0 | 170.9 | 56.8 | 7.7* | 12.9 | 24.5 | 125.6 |
| 1.0 – 1.99 | 4.8 | 233.1 | 46.7 | 4.2 | 18.2 | 28.7 | 152.0 |
| 2.0 – 2.99 | 4.7 | 242.9 | 67.3 | 3.6 | 17.1** | 53.35 | 216.3 |
| > 3.0 | 4.0 | 434.0 | 55.1 | 10.1 | 20.1 | 77.86 | 166.5 |

## ៧.១.១. យេនឌ័រ

គំរូកាន់កាប់ដីសំរាប់បុរស និងស្ត្រីជាមេគ្រួសារនៅក្នុងតំបន់ត្រួតពិនិត្យ មានប្រហាក់ប្រហែលគ្នានឹងតំបន់នៃគំរោង LMAP ។ ជាមធ្យម បុរសជាមេគ្រួសារ មានដីកាន់កាប់ច្រើនជាងស្ត្រីជាមេគ្រួសារ បើគិតពីទំហំដី និងចំនួនក្បាលដីសរុប ។ ទោះយ៉ាងណាទំហំជាមធ្យមនៃក្បាលដី (0,២២ហ.ត) វាប្រហាក់ប្រហែលគ្នាសំរាប់បុរស និងស្ត្រីជាមេគ្រួសារ (តារាង ៧.១ឃ) ដែលខុសគ្នាពីតំបន់អង្កេត LMAP ដែលនៅទីនោះ ទំហំជាមធ្យមនៃក្បាលដីរបស់បុរស និងស្ត្រីជាមេគ្រួសារគឺ 0,៣៩ហ.ត និង 0,៣0ហ.ត រៀងគ្នា ។

**តារាង ៧.១ឃ. ការកាន់កាប់ដីតាមយេនឌ័រ**

| ទំហំដី (ហ.ត) | ចំនួនគ្រួសារ | | ចំនួនឡូត៍សរុប | | ផ្ទៃដីសរុប | | ផ្ទៃដី/គ្រួសារ | | ឡូត៍/គ្រួសារ | | ផ្ទៃដី/ឡូត៍ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| < 0.5 | 44 | 21 | 120 | 47 | 12.0 | 6.2 | 0.27 | 0.29 | 2.72 | 2.23 | 0.10 | 0.13 |
| 0.5 – 0.99 | 61 | 20 | 272 | 96 | 42.4 | 13.9 | 0.69 | 0.69 | 4.45 | 4.80 | 0.15 | 0.14 |
| 1.0 – 1.99 | 45 | 14 | 286 | 90 | 61.3 | 19.8 | 1.36 | 1.41 | 6.35 | 6.42 | 0.21 | 0.22 |
| 2.0 – 2.99 | 14 | 5 | 120 | 24 | 34.8 | 11.4 | 2.48 | 2.27 | 8.57 | 4.80 | 0.29 | 0.47 |
| > 3.0 | 15 | 3 | 147 | 30 | 60.6 | 12.1 | 4.03 | 4.02 | 9.80 | 10.0 | 0.41 | 0.33 |
| | | | | | | | | | | | | |
| សរុប | 179 | 63 | 945 | 287 | 211.1 | 63.4 | 1.18 | 1.00 | 5.27 | 4.55 | 0.22 | 0.22 |

ទិន្នន័យនេះបង្ហាញថា ៣៣% នៃស្ត្រីជាមេគ្រួសារ បានកាន់កាប់ដីកសិកម្មតិចជាង 0,៥ហ.ត រីឯបុរសជាមេគ្រួសារមានចំនួន ២៤,៦% ។ ប្រហែលជា ៦៥% នៃស្ត្រីជាមេគ្រួសារ និង ៥៨,៧% នៃបុរសជាមេគ្រួសារ បានកាន់កាប់ដីតិចជាង 0,៥ហ.ត ។ គំលាតនៅក្នុងការបែងចែកដីនេះ មានតូចជាងការរកឃើញនៅក្នុងតំបន់អង្កេត LMAP ។ ប្រហែលជា ១២,៧%

នៃស្ត្រីជាមេគ្រួសារ បានកាន់កាប់ដីច្រើនជាង ២ហ.ត រីឯបុរសជាមេគ្រួសារមានចំនួន ១០,៦% ។ វាខុសគ្នាពីតំបន់អង្កេត LMAP ដែលនៅទីនោះ ១៧% នៃស្ត្រីជាមេគ្រួសារ និង ៣១% នៃបុរសជាមេគ្រួសារ បានកាន់កាប់ដីកសិកម្មច្រើនជាង ២ហ.ត ។ ទោះយ៉ាងណាចំនួនគ្រួសារបានជ្រើសរើសជាគំរូ ជាពិសេសស្ត្រីជាមេគ្រួសារ គឺមានចំនួនតិចតួចប៉ុណ្ណោះ ។

គំរូនៃការទិញក្បាលដីកសិកម្មតាមយេនឌ័រនៃមេគ្រួសារនៅតំបន់ត្រួតពិនិត្យក្នុងខេត្តកំពង់ឆ្នាំង ក៏មានលក្ខណៈដូចគ្នានឹងតំបន់អង្កេត LMAP ដែរ ។ ឧទាហរណ៍ ស្ត្រីជាមេគ្រួសារ មានភាគរយនៃក្បាលដី (៦៧,២%) ទទួលបានពីរដ្ឋចែកឱ្យខ្ពស់ជាងបុរសជាមេគ្រួសារ (៤៦,៨%) ។ នៅពេលជាមួយគ្នានេះ ភាគរយនៃក្បាលដីដែលទទួល បានតាមរយៈការធ្វើមរតកគឺមានកំរិតទាបណាស់ សំរាប់ស្ត្រីជាមេគ្រួសារ (១៣,៩%) បើធៀបនឹងបុរសជាមេគ្រួសារ (២៦,៣%) ។ ភាគរយនៃក្បាលដីដែលទទួលបានតាមរយៈការទិញ (៩,៨%) និងតាមរយៈការកាប់រាន (៩,១%) ចំពោះស្ត្រីជាមេគ្រួសារ ទាបជាងបុរសជាមេគ្រួសារ (១៧,៣% បានតាមរយៈការទិញ និង ៩,៦% បានតាមរយៈការកាប់រាន) ។ ដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP តួលេខភាគរយទាបនៃដីបានមកតាមរយៈការធ្វើមរតក ការទិញ និងការកាប់រាន បង្ហាញថា ស្ត្រីជាមេគ្រួសារ មានលទ្ធភាពទទួលបានក្បាលដីបន្ថែម តិចជាងបុរសជាមេគ្រួសារ (តារាង ៧.១ង) ។

**តារាង ៧.១ង ការទទួលបានដីតាមយេនឌ័រ**

| ទំហំដី (ហ.ត) | រដ្ឋ | | កេរ្តិ៍មរតក | | ទិញ | | រានព្រៃ | |
|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | |
| < 0.5 | 35.2 | 75.6 | 52.3 | 19.5 | 6.3 | 2.4 | 6.3 | 2.4 |
| 0.5 – 0.9 | 47.4 | 74.5 | 33.8 | 10.0 | 13.9 | 10.9 | 4.9 | 4.5 |
| 1.0 – 1.9 | 61.2 | 64.6 | 14.0 | 14.6 | 16.1 | 8.5 | 8.7 | 12.2 |
| 2.0 – 2.9 | 41.5 | 58.3 | 23.2 | 8.3 | 26.8 | 16.7 | 8.5 | 16.7 |
| > 3.0 | 37.7 | 43.3 | 13.2 | 23.3 | 25.8 | 13.3 | 23.2 | 20.0 |
| | | | | | | | | |
| ចំនួនឡូត៍សរុប | 435 | 193 | 244 | 40 | 161 | 28 | 89 | 26 |
| % នៃគំរូ | 46.8 | 67.2 | 26.3 | 13.9 | 17.3 | 9.8 | 9.6 | 9.1 |

បើគិតពីទំហំនៃការកាន់កាប់ដី ក្រុមកាន់កាប់ដីទំហំតូច ២ បានទទួលក្បាលដីលើសពាក់កណ្តាលពីរដ្ឋចែកឱ្យ និងតាមរយៈការផ្ទេរមរតក ដែលផ្ទុយពីការទិញ និងការកាប់រាន ។ ក្នុងករណីនេះ ភាគរយនៃដីទទួលបានពីរដ្ឋចែកឱ្យ ហាក់ដូចជាថយចុះដោយសារទំហំដីកើនឡើង ជាពិសេសចំពោះស្ត្រីជាមេគ្រួសារ ។ ចំនែកឯភាគរយនៃក្បាលដីទទួលបានតាមរយៈការទិញ និងការកាប់រាន ហាក់ដូចជាកើនឡើង ស្របជាមួយនឹងទំហំនៃការកាន់កាប់ដី សំរាប់មេគ្រួសារទាំងស្ត្រី និងបុរស ។

តារាង ៧.១ច ខាងក្រោមបង្ហាញថា ជាមធ្យម ស្ត្រីជាមេគ្រួសារនៅគ្រប់ចន្លោះនៃការកាន់កាប់ដី មានទ្រព្យសកម្ម និងចំណូលទាបជាងបុរសជាមេគ្រួសារ ដែលវាស៊ីសង្វាក់គ្នានឹងគំរូនៃរបាយទ្រព្យសកម្ម និងចំណូលនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ ចំនុចលើកលែងតែមួយគត់នៃគំរូនេះគឺ ស្ត្រីជាមេគ្រួសារកាន់កាប់ដីច្រើនជាង ២ហ.ត ត្រូវបានរាយការណ៍ថា មានចំណូលខ្ពស់ជាងបុរសជាមេគ្រួសារ ។ ការពន្យល់សមរម្យគឺ គ្រួសារទាំងនោះ អាចពាក់ព័ន្ធនឹងការងារមិនមែនកសិកម្ម ដូចជាការធ្វើជំនួញ ឬធ្វើអាជីវកម្មផ្សេងៗ ។ គួរគិតពិចារណាផងដែរថា ចំនួនស្ត្រីជាមេគ្រួសារនៅក្នុងចន្លោះនេះ គឺមានចំនួនតិចតួចណាស់ ។ ដូចមាននៅក្នុងតំបន់អង្កេត LMAP ទ្រព្យសកម្មធ្វើកសិកម្មដ៏តិចតួច គឺជាកំហិតនៃចំនួនដីសំរាប់ធ្វើការដាំដុះ រីឯចំណូលដ៏តិចតួច គឺជាកំហិតលើសមត្ថភាពនៃការទិញដីថ្មី ។

### តារាង ៧.១ច. កំលាំងពលកម្ម ទ្រព្យ ចំណូល តាមយិនឌ័រនៃមេគ្រួសារ

| ទំហំដី (ហ.ត) | គ្រួសារ | | កំលាំងពលកម្ម | | ការចិញ្ចឹមសត្វជាមធ្យម | | ទ្រព្យសកម្មប្រើបានយូរ មិនមែនកសិកម្ម | | ទ្រព្យសកម្មជាប់លាប់មិនមែនកសិកម្ម | |
|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| 0 | | | 2.8 | 2.7 | | | | | | |
| < 0.5 | 44 | 2 1 | 3.4 | 2.5 | 132.6 | 60.6 | 37.7 | 4.6 | 5.6 | 3.3 |
| 0.5 – 0.99 | 61 | 20 | 4.4 | 3.0 | 187.3 | 113.8 | 66.2 | 28.1 | 9.2 | 2.6* |
| 1.0 – 1.99 | 45 | 14 | 5.2 | 3.4 | 239.0 | 212.5 | 53.1 | 26.1 | 3.6 | 5.9 |
| 2.0 – 2.99 | 14 | 5 | 4.4 | 5.6 | 256.2 | 200.0 | 83.0 | 23.4 | 4.0 | 1.7 |
| > 3.0 | 15 | 3 | 5.0 | 3.0 | 488.1 | 163.3 | 64.0 | 10.7 | 11.4 | 2.0 |

| ទំហំដី (ហ.ត) | ទ្រព្យសកម្មកសិកម្ម/មិនមែនម៉ាស៊ីន | | ទ្រព្យសកម្មកសិកម្ម/ម៉ាស៊ីន | | ចំណូលគ្រួសារ | |
|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | | | | | | |
| < 0.5 | 12.3 | 7.7 | 32.1 | 0 | 93.0 | 53.7 |
| 0.5 – 0.99 | 14.5 | 7.9 | 32.5 | 7.8 | 137.0 | 90.8 |
| 1.0 – 1.99 | 19.3 | 14.9 | 36.5 | 9.6 | 166.4 | 105.9 |
| 2.0 – 2.99 | 20.5 | 7.3** | 63.7 | 15.3 | 206.8 | 243.0 |
| > 3.0 | 19.2 | 24.2 | 91.2 | 20.0 | 165.5 | 171.1 |

## ៧.១.២. ភាពគ្រប់គ្រាន់នៃផលស្រូវ

នៅក្នុងតំបន់ត្រួតពិនិត្យក្នុងខេត្តកំពង់ឆ្នាំង គ្រួសារចំនួន ២៧.៣% ផលិតបានលើសពីសេចក្តីត្រូវការសំរាប់យកទៅលក់ ដែលមានចំនួនប្រហាក់ប្រហែលគ្នានឹងភាគរយនៅក្នុងតំបន់អង្កេត LMAP ដែលនៅទីនោះ គ្រួសារ ២៨.២% ផលិតបានលើពីសេចក្តីត្រូវការ ។ នៅមានផលស្រូវ ២០% ផ្សេងទៀត ផលិតបានគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ធៀបនឹង ១២.៩% នៅក្នុងគំរោង LMAP ។ គ្រួសារប្រហែលជា ២០.៣% ផលិតបានសំរាប់ការប្រើប្រាស់ក្នុងគ្រួសារត្រឹមតែពី ៧-១០ខែ រីឯ ១៣.១% ផលិតគ្រប់គ្រាន់សំរាប់តែរយៈពេលពី ៣-៦ខែ និងប្រហែល ៩.៣% ផលិតបានគ្រប់គ្រាន់សំរាប់តែរយៈពេល ៣ ខែ ឬតិចជាងប៉ុណ្ណោះ ។ ឯគ្រួសារចំនួន ១០% ទៀត ត្រូវទិញស្រូវ សំរាប់ប្រើប្រាស់ពេញមួយឆ្នាំ (តារាង ៧.១ឃ) ។

### តារាង ៧.១ឃ. ភាពគ្រប់គ្រាន់នៃការផលិតស្រូវ

| ទំហំដី (ហ.ត) | អតិរេក | | គ្រប់គ្រាន់ | | ខ្វះពី ៧ខែ-១០ខែ | | ខ្វះពី ៣ខែ-៦ខែ | | ខ្វះតិចជាង ៣ខែ | | ទិញស្បៀងពេញមួយឆ្នាំ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | | | |
| 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 1 | 0 | 6 | 10 | 8 | 10 |
| < 0.5 | 4 | 3 | 7 | 2 | 15 | 4 | 11 | 5 | 7 | 3 | 1 | 3 | 45 | 20 |
| 0.5 – 0.9 | 22 | 5 | 17 | 3 | 12 | 5 | 4 | 3 | 4 | 2 | 1 | 3 | 60 | 21 |
| 1.0 – 1.9 | 14 | 5 | 12 | 1 | 9 | 5 | 3 | 3 | 4 | 0 | 1 | 0 | 43 | 14 |
| 2.0 – 2.9 | 9 | 2 | 4 | 0 | 1 | 0 | 0 | 1 | 2 | 1 | 0 | 1 | 16 | 5 |
| > 3.0 | 6 | 1 | 4 | 2 | 2 | 0 | 3 | 0 | 0 | 0 | 0 | 0 | 15 | 3 |
| | | | | | | | | | | | | | | |
| សរុប | 55 | 16 | 44 | 8 | 39 | 14 | 22 | 12 | 18 | 6 | 9 | 17 | 187 | 73 |
| សរុប | 71 | | 52 | | 53 | | 34 | | 24 | | 26 | | 260 | |

ក្នុងចំណោម ៧១គ្រួសារ ដែលផលិតស្រូវបានលើសពីសេចក្តីត្រូវការ មាន ៣៤គ្រួសារ (៤៧,៩%) កាន់កាប់ដីតិចជាងមួយហិកតា រីឯ ៣៧គ្រួសារ (៥២,១%) បានកាន់កាប់ដីមួយហិកតា ឬច្រើនជាងនេះ ។ នៅក្នុងចំណោម ៥២គ្រួសារ ដែលផលិតស្រូវបានគ្រប់គ្រាន់ មានគ្រួសារ ៦៥% បានកាន់កាប់ដី ១ហ.ត ឬច្រើនជាងនេះ រីឯ ៣៥% ទៀត បានកាន់កាប់ដីតិចជាង ១ហ.ត ។ មានគ្រួសារកាន់កាប់ដីមួយហិកតា ឬច្រើនជាងនេះចំនួន ២ បានទិញស្រូវហូបសំរាប់រយៈពេលមួយឆ្នាំពេញ រីឯ ២៣គ្រួសារទៀត បានទិញស្រូវសំរាប់ហូបពេញមួយឆ្នាំដែរ តែកាន់កាប់ដីតិចជាងមួយហិកតា ។

ស្ត្រីជាមេគ្រួសារចំនួន ៦៥,៤% នៅក្នុងចំណោមគ្រួសារទាំងអស់ បានទិញស្រូវសំរាប់បរិភោគពេញមួយឆ្នាំ ប៉ុន្តែពួកគេមានចំនួនតែ ២៨,១% នៃគ្រួសារក្នុងគំរូត្រួតពិនិត្យប៉ុណ្ណោះ ។ ស្ត្រីជាមេគ្រួសារគ្មានដីចំនួន ១០គ្រួសារ ត្រូវទិញស្រូវហូបពេញមួយឆ្នាំ ។ ពួកគេតំណាងឱ្យ ៦២,៥%នៃគ្រួសារគ្មានដី ដែលត្រូវទិញស្រូវសំរាប់បរិភោគពេញមួយឆ្នាំ ។ ស្របពេលជាមួយគ្នា មានស្ត្រីជាមេគ្រួសារចំនួន ១៥,៥% អាចផលិតស្រូវសំរាប់ប្រើប្រាស់ក្នុងគ្រួសារបានគ្រប់គ្រាន់ ឬលើសពីសេចក្តីត្រូវការ ។

## ៧.២. ឥណទានៈ សកម្មភាពខ្ចីប្រាក់ និង ការផ្តល់ប្រាក់ឱ្យខ្ចីនៅកំរិតគ្រួសារ

គ្រួសារប្រហែលជា ៤៥,៦% (១១៥គ្រួ) នៅក្នុងតំបន់ត្រួតពិនិត្យក្នុងខេត្តកំពង់ឆ្នាំង បានរាយការណ៍ថា បានទទួលកំចីចំនួន ១៥៥ ក្នុងរយៈពេល ៦ខែ មុនពេលធ្វើអង្កេត ដែលគិតជាមធ្យមមានប្រហែល ១,៣៥កំចី ក្នុងមួយគ្រួសារ ។ នេះបើធៀបនឹងអត្រាកំចី ១,៤០ ក្នុងមួយគ្រួសារ នៅក្នុងតំបន់អង្កេត LMAP ។ បុរស និងស្ត្រីជាមេគ្រួសារចំនួន ៧៣,៥% និង ២៦,៥% រៀងគ្នាបានខ្ចីប្រាក់ពីគេ ។ បើប្រៀបធៀបតួលេខនេះជាមួយនឹងតំបន់អង្កេតនៃគំរោង LMAP គឺបុរស និងស្ត្រីមាន ចំនួនកំចីរហូតទៅដល់ ៧៩% និង ២១% រៀងគ្នា ។

ប្រហែលជា ៧៤,៨% នៃកំចី ត្រូវបានទទួលពីស្ថាប័នក្រៅផ្លូវការ (ឧ. ខ្ចីពីគ្រួសារ មិត្តភក្តិ ឬអ្នកចងការប្រាក់) ហើយតួលេខនេះ ខ្ពស់ជាងនៅក្នុងតំបន់អង្កេត LMAP (៦០%) ។ កំចីនៅសល់ ត្រូវបានបែងចែកទៅក្នុងកំចីពីស្ថាប័នផ្លូវការចំនួន (១៤,៩%) និងស្ថាប័នពាក់កណ្តាលផ្លូវការចំនួន (១០,៣%) ។ នេះគឺជាចំនួនភាគរយទាបនៃកំចីពីស្ថាប័នផ្លូវការ បើធៀបនឹងតំបន់អង្កេតនៃគំរោង LMAP (៣១%) ។ រឿងនេះបង្ហាញថា ស្ថាប័នផ្លូវការមិនមានជាទូទៅ នៅក្នុងខេត្តកំពង់ឆ្នាំងដូចដែលមាននៅក្នុងតំបន់អង្កេតខ្លះនៃគំរោង LMAP ទេ ។

**តារាង ៧.២កៈ ប្រភពឥណទាន ដោយអ្នកកាន់ កាប់ដី (គជ)**

| ទំហំដី (ហ.ត) | សាច់ញាតិ/មិត្តភក្តិ | | អ្នកចងការប្រាក់ | | អង្គការ NGO | | អេស៊ីលីដា | | ស្ថាប័ន MFIs | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 2 | 2 | 2 |
| < 0.5 | 17 | 4 | 6 | 0 | 5 | 1 | 1 | 0 | 4 | 1 | 33 | 6 |
| 0.5 – 0.99 | 22 | 16 | 8 | 2 | 3 | 1 | 1 | 1 | 3 | 1 | 37 | 21 |
| 1.0 – 1.99 | 16 | 5 | 2 | 1 | 2 | 1 | 1 | 0 | 6 | 0 | 27 | 7 |
| 2.0 – 2.99 | 4 | 4 | 2 | 0 | 1 | 0 | 0 | 0 | 1 | 0 | 9 | 4 |
| > 3.0 | 3 | 1 | 1 | 0 | 2 | 0 | 0 | 0 | | | 6 | 1 |
| សរុប % | 57 | 73 | 16.7 | 7.3 | 11.4 | 7.3 | 2.5 | 2.4 | | 9.8 | | |
| កំចីសរុប | 64 | 30 | 19 | 3 | 13 | 3 | 3 | 1 | 11 | 4 | 114 | 41 |
| បំណុលសរុប | 94 | | 22 | | 16 | | 4 | | 19 | | 155 | |
| % កំចី | 60.6 | | 14.2 | | 10.3 | | 2.6 | | 12.9 | | 100 | |

តារាង ៧.២ខ ខាងក្រោមបង្ហាញថា កំចីសំរាប់វិនិយោគលើផលិតកម្មមានចំនួន ៤២% នៃសកម្មភាពកំចីទាំងអស់នៅក្នុងតំបន់ត្រួតពិនិត្យ ធៀបនឹងកំចី ៣៦% នៅក្នុងតំបន់អង្កេត LMAP ។ ១១% នៃកំចី គឺសំរាប់យកទៅប្រើប្រាស់នៅក្នុងសកម្មភាពអាជីវកម្មតូច ២៥.២% ក្នុងសកម្មភាពផលិតកម្មកសិកម្ម និង ៥.៨% ក្នុងការចិញ្ចឹមសត្វ ។ ភាគរយទាំងនេះ វាមានភាពប្រហាក់ប្រហែលគ្នា បើធៀបនឹងតំបន់អង្កេត LMAP ។ បុរសជាមេគ្រួសារ បានប្រើប្រាស់កំចី ៨៨% សំរាប់វិនិយោគលើផលិតកម្ម បើធៀបនឹងតំបន់អង្កេតនៃគំរោង LMAP មានតែ ៨៣.៦% ប៉ុណ្ណោះ ។

ការប្រើប្រាស់លើការថែទាំសុខភាព និងការទិញម្ហូបអាហារមានចំនួន ២៩.៧% នៃកំចី នៅក្នុងតំបន់ត្រួតពិនិត្យធៀបនឹង ៤0% នៅក្នុងតំបន់អង្កេត LMAP ។ បុរសជាមេគ្រួសារ បានខ្ចីប្រហែលជា ៦0% នៃប្រាក់កំចីនេះ ។ នៅសល់ ២៧.៧% ទៀត ត្រូវបានប្រើប្រាស់នៅក្នុងគោលដៅផ្សេងទៀត ក្នុងនោះមាន ការសងបំណុល ការសង់លំនៅដ្ឋាន និងការធ្វើដំណើរ ។ បុរសជាមេគ្រួសារ បានខ្ចីចំនួន ៧៥% នៃកំចីប្រភេទនេះ ។

ដូចនៅក្នុងតំបន់អង្កេត LMAP ក្រុមចន្លោះកាន់កាប់ដីធំបំផុតចំនួន ២ បានខ្ចីប្រាក់ មិនសូវញឹកញាប់ដូចក្រុមចន្លោះកាន់កាប់ដីផ្សេងទៀតទេ ។ គំរូនេះ គឺស្របគ្នាច្រើន ជាមួយនឹងក្រុមចន្លោះកាន់កាប់ដីទាំងអស់ រួមទាំងគោលដៅផលិតកម្ម (ឧ. ការធ្វើកសិកម្ម ការធ្វើជំនួញ ការចិញ្ចឹមសត្វ) ដែលមានចំនួនច្រើនលើសលុប នៅក្នុងក្រុមចន្លោះកាន់កាប់ដីខ្ពស់បំផុត ២ នៅក្នុងតំបន់អង្កេត LMAP ។

**តារាង ៧.២ខ. ការប្រើប្រាស់ឥណទាន តាមទំហំកាន់កាប់ដីធ្លី**

| ទំហំដី (ហ.ត) | កសិកម្ម | | ជំនួញ | | ស្បៀងអាហារ | | ថែទាំសុខភាព | | ចិញ្ចឹមសត្វ | | ផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | | | | | |
| 0 | 0 | 0 | 1 | 1 | 0 | 1 | 0 | 0 | 0 | 0 | 1 | 0 | 2 | 2 |
| < 0.5 | 7 | 0 | 0 | 0 | 6 | 1 | 9 | 2 | 1 | 0 | 10 | 3 | 33 | 6 |
| 0.5 – 0.99 | 9 | 6 | 4 | 3 | 2 | 3 | 6 | 5 | 5 | 0 | 10 | 5 | 37 | 21 |
| 1.0 – 1.99 | 9 | 1 | 3 | 1 | 2 | 2 | 3 | 2 | 2 | 0 | 6 | 1 | 27 | 7 |
| 2.0 – 2.99 | 2 | 1 | 4 | 0 | 0 | 0 | 0 | 2 | 1 | 0 | 2 | 1 | 9 | 4 |
| > 3.0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 6 | 1 |
| | | | | | | | | | | | | | | |
| សរុប % | | | | | | | | | | | | | | |
| កំចីសរុប | 30 | 9 | 12 | 5 | 10 | 7 | 18 | 11 | 9 | 0 | 33 | 10 | 114 | 41 |
| | | | | | | | | | | | | | | |
| បំណុលសរុប | 39 | | 17 | | 17 | | 29 | | 9 | | 44 | | 155 | |
| % កំចី | 25.2 | | 11.0 | | 11.0 | | 18.7 | | 5.8 | | 28.4 | | 100 | |

តារាង ៧.២គ ខាងក្រោមបង្ហាញថា កំចីជាមធ្យមធំបំផុត បានទទួលពីសាច់ញាតិ និងមិត្តភក្តិ បន្ទាប់មកទទួលបានពីធនាគារ ACLEDA និងបន្ទាប់មកទៀតពីអ្នកចងការប្រាក់ ។ ទំហំនៃកំចីពីស្ថាប័នពាក់កណ្តាលផ្លូវការ និងពី MFIs គឺមានកំរិតប្រហាក់ប្រហែលគ្នាច្រើន ។ គំរូនេះ មានភាពខុសគ្នានឹងគំរូនៅក្នុងតំបន់អង្កេត LMAP ដែលនៅទីនោះ ទំហំកំចីជាមធ្យមពីធនាគារ ACLEDA គឺធំជាងគេ បន្ទាប់មកកំចីពីសាច់ញាតិ និងមិត្តភក្តិ ។ តួលេខនេះ បានអះអាងជាថ្មីទៀតថា ស្ថាប័នឥណទានផ្លូវការនៅក្នុងខេត្តកំពង់ឆ្នាំង (យ៉ាងហោចណាស់នៅក្នុងតំបន់ត្រួតពិនិត្យអង្កេត) គឺមិនទាន់មានការអភិវឌ្ឍន៍ ដូចនៅក្នុងតំបន់អង្កេត LMAP នៅឡើយទេ ។

**តារាង ៧.២គ. ប្រភពធនធានដែលប្រើប្រាស់សំរាប់កំចី**

| គោលបំណង | សាច់ញាតិ/ មិត្តភក្តិ | | អ្នកចងការប្រាក់ | | ស្ថាប័ន NGO (SHGs) | | អេស៊ីលីដា | | ស្ថាប័ន MFIs | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | No. | Amt* | No. | Amt. | No. | Amt. | No. | Amt. | No. | Amt. | No. | Amt. |
| | | | | | | | | | | | | |
| កសិកម្ម | 26 | 11.9 | 5 | 12.00 | 9 | 7.07 | 1 | 20.0 | | | 41 | 11.0 |
| ជំនួញ | 11 | 33.6 | 1 | 10.00 | 0 | | 2 | 60.0 | 3 | 11.2 | 17 | 31.4 |
| កង្វះម្ហូបអាហារ | 14 | 6.0 | 2 | 15.5 | 1 | 90.00 | | | 2 | 60.0 | 19 | 12.5 |
| ថៃទាំសុខភាព | 17 | 52.9 | 2 | 15.50 | 2 | 77.50 | | | 8 | 16.0 | 29 | 42.1 |
| ចិញ្ចឹមសត្វ | 5 | 82.6 | 2 | 19.50 | 2 | 20.00 | | | | | 9 | 54.7 |
| ផ្សេងទៀត | 24 | 73.5 | 11 | 43.46 | 2 | 6.48 | 1 | 10.0 | 6 | 26.8 | 44 | 55.1 |
| | | | | | | | | | | | | |
| សរុប | 97 | 39.4 | 23 | 28.22 | 16 | 22.6 | 4 | 37.5 | 19 | 23.7 | 159 | 34.1 |
| % កំចីសរុប | 61.00 | | 14.5 | | 10.1 | | 2.5 | | 9.4 | | 100 | |

* Average amount in *moeun riels*

## ៧.៣ ការវិនិយោគលើវិស័យកសិកម្ម ផលិតកម្ម និងការប្រើប្រាស់ដីធ្លី

តារាង ៧.៣ក ខាងក្រោម រៀបរាប់ត្រួសៗអំពីចំណាយលើវិស័យកសិកម្ម សំរាប់ផលិតកម្មស្រូវនៅក្នុងអំឡុងពេលរដូវធ្វើស្រែនាពេលថ្មីបំផុតនេះ យោងតាមអង្កេតនៅក្នុងតំបន់ត្រួពិនិត្យនៅខេត្តកំពង់ឆ្នាំ ។ ដូចនៅក្នុងតំបន់អង្កេត LMAP ចំណាយជាមធ្យមសំរាប់គ្រួសារនីមួយៗ មាននិន្នាការកើនឡើងទៅតាមទំហំកាន់កាប់ដី ។ ចំណុចខុសគ្នាមួយគឺ ចំណាយសំរាប់គ្រួសារកាន់កាប់ដីពី ៣ហ.ត ឬច្រើនជាងនេះ ធ្លាក់ចុះក្នុងកំរិតដូចគ្នានឹងក្រុមចន្លោះកាន់កាប់ដីកណ្តាល ។ កំរិតចំណាយនៅក្នុងតំបន់អង្កេត LMAP និងតំបន់ត្រួតពិនិត្យគឺ ប្រហាក់ប្រហែលគ្នា នៅក្នុងចំនោម ក្រុមចន្លោះកាន់កាប់ដីតូចបំផុតចំនួន ៣ ។ ដូច្នេះវាមានភាពខុសគ្នាគួរឱ្យចាប់អារម្មណ៍ នៅក្នុងចំណោមក្រុមចន្លោះកាន់កាប់ដីធំបំផុតទាំង ២ ។

ដូចនៅក្នុងតំបន់អង្កេត LMAP ក៏មានគំរូច្បាស់លាស់ពីការចំណាយដោយផ្អែកទៅលើយេនឌ័រនៃមេគ្រួសារ ។ ជាមធ្យមបុរសជាមេគ្រួសារចំណាយប្រហែល ៧៥,៨% ច្រើនជាងស្ត្រីជាមេគ្រួសារ ធៀបនឹងតំបន់អង្កេត LMAP មានប្រហែល ៥៥% ប៉ុណ្ណោះ ។ ស្ត្រីជាមេគ្រួសារបានចំណាយច្រើនជាងបុរសជាមេគ្រួសារ តែទៅលើធាតុចូលជាក់លាក់ណាមួយតែប៉ុណ្ណោះ (ឧ. កំលាំងពលកម្មសំរាប់ការដាំដុះ និងការប្រមូលផល) នៅក្នុងក្រុមចន្លោះកាន់កាប់ដី ទំហំជាក់លាក់ (ឧ. ២,០-២,៩៩ ហ.ត) ។

ដូចនៅក្នុងតំបន់អង្កេត LMAP ចំណាយសំរាប់ផលិតកម្មស្រូវភាគច្រើនបំផុត គឺជាចំណាយទៅលើធាតុចូលកំលាំងពលកម្ម ដែលសំខាន់សំរាប់ការដាំដុះ និងការប្រមូលផល ក៏ដូចជាការចំណាយទៅលើជីគីមី និងចំណាយទៅលើការបូមទឹកដាក់ស្រែ ។ គួរកត់សំគាល់ថា ការជួលដី គឺមានតែលើក្រុមចន្លោះកាន់កាប់ដីតូចបំផុត២ ដែលមានអត្រាប្រើប្រាស់ដីខ្ពស់គ្រាន់បើ ដូចដែលឃើញនៅក្នុងតារាង ៧.៣ក ។

### តារាង ៧.៣ក. ធាតុចូលសំរាប់ផលិតកម្មស្រូវ*

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | សរុបគិតជាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | |
| ជីគីមី | 4.4 | 3.2 | 8.2 | 5.2 | 10.9 | 6.5 | 14.9 | 8.2 | 9.3 | 1.3 | 7.7 | |
| ថ្នាំកំចាត់សត្វល្អិត | 0.8 | 3.1 | 0.9 | .59 | 1.5 | 1.2 | 1.7 | 1.2 | 1.4 | 4.6 | 1.3 | |
| បូមទឹកចូលស្រែ | 6.3 | 2.2 | 8.2 | 4.4 | 9.8 | 7.7 | 9.4 | 9.4 | 10.9 | 2.0 | 7.8 | |
| ពលកម្មរៀបចំដី | 4.0 | 3.0 | 4.3 | 3.6 | 4.1 | 4.1 | 11.9 | 3.0 | 2.7 | 3.0 | 4.5 | |
| ពលកម្មដកស្ទូង | 8.0 | | 8.1 | 4.1 | 14.8 | 22.0 | 18.4 | 25.0 | 9.4 | 7.0 | 11.0 | |
| ពលកម្មច្រូតកាត់ | 4.7 | 1.0 | 8.2 | 6.5 | 8.7 | 7.7 | 13.5 | 20.0 | 5.7 | 8.0 | 8.3 | |
| បោកបែន | 1.8 | 1.4 | 3.9 | 2.3 | 3.8 | 3.0 | 6.4 | 6.8 | 5.3 | | 3.5 | |
| ជួសជុលឧបករណ៍ | 0.2 | 3.0 | .86 | .33 | 1.6 | 1.8 | 15.0 | 16.5 | 2.3 | | 2.7 | |
| ដឹកជញ្ជូន | 1.9 | 1.3 | 2.9 | 2.2 | 2.6 | 2.0 | 6.1 | 1.0 | 6.2 | | 2.8 | |
| ជួលដី | 7.2 | 3.0 | 9.9 | 22.4 | | | | | | | 11.1 | |
| ជួលសត្វពាហនៈ | | .45 | 1.8 | .30 | | | 3.5 | | 8.0 | | 2.8 | |
| ផ្សេងទៀត | .75 | .75 | 2.75 | | 3.0 | | 15.5 | 10.0 | 2.5 | | 4.3 | |
| **សរុប** | 15.1 | 7.2 | 22.9 | 13.0 | 31.3 | 20.0 | 54.2 | 32.4 | 28.7 | 12.1 | 26.2 | 14.9 |
| | | | | | | | | | | | | |
| សរុប | 12.9 | | 20.6 | | 28.7 | | 48.6 | | 26.8 | | 23.5 | |

* Note: Data gaps (e.g., Female/.3.0 hectares) to be resolved.

## ៧.៣.១ ប្រភពនៃហិរញ្ញវត្ថុសំរាប់ធ្វើការចំណាយ

តារាង ៧.៣ខ ខាងក្រោមបង្ហាញថា ច្រើនជាង ៩៤% នៃចំណាយលើផលិតកម្មស្រូវនៅក្នុងតំបន់ត្រួតពិនិត្យ គឺបានផ្គត់ផ្គង់ថវិកាដោយធនធានផ្ទាល់ខ្លួន បើធៀបនឹង ៨៩,៤% នៅក្នុងតំបន់អង្កេត LMAP ។ ប្រាក់ចំណាយបានមកពីសាច់ញាតិ និងមិត្តភក្តិមានប្រហែល ៥,0% ហើយភាគរយនៅសល់ដ៏តូច (0,៩0%) គឺជាកំចីបានពីកម្មវិធីឥណទាន ។ លើកលែងតែការចំណាយលើជីគីមី (៨៥,៩%) គឺច្បាស់ណាស់ថា ការចំណាយទាំងកំលាំងពលកម្ម និងធាតុចូលផ្សេងទៀត ដោយប្រើធនធានផ្ទាល់ខ្លួន ។ ជាថ្មីម្តងទៀត គួរកត់សំគាល់ថា ទីផ្សារឥណទាន អាចមិនមានការអភិវឌ្ឍន៍នៅក្នុង ខេត្តកំពង់ឆ្នាំង ដូចនៅក្នុងតំបន់អង្កេតខ្លះនៃតំបន់គំរោង LMAP ទេ ។

### តារាង ៧.៣ខ. ប្រភពធនធានសំរាប់ចំណាយទៅលើធាតុចូលសំខាន់ៗ

| ធាតុចូល | ប្រភពផ្ទាល់ខ្លួន | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន |
| | | | | | | | |
| ជីគីមី | 165 | 85.9 | 24 | 12.5 | 3 | | 192 |
| ថ្នាំកំចាត់សត្វល្អិត | 64 | 100.0 | | | | | 64 |
| បូលទឹកបញ្ចូលស្រែ | 115 | 95.0 | 4 | 3.3 | 2 | .83 | 121 |
| រៀបចំដី | 73 | 97.3 | 2 | 2.6 | | | 75 |
| ដកស្ទូង | 93 | 100.0 | | | | | 93 |
| ច្រូតកាត់ | 76 | 98.7 | 1 | 1.3 | | | 77 |
| | | | | | | | |
| សរុប | 586 | 94.2 | 31 | 4.9 | 5 | .90 | 622 |

ទិន្នន័យក៏បានបង្ហាញដែរថា និន្នាការទៅរកការទូទាត់ធាតុចូលវិស័យកសិកម្ម ដោយប្រើធនធានផ្ទាល់ខ្លួន លើគ្រប់ក្រុមចន្លោះកាន់កាប់ដី គឺរួមបញ្ចូលរាល់ធាតុចូលសំខាន់ៗ លើកលែងតែជីគីមី ។ តារាង ៧.៣គ ខាងក្រោមបង្ហាញថា ប្រហែល ១៥% នៃធាតុចូល គឺបានផ្គត់ផ្គង់ថវិកាដោយកំចីបានពីសាច់ញាតិ និងមិត្តភក្តិ នៅក្នុងចំណោមក្រុមចន្លោះកាន់កាប់ដីតូចបំផុត ៣ ។ ទោះជាយ៉ាងណា ក្រុមចន្លោះកាន់កាប់ធំបំផុត ២ ដំបូងគឺពឹងផ្អែកទៅលើធនធានផ្ទាល់ខ្លួនក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុ ។ គំរូនេះគឺខុសគ្នាពីគំរូនៅក្នុងតំបន់អង្កេត LMAP ។

**តារាង ៧.៣គ. ប្រភពហិរញ្ញវត្ថុ សំរាប់ប្រើប្រាស់ជាធាតុចូលលើជីគីមី**

| ធាតុចូល | ប្រភពផ្ទាល់ខ្លួន | | សាច់ញាតិ/មិត្តភក្តិ | | កម្មវិធីឥណទាន | | សរុប |
|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន |
| | | | | | | | |
| < 0.5 | 43 | 84.3 | 7 | 13.7 | 1 | 1.9 | 51 |
| 0.5 – 0.99 | 54 | 84.4 | 10 | 15.6 | | | 64 |
| 1.0 – 1.99 | 37 | 82.2 | 7 | 15.5 | 1 | 2.2 | 45 |
| 2.0 – 2.99 | 17 | 100.0 | | | | | 17 |
| > 3.0 | 14 | 93.3 | | | 1 | 6.6 | 15 |
| | | | | | | | |
| សរុប | 165 | 85.9 | 24 | 12.5 | 3 | 1.6 | 192 |

## ៧.៣.២ ផលិតភាព

ដូចនៅក្នុងតំបន់អង្កេត LMAP ទិន្នន័យនៅក្នុងតារាង ៧.៣ឃ បញ្ជាក់នូវភាពបញ្រាសគ្នានៃទំនាក់ទំនងរវាងទំហំកសិដ្ឋាន និងផលិតភាព ដែលក្នុងនោះកសិដ្ឋានតូច ហាក់ដូចជាមានផលិតភាពខ្ពស់ បើគិតពីការប្រមូលផលស្រូវក្នុងមួយហិកតាច្រើនជាងកសិដ្ឋានធំ ។ ជាទូទៅ ផលិតផលជាមធ្យមសំរាប់គ្រប់ក្រុមចន្លោះកាន់កាប់ដីនៅក្នុងតំបន់អង្កេត LMAP និងតំបន់ត្រួតពិនិត្យមានលក្ខណៈស្មើគ្នា លើកលែងតែចន្លោះទី ២ ។

**តារាង ៧.៣ឃ. ផលិតផលស្រូវជាមធ្យមនៅតំបន់ប្រមូលផលទាំងអស់ (គ.ក/ហ.ត)**

| ទំហំដី (ហ.ត) | បុរស | | ស្ត្រី | | សរុប | |
|---|---|---|---|---|---|---|
| | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល | គ្រួសារ | ទិន្នផល |
| | | | | | | |
| < 0.5 | 44 | 2,114 | 17 | 1,821 | 61 | 2,032 |
| 0.5 – 0.99 | 57 | 2,126 | 19 | 1,743 | 76 | 2,032 |
| 1.0 – 1.99 | 42 | 1,593 | 13 | 1,105 | 55 | 1,478 |
| 2.0 – 2.99 | 16 | 1,296 | 4 | 819 | 20 | 1,200 |
| ≥ 3.0 | 15 | 1,046 | 3 | 975 | 18 | 1,034 |
| | | | | | | |
| សរុប | 174 | 1,836 | 56 | 1,511 | 230 | 1,757 |

ដូចនៅក្នុងតំបន់អង្កេត LMAP មានហេតុផលមួយចំពោះផលិតភាពដីខ្ពស់របស់ពួកគេគឺ កសិករតូចៗ ហាក់ដូចជាទិញធាតុចូលមានភាពចំរុះក្នុងដីមួយហិកតា ច្រើនជាងកសិដ្ឋានធំ ។ ឧទាហរណ៍ បើគិតជាធាតុចូលទាំងអស់ក្នុងមួយហិកតា ក្រុមចន្លោះកាន់កាប់ដីតូចបំផុត ២ បានចំណាយ ៣៨,១ម៉ឺនរៀល និង ៣៩,០ម៉ឺនរៀល រៀងគ្នា រីឯក្រុមចន្លោះកាន់កាប់ដីធំបំផុត ២ បានចំណាយតែ ២៥,៧ម៉ឺនរៀល និង១៧,៥ ម៉ឺនរៀល រៀងគ្នា (តារាង ៧.៣ង) ។

**តារាង ៧.៣ង. ចំណាយលើធាតុចូលនៃផលិផលស្រូវ (ម៉ឺនរៀល/ហ.ត)**

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 – 2.99 | | ≥ 3.0 | | សរុបជាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | N | Amt | N | Amt | N | Amt | N | Amt | N | Amt | N | Amt |
| | | | | | | | | | | | | |
| ជីគីមី | 50 | 12.8 | 62 | 12.1 | 45 | 8.9 | 16 | 7.2 | 15 | 6.2 | 188 | 10.6 |
| ថ្នាំកំចាត់សត្វល្អិត | 13 | 3.1 | 17 | 2.9 | 20 | 1.9 | 6 | 1.4 | 7 | 1.9 | 63 | 2.4 |
| បូមទឹកបញ្ចូលស្រែ | 28 | 18.1 | 35 | 21.2 | 31 | 11.8 | 13 | 4.8 | 12 | 6.3 | 119 | 14.7 |
| ពលកម្មរៀបចំដី | 28 | 12.7 | 20 | 8.3 | 16 | 5.7 | 7 | 5.6 | 4 | 2.1 | 75 | 8.8 |
| | | | | | | | | | | | | |
| ផលិកម្មសរុប | 57 | 38.1 | 74 | 39.0 | 53 | 27.8 | 19 | 25.7 | 17 | 17.5 | 220 | 33.3 |

ភាពខុសគ្នារវាងផលិតភាពដី (ផលក្នុងមួយហិកតា) និងការវិនិយោគលើផលិតភាព (ផលក្នុងមួយម៉ឺនរៀល/ហ.ត) នៅក្នុងតំបន់អង្កេត LMAP ក៏មានកត់សំគាល់នៅក្នុងតំបន់ត្រួតពិនិត្យខេត្តកំពង់ឆ្នាំងដែរ ។ តារាង ៧.៣ច បង្ហាញថា កសិដ្ឋានទំហំតូចជាង 0,៥ហ.ត ទទួលបានស្រូវ ៥៣,៣គ.ក ក្នុងការចំណាយមួយម៉ឺនរៀល រីឯកសិដ្ឋានទំហំធំជាង ៣ហ.ត ទទួលបានប្រហែលជា ៥៩គ.កស្រូវ សំរាប់ការចំណាយមួយម៉ឺនរៀល ។ ដូចនៅក្នុងតំបន់អង្កេត LMAP ការវិនិយោគក្នុងមួយហិកតាដីហាក់ដូចជាធ្លាក់ចុះ នៅពេលដែលទំហំដីកើនឡើង ។

**តារាង ៧.៣ច. ដី និងការវិនិយោគលើផលិតភាព**

| ទំហំដី (ហ.ត) | ផ្ទៃដីច្រូតកាត់ | ទិន្នផល (គ.ក/ហ.ត) | ការចំណាយ (ម៉ឺនរៀល/ហ.ត) | ការចំណាយ (គ.ក/ម៉ឺនរៀល) | ការចំណាយ (ម៉ឺនរៀល/គ្រួសារ) |
|---|---|---|---|---|---|
| | | | | | |
| < 0.5 | .4041 | 2,032 | 38.1 | 53.3 | 15.40 |
| 0.5 – 0.99 | .6267 | 2,032 | 39.0 | 52.1 | 24.44 |
| 1.0 – 1.99 | 1.071 | 1,478 | 27.8 | 53.2 | 29.77 |
| 2.0 – 2.99 | 1.812 | 1,200 | 25.7 | 46.7 | 46.57 |
| ≥ 3.0 | 2.493 | 1,034 | 17.5 | 59.1 | 43.63 |

ដូចនៅក្នុងតំបន់អង្កេត LMAP ដីមានផលិតភាពខ្ពស់បំផុត មិនមានន័យថាមានកំរិតផលិតផលស្រូវខ្ពស់ដែរនោះទេសំរាប់គ្រួសារនីមួយៗ ។ តារាង ៧.៣ឆ បង្ហាញថា គ្រួសារកាន់កាប់ដីតិចជាង 0,៥ហ.ត ផលិតបានស្រូវតែ ៨២១,១៣គ.ក ប៉ុណ្ណោះ ទោះបីជាផលិតភាពរបស់ពួកគេខ្ពស់ក៏ដោយ ។ រីឯគ្រួសារកាន់កាប់ដី ៣ហ.ត ឬច្រើនជាងនេះ ផលិតស្រូវបានដល់ ២,៥៨តោនក្នុងមួយគ្រួសារ ទោះជាមានផលិតភាពតែពាក់កណ្តាលប៉ុណ្ណោះ ធៀបនឹងផលិតភាពរបស់កសិដ្ឋានតូចបំផុតនៅក្នុងតំបន់ត្រួតពិនិត្យ ។

ភាពមិនស្របគ្នាដោយអន្លើនៃផលិតផលទាំងនេះ ក៏កើតឡើងផងដែរ ទោះបីជាអត្រាខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងចំណោមកសិដ្ឋានតូចៗ ។ ឧទាហរណ៍ កសិដ្ឋានតូចៗ ត្រូវបានរាយការណ៍ថាមានកាន់កាប់ដីជាមធ្យម 0,២៨ហ.ត/គ្រួសារ ប៉ុន្តែអាចប្រមូលផលបានច្រើនជាង 0,៤ហ.ត ដែលកំរិតនៃការប្រើប្រាស់ដី ១៤៣% (មានការជួលដីខ្លះ) ។ ក្រុមចន្លោះកាន់កាប់ដីធំបំផុត មានដីទំហំ ៤,0៤ហ.ត ប៉ុន្តែអាចប្រមូលផលបានតែ ២,៤៩៨ហ.ត ដែលកំរិតនៃការប្រើប្រាស់ដីមានត្រឹម ៦២% ។ យ៉ាងណាក៏ដោយ គំលាតផលិតផលរវាង ក្រុមចន្លោះកាន់កាប់ដីតូចបំផុត និងធំបំផុតនៅក្នុងតំបន់ត្រួតពិនិត្យ (៦៨,២%) គឺតូច

ជាងនៅក្នុងតំបន់អង្កេតនៃគំរោង LMAP (៨០.៤%) ។ រឿងនេះបានអះអាងថា ភាពផ្សេងៗគ្នានៃសមត្ថភាពផលិត និងលក្ខខណ្ឌនានា នៅក្នុងតំបន់អង្កេត LMAP គឺធំធេងជាងនៅក្នុងតំបន់ត្រួតពិនិត្យ ។

**តារាង ៧.៣ឆ. ផលិតផលនៅក្នុងគ្រួសារ**

| ទំហំដី (ហ.ត) | ទិន្នផល (គ.ក/ហ.ត) | ផ្ទៃដី (ហ.ត/គ្រួសារ) | | ផលិតកម្មសរុប (គ.ក/គ្រួសារ) |
|---|---|---|---|---|
| | | កម្មសិទ្ធិ | ប្រមូលផល | ទិន្នផល x ផ្ទៃដីប្រមូលផល |
| < 0.5 | 2,032 | 0.28 | .4041 | 821.13 |
| 0.5 – 0.99 | 2,030 | 0.70 | .6267 | 1,272.2 |
| 1.0 – 1.99 | 1,478 | 1.37 | 1.071 | 1,582.9 |
| 2.0 – 2.99 | 1,201 | 2.43 | 1.812 | 2,176.2 |
| ≥ 3.0 | 1,035 | 4.04 | 2.493 | 2,580.3 |

## ៧.៣.៣ ការប្រើប្រាស់ដី

ដូចនៅក្នុងតំបន់អង្កេត LMAP ដីលំនៅដ្ឋាននៅក្នុងតំបន់ត្រួតពិនិត្យ ត្រូវបានប្រើប្រាស់ច្រើនគោលដៅ ប៉ុន្តែភាពចំរុះនៃការប្រើប្រាស់ដីលំនៅដ្ឋានវិញ វាបង្ហាញពីគំរូចំរុះគ្នានៃការប្រើប្រាស់ ដោយផ្អែកទៅលើទំហំដី ។ ឧទាហរណ៍ ការប្រើប្រាស់ដីលំនៅដ្ឋានសំរាប់សង់លំនៅ និងដាំដើមឈើ គឺមានភាពស្របគ្នានៅក្នុងចំណោមក្រុមចន្លោះកាន់កាប់ដីទាំងអស់ ។ នៅខណៈនេះដែរ គ្រួសារកាន់កាប់ដី ៣ហ.ត ឬច្រើនជាងនេះ មិនបង្ហាញនូវការប្រើប្រាស់ដីលំនៅដ្ឋាន សំរាប់សង់លំនៅតែមួយមុខគត់នោះទេ ហើយ ១៥% នៃដីលំនៅដ្ឋានរបស់ពួកគេ ត្រូវបានទុកទំនេរចោល ។ ការប្រើប្រាស់ដីលំនៅដ្ឋាន សំរាប់សង់លំនៅ ដាំបន្លែ និងធ្វើអាជីវកម្មខ្នាតតូច ក៏មានភាពផ្សេងៗគ្នា ដោយផ្អែកទៅលើទំហំកាន់កាប់ដី ទោះបីជាមិនមានភាពស្របគ្នាក៏ដោយ ។

**តារាង ៧.៣ជ. ការប្រើប្រាស់ដីលំនៅដ្ឋាន**

| នៅកំពង់ឆ្នាំង | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណងប្រើប្រាស់ | ភាពគ្មានដី | < 0.5 | 0.5-0.99 | 1-1.99 | 2-2.99 | > 3.0 | សរុប |
| ទុកចោលទំនេរ | 0.0 | 0.0 | 8.0 | 8.0 | 0.0 | 15.0 | 6.0 |
| សាច់ញាតិរស់នៅបណ្តោះអាសន្នមិនគិតឈ្នួលផ្ទះ | 0.0 | 2.0 | 1.0 | 2.0 | 0.0 | 0.0 | 1.0 |
| រស់នៅ និង ដាំដំណាំ | 58.0 | 52.0 | 48.0 | 45.0 | 52.0 | 58.0 | 50.0 |
| ដាំដំណាំ/បន្លែ | 5.0 | 7.0 | 10.0 | 8.0 | 5.0 | 15.0 | 8.0 |
| រស់នៅ និង ធ្វើជំនួញ | 21.0 | 31.0 | 29.0 | 30.0 | 33.0 | 12.0 | 28.0 |
| ធ្វើជំនួញ | 0.0 | 0.0 | 0.0 | 2.0 | 0.0 | 0.0 | 0.0 |
| រស់នៅ | 16.0 | 8.0 | 4.0 | 6.0 | 10.0 | 0.0 | 6.0 |
| ផ្សេងទៀត | 0.0 | 2.0 | 0.0 | 2.0 | 0.0 | 0.0 | 1.0 |
| សរុប | 19 | 62 | 93 | 67 | 21 | 26 | 288 |

### *ដីកសិកម្ម*

ក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់ដី ទិន្នន័យអង្កេតនៅខេត្តកំពង់ឆ្នាំង បង្ហាញនូវគំរូប្រហាក់ប្រហែលគ្នានឹងទិន្នន័យបានកត់សំគាល់នៅក្នុងតំបន់អង្កេត LMAP ។ ជាទូទៅ ភាគរយនៃក្បាលដីបែងចែកសំរាប់បង្កបង្កើនផលស្រូវនៅរដូវវស្សា មាននិន្នាការថយចុះតាមទំហំកាន់កាប់ដី រីឯភាគរយនៃក្បាលដីសំរាប់បង្កបង្កើនផលស្រូវនៅរដូវប្រាំង មានការកើនឡើង ។ ទោះជាយ៉ាងណាភាគរយនៃក្បាលដីបែងចែកសំរាប់បង្កបង្កើនផលស្រូវនៅរដូវវស្សា (៧២%) គឺតិចជាងនៅក្នុង តំបន់អង្កេតនៃគំរោង LMAP

(៨០,៤%) ។ រឿងនេះគឺឆ្លើយតបទៅលើភាពខុសគ្នានឹងភាគរយនៃការបែងចែកក្បាលដីសំរាប់ធ្វើស្រែនៅរដូវប្រាំងរវាងខេត្តកំពង់ឆ្នាំង (១៧%) និងតំបន់អង្កេតនៃគំរោង LMAP (៦,៦%) ។ ភាគរយនៃក្បាលដីបែងចែកសំរាប់ធ្វើចំការ (៤%ជាទូទៅ) និងភាគរយនៃក្បាលដីទុកចោលទំនេរ (៤% ជាទូទៅ) កើនឡើងបន្តិចបន្តួចទៅតាមទំហំដី ។

បើនិយាយពីការប្រើប្រាស់ក្បាលដីជាក់ស្តែង ក្បាលដីទាំងអស់ ៩១% ត្រូវបានធ្វើការដាំដុះ ។ ប៉ុន្តែ មិនដូចនៅក្នុងតំបន់អង្កេត LMAP អត្រាប្រើប្រាស់ដី គឺមានភាពប្រែប្រួលបន្តិចបន្តួច គ្រប់ទំហំកាន់កាប់ដី ។ អត្រានៃការធ្វើកសិកម្មសំរាប់ស្ត្រីជាមេគ្រួសារ គឺទាបជាងបុរសជាមេគ្រួសារ ។ ប្រហែលជា ២% នៃក្បាលដី ត្រូវបានជួលឱ្យគេ និង ៥% ទៀតទុកទំនេរចោល ។ ដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ស្ត្រីជាមេគ្រួសារ មានអត្រាភាគរយខ្ពស់ជាងបុរសជាមេគ្រួសារបន្តិច ទាំងការ ជួលដី និងការទុកដីទំនោរចោល ។ ភាគរយនៃក្បាលដីសំរាប់ការបង្កបង្កើនផល និងដាំដំណាំផ្សេងទៀត ក៏មានការកើនឡើងតាមទំហំកាន់កាប់ដី ទោះបីជាភាគរយសរុបមានកំរិតទាបក៏ដោយ (៣%) ។

ដូចនៅក្នុងតំបន់អង្កេត LMAP ហេតុផលសំខាន់ ៤៧ បណ្តាលអោយទុកដីកសិកម្មឱ្យនៅទំនេរចោល គឺដោយសារខ្វះខាតកំលាំងពលកម្ម (២៨%) មិនចំណេញ (៣២%) និងខ្វះទុនវិនិយោគ (១១%) ។ ហេតុផលផ្សេងទៀត មានចំនួន ៣១% ។ ទោះបីជាចំនួនឆ្លើយតបជាក់ស្តែងមានតិចតួច ភាគរយដ៏ធំនៃស្ត្រីជាមេគ្រួសារ បានបង្ហាញពីការខ្វះខាតកំលាំងពលកម្ម រីឯភាគរយដ៏ធំនៃបុរសជាមេគ្រួសារ បង្ហាញថា មិនមានការចំណេញ និងខ្វះខាតទុនវិនិយោគ ។ ភាគរយស្រដៀងគ្នានៃបុរសនិងស្ត្រីជាមេគ្រួសារបង្ហាញពីហេតុផលផ្សេងទៀត ។

## ៧.៤ ទីផ្សារដីធ្លីៈ តំលៃ ថ្លៃ និងការផ្ទេរដីធ្លី

គំរូនៃតំលៃដីបានរាយការណ៍ក្នុងខេត្តកំពង់ឆ្នាំង គឺមានភាពខុសគ្នាដោយអន្លើទៅនឹងតំបន់អង្កេតនៃគំរោង LMAP ដែលនៅទីនោះតំលៃដី (ម៉ឺនរៀល/ហិកតា) គឺមានការធ្លាក់ចុះសន្សឹមៗ ពេលទំហំកាន់កាប់ដីកើនឡើង ទាំងសំរាប់បុរស និងស្ត្រីជាមេគ្រួសារ ។ នៅខេត្តកំពង់ឆ្នាំង ទោះយ៉ាងណាក្តី គំរូនេះ គឺកើតមានតែទៅលើ ស្ត្រីជាមេគ្រួសារប៉ុណ្ណោះ រីឯបុរសជាមេគ្រួសារ គំរូនេះមានភាពចំរុះគ្នា ។ រឿងនេះ ជាលទ្ធផលនៃគំរូចំរុះគ្នា សំរាប់គ្រប់គ្រួសារ ដូចក្រុមអង្កេតភាគច្រើន រាប់បញ្ចូលទាំងបុរសជាមេគ្រួសារ ។ ប៉ុន្តែ គំរូនៃតំលៃក្បាលដីជាមធ្យម គឺប្រហាក់ប្រហែលគ្នា ទៅនឹងគំរូក្នុងតំបន់អង្កេតនៃគំរោង LMAP ព្រោះតំលៃក្បាលដីមានការធ្លាក់ចុះ នៅពេលទំហំកាន់កាប់ដីកើនឡើង ។ មានការលើកលែងមួយពាក់ព័ន្ធនឹងក្រុមចន្លោះកាន់កាប់ដីធំបំផុត ដែលបង្ហាញនូវការថយចុះធៀបនឹងក្រុមចន្លោះកាន់កាប់ដីពីមុន (តារាង ៧.៤ក) ។

**តារាង ៧.៤ក. តំលៃដី គិតជាហិកតា និងក្បាលដី (ម៉ឺនរៀល/ហ.ត)**

| ទំហំកាន់កាប់ដី (ហ.ត) | ចំនួនឡូត៍ | ទំហំ (ហ.ត) | តំលៃ/ហ.តបុរស | តំលៃ/ហ.ត ស្ត្រី | តំលៃ/ហ.តសរុប | តំលៃ/ឡូត៍ |
|---|---|---|---|---|---|---|
| < 0.5 | 128 | 0.109 | 583 | 695 | 610 | 66.6 |
| 0.5 – 0.9 | 266 | 0.153 | 820 | 490 | 724 | 110.8 |
| 1.0 – 1.9 | 242 | 0.216 | 716 | 494 | 660 | 142.6 |
| 2.0 – 2.9 | 142 | 0.321 | 712 | 466 | 677 | 217.3 |
| > 3.0 | 151 | 0.411 | 357 | 292 | 346 | 142.2 |
| សរុប | 929 * | .2200 | 669 | 498 | 628 | 138.2 |

n = 303 plots missing

គ្រួសារចំនួន ៤៧ ត្រូវបានរាយការណ៍ថា បានលក់ដីកសិកម្មចំនួន ៦៥ក្បាលដី តាំងពីឆ្នាំ១៩៨៩ ដែលតំណាងឱ្យប្រហែលជា ៥.៣% នៃក្បាលដីនៅក្នុងតំបន់ត្រួតពិនិត្យ ។ តួលេខនេះ មានចំនួនតិចជាង នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ដែលមានចំនួន ៧.៨% ។ ដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP មានចំនួនមិនសមាមាត្រគ្នានៃការលក់ដីនៅក្នុងចំណោមក្រុមកាន់កាប់ដីតិចបំផុតចំនួន ២ ធៀបនឹងក្រុមចន្លោះកាន់កាប់ដីធំបំផុត ២ទៀត ។ ក្រុមចន្លោះកាន់កាប់ដីតិចបំផុត ២ បានរាយការណ៍ថា កាន់កាប់ក្បាលដីសរុបចំនួន ៥៣៥ ក្បាលដី ឬប្រហែលជា ៤៣.៤% នៃក្បាលដីទាំងអស់ (១២៣២ក្បាលដី) នៅក្នុងតំបន់គំរូ ។ ប៉ុន្តែ មានរបាយការណ៍ថា មានការលក់ដី ៣២ក្បាលដី រឺ ៤៩.២% នៃចំនួនក្បាលដីបានលក់ទាំងអស់ ។ នៅខណៈដែល ក្រុមចន្លោះកាន់កាប់ដីធំបំផុត ២ បានកាន់កាប់ក្បាលដី ២៦.១% ប៉ុន្តែបានលក់អស់តែ ៩.២% នៃក្បាលដីបានលក់ទាំងអស់ ។ ចំនួនប្រហែលជា មួយភាគបីនៃការលក់ នៅក្នុងចំណោមក្រុមចន្លោះកាន់កាប់ដីតិចបំផុត ២ គឺពាក់ព័ន្ធនឹងស្ត្រីជាមេគ្រួសារ ។ ជាទូទៅ ប្រហែលជា ៣៣.៨% នៃការលក់ដី គឺពាក់ព័ន្ធជាមួយនឹងស្ត្រីជាមេគ្រួសារ ។[៣៤]

**តារាង ៧.៤ខ. ការលក់ក្បាលដី តាមទំហំកាន់កាប់ដី និងយេនឌ័រ នៃមេគ្រួសារ**

| ទំហំដី (ហ.ត) | ឡូតិ៍ | ការលក់ | ការលក់ | | ផ្ទៃដីមធ្យម | | ថ្លៃ (ម៉ឺនរៀល/ហ.ត) | | ផ្ទៃដីសរុប (ហ.ត) | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ប | ស | ប | ស | ប | ស | ថ្លៃ | ផ្ទៃដី |
| 0 | | 14 | 4 | 10 | .11 | .32 | 944 | 202 | 414 | .26 |
| < 0.5 | 167 | 16 | 12 | 3 | .26 | .20 | 420 | 567 | 449 | .25 |
| 0.5 – 0.9 | 368 | 17 | 9 | 8 | .15 | .18 | 618 | 301 | 469 | .17 |
| 1.0 – 1.9 | 376 | 13 | 12 | 1 | .18 | .10 | 1,213 | 1,000 | 1,197 | .17 |
| 2.0 – 2.9 | 144 | 3 | 3 | 0 | .13 | | 858 | | 858 | .13 |
| > 3.0 | 177 | 3 | 3 | 0 | .60 | | 289 | | 2289 | .60 |
| | | | | | | | | | | |
| សរុប | 1,232 | 65 | 43 | 22 | .22 | .24 | 753 | 324 | 608 | .23 |

ជាទូទៅ ថ្លៃដីលក់ជាមធ្យមបានរាយការណ៍ នៅក្នុងតំបន់ត្រួតពិនិត្យនៅខេត្តកំពង់ឆ្នាំង (៦០៨ម៉ឺនរៀល/ហ.ត) គឺទាបជាងថ្លៃដីលក់ជាមធ្យមនៅក្នុងតំបន់អង្កេតនៃគំរោង LMAP (១,៥៥៥ ម៉ឺនរៀល/ហ.ត) ។ ថ្លៃដីជាមធ្យម មានភាពប្រហាក់ប្រហែលគ្នាដោយអន្លើសំរាប់ឃុំរលាប្អៀរ (៥៩០ម៉ឺនរៀល/ហ.ត) និងឃុំច្រេស (៦៣០ម៉ឺនរៀល/ហ.ត) ។ ឃុំរលាប្អៀរមានទីតាំងនៅជិតទីរួមខេត្តកំពង់ឆ្នាំង រីឯឃុំច្រេស នៅជិតនឹងទីក្រុងភ្នំពេញ ។ ឃុំទាំងពីរ មានទីតាំងដីនៅតាមដងផ្លូវជាតិលេខ ៥ ។ បើប្រៀបធៀបថ្លៃលក់ជាមធ្យម នៅក្នុងឃុំទាំងពីរនេះ ជាមួយថ្លៃលក់ ជាមធ្យមនៅតំបន់អង្កេតនៃគំរោង LMAP ឃុំរលាប្អៀរ និងឃុំច្រេស គឺស្ថិតនៅចន្លោះរវាងឃុំសំបូរ (៣៨២ម៉ឺនរៀល/ហ.ត) និងឃុំព្រៃទប់ (៧២០ម៉ឺនរៀល/ហ.ត) ។ គួរឱ្យកត់សំគាល់ថា ថ្លៃដីលក់ជាមធ្យមបានរាយការណ៍ ៦០៨ម៉ឺនរៀល/ហ.ត (តារាង ៧.៤ខ) ស្ទើរតែស្មើតំលៃដីជាមធ្យម បានរាយការណ៍ ៦២៨ម៉ឺនរៀល/ហ.ត (តារាង ៧.៤ក) ។

**តារាង ៧.៤គ. ការលក់ក្បាលដីតាមឃុំ**

| ឃុំ | ចំនួនឡូតិ៍ | ទំហំឡូតិ៍ជាមធ្យម (ហ.ត) | ថ្លៃ (ម៉ឺនរៀល/ហ.ត) | ខេត្ត |
|---|---|---|---|---|
| រលាប្អៀរ | 36 | .20 | 590 | កំពង់ឆ្នាំង |
| ច្រេស | 29 | .25 | 630 | កំពង់ឆ្នាំង |
| សរុប | 65 | .23 | 608 | |

[៣៤] នៅក្នុងចំណោមគ្រួសារដែលគ្មានដី ដែលបានរាយការណ៍ថាបានលក់ដី ៧០% មានស្ត្រីជាមេគ្រួសារ ។

នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ៦២% នៃការលក់ដីបានរាយការណ៍ បានធ្វើឡើងតាំងពីឆ្នាំ១៩៩៨ រីឯនៅក្នុងតំបន់ត្រួតពិនិត្យនៅខេត្តកំពង់ឆ្នាំង ៦៤% នៃការលក់ដី បានធ្វើឡើងនៅក្នុងអំឡុងពេលដូចគ្នា ។ ដូចនៅឃុំអង្កេតភាគច្រើននៃតំបន់គំរោង LMAP ការលក់ដីទាំងនៅក្នុងឃុំរលាប្អៀរ និងឃុំជ្រេស ហាក់ដូចជាកើនឡើងខ្ពស់បំផុត នៅអំឡុងពេលឆ្នាំ១៩៩៨-២០០១ ។

**តារាង ៧.៤ឃ. ការលក់ក្បាលដី តាមឆ្នាំ (ខេត្តកំពង់ឆ្នាំង)**

| ឃុំ | < 1989 | 1989-93 | 1994-97 | 1998-2001 | 2002-2004 | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| រលាប្អៀរ | 1 | 8 | 7 | 16 | 4 | 36 |
| ជ្រេស | 4 | 1 | 3 | 15 | 6 | 29 |
| | | | | | | |
| សរុប | 5 | 9 | 10 | 32 | 10 | 65 |

ចុងក្រោយ ហេតុផលបានលើកឡើងញឹកញាប់បំផុតទី១នៃការលក់ដី គឺបញ្ហាសុខភាព (២៣ករណី) រឺ ២៥% នៃហេតុផលបានលើកឡើង ហើយតួលេខនេះ គឺវាមានកំរិតខ្ពស់ជាងតួលេខនៅក្នុងតំបន់អង្កេតនៃគំរោង LMAP (២៤.៩%) ។ ហេតុផលលើកឡើងញឹកញាប់បំផុតទី២ គឺបញ្ហាខ្វះម្ហូបអាហារ (៩ករណី) រឺ ១៣.៨% ។ តួលេខនេះ គឺខុសគ្នាពីតួលេខនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ដែលនៅទីនោះ ហេតុផលលើកឡើងជាញឹកញាប់ទី២ គឺបញ្ហាទុនវិនិយោគធ្វើអាជីវកម្ម រឺ ២៨.៦% ។ ដូចមាននៅក្នុងតំបន់អង្កេតនៃគំរោង LMAP ហេតុផលផ្សេងទៀត មានភាគរយច្រើនគួរឱ្យកត់សំគាល់ ក្នុងនោះមានការសងបំណុល ការធ្វើបុណ្យសព និងពិធីបែបសង្គមផ្សេងៗ ការចំណាយលើការផ្លាស់ប្តូរទីលំនៅ និងវិបត្តិពាក់ព័ន្ធនឹងភាពគ្រោះថ្នាក់ផ្សេងៗ ។ ចំពោះហេតុផលនៃការលក់ដីតំបន់ត្រួតពិនិត្យ ២ នៅខេត្តកំពង់ឆ្នាំង មានហេតុផលដូចគ្នាទៅនឹងតំបន់ អង្កេត ២ នៃគំរោង LMAP នៅខេត្តតាកែវ ។

**តារាង ៧.៤ង. ការលក់ក្បាលដី ដោយហេតុផលផ្សេងៗ**

| ឃុំ | ជំនួញ | ថែទាំសុខភាព | ទិញស្បៀង | លក្ខណៈឡូតិ៍ | ផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| រលាប្អៀរ | 4 | 9 | 1 | 4 | 18 | 36 |
| ជ្រេស | 1 | 5 | 7 | 1 | 15 | 29 |
| | | | | | | |
| សរុប | 5 | 23 | 9 | 5 | 33 | 65 |

## ៧.៥ ការរៀបចំដែនដី និងរដ្ឋបាលដីធ្លី

ក្នុងចំណោមក្បាលដីលំនៅដ្ឋានចំនួន ២៩១ នៅក្នុងតំបន់ត្រួតពិនិត្យ មាន ១៤០ក្បាលដី (៥០.៩%) មិនដែលមានឯកសារអ្វីទាំងអស់ ។ តួលេខនេះ គឺទាបខ្លាំងណាស់បើធៀបនឹងតួលេខ នៅក្នុងតំបន់អង្កេតនៃគំរោង LMAP (៦៥.៦%) ។ ក្បាលដីប្រហែលជា ៥.៨% មានឯកសារនៅពេលផ្សេងទៀត ប៉ុន្តែឯកសារទាំងនោះ បានបាត់បង់អស់ទៅហើយ ។ ក្នុងចំណោមក្បាលដីលំនៅដ្ឋាននៅសល់ចំនួន ៩៩ មាន ៦៧ក្បាលដី មានឯកសារជាវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី រឺឯ ៥២ក្បាលដីផ្សេងទៀត

មានវិញ្ញាបនប័ត្រកាន់កាប់ដី ។ ភាគរយនៃវិញ្ញាបនប័ត្រកាន់កាប់ ដីលំនៅដ្ឋាននៅខេត្តកំពង់ឆ្នាំ (៥២,៥%) គឺមានអត្រាខ្ពស់ណាស់ធៀបនឹងភាគរយនៅក្នុងតំបន់អង្កេតនៃគំរោង LMAP (៤,២%) ។ ក្បាលដីលំនៅដ្ឋាននៅសល់ ៥ផ្សេងទៀត មានតែឯកសារវាស់វែងដីប៉ុណ្ណោះ ។

***ដីកសិកម្ម:*** នៅក្នុងចំណោម ១.២៣២ក្បាលដីកសិកម្ម នៅក្នុងតំបន់ត្រួតពិនិត្យ មាន ៦៩២ក្បាលដី (៥៦.២%) មិនដែលមានឯកសារអ្វីទេ ។ ក្បាលដីបានរៀបចំឯកសារតាមមធ្យោបាយផ្សេងៗ ក្នុងនោះមាន ៤៧៩ក្បាលដី (មានឯកសារខ្លះក្នុងដៃ) ហើយ ៤៨ក្បាលដីផ្សេងទៀត (ឯកសារទាំងផ្លូវការ និងក្រៅផ្លូវការ) បានបាត់បង់ឯកសារ ។ ជាលទ្ធផល ៤៣.៨% នៃក្បាលដីកសិកម្ម មានឯកសារខ្លះធ្វើការបញ្ជាក់ រឺយ៉ាងហោចណាស់មានការប្រកាសថាជាម្ចាស់កម្មសិទ្ធិ ។ តួលេខនេះគឺខ្ពស់ជាង ៣៧,៣% នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។

ក្បាលដីមានឯកសារចំនួន ៥៩,៣% គឺមានតែវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី ដែលវាប្រហាក់ប្រហែលទៅនឹង ៦១,៦% នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ ចំនួន ២២,៨% ផ្សេងទៀត មានវិញ្ញាបនប័ត្រកាន់កាប់ដីពិតប្រាកដ ហើយនេះជាភាគរយយ៉ាងខ្ពស់ ធៀបនឹង ៨,១% នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ រឿងនេះអាចបណ្តាលមកពីខេត្តទាំងនោះមានការខិតខំប្រឹងប្រែងដើម្បីផ្តល់វិញ្ញាបនប័ត្រនៅក្នុងតំបន់ជាក់លាក់ណាមួយ ដែលអាចជាការឆ្លុះបញ្ចាំងថា ការបែងចែកវិញ្ញាបនប័ត្រគឺមានរបាយស្មើគ្នានៅគ្រប់ក្រុមចន្លោះនៃការកាន់កាប់ដី ។ នៅខណៈនេះដែរ ចំនួន ៩,៨% មានឯកសារវាស់វែងដី និង ៨,១% មានការប្រើប្រាស់ឯកសារផ្សេងទៀត ។

**តារាង ៧.៥ក. ឯកសារដីកសិកម្ម**

| ទំហំដី (ហ.ត) | វិក័យប័ត្រសុំកាន់កាប់ដី | | ឯកសារអង្កេត | | ប័ណ្ណកម្មសិទ្ធិដីធ្លី | | ផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | |
| < 0.5 | 24 | 1 | 0 | 0 | 12 | 4 | 4 | 0 | 40 | 5 |
| 0.5 – 0.9 | 65 | 24 | 19 | 4 | 16 | 4 | 2 | 0 | 102 | 32 |
| 1.0 – 1.9 | 64 | 18 | 13 | 0 | 19 | 12 | 19 | 0 | 115 | 30 |
| 2.0 – 2.9 | 40 | 9 | 10 | 0 | 14 | 7 | 1 | 0 | 65 | 16 |
| > 3.0 | 38 | 1 | 1 | 0 | 17 | 4 | 13 | 0 | 69 | 5 |
| | | | | | | | | | | |
| សរុប | 231 | 53 | 43 | 4 | 78 | 31 | 39 | 0 | 391 | 88 |
| សរុប | 284 | | 47 | | 109 | | 39 | | 479 | |

តារាង ៧.៥ខ ពាក់ព័ន្ធនឹងហេតុផលដែលអ្នកឆ្លើយតប បានផ្តល់ចំពោះការមិនបានចុះបញ្ជីក្បាលដីកសិកម្មរបស់ពួកគេ ។ វាបង្ហាញថា ២០,៤% នៃក្បាលដីកសិកម្មមិនបានធ្វើឯកសារ ដោយសារការបង់ថ្លៃសេវាក្រៅផ្លូវការខ្ពស់ក្នុងដំណើរការចុះបញ្ជី ។ រឿងនេះ មានភាពខុសគ្នាយ៉ាងខ្លាំងពីតំបន់អង្កេតនៃគំរោង LMAP ដែលនៅទីនោះ មានអ្នកឆ្លើយតបតែពីរ-បីនាក់ប៉ុណ្ណោះបានបញ្ជាក់ពីការបង់សេវាក្រៅផ្លូវការ ។ ប្រហែលជា ១៤,៨% មិនទាន់បានចុះបញ្ជី ពីព្រោះតែគេគិតថាវាមិនចាំបាច់ ។ ចំនួន ១២,២% ផ្សេងទៀតនៃក្បាលដីមិនបានចុះបញ្ជី ពីព្រោះតែគេមិនដឹងពីនីតិវិធី រីឯ ៩,៤% នៃក្បាលដីមិនបានចុះបញ្ជី ពីព្រោះតែគេគិតថា ដំណើរការនេះ វាមានភាពស្មុគស្មាញពេក ។ ប្រហែលជា ៤៧,២% នៃក្បាលដីមិនបានរៀបចំឯកសារ គឺដោយសារហេតុផលផ្សេងៗគ្នា តែគ្មានទិន្នន័យជាក់លាក់ ។

**តារាង ៧.៥ខ. ហេតុផលនាំឱ្យគេមិនធ្វើការចុះបញ្ជីដីកសិកម្ម**

| ទំហំដី (ហ.ត) | មិនចាំបាច់ | | មិនយល់ពីនីតិវិធី | | ថ្លៃសេវាក្រៅផ្លូវការ | | ប្រព័ន្ធស្មុគស្មាញ | | ផ្សេងទៀត | |
|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស |
| | | | | | | | | | | |
| < 0.5 | 18 | 6 | 16 | 4 | 10 | 5 | 4 | 0 | 39 | 18 |
| 0.5 – 0.9 | 25 | 6 | 44 | 0 | 19 | 27 | 12 | 2 | 63 | 36 |
| 1.0 – 1.9 | 24 | 2 | 7 | 4 | 30 | 18 | 8 | 0 | 49 | 28 |
| 2.0 – 2.9 | 8 | 1 | 3 | 4 | 14 | 0 | 13 | 0 | 39 | 3 |
| > 3.0 | 16 | 0 | 5 | 0 | 14 | 9 | 0 | 0 | 47 | 16 |
| | | | | | | | | | | |
| សរុប | 91 | 15 | 75 | 12 | 87 | 59 | 37 | 2 | 237 | 101 |
| សរុប * | 106 | | 87 | | 146 | | 39 | | 338 | |

* Total n = 716 (may include some “no” in category with paper.)

ភាគរយនៃការផ្ទេរដីដោយធ្វើការផ្លាស់ប្តូរឈ្មោះនៅលើវិក័យប័ត្រដាក់ពាក្យសុំកាន់កាប់ដី គឺស្ទើរតែមានភាពដូចគ្នាបេះបិទរវាងក្រុមអង្កេត និងក្រុមនៅតំបន់ត្រួតពិនិត្យ (មាន ៦៥%) ។ នៅក្នុងតំបន់អង្កេតនៃគំរោង LMAP របាយការណ៏នៃការលក់ដីមិនបានទៅចុះបញ្ជីផ្លូវការ គឺមានអត្រាខ្ពស់ ពីព្រោះ ២១ករណី នៃហេតុផលផ្សេងទៀត ប្រហែលជារួមបញ្ចូលលិខិតកិច្ចព្រមព្រៀង និងវិធីសាស្ត្រក្រៅផ្លូវការផ្សេងទៀត ។ ជាថ្មីម្តងទៀត នៅក្នុងតំបន់អង្កេតនៃគំរោង LMAP របាយការណ៏នៃការផ្លាស់ប្តូរឈ្មោះនៅលើវិក័យប័ត្រ គឺមានការថយចុះជាបង្គួរ ដែលមានការស្នើថា តំលៃនៃកាផ្ទេរជាប់ពាក់ព័ន្ធជាមួយការធ្វើដំណើរ ពេលវេលា គឺជាឧបសគ្គយ៉ាងសំខាន់ ដល់ការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីផ្លូវការ ។

**តារាង ៧.៥គ. ការលក់ក្បាលដី គិតតាមការរៀបចំឯកសារ (នៅក្នុងខេត្តកំពង់ឆ្នាំង )**

| ឃុំ | ប្តូរឈ្មោះក៏រិតភូមិ | ប្តូរឈ្មោះក៏រិតឃុំ | ប្តូរឈ្មោះក៏រិតស្រុក | ប្តូរឈ្មោះក៏រិតខេត្ត | ផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| រលាប្អៀរ | 17 | 11 | 1 | | 6 | 35 |
| ច្រើស | 12 | 2 | | | 15 | 29 |
| | | | | | | |
| សរុប | 29 | 13 | 1 | | 21 | 64 * |

* N = 1 missing

## ៧.៦. វិវាទ និងជំលោះដីធ្លី

មានរបាយការណ៏ថា វិវាទដីធ្លីចំនួន ១៥ករណី បានកើតឡើងនៅក្នុងតំបន់ត្រួតពិនិត្យតាំងពីការបោះឆ្នោតឃុំមកម្ល៉េះ ។ ចំនួននេះស្មើនឹង ៥,៧៧% នៃគ្រួសារចំនួន ២៦០ ដែលជាអត្រាទាបជាងបន្តិចធៀបនឹង ៦,៣% នៅក្នុងតំបន់អង្កេត នៃគំរោង LMAP ។ នៅក្នុងចំណោម ១៥ករណី មាន ៩ករណី (៦០%) គឺពាក់ព័ន្ធជាមួយនឹងបុរសជាមេគ្រួសារ ហើយ ៦ករណី (៤០%) ពាក់ព័ន្ធជាមួយនឹងស្ត្រីជាមេគ្រួសារ ។ មាន ៨ករណី (៥៥,៣%) ពាក់ព័ន្ធជាមួយនឹងគ្រួសារកាន់កាប់ដីកសិកម្មមួយហិកតា ឬតិចជាងនេះ រីឯ ២ករណី ពាក់ព័ន្ធជាមួយគ្រួសារកាន់កាប់ដីពី ២-៣ហិកតា ។ មិនមានរបាយការណ៏ពីវិវាទដីធ្លីនៅក្នុងចំណោមគ្រួសារកាន់កាប់ដីច្រើនជាង ៣ហិកតានោះទេ ។ ដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ប្រភេទដីពាក់ព័ន្ធនឹងវិវាទ គឺមានការបែងចែកជាដីកសិកម្ម (៧ករណី) និងដីលំនៅដ្ឋាន (៨ករណី) ។

**តារាង ៧.៦ក. របាយការណ៍ពីវិវាទដីធ្លីតាំងពីឆ្នាំ២០០១**

| យេនឌ័រ | < 0.5 | 0.5-.99 | 1.0 – 1.99 | 2.0 – 2.99 | ≥ 3.0 | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| បុរស | 1 | 3 | 4 | 2 | 0 | 9 |
| ស្ត្រី | 1 | 4 | 1 | 0 | 0 | 6 |
| | | | | | | |
| សរុប | 2 | 7 | 5 | 2 | 0 | 15 |

វិវាទព្រំប្រទល់ជាមួយអ្នកជិតខាងមាន ៧ ករណី (៤៦.៦%) បន្ទាប់មកមាន ៤ករណី ពាក់ព័ន្ធនឹងអ្នកភូមិផ្សេងទៀត និង ១ករណី ជាជំលោះរវាងសាច់ញាតិ ។ មាន ៣ករណី ជាវិវាទពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត ។ វាមិនដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ពីព្រោះមិនមានរបាយការណ៍អំពីវិវាទដីធ្លីពាក់ព័ន្ធជាមួយអាជ្ញាធរ ឬអ្នកមានអំណាចទេ ។ ការបែងចែកប្រភេទនៃវិវាទ គឺវាឆ្លើយតបនឹងការកត់សំគាល់ ដែលបានធ្វើការបរិយាយនៅ ខាងលើនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ ភាគច្រើននៃជំលោះដីធ្លី គឺមានលក្ខណៈនៅមូលដ្ឋានសុទ្ធសាធ ដូចជាពាក់ព័ន្ធនឹងព្រំប្រទល់ជាមួយអ្នកជិតខាង ឬក៏ជំលោះសិទ្ធិរវាងបងប្អូន ។

## ៧.៦.១ ការដោះស្រាយវិវាទ

ចំនួន ១៥គ្រួសារពាក់ព័ន្ធនឹងវិវាទ បានប្រើប្រាស់វិធីសាស្ត្រដោះស្រាយវិវាទចំនួនតិចជាងគ្រួសារ នៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ បញ្ហានេះ អាចបណ្តាលមកពីនៅក្នុងខេត្តកំពង់ឆ្នាំង មានចំនួនវិវាទដីធ្លី តិចតួចជាងនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ នៅក្នុងការចរចាគ្នានៅជំហានទី ១ គ្រួសារចំនួន ៦ ព្យាយាមដោះស្រាយដោយផ្ទាល់ជាមួយភាគីម្ខាងទៀត រីឯ ៥គ្រួសារ បានឡើងទៅដល់មេភូមិ និង ៤គ្រួសារ បានឡើងទៅដល់មេឃុំ ។ មានករណីវិវាទចំនួន ៨ ត្រូវបានដោះស្រាយនៅជំហានទី១ រីឯ ៧ករណី មិនត្រូវបានដោះស្រាយទេ ។

នៅក្នុងចំណោម ៧ករណី ដែលមិនទាន់បានដោះស្រាយនៅក្នុងជំហានទី១ ៥គ្រួសារ ត្រូវបានរាយការណ៍ថា បានធ្វើការចរចាគ្នានៅជំហានទី ២ ។ ក្នុងនោះមាន ៣គ្រួសារ បានឡើងដល់មេភូមិ និង ២ករណីបានឡើងដល់មេឃុំ ។ នៅក្នុងចំណោម ៥ករណី មាន ១ករណី ត្រូវបានដោះស្រាយរួច ។ នៅក្នុងចំណោម ៤ករណី មិនទាន់ដោះស្រាយនៅក្នុងជំហានទី២ ចំនួន ៣គ្រួសារ ត្រូវបានរាយការណ៍ថា បានឡើងទៅដល់ជំហានទី ៣ ។ មួយករណីឡើងទៅដល់ មេឃុំ រីឯនៅសល់ ២ករណីទៀតឡើងទៅដល់គណៈកម្មការដោះស្រាយវិវាទថ្នាក់ស្រុក ។ នៅក្នុងចំណោម ៣ករណី មួយករណីត្រូវបានដោះស្រាយ និង ២ករណីទៀតដោះស្រាយមិនចេញ ។

ទាក់ទងនឹងរបាយការណ៍អំពីការចំណាយលើការចរចាដោះស្រាយវិវាទ ចំនួន ១៥គ្រួសារ ដែលពាក់ព័ន្ធនឹងការចរចាដោះស្រាយវិវាទនៅជំហានទី១ ត្រូវបានរាយការណ៍ថាចំណាយជាមធ្យមមាន ប្រហែលជា ១.៤៨ ម៉ឺនរៀល រីឯ ៥គ្រួសារ ដែលធ្វើការចរចាដោះស្រាយវិវាទនៅជំហានទី ២ ត្រូវចំណាយជាមធ្យមចំនួន ០.១៤ម៉ឺនរៀល ។ ចំនួន ៣ គ្រួសារដែលធ្វើការចរចាដោះស្រាយវិវាទនៅជំហានទី ៣ ត្រូវបានរាយការណ៍ថា ចំណាយជាមធ្យមចំនួន ១.០៧ម៉ឺនរៀល ។ គំរូនេះគឺមានភាព

ផ្សេងៗគ្នាទៅនឹងគំរូនៅក្នុងតំបន់អង្កេតនៃគំរោង LMAP ។ ហេតុផលមួយនៅលើភាពផ្សេងគ្នានេះ គឺអាចពាក់ព័ន្ធទៅនឹងប៉ាន់គំរូដ៏តូចនៃវិវាទនៅក្នុងខេត្តកំពង់ឆ្នាំង ។

ដូចក្នុងតំបន់អង្កេតនៃគំរោង LMAP គ្រួសារជាច្រើនត្រូវបានគេសួរពីការបាត់បង់ដី បន្ទាប់ពីលទ្ធផលនៃការដោះស្រាយវិវាទ ។ នៅក្នុងចំណោម ១៤គ្រួសារ ដែលបានបញ្ចូលទៅក្នុងកំរងទិន្នន័យ ៦គ្រួសារ ត្រូវបានរាយការណ៍ថា គេមិនបាត់បង់ដីទេ រីឯ ៤គ្រួសារ ត្រូវបានរាយការណ៍ថាបាត់បង់ដីខ្លះ ។ ចំនួន ២គ្រួសារ ត្រូវបានរាយការណ៍ថា បានបាត់បង់ដីទាំងស្រុង ។ ដីទាំងនេះប្រហែលជាសំដៅលើក្បាលដីពាក់ព័ន្ធជាមួយនឹងវិវាទ មិនមែនលើក្បាលដីកាន់កាប់ទាំងស្រុង ដូចនៅក្នុងតំបន់អង្កេតនៃគំរោង LMAP នោះទេ ។ ចំនួន ២គ្រួសារ ត្រូវបានរាយការណ៍ថា គ្មានយោបល់ ឬ មិនឆ្លើយតប ។

ជាចុងក្រោយ គ្រួសារត្រូវបានគេសួរពីការពេញចិត្តអំពីមធ្យោបាយ ឬអ្នកដែលជួយដោះស្រាយវិវាទ ។ ៧គ្រួសារ ឆ្លើយថា ពេញចិត្ត រីឯ ៥គ្រួសារទៀត ឆ្លើយថា មិនពេញចិត្ត ។ ដូចក្នុងតំបន់អង្កេតនៃគំរោង LMAP ដែរ ចំនួនគ្រួសារដូចគ្នាបាននិយាយថា ដំណើរការនេះមានភាពយុត្តិធម៌ រីឯ ចំនួនដូចគ្នាមួយទៀត គឺគេគិតថា ដំណើរការនេះមិនយុត្តិធម៌ទេ ។

# ជំពូក ៨.
# សេចក្តីសន្និដ្ឋាន និងការកត់សំគាល់នានា

សុវត្ថិភាពលើសិទ្ធិនៃការកាន់កាប់ដីធ្លី អាចរួមចំណែកធ្វើឱ្យមានការលូតលាស់ផ្នែកសេដ្ឋកិច្ច-សង្គមកិច្ចនិងការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយផ្អែកយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់រដ្ឋបាលសាធារណៈដើម្បីគ្រប់គ្រង និងពង្រឹងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព ។ ផលប៉ះពាល់នៃកម្មសិទ្ធិដីធ្លី វាហាក់ដូចជាមានភាពខ្លាំង នៅពេលដែលប្រជាពលរដ្ឋជឿជាក់ទៅលើសមត្ថភាព និងការប្តេជ្ញាចិត្តរបស់ស្ថាប័នរដ្ឋាភិបាលដើម្បីអនុវត្ត និងពង្រឹងនូវការអនុវត្តសិទ្ធិកម្មសិទ្ធិលើដីធ្លីដោយយុត្តិធម៌ និងមានតំលាភាព ។ នៅក្នុងទិដ្ឋភាពបែបនេះ ប្រជាពលរដ្ឋនៅក្នុងតំបន់អង្កេតមូលដ្ឋាន បានបង្ហាញនូវការផ្តើមមានទំនុកចិត្តលើប័ណ្ណកម្មសិទ្ធិដីធ្លីដែលទើបតែបានចេញឱ្យនាពេលថ្មីៗនេះ ។

ផលប្រយោជន៍ពីប័ណ្ណកម្មសិទ្ធិដីធ្លីនេះ ក៏វាអាស្រ័យផងដែរទៅលើកាលៈទេសៈអំណោយផល ក្នុងនោះមាន (ក) កំរិតនៃសកម្មភាពទីផ្សារ (ខ) វត្តមាននៃឥណទានបាន សេវាកម្មបច្ចេកទេស លទ្ធភាពអាចប្រើប្រាស់សេវាកម្មថែទាំសុខភាពបាន និងសេវាផ្នែកសង្គមកិច្ចផ្សេងទៀត (គ) កំរិតនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និង (ឃ) ទីតាំងភូមិសាស្ត្រនៅក្នុងក្របខ័ណ្ឌនៃការដឹកជញ្ជូន និងទីផ្សារ ។ ផលចំណេញសំរាប់គ្រួសារ និងសហគមន៍ វាហាក់ដូចជាល្អបំផុតចំពោះតំបន់មានសមត្ថភាពខ្ពស់ ដែលបានចាត់ថា មានសកម្មភាពទីផ្សារដីធ្លី ភាពងាយស្រួលក្នុងការអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មផ្នែកសង្គមកិច្ច លក្ខខណ្ឌដីមានគុណភាពល្អ លទ្ធភាពអាចប្រើប្រាស់ប្រភពទឹក និងសក្តានុពលនៃភាពចំរុះក្នុងការប្រើប្រាស់ដី និងឱកាសមានការងារធ្វើ ។ ចំពោះតំបន់មានសមត្ថភាពទាប ក្នុងនោះមានភូមិ មានទីតាំងនៅឆ្ងាយពីផ្លូវថ្នល់ និង/ឬនៅឆ្ងាយពីមជ្ឈមណ្ឌលពាណិជ្ជកម្ម និងរដ្ឋបាល មានដីគុណភាពអន់ ខ្វះប្រភពទឹក ហើយគំរូនៃការប្រើប្រាស់ដីមានលក្ខណៈតែមួយមុខ និងមានឱកាសការងារតិចតួចក្រៅពីធ្វើកសិកម្ម ។

ផលចំណេញពីប័ណ្ណកម្មសិទ្ធិដីធ្លី ក៏វាអាស្រ័យផងដែរទៅនឹងលក្ខណៈនៃគ្រួសារ ។ នៅក្នុងករណីនេះ ទំហំកាន់កាប់ដី និងយេនឌ័រនៃមេគ្រួសារ គឺជាកត្តាកំនត់ដ៏ល្អនៃកំលាំងពលកម្ម ទ្រព្យ និងចំណូលរបស់គ្រួសារ ហើយផ្តល់នូវសូចនាករដ៏ល្អនៃសមត្ថភាពសក្តានុពលរបស់គ្រួសារ ដើម្បីទទួលបានផលចំណេញពីកម្មវិធីចុះបញ្ជីដីធ្លី ។ យើងរំពឹងថា គ្រួសារកំពុងកាន់កាប់ដីធំ គឺជាគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពគួរឱ្យពេញចិត្តជាងគ្រួសារកាន់កាប់ដីតូច ។ ក្នុងពេលជាមួយគ្នានេះ បុរសជាមេគ្រួសារហាក់ស្ថិតនៅក្នុងទីតាំងគួរឱ្យពេញចិត្តផងដែរក្នុងការទទួលបានផលចំណេញពីប័ណ្ណកម្មសិទ្ធិដី ជាងស្ត្រីជាមេគ្រួសារ ។ និយាយជាទូទៅ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលខ្ពស់ គឺជាគ្រួសារដែលមានដីកាន់កាប់ធំ មានកំលាំងពលកម្មច្រើន មានទុនវិនិយោគច្រើន និងមានចំណូលខ្ពស់ ។ គ្រួសារមានផលប៉ះពាល់ជាសក្តានុពលទាប គឺគ្រួសារដែលមានដីកាន់កាប់តូច មានកំលាំងពលកម្មតិច មានទុនវិនិយោគតិច និងមានចំណូលទាប ។ គេបានដាក់បញ្ចូលគ្រួសារងាយរងគ្រោះ ដូចជាស្ត្រីមេម៉ាយ

ជាមេគ្រួសារផងដែរ ។ ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានរំពឹងថា នឹងអាចមានឥទ្ធិពលលើការទទួលបានឥណទាន ការវិនិយោគខាងកសិកម្ម និងការប្រើប្រាស់ដី ការអភិវឌ្ឍទីផ្សារដី ការផ្ទេរដី ការប្រើប្រាស់ការចុះបញ្ជីផ្លូវការ និងចំនួននៃវិវាទដីធ្លី ។ នៅចំណុចបន្ទាប់ ជាសង្ខេបនៃការព្យាករណ៍ខ្លះៗ ដោយផ្អែកទៅលើការពិភាក្សាខាងលើនៃទិន្នន័យអង្កេតមូលដ្ឋាន ។

***ឥណទាន:*** យើងធ្វើការព្យាករណ៍ថា ប័ណ្ណកម្មសិទ្ធិដីធ្លីនឹងធ្វើឱ្យកំរើកឡើងនូវសកម្មភាពឥណទាន ហើយស្ថាប័នឥណទានផ្លូវការនឹងកាន់តែងាយស្រួលដល់ប្រជាជន ។ កសិកររស់នៅជិតទីប្រជុំជនស្រុក និង/ឬនៅជិតមជ្ឈមណ្ឌលទីផ្សារនៅតាមដងផ្លូវ អាចមានលទ្ធភាពច្រើនដើម្បីទទួលបានឥណទានពីស្ថាប័នផ្លូវការ ជាងកសិកររស់នៅតំបន់ដាច់ស្រយាល ។ យើងកត់សំគាល់ឃើញថា មានភាពខុសគ្នាដោយផ្អែកទៅលើទំហំកាន់កាប់ដី យេនឌ័រនៃមេគ្រួសារ នៅក្នុងក្របខ័ណ្ឌនៃភាពញឹកញាប់ ទំហំ និងការប្រើប្រាស់កំចី ។ និយាយជាទូទៅ គ្រួសារកាន់កាប់ដីតូច មានធនធានតិច នឹងទទួលបានឥណទានតិច ហើយកាន់តែតិចទៅៗ រីឯគ្រួសារកាន់កាប់ដីធ្លីធំ នឹងទទួលបាន ឥណទានច្រើន ហើយកាន់តែច្រើនឡើងៗ ។

***ការវិនិយោគលើវិស័យកសិកម្ម និងការប្រើប្រាស់ដី:*** យើងធ្វើការព្យាករណ៍ថា អត្រានៃការវិនិយោគលើវិស័យកសិកម្ម នឹងមានភាពខុសគ្នាដោយផ្អែកទៅលើទំហំកាន់កាប់ដី ដោយគ្រួសារកាន់កាប់ដីធំ នឹងធ្វើការវិនិយោគច្រើនជាងគ្រួសារកាន់កាប់ដីតូច ។ ទោះជាយ៉ាងណាក្តី អត្រា និងប្រភេទនៃការវិនិយោគ អាចផ្អែកទៅលើ វត្តមាននៃឥណទាន និងសេវាកម្មបច្ចេកទេស នៅក្នុងតំបន់នោះផងដែរ ។ អត្រានៃការវិនិយោគ វាក៏អាស្រ័យផងដែរទៅនឹងលក្ខខណ្ឌនៃទីតាំង ក្នុងនោះមានបញ្ហាអាកាសធាតុ លក្ខខណ្ឌដី និងវត្តមានប្រភពទឹក ។ យើងធ្វើការកត់សំគាល់ឃើញថា ការកើនឡើងនូវកំរិតផលិតភាពស្របគ្នាជាមួយនឹងការកើនឡើងនៃសកម្មភាពវិនិយោគ ទោះបីរឿងនេះវាផ្អែកទៅលើលក្ខខណ្ឌនៃទីតាំងក៏ដោយ ។ អត្រានៃការប្រើប្រាស់ដីបែបចំរុះ ក៏វាផ្អែកផងដែរទៅលើកត្តាខុសៗគ្នាជាច្រើន ដូចជា ថ្លៃនៅទីផ្សារ និងព័ត៌មាន ។ យើងរំពឹងថា គ្រួសារកាន់កាប់ដីធំ នឹងចាប់ផ្តើមប្រើប្រាស់ដីក្នុងលក្ខណៈចំរុះបន្តិចម្តងៗ ដូច្នេះ ផលប៉ះពាល់ពិតប្រាកដ មិនអាចនឹងធ្វើការកត់សំគាល់បានទេ បន្ទាប់ពីរយៈពេល ៣ឆ្នាំ ។ យើងក៏រំពឹងដែរថា គ្រួសារកាន់កាប់ដីធំ នឹងបង្កើននូវអត្រាប្រើប្រាស់ដីរបស់ពួកគេ ។

***ទីផ្សារដីធ្លី:*** យើងរំពឹងថា ប័ណ្ណកម្មសិទ្ធិដីធ្លីអាចធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការបង្កើតទីផ្សារដី ជាពិសេសនៅតាមតំបន់ដងផ្លូវជាតិសំខាន់ៗ តំបន់នៅជិតមជ្ឈមណ្ឌលទីផ្សារ និងរដ្ឋបាល ដោយធ្វើការកាត់បន្ថយនូវតំលៃនៃការផ្ទេរ ដែលជាប់ពាក់ព័ន្ធនឹងកិច្ចសន្យាផ្លាស់ប្តូរ ។ តំលៃដីពិតប្រាកដ ដែលឆ្លុះបញ្ចាំងតំលៃផលិតកម្មពិតនៃដី ជារឿយៗវាតំរង់ឆ្ពោះទៅរកការប្រើប្រាស់ដីកាន់តែមានលក្ខណៈសេដ្ឋកិច្ច ។ យើងរំពឹងនិងកត់សំគាល់ឃើញពីការកើនឡើងនៃចំនួនការផ្ទេរលក់ក្បាលដី ពិសេសនៅក្នុងតំបន់ដែលហេដ្ឋារចនាសម្ព័ន្ធត្រូវបានពង្រឹង ហើយតំលៃផលិតកម្មនៃដី មានការកើនឡើង ។ ទោះជាយ៉ាងណា ប័ណ្ណកម្មសិទ្ធិដីធ្លីតែឯង គឺវានឹងមិនអាចពន្យឺត ឬពន្លឿននូវអត្រាលក់ដីនោះទេ ព្រោះការលក់ដី គឺវាអាស្រ័យលើកត្តាជាច្រើនទៀត ។ នៅក្នុងតំបន់ដែលខ្វះសេវាកម្មថែទាំសុខភាព និងសេវាផ្អែកសង្គមកិច្ចផ្សេងទៀត ទំហំនៃការលក់ដីជាបន្ទាន់នៅក្នុងចំណោមអ្នកក្រីក្រ អាចនឹងកើនឡើង រីឯនៅតំបន់មានភាពងាយស្រួលក្នុងការទទួលបានឥណទានផ្លូវការ នោះការលក់ដីអាចនឹងថយចុះ ។

***រដ្ឋបាលដីធ្លី:*** យើងធ្វើការព្យាករណ៍ពីកំនើននៃការប្រើប្រាស់ការចុះបញ្ជីផ្លូវការដើម្បីសំរបសំរួល និង កត់ត្រាការផ្ទេរ/លក់ ក្បាលដី (ការលក់ ការផ្ទេរមរតក) ជាពិសេសនៅតំបន់ដែលសកម្មភាពទីផ្សារដីកើតឡើងនៅតាមដងផ្លូវសំខាន់ៗ នៅជិតមជ្ឈមណ្ឌលរដ្ឋបាល និងតំបន់ពាណិជ្ជកម្ម ។ ទោះជាយ៉ាងណា យើងធ្វើការប៉ាន់ស្មានថា (១)តំលៃផ្ទេរ/លក់ដីពាក់ព័ន្ធ

នឹងការចុះបញ្ជីផ្លូវការ នឹងមានកេរ្តិ៍តទាបជាងតំលៃនាពេលសព្វថ្ងៃនេះ (២) ប្រជាពលរដ្ឋ កាន់តែមានជំនឿលើសុវត្ថិភាពនៃការកាន់កាប់ដី និង (៣) ប្រជាពលរដ្ឋនឹងមានចំណេះដឹងសមល្មមអំពីនីតិវិធី និងមានសមត្ថភាពអាចប្រើប្រាស់ប្រព័ន្ធនេះបាន ។

***វិវាទដីធ្លី:*** យើងរំពឹងថា បញ្ហាដីធ្លីរំពឹងទុកនានា ឬវិវាទដីធ្លីមិនទាន់ដោះស្រាយអាចដោះស្រាយបាននៅពេលដែលកម្មវិធីចុះបញ្ជីដីធ្លី ត្រូវបានអនុវត្ត ជាពិសេសនៅក្នុងថ្នាក់ភូមិ ពីព្រោះប្រជាពលរដ្ឋយល់ថា ប័ណ្ណកម្មសិទ្ធិដីធ្លី ដែលធ្វើឡើងដោយគំរោង LMAP គឺជាលើកចុងក្រោយ ។ ទោះជាយ៉ាងណា នៅពេលប័ណ្ណកម្មសិទ្ធិត្រូវចេញជាផ្លូវការ យើងរំពឹងថា វិវាទដីធ្លីនឹងថយចុះ ជាពិសេសពាក់ព័ន្ធនឹងជំលោះព្រំប្រទល់ជាមួយអ្នកជិតខាង ។ ចំនួននៃវិវាទកម្មសិទ្ធិ ក៏អាចនឹងថយចុះផងដែរ ទោះបីមិនបាត់ទាំងស្រុងក្នុងករណីពាក់ព័ន្ធនឹងការផ្ទេរមរតក ។ សំរាប់ជំនឿទុកចិត្តរយៈពេលវែងពីសំណាក់ប្រជាពលរដ្ឋទៅលើសុវត្ថិភាពនៃការកាន់កាប់ និងរដ្ឋបាលដីធ្លី គឺវាអាស្រ័យមួយផ្នែកលើកេរ្តិ៍តដែលគេយល់ថា ការដោះស្រាយវិវាទដីធ្លីធ្វើឡើងដោយយុត្តិធម៌ និងមិនលំអៀង ។

## ៨.១ ការកត់សំគាល់មួយចំនួន

ជាផ្នែកមួយនៃសេចក្តីសង្ខេបពីគំរោង LMAP គំរោង BSP ត្រូវបានស្នើឱ្យធ្វើការកត់សំគាល់ និងផ្តល់នូវអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការអនុវត្តន៍គំរោង ក៏ដូចជាការកសាងគោលនយោបាយ ។ អនុសាសន៍នានានៅខាងក្រោមនេះ គឺមានគោលបំណងពង្រឹងគុណភាព និងប្រសិទ្ធភាពនៃគំរោង ។

### ៨.១.១ ក្រុមអង្កេតនៃគំរោង LMAP

ក្រុមរបស់ BSP បានទទួលនូវកិច្ចសហការណ៍ដ៏ល្អ និងការគាំទ្រពីសំណាក់ មន្ត្រីនៃគំរោង LMAP ខេត្តក្រុង ។ ក្រុម BSP ក៏មានការពេញចិត្តផងដែរចំពោះ ការយកចិត្តទុកដាក់ និងប្រកបដោយវិជ្ជាជីវៈរបស់ក្រុមមន្ត្រីអង្កេតនៃគំរោង LMAP ដែលធ្វើការនៅក្នុងខេត្តកំពង់ធំ និងកំពង់ចាម ដែលជាទីកន្លែងគំរោង BSP ជាន់គ្នាជាមួយគំរោង LMAP ។ ក្រុមនេះ ហាក់ធ្វើការងារដោយបើកចំហរ និងមានតំលាភាពជាមួយមន្ត្រីមូលដ្ឋាន និងប្រជាពលរដ្ឋ ។ មន្ត្រីគំរោង BSP បានកោតសរសើរ ចំពោះការអនុវត្តដំណើរការគំរោង LMAP ដ៏ស្មុគស្មាញ ហើយបង្ហាញការចាប់អារម្មណ៍ទូទៅលើដំណើរការប្រកបដោយលទ្ធផលល្អ ជាពិសេសទៅលើតំរូវការផ្នែកបច្ចេកទេស មធ្យោបាយសំភារៈ និងការងារផ្នែករដ្ឋបាល ។

### ៨.១.២ ការសំរបសំរួលរវាងការធ្វើអង្កេតមូលដ្ឋាន ជាមួយនឹងការអនុវត្តគំរោង LMAP

គំរោង LMAP បានចាប់ផ្តើម រួចជាស្រេចនៅក្នុងខេត្តមួយចំនួននៅពេលដែលគំរោង BSP ត្រូវបានបង្កើតឡើងនឹងដាក់ឱ្យដំណើរការ ។ នៅក្នុងក្របខ័ណ្ឌការងារអង្កេត យើងធ្វើការជ្រើសរើសជាមុននូវតំបន់ខ្លះដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ច និងជាតំបន់ដែលមានការចាប់អារម្មណ៍ ដែលអាចរំពឹងទុកថាមានផលប៉ះពាល់ខ្លះៗពីប័ណ្ណកម្មសិទ្ធិដីធ្លី ។ ទាំងអស់នេះ វាបង្ហាញឱ្យឃើញនូវចំណុចសំខាន់ៗនៃផលចំណេញជាសក្តានុពលបានពីការធ្វើសមាហរណកម្មផែនការអង្កេតមូលដ្ឋាន ទៅក្នុងក្របខ័ណ្ឌផែនការគំរោងជាទូទៅ មុនការអនុវត្តគំរោងជាក់ស្តែង ។

## ៨.១.៣ ការធ្វើអត្តសញ្ញាណក្បាលដី

វាមានសារៈសំខាន់ណាស់សំរាប់អនាគតនៃអ្នកវាស់វែង ដែលអាចធ្វើអត្តសញ្ញាណក្បាលដីដូចគ្នាដែលគ្រប់ដណ្តប់នៅក្នុងតំបន់ធ្វើអង្កេតមូលដ្ឋាននាពេលបច្ចុប្បន្ននេះ ។ ការធ្វើអត្តសញ្ញាណក្បាលដីត្រូវបានសំរួលនៅក្នុងភូមិទាំងនោះ ដែលប្រជាពលរដ្ឋបានទទួលរួចហើយនូវលេខក្បាលដី ឬក៏ពួកគេទទួលបាននូវវិក័យប័ត្រ ដែលមានចុះលេខពីមន្ត្រីនៃគំរោង LMAP ។ លេខទាំងអស់ត្រូវបានកត់ត្រានៅក្នុងកំរងសំណួរអង្កេត ។ នៅភូមិខ្លះទៀត លេខក្បាលដីមិនទាន់បានទទួលនៅឡើយទេ អ្នកប្រមូលទិន្នន័យត្រូវបានសួរឱ្យពួកគេគូររូបរាងដីនៅខាងក្រោយក្រដាស់នៃកំរងសំណួរ ។ ធ្វើយ៉ាងនេះ គឺអាចមានការងាយស្រួលសំរាប់អ្នកវាស់វែងក្នុងការធ្វើអត្តសញ្ញាណក្បាលដីជាក់លាក់ ។[៣៥]

## ៨.១.៤ ការយល់ដឹងពីដំណើរការនៃគំរោង LMAP

និយាយជាទូទៅ ប្រជាពលរដ្ឋក្នុងភូមិបានបង្ហាញនូវភាពជឿជាក់ទៅ លើគំរោង LMAP ។ គេជឿថា ប័ណ្ណកម្មសិទ្ធិនេះ មានសុវត្ថិភាពជាងវិញ្ញាប័ណ្ណប័ត្រដែលបានផ្តល់ឱ្យពីពេលកន្លងទៅ ។ រឿងនេះ ក៏វាកើតចេញពីភស្តុតាងដែលប្រជាពលរដ្ឋគិតថានេះជាដំណើរការចុងក្រោយ ។ ឧទាហរណ៍ ប្រជាពលរដ្ឋទទួលបាននូវអត្ថប្រយោជន៍អំពីដំណើរការនេះ ដោយអាចធ្វើការបែងចែក និងផ្តល់មរតកទៅឱ្យកូនចៅរបស់ពួកគេ ។[៣៦] ជាទូទៅប្រជាពលរដ្ឋ ក៏មានអារម្មណ៏វិជ្ជមានផងដែរអំពីមធ្យោបាយដែលមន្ត្រីគំរោង LMAP និងមន្ត្រីមូលដ្ឋាន បានធ្វើការដោះស្រាយវិវាទដែលកើតមាននៅក្នុងអំឡុងពេលដំណើរការវិនិច្ឆ័យ ។ ការដាក់បង្ហាញជាសាធារណៈនូវទិន្នន័យក្បាលដីដោយប្រើប្រាស់បច្ចេកវិទ្យាផែនទី Digital ក៏បានជួយផងដែរក្នុងការបង្កើតឱ្យមានគោលដៅជាលក្ខណៈវិទ្យាសាស្ត្រជាងការធ្វើតាមរបៀបវិនិច្ឆ័យតាមការគិតឃើញ ។ ប្រជាពលរដ្ឋក៏មានការកោតសរសើរ និងរីករាយផងដែរ ចំពោះតំលៃសេវានៃការចុះបញ្ជីដីរបស់គំរោង LMAP ព្រោះវាមានតំលៃថោកឆ្ងាយណាស់ បើធៀបជាមួយសោហ៊ុយសេវាចុះបញ្ជីដែលធ្វើឡើងម្តងម្កាលនោះ ។

## ៨.១.៤ ក្រុមប្រឹក្សាឃុំ

សមាជិកក្រុមប្រឹក្សាឃុំក៏បានសំដែងនូវការចាប់អារម្មណ៏ជាវិជ្ជមានចំពោះដំណើរការនៃគំរោង LMAP ហើយពួកគេមានសេចក្តីសង្ឃឹម និងជឿជាក់ថា ដំណើរការចុះបញ្ជីដីធ្លីរបស់គំរោង LMAP នឹងជួយកាត់បន្ថយនូវបន្ទុកការងារដោះស្រាយវិវាទពាក់ព័ន្ធនឹងជំលោះព្រំប្រទល់ និងបញ្ហាសិទ្ធិកម្មសិទ្ធិនៅក្នុងគ្រួសារ ។ ទាំងអស់នេះ ជាការពង្រឹងឡើងវិញនូវការយល់ឃើញថា ប័ណ្ណកម្មសិទ្ធិនាពេលនេះ គឺជាដំណាក់កាលចុងក្រោយ ហើយពួកគេមានការជឿជាក់ថា បញ្ហាទាំងនេះនឹងត្រូវបានដោះស្រាយ ហើយវានឹងមិនអាចកើតមានម្តងទៀតទេ ។

---

៣៥ កំរងសំនួរចុងក្រោយសំរាប់សំភាសន៏ បានបញ្ជូនទៅក្រសួង ដនស ដើម្បីរក្សាទុករហូតដល់ពេលត្រូវប្រើប្រាស់សំរាប់វាស់វែងបន្តបន្ទាប់ ។

៣៦ Onchan Aungsumalin (2002) បានរកឃើញប្រហាក់ប្រហែលគ្នានៅក្នុងប្រទេសថៃ គេបានធ្វើការកត់សំគាល់ថា គំរោងចុះបញ្ជីដីធ្លី អាចធ្វើបានយ៉ាងឆាប់រហ័សលើការបែងចែកដីឱ្យទៅកូនចៅ នេះវាបង្ហាញឱ្យឃើញថា ឪពុកម្តាយចង់យកឱកាសនេះនៅពេលដែលគំរោងដំណើរការ ។

### ៨.១.៥ សោហ៊ុយសេវាលើការប្រើប្រាស់

មន្ត្រីនៃ BSP បានធ្វើការកត់សំគាល់ថា មានកំរិតនៃការយល់ច្រលំពាក់ព័ន្ធនឹងកំរៃសេវាដែលត្រូវបង់នៅក្នុងទីតាំងមួយចំនួន ។ ឧទាហរណ៍ នៅក្នុងខេត្តកំពង់ធំ មេភូមិនៅភូមិស្រែវៅ មានការបារម្ភថា ប្រជាពលរដ្ឋនៅក្នុងភូមិគិតថា នឹងត្រូវចំណាយសោហ៊ុយទៅលើប័ណ្ណកម្មសិទ្ធិរបស់ពួកគេ នៅពេលដែលប្រជាពលរដ្ឋនៅក្នុងតំបន់ផ្សេងទៀតដែលបានចុះបញ្ជីកម្មសិទ្ធិមុនរួចហើយ មិនមានការបង់ថ្លៃលើសោហ៊ុយនេះទេ ។[៣៧] នៅខណៈនេះដែរ ក្រុមប្រឹក្សាឃុំ នៅឃុំស្រែញ៉ៅ (ខេត្តកំពង់ចាម) បានគូសបញ្ជាក់ថា ពួកគេមិនទាន់មានភាពច្បាស់លាស់ទេ ពីមធ្យោបាយប្រមូល និងគ្រប់គ្រងថ្លៃសោហ៊ុយទាំងនោះ ។

### ៨.១.៦ ការប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីដីធ្លី

នៅពេលដែលប្រជាពលរដ្ឋសំដែងនូវការពេញចិត្តលើដំណើរការរបស់គំរោង LMAP និងសំដែងនូវការជឿទុកចិត្តទៅលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លី វាក៏បានលេចចេញនូវភាពមិនច្បាស់លាស់ខ្លះៗ អំពីរបៀបគ្រប់គ្រងការផ្ទេរដី (ការលក់ ការផ្ទេរមរតកជាដើម) នៅពេលអនាគត ។ នៅក្នុងករណីនេះ ការខ្វះខាតព័ត៌មានអំពីនីតិវិធី នឹងរារាំងដល់និន្នាការរបស់ប្រជាពលរដ្ឋក្នុងការទៅចុះបញ្ជីតាមប្រព័ន្ធផ្លូវការ ហើយពួកគេបែរជាប្រើប្រាស់មធ្យោបាយធ្លាប់អនុវត្តនៅពេលមុន ដែលជាការផ្ទេរឯកសារក្រៅផ្លូវការ ។

### ៨.១.៧ សិទ្ធិលើទ្រព្យជាប្រពៃណីនៅមូលដ្ឋាន

ដូចដែលបានកត់សំគាល់ខាងលើ ប្រជាពលរដ្ឋអោយតំលៃលើ ប័ណ្ណកម្មសិទ្ធិដីធ្លី ដោយជាទូទៅមានការយល់ដឹងថា ប័ណ្ណកម្មសិទ្ធិដីធ្លី នឹងផ្តល់នូវសិទ្ធិជាមូលដ្ឋានពាក់ព័ន្ធនឹងការប្រើប្រាស់ ការត្រួតពិនិត្យ និងសិទ្ធិកម្មសិទ្ធិ ។ ប៉ុន្តែនៅតំបន់ខ្លះ សិទ្ធិកម្មសិទ្ធិដីធ្លី អាចមិនមែនជាសិទ្ធិលើទ្រព្យផ្សេងទៀត ដែលស្ថិតនៅជាមួយនឹងដីធ្លីនោះទេ ។ ឧទាហរណ៍ នៅឃុំស្រែញ៉ៅ ក្នុងខេត្តកំពង់ចាម ប្រជាពលរដ្ឋរកចំណូលបានគ្រប់គ្រាន់តាមលក្ខណៈប្រពៃណីសំរាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ពីផលិតផលស្ករត្នោត ហើយរឿងនេះធ្វើឱ្យដើមត្នោតមានតំលៃខាងកត្តាផលិតកម្មមួយ ។ ជាយូរមកហើយ ប្រជាពលរដ្ឋមានសិទ្ធិប្រើប្រាស់ដើមត្នោតជាក់លាក់ណាមួយ ដោយមិនចាំបាច់ថា វាដុះនៅលើដីជាកម្មសិទ្ធិរបស់គេ ឬអត់នោះទេ ។ ប៉ុន្តែ ប្រជាពលរដ្ឋចាប់ផ្តើមកាប់រំលំដើមត្នោតនៅលើដីមិនមែនជារបស់គេ នៅពេលដែលគំរោង LMAP បានលាតសន្ធឹងទៅដល់ ។ ទាំងនេះ គឺជាប្រភេទនៃទំនាក់ទំនងរវាងទំរង់ខុសៗគ្នានៃទ្រព្យសម្បត្តិ ហើយចាំបាច់ណាស់ត្រូវមានការយកចិត្តទុកដាក់ ជាពិសេសសំរាប់នីតិវិធីនៃការវិនិច្ឆ័យនាពេលអនាគត ។

---

[៣៧] នៅតំបន់ផ្សេងទៀតមានកិច្ចការជាច្រើនត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលនៃគំរោងសាកល្បង ។

## ៨.២ ការធ្វើផែនការ និងគោលនយោបាយ

### ៨.២.១ ផលប៉ះពាល់វិជ្ជមាន

គំរោង BSP ធ្វើការព្យាករណ៍ថា ការប៉ះពាល់ពីការចុះបញ្ជីដីធ្លីវាហាក់ដូចជាមានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ដោយផ្អែកទៅលើកាលៈទេសៈ និងកត្តាផ្សេងៗគ្នា ។ ជាលទ្ធផល ប្រជាពលរដ្ឋនៅក្នុងតំបន់ខ្លះហាក់ដូចជាទទួលបានផលចំណេញច្រើននៅក្នុងលក្ខខណ្ឌជាក់ស្តែងណាមួយ ជាងគ្រួសារនៅក្នុងតំបន់ផ្សេងទៀត ដែលមិនមានលក្ខខណ្ឌទាំងនោះ ។ ករណីទាំងនេះបានស្នើថា ផលប៉ះពាល់វិជ្ជមានអាចសំរេចបានតែនៅក្នុងតំបន់ ដែលមានលទ្ធភាពច្រើនក្នុងការចំណេញជាងតំបន់មានលទ្ធភាពតិចក្នុងការចំណេញ ។ ការវិភាគទិន្នន័យនៃគំរោង BSP អាចជួយឱ្យអ្នករៀបចំផែនការប្រើប្រាស់អោយកាន់តែល្អ នូវធនធានកំរនៅពេលអនាគត នៅក្នុងទិសដៅទៅរកទីតាំងវិជ្ជមាន ។ នៅក្នុងករណីបែបនេះ អត្តសញ្ញាណនៃកត្តា និងលក្ខខណ្ឌជោគជ័យ អាចធ្វើឱ្យអ្នករៀបចំគំរោង និងអ្នកផ្តល់ជំនួយអភិវឌ្ឍគោលការណ៍ណែនាំកាន់តែជាក់លាក់ ដែលអាចជាយោបល់ដល់មន្ត្រីថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត សំរាប់ជានីតិវិធីក្នុងការជ្រើសរើសទីតាំងនាពេលអនាគត ។

ការកត់សំគាល់នេះ ក៏ជាការគូសចំណាំផងដែរ នូវសក្តានុពលសំរាប់ការទទួលបានចំណេញជាវិជ្ជមានកើតឡើងពីវិធីសាស្ត្រសមាហរណកម្ម ជាមួយនឹងតួអង្គអភិវឌ្ឍផ្សេងទៀតពាក់ព័ន្ធនឹងការធ្វើផែនការ និងការអនុវត្តគំរោង LMAP ។ ជាឧទាហរណ៍ ផលចំណេញពីការចុះបញ្ជីដីធ្លី អាចនឹងល្អប្រសើរនៅក្នុងតំបន់ដែលមានការអភិវឌ្ឍន៍នាពេលថ្មីៗនេះ ឬក៏កំពុងមានផែនការ ។ ធាតុចូលទាំងនោះមាន សេវាកម្មបច្ចេកទេស សេវាកម្មផ្អែកសង្គមកិច្ច ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ ដូចជាផ្លូវថ្នល់ជាដើម ។

ប័ណ្ណកម្មសិទ្ធិដីធ្លីក៏ជាសក្តានុពលមានសារៈសំខាន់ ក្នុងការជួយអន្តរាគមន៍លើការកាត់បន្ថយភាពក្រីក្រនៅជនបទ ដែលនៅទីនោះ ភាពគ្មានដី និងជិតគ្មានដី បង្ហាញឱ្យឃើញថាវាមានចំណងទាក់ទងយ៉ាងជិតស្និតទៅនឹងភាពក្រីក្រ និងអសុវត្ថិភាពលើម្ហូបអាហារ ។ បញ្ហានេះ កើតឡើងយ៉ាងពិតប្រាកដទៅលើអ្នកដែលងាយរងគ្រោះ ដូចជាស្ត្រីមេម៉ាយជាមេគ្រួសារជាដើម ។ ក្នុងករណីជាច្រើន ភាពគ្មានដី និងភាពជិតគ្មានដី គឺដោយសារបញ្ហាជំងឺ និងលទ្ធផលនៃភាពក្រីក្រ ។ ទាំងអស់នេះ វាបង្ហាញនូវភាពច្បាស់លាស់បំផុតថា មានគ្រួសារជាច្រើន លក់ដីរបស់គេដើម្បីចំណាយទៅលើការថែទាំសុខភាព ។ រឿងនេះស្នើថា ផលចំណេញជាវិជ្ជមានពីការចុះបញ្ជីដីធ្លី អាចទទួលបាននៅក្នុងស្ថានភាព ដែលសេវាកម្មថែទាំសុខភាព មានតំលៃថោកសមរម្យសំរាប់ប្រជាពលរដ្ឋទូទៅ ។ នៅក្នុងករណីអវត្តមានការប្រើប្រាស់បាន និងប្រសិទ្ធភាពនៃសេវាកម្មសុខភាព និងសេវាកម្មផ្អែកសង្គមកិច្ចផ្សេងទៀតសំរាប់ប្រជាពលរដ្ឋ ប័ណ្ណកម្មសិទ្ធដីធ្លីមិនអាចមានប្រសិទ្ធភាពគួរឱ្យចង់បាន ដើម្បីការកាត់បន្ថយភាពក្រីក្រពាក់ព័ន្ធនឹងភាពគ្មានដីបានទេ ។

ការរួមចំណែកនៃប័ណ្ណកម្មសិទ្ធិដីធ្លីលើការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅជនបទ អាចមានផលល្អ ដោយធ្វើការកំណត់គោលដៅនៃការចុះបញ្ជីដីធ្លីនៅក្នុងតំបន់ដែលគំរោងរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកវិនិយោគឯកជនមានសកម្មភាពនៅតំបន់នោះ ។ នៅក្នុងករណីនេះ ផលចំណេញសំរាប់គ្រួសារចាញ់ប្រៀប និងគ្រួសារងាយរងគ្រោះ អាចធ្វើការលើកកំពស់ ដោយកំនត់គោលដៅជាក់លាក់ថែមទៀតនៅក្នុងតំបន់ដែលសេវាសង្គមកិច្ច និងធនធាន

សំរាប់អភិវឌ្ឍត្រូវបានផ្តោតទៅលើអ្នកក្រីក្រ ។ នេះគឺជាការព្រួយបារម្ភពិសេសសំរាប់គ្រួសារដែលរស់នៅក្នុងភាពងាយនឹងបាត់បង់ដី ។

ផលចំណេញសំរាប់គ្រួសារចាញ់ប្រៀប ក៏អាចកើនឡើងផងដែរដោយការរៀបចំគោលនយោបាយជាក់លាក់ ដែលផ្សារភ្ជាប់ការចុះបញ្ជីដីធ្លីទៅនឹងការកាត់បន្ថយភាពក្រីក្រសំរាប់គោលដៅនៃការអភិវឌ្ឍន៍ ។ គោលនយោបាយមានសក្តានុពលចំនួន ២ គឺជាការផ្តល់ឥណទាន និងហិរញ្ញវត្ថុសាធារណៈ ។ ឧទាហរណ៍ គោលនយោបាយ និងការអនុវត្តន៍ណាដែលធ្វើឱ្យមានចីរភាពនូវអត្រាការប្រាក់ខ្ពស់នៅក្នុងស្ថាប័នផ្លូវការ នឹងធ្វើឱ្យអន្តរាយដល់សក្តានុពលនៃការទទួលផលចំណេញពីប័ណ្ណកម្មសិទ្ធិដីធ្លី ព្រោះវាបានបំបាក់ទឹកចិត្តប្រជាពលរដ្ឋក្នុងការទៅរកឥណទាន ។ នៅក្នុងករណីនេះ គឺធ្វើយ៉ាងណាឱ្យគោលបំណងនៃគោលនយោបាយសំដៅទៅរកការកាត់បន្ថយអត្រាការប្រាក់ ដែលជាការអាចធ្វើឱ្យប្រសើរឡើង ចំពោះការប្រើប្រាស់ឥណទាននៅក្នុងចំណោមគ្រួសារតូចៗ ។ នៅពេលជាមួយគ្នា ការទុកដីចោលឱ្យនៅទំនេរដោយមិនបានយកពន្ធ គឺជាការលើកទឹកចិត្តឱ្យមានការប្រមូលទិញដីទុក និងបង្កជាវិវាទ ក៏ដូចជាការបង្អាក់ការប្រើប្រាស់ដីមានលក្ខណៈពហុវប្បកម្ម និងអត្រានៃការប្រើប្រាស់ខ្ពស់ ។ ការយកពន្ធលើដីមិនបានប្រើប្រាស់ នៅក្នុងតំលៃជាក់ស្តែងមួយអាចកាត់បន្ថយបាននូវការប្រមូលទិញដីទុក ហើយបង្កើតនូវអត្រានៃការប្រើប្រាស់ខ្ពស់ក៏ដូចជា ផ្តល់នូវចំណូលសំរាប់រដ្ឋាភិបាល ។

# ឯកសារយោង


***Cambodia***

Biddulph, Robin (2000a); Interim Report on Findings of Landlessness and Development Information Tool (LADIT), Oxfam GB: Phnom Penh.

Biddulph, Robin (2000b); “Landlessness: A Growing Problem,” Cambodia Development Review, September 2000, CDRI: Phnom Penh.

Biddulph, Robin (2004); Poverty and Social Impact Assessment of Social Land Concessions in Cambodia: Landlessness Assessment, January, Oxfam GB: Phnom Penh.

Boreak, Sik (2000); Land Ownership, Sales and Concentration in Cambodia, Working Paper No. 16, Cambodia Development Resource Institute: Phnom Penh.

Kang Chandararot and Chan Sophal (2003); Cambodia’s Annual Economic Review, Cambodia Development Resource Institute: Phnom Penh.

Sedara, Kim, Chan Sophal, and Sarthi Acharya (2002); “Land, Rural Livelihoods and Food Security in Cambodia: A Perspective from Field Reconnaissance,” Working Paper No. 24, Cambodia Development Resource Institute: Phnom Penh.

So Savannarith, Real Sopheap, Uch Utey, Sy Rathmony, Brett Ballard, and Sarthi Acharya (2001); “Social Assessment of Land in Cambodia,” Working Paper No. 20, Cambodia Development Resource Institute: Phnom Penh.

Sophal, Chan and Sarthi Acharya (2001); “An Assessment of Land Tenure in Rural Cambodia,” Cambodia Development Review, October – December 2001, CDRI: Phnom Penh.

Sophal, Chan, Tep Saravy, and Sarthi Acharya (2001); “Land Tenure in Cambodia: A Data Update,“ Working Paper No. 19, Cambodia Development Resource Institute: Phnom Penh.

Sophal, Chan and Sarthi Acharya (2002a); “Land Transactions in Cambodia: An Analysis of Transfers and Transaction Records,” Working Paper No. 22, Cambodia Development Resource Institute: Phnom Penh.

Sophal, Chan and Sarthi Acharya (2002b); “Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia,” Working Paper No. 25, Cambodia Development Resource Institute: Phnom Penh.

Sophal, Chan, Kim Sedara, and Sarthi Acharya (2003); “Enhancing Rural Livelihoods,” Cambodia Development Review, January-March 2003.

Van Acker, Frank (1999); “Land Tenure: Hitting a Stone with an Egg?” Cambodia Development Review, September 1999, CDRI: Phnom Penh.

***Other Documents***

Asian Development Bank (2003); Cambodia: Sectoral Policy Implementation Assessment.

World Bank (2002): Project Appraisal Document for A Land Management and Administration Project.

***Land and Property Rights and Governance***

Alchian, Armen and Harold Demsetz, 1973; “The Property Rights Paradigm,” *The Journal of Economic History*, 33(1): 27.

Ballard, Brett (2003); “*Refugee Reintegration in Rural Areas: Land Distribution in Ban Pha Thao, Lao PDR*, “ Working Paper No. 18, The Inter-University Committee on International Migration: Cambridge, MA.

Barzel, Yoram (1989); *Economic Analysis of Property Rights*, Cambridge Press.

Brandao, A S P and Gershon Feder (1996); "Regulatory Policies and Reform: The Case of Land Markets," PSD Occasional Paper No. 15, The World Bank, Washington, DC, January.

Libecap, Gary (1989); *Contracting for Property Rights*, New York: Cambridge University Press.

Munro-Faure, Paul (2001); "*Regularization of Property Rights and Rural Development: Challenges for Latin America," Food and Agriculture Organization*," http://www.for.nta.gob.nx/ponencias/Faure.PDF

North, Douglas (1990); *Institutions, Institutional Change, and Economic Performance*, Cambridge: Cambridge University Press.

Ou Vuddy et al (2002); "Case Study 1 on Evaluation on Land Use and Housing Conditions and Recommendations on Land Use Planning at Sangkhat 2 and Sangkhat 4, Mittapheap, Sihanoukville," General Department of Land Management and Urban Planning, MLMUPC: Phnom Penh.

Payne, Geoffrey (2000), "Urban Land Tenure Policy Options: Titles or Rights?" Paper presented at the World Bank Urban Forum, Virginia.

Tongroj Ochan and Saroj Aungsumalin, (2002); "*Socio-Economic and Environmental Impact of the Land Titling Program*," Centre for Applied Economics Research, Kasetsart University: Thailand

# កំរងសំណួរអំពីការផ្តល់ប័ណ្ណកម្មសិទ្ធិ ការចុះបញ្ជីដីធ្លី និងជីវភាពរស់នៅរបស់ប្រជាជន

លេខកូដអ្នកសំភាសន៏: ............................ លេខរៀងបញ្ជីសំណួរ: ..........................................

សំភាសន៏ចាប់ពីម៉ោង: ................................................ ចប់នៅម៉ោង:....................................................

**ទីតាំងភូមិសាស្ត្រ**

| | |
|---|---|
| ខេត្ត .................................................... | ចំងាយពីផ្ទះទៅ |
| ស្រុក .................................................... | ខេត្ត .................................................... (គ.ម) |
| ឃុំ .................................................... | ស្រុក .................................................... (គ.ម) |
| ភូមិ .................................................... | ឃុំ ........................................................ (គ.ម) |

**<u>កំណត់ត្រាស្តីពីការអង្កេត</u>**

ឈ្មោះអ្នកឆ្លើយសំភាសន៏:............................................ អាយុ:................ភេទ: 1 = ប្រុស 2 = ស្រី

មេគ្រួសារ ឬមិនមែន? 1 = មែន 2 = មិនមែន

ឬត្រូវដូចម្តេចនឹងមេគ្រួសារ? ..........................................................................

ឈ្មោះអ្នកសំភាសន៏:................................................ សំភាសន៏នៅថ្ងៃទី: ................../.................. 2004

ហត្ថលេខាអ្នកសំភាសន៏ក្រោយពីបានពិនិត្យឡើងវិញដោយខ្លួនឯង: .............................................................

កំណត់សំគាល់របស់អ្នកសំភាសន៏ (ក្រោយពេលសំភាសន៏ តើអ្នកមានទស្សនៈយ៉ាងណាចំពោះដំណើរការសំភាសន៏?)

1 = ល្អគួរិតខ្ពស់ 2 = ល្អគួរិតមធ្យម 3 = មធ្យម 4 = ខ្សោយ

**កំណត់ត្រាស្តីពីការត្រួតពិនិត្យគុណភាព**

ឈ្មោះប្រធានក្រុមអង្កេត: ..................................................

ហត្ថលេខាក្រោយពេលពិនិត្យគ្រប់សំណួរហើយ:...........................បានពិនិត្យនៅថ្ងៃទី:.........../........... 2004

កំណត់សំគាល់របស់ប្រធានក្រុម:

......................................................................................................................................................

សំណួរដែលត្រូវប្រធានក្រុមឱ្យទៅសំភាសន៏ម្តងទៀត:

......................................................................................................................................................

**ការត្រួតពិនិត្យដោយអ្នកស្រាវជ្រាវ CDRI (Supervision by CDRI Researcher)**

ឈ្មោះអ្នកស្រាវជ្រាវត្រួតពិនិត្យអង្កេត (CDRI Researcher checking the questionnaire): .............................

បានពិនិត្យនៅថ្ងៃទី .............../.............. 2004

សំណួរដែលបានបំភ្លឺ (Questions that were clarified): ..............................................................................

សំណួរដែលត្រូវទៅសំភាសន៍ម្តងទៀត (Questions that need call back): .......................................................

**កំណត់ត្រាស្តីពីការពិនិត្យនៅ CDRI មុនការបញ្ចូលទិន្នន័យ**

ឈ្មោះអ្នកត្រួតពិនិត្យ .............................. ហត្ថលេខា ..................... កាលបរិច្ឆេទ ........../......... 2004

កំណត់សំគាល់របស់អ្នកពិនិត្យនៅ CDRI/សំណួរដែលមានបញ្ហា ............................................................

អ្នកបញ្ចូលទិន្នន័យ ................................. ហត្ថលេខា ..................... កាលបរិច្ឆេទ .........../......... 2004

## I. ប្រជាសាស្ត្រគ្រួសារ និងមុខរបរបុគ្គលនីមួយៗ

1.1. តើបច្ចុប្បន្នគ្រួសារអ្នកមានមនុស្សចំនួនប៉ុន្មាននាក់ (ទាំងក្មេង ទាំងចាស់)? ..............................................

1.2.1. ឈ្មោះមេគ្រួសារពេញ: ............................................ (មេគ្រួសារ គឺជាអ្នកជំហរជាបង្គោលក្នុងគ្រួសារ)

1.2.2. ភេទនៃមេគ្រួសារ : 1 = ប្រុស 2 = ស្រី

1.2.3. តើផ្ទះសំបែងនេះមានទីតាំងដូចម្តេច?

1. នៅលើចិញ្ចើមផ្លូវជាតិ ឬផ្លូវចាក់កៅស៊ូ
2. នៅជាប់ផ្លូវជាតិ ឬផ្លូវចាក់កៅស៊ូ
3. នៅលើចិញ្ចើមផ្លូវលំ (ដី ឬគ្រួសក្រហម)
4. នៅជាប់ផ្លូវលំ (ដី ឬគ្រួសក្រហម)
5. នៅឆ្ងាយពីផ្លូវ

## ព័ត៌មានលំអិតស្តីពីសមាជិកគ្រួសារដែលមានអាយុចាប់ពី ៧ឆ្នាំឡើងទៅ *(សូមចុះលេខ 0 បើគ្មានព័ត៌មាន)*

| ល.រ | ឈ្មោះ (យកតែនាមខ្លួន) | ទំនាក់ទំនងជាមួយមេគ្រួសារ | ភេទ 1=ប្រុស 2=ស្រី | អាយុ | ស្ថានភាពអាពាហ៍ពិពាហ៍ | ចំនួនឆ្នាំបានសិក្សា | សកម្មភាពសេដ្ឋកិច្ច? | ការដាំដុះលក្ខណៈគ្រួសារ (ស្រូវ, ចំការ, កសិកម្មផ្សេងៗ របស់គ្រួសារ) ចូលវស្សាមក (៦ខែ) | | ការចិញ្ចឹមសត្វ (គោ ជ្រូក មាន់ទា,......) រដូវភ្លៀងឆ្នាំមុន | មុខរបរក្រៅពីស្រែចំការក្នុងគ្រួសារដែលទទួលកំរៃបានជាប្រាក់ខែ, ប្រាក់ថ្ងៃ ឬប្រាក់ចំណូលផ្សេងៗ<br>លេខកូដ: 1 = ការងារកសិកម្មក្នុងភូមិ 2 = ពលករក្នុងភូមិ (ក្នុងកម្ពុជា) 3 = ទៅថ្ងៃ 4 = លក់ដូរតូចតាច 5 = ឡើងត្នោត 6 = នេសាទ 7 = ប្រមូលធនធានផ្សេងៗពីទឹក ឬទីវាល 8 = ប្រមូលធនធានផ្សេងពីព្រៃឈើ ៩ = រត់ម៉ូតូឌុប. ១០ = ផ្សេងទៀត .......................... (ឧ. ការងាររាជការ ។ល។)<br>**(សំណួរនេះត្រូវសួរក្នុងរដូវភ្លៀងឆ្នាំមុន រយៈពេល៦ខែ, ឯកតាគិតជាម៉ឺនរៀល)**<br>កត់ចូល N/A ប្រសិនបើគ្មានចម្លើយសំរាប់សំណួរនីមួយៗខាងក្រោម | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | ការងាររកកំរៃទី១ | | | | ការងាររកកំរៃទី២ | | | |
| | | (លេខកូដខាងក្រោម) | | | (លេខកូដខាងក្រោម) | (សំរាប់កំរិតឧត្តមសិក្សាលេខកូដ 99) | (លេខកូដខាងក្រោម) | ជាមធ្យមធ្វើការប៉ុន្មានម៉ោង/ថ្ងៃ? | ជាមធ្យមធ្វើការប៉ុន្មានខែ/ឆ្នាំ? | ជាមធ្យមធ្វើការប៉ុន្មានម៉ោង/ថ្ងៃ? | ធ្វើអ្វី ? (លេខកូដខាងលើ) | ជាមធ្យមធ្វើការប៉ុន្មានម៉ោង/ថ្ងៃ? | ទទួលបានកំរៃប៉ុន្មាន/ថ្ងៃ (ជារៀល) | ចាប់ដើមរដូវភ្លៀងឆ្នាំមុនមកទទួលបានកំរៃប៉ុន្មានពីការងារនេះ? (ជាម៉ឺនរៀល) | ធ្វើអ្វី? (លេខកូដខាងលើ) | ជាមធ្យមធ្វើការប៉ុន្មានម៉ោង/ថ្ងៃ | ទទួលបាន កំរៃប៉ុន្មាន/ថ្ងៃ (ជារៀល) | ចាប់ពីដើមរដូវភ្លៀងឆ្នាំមុនមកទទួលបានកំរៃប៉ុន្មានពីការងារនេះ? (ជាម៉ឺនរៀល) |
| 1.3 | 1.4 | 1.5 | 1.6 | 1.7 | 1.8 | 1.9 | 1.10 | 1.11 | 1.12 | 1.13 | 1.14 | 1.15 | 1.16 | 1.17 | 1.18 | 1.19 | 1.20 | 1.21 |
| 01 | | | | | | | | | | | | | | ................* | | | | ................* |
| 02 | | | | | | | | | | | | | | ................* | | | | ................* |
| 03 | | | | | | | | | | | | | | ................* | | | | ................* |
| 04 | | | | | | | | | | | | | | ................* | | | | ................* |
| 05 | | | | | | | | | | | | | | ................* | | | | ................* |
| 06 | | | | | | | | | | | | | | ................* | | | | ................* |
| 07 | | | | | | | | | | | | | | ................* | | | | ................* |
| 08 | | | | | | | | | | | | | | ................* | | | | ................* |
| 09 | | | | | | | | | | | | | | ................* | | | | ................* |
| 10 | | | | | | | | | | | | | | ................* | | | | ................* |
| 11 | | | | | | | | | | | | | | ................* | | | | ................* |
| 12 | | | | | | | | | | | | | | ................* | | | | ................* |
| 13 | | | | | | | | | | | | | | ................* | | | | ................* |
| 14 | | | | | | | | | | | | | | ................* | | | | ................* |

***ឯកតាគិតជាម៉ឺនរៀល ឬ ១០.០០០៛**

**លេខកូដ:**

សំរាប់សំណួរ 1.5: 1 = មេគ្រួសារ 2 = ប្តី ឬប្រពន្ធ 3 = បងប្អូនថ្លៃ 4 = កូនប្រុស/ស្រី 5 = កូនប្រសារ 6 = ចៅ 7 = កូនដើម/កូនចិញ្ចឹម 8 = ឪពុក/ម្តាយ 9 = ជីតា/ជីដូន 10=ក្មួយ 11 = បងប្អូនដទៃទៀត

សំរាប់សំណួរ 1.8: 1 = រៀបការ 2 = នៅលីវ 3 = លែងលះ 4 = មេម៉ាយ/ ពោះម៉ាយ 5 = គ្រួសារចាកចោល

សំរាប់សំណួរ 1.10: 1 = ប្រកបការងារបាន 2 = សិស្សផង ធ្វើការងារផង 3 = សិស្សមិនធ្វើការងារអ្វីឡើយ 4 = ពិការធ្វើការមិនកើត 5 = ជរាធ្វើការមិនកើត 6 = ក្មេងពេកធ្វើការមិនកើត (ទាល់តែចុះលេខកូដ 1 ឬ2 ហើយទើបអាចសួរបន្តទៀតនៅក្នុងតារាង)

## II. ស្ថានភាពផ្ទះ ឥវ៉ាន់ប្រើប្រាស់ធម្មតាក្នុងផ្ទះ និងទ្រព្យប្រើយូរឆ្នាំ

2.1. ស្ថានភាពផ្ទះសំបែង?

| ជំបូល | ជញ្ជាំង | កំរាល | របង |
|---|---|---|---|
| 1. ផ្ទះស្លឹក | 1. ស្លឹក | 1. ដី | 1. គ្មាន |
| 2. ប្រក់ស័ង្កសី | 2. ស័ង្កសី | 2. ឈើ, រនាបឫស្សី | 2. មែកឈើ |
| 3. ប្រក់ក្បឿង | 3. ឈើ | 3. ថ្ម/ឥដ្ឋ | 3. កូនឈើ ឫស្សី |
| 4. ផ្ទះថ្ម/ឥដ្ឋ | 4. ផ្ទះថ្ម/ឥដ្ឋ | 4. ផ្សេងទៀត........ | 4. ឈើធំៗ |
| 5. ផ្សេងទៀត................. | 5. ផ្សេងទៀត.............. | 5. ផ្សេងទៀត......... | 5. លួសបន្លា |
| | | | 6. ថ្ម |
| | | | 7. ផ្សេងទៀត............. |

2.2. តើអ្នករស់នៅទីនេះប៉ុន្មានឆ្នាំហើយ?......................................................

2.2. តើផ្ទះអ្នកមានទំហំប៉ុន្មានម៉ែត្រការ៉េ?

ទទឹង .................. ម៉ែត្រ X បណ្ដោយ ................. ម៉ែត្រ = ......................... ម៉ែត្រការ៉េ

2.3. បើគិតក្នុងតំលៃបច្ចុប្បន្ន តើផ្ទះនេះមានតំលៃប្រហែលប៉ុន្មាន?

1. ...........................លានរៀល, ឬ 2. ......................តម្លឹងមាស, ឬ 3. ......................ដុល្លារអាមេរិក

2.4. តើអ្នកមានបានជួសជុល ឬពង្រីកបន្ថែមផ្ទះអ្នកទេចាប់តាំងពីការបោះឆ្នោតឃុំសង្កាត់មក (តាំងពីបីឆ្នាំមុន)?

1. បើមាន (ឆ្លើយសំណួរលេខ 2.5)

2. បើគ្មាន (រំលងសំណួរលេខ 2.5)

2.5. ក).តើអ្នកចំណាយប្រាក់អស់ប៉ុន្មាន? ............................................ នៅឆ្នាំណា? ............................

ខ).ចេញពីប្រភពចំណូលណា:

1. ផ្ទាល់ខ្លួន (សន្សំ និងចំណូលផ្ទាល់ខ្លួន)
2. ទទួលពីបងប្អូននៅក្រៅស្រុក ឬពីទីក្រុងនៅកម្ពុជា
3. លក់ផលិតផលកសិផល
4. កម្ចី/ចងការ
5. ផ្សេងទៀត (បញ្ជាក់) ..............................................

2.6. ប្រភពទឹកហូបសំខាន់របស់គ្រួសារអ្នក?

1. បំពង់ទឹកតមកក្នុងផ្ទះ
2. មានស្នប់ដៃ/អណ្ដូងខួង
3. អណ្ដូងជីក
4. ព្រែក/ស្ទឹង/បឹងបួរ
5. ទន្លេ (ធំៗ)
6. ផ្សេងទៀត (បញ្ជាក់) ....................................

2.7. ជាទូទៅ តើគ្រួសារអ្នកបរិភោគទឹកដាំឆ្អិន ឬទឹកឆៅ?

1. ទឹកឆៅ
2. ទឹកដាំឆ្អិន

2.8. តើអ្នកមានបង្គន់ឬទេ?

1. មាន ក្នុងផ្ទះ.................... ក្រៅផ្ទះ............................
2. គ្មាន

2.9. តើអ្នកដុតអ្វីដើម្បីចំអិនបាយ ទឹក និងម្ហូបអាហារ?

1. អុសរកខ្លួនឯង
2. អុសទិញគេ
3. ធ្យូង
4. អគ្គិសនី, ហ្គាស
5. ផ្សេងទៀត (បញ្ជាក់) : ...............................

ទ្រព្យសម្បត្តិផ្សេងៗក្រៅពីដីធ្លីរបស់គ្រួសារ (សូមគណនាពីមាស ឬដុល្លារមកជារៀល)

| | ចំនួន | តំលៃបច្ចុប្បន្ន (ឧ. បើលក់ចេញវិញ) *(ឯកតាជាម៉ឺន)* |
|---|---|---|
| 2.10. ម៉ូតូ | | ......................................................ម៉ឺនរៀល |
| 2.11. កង់ជិះ | | ......................................................ម៉ឺនរៀល |
| 2.12. ទូរទស្សន៍ | | ......................................................ម៉ឺនរៀល |
| 2.13. ម៉ាញ៉េ | | ......................................................ម៉ឺនរៀល |
| 2.14. វិទ្យុ | | ......................................................ម៉ឺនរៀល |
| 2.15. ម៉ាស៊ីនដេរ | | ......................................................ម៉ឺនរៀល |
| 2.16. ទូក (គិតទាំងថ្លៃម៉ាស៊ីន បើសិនទូកមានម៉ាស៊ីន) | | ......................................................ម៉ឺនរៀល |
| 2.17. រ៉ឺម៉ក | | ......................................................ម៉ឺនរៀល |
| 2.18. ម៉ាស៊ីនភ្លើង | | ......................................................ម៉ឺនរៀល |
| 2.19. ម៉ាស៊ីនបូមទឹក | | ......................................................ម៉ឺនរៀល |
| 2.20. ម៉ាស៊ីនបោកស្រូវ | | ......................................................ម៉ឺនរៀល |
| 2.21. ម៉ាស៊ីនកិនស្រូវ | | ......................................................ម៉ឺនរៀល |
| 2.22. រទេះ (រទេះគោបុរាណ ឬរទេះមានកង់ឡាន) | | ......................................................ម៉ឺនរៀល |
| 2.23. រទេះសេះ | | ......................................................ម៉ឺនរៀល |
| 2.24. នង្គ័ល និងរនាស់ | | ......................................................ម៉ឺនរៀល |
| 2.25. គោយន្ត | | ......................................................ម៉ឺនរៀល |
| 2.26. យានយន្ត | | ......................................................ម៉ឺនរៀល |
| 2.27. ទ្រព្យសម្បត្តិធំៗផ្សេងទៀត (បញ្ជាក់) .................... | | ......................................................ម៉ឺនរៀល |
| 2.28. ទ្រព្យសម្បត្តិធំៗផ្សេងទៀត (បញ្ជាក់).................... | | ......................................................ម៉ឺនរៀល |

**អំពីសត្វចិញ្ចឹមដែលអ្នកមានក្នុងពេលឥឡូវនេះ**

| សត្វដែលអ្នកមាន (គិតចូលសត្វប្រវាស់ឱ្យគេចិញ្ចឹម តែមិនគិតចូលសត្វប្រវាស់ពីគេយកមកចិញ្ចឹម) | ចំនួន | តំលៃសរុប (បើលក់ឥឡូវនេះ) |
|---|---|---|
| 2.29. គោ | | ............................................មុឺនរៀល |
| 2.30. ក្របី | | ............................................មុឺនរៀល |
| 2.31. ជ្រូក | | ............................................មុឺនរៀល |
| 2.32. សេះ | | ............................................មុឺនរៀល |
| 2.33. មាន់ (ដែលមានទំងន់អាចលក់បាន) | | ............................................មុឺនរៀល |
| 2.34. ទា (ដែលមានទំងន់អាចលក់បាន) | | ............................................មុឺនរៀល |
| 2.35. ផ្សេងទៀត (បញ្ជាក់) ............................................ | | ............................................មុឺនរៀល |
| 2.36. ផ្សេងទៀត (បញ្ជាក់) ............................................ | | ............................................មុឺនរៀល |

## III. ទ្រព្យសម្បត្តិជាដីធ្លី និងការលក់ដីធ្លី

### អំពីដីលំនៅដ្ឋាន:

3.1. តើអ្នកជាម្ចាស់លើដីដែលអ្នកកំពុងស្នាក់នៅសព្វថ្ងៃនេះមែនឬទេ (ដីឡូត៍លំនៅដ្ឋាន)?

1. ជាម្ចាស់មែន (បន្តទៅ 3.3)
2. មិនមែនទេ (ឆ្លងទៅសំណួរ 3.9)

3.2. តើអ្នកមានដីលំនៅដ្ឋានដែរឬទេ?

1. មានប៉ុន្មានកន្លែង? (ដោយរួមទាំងដីទិញបានទាំងឡាយ)............................
2. មិនមាន (សូមរំលងទៅ 3.9)

| | កន្លែងទី 1 | កន្លែងទី 2 | កន្លែងទី 3 | កន្លែងទី 4 |
|---|---|---|---|---|
| 3.3. ទំហំដីឡូត៍លំនៅដ្ឋាន? (គិតឱ្យចេញជាម៉ែត្រការ៉េ) | | | | |
| 3.4. បើសិនអ្នកលក់វាឥឡូវនេះ តើបានថ្លៃប៉ុន្មាន? គិតឱ្យចេញជាតម្លឹងមាស (*កុំតាមតែគាត់ថាទាំងស្រុងពេក*) | | | | |
| 3.5. តើអ្នកបានវាពីឆ្នាំណា? | | | | |
| 1. មុនឆ្នាំ១៩៧៩ | 1 | 1 | 1 | 1 |
| 2. ក្នុងចន្លោះពេលពីឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៣ ក្នុងសម័យ UNTAC | 2 | 2 | 2 | 2 |
| 3. ក្រោយពេលបោះឆ្នោតសម័យ UNTAC ឆ្នាំ១៩៩៣ | 3 | 3 | 3 | 3 |
| 3.6. តើអ្នកបានដីឡូត៍លំនៅដ្ឋាននេះតាមរបៀបណា? | | | | |
| 1. រដ្ឋផ្តល់ឱ្យ (ឬរដ្ឋអំណាចមូលដ្ឋាន) | 1 | 1 | 1 | 1 |
| 2. ទទួលមរតក ឬសាច់ញាតិផ្តល់ឱ្យ (ឪពុកម្តាយ, បង, ប្អូន) | 2 | 2 | 2 | 2 |
| 3. មិត្តភក្តិផ្តល់ឱ្យ | 3 | 3 | 3 | 3 |
| 4. ទិញដោយខ្លួនឯង | 4 | 4 | 4 | 4 |
| 5. ដីរានបាន ឬដីកាន់កាប់ដោយសេរី | 5 | 5 | 5 | 5 |
| 6. ផ្សេងទៀត (បញ្ជាក់) .................................................... | 6 | 6 | 6 | 6 |

| | | | | |
|---|---|---|---|---|
| **3.7.** តើអ្នកមានលិខិតស្នាមអ្វីទេសំរាប់បញ្ជាក់ពីកម្មសិទ្ធិរបស់អ្នកនៅលើដីឡូត៍នេះ? | | | | |
| 1. បង្កាន់ដៃទទួលពាក្យសុំកាន់កាប់អចលនវត្ថុ | 1 | 1 | 1 | 1 |
| 2. កំណត់ហេតុអង្កេតដី | 2 | 2 | 2 | 2 |
| 3. ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ | 3 | 3 | 3 | 3 |
| 4. គ្មានលិខិតសំគាល់កម្មសិទ្ធិនៅក្នុងផ្ទះទេ | 4 | 4 | 4 | 4 |
| 5. បាត់បង្កាន់ដៃទទួលពាក្យសុំកាន់កាប់អចលនវត្ថុ | 5 | 5 | 5 | 5 |
| (ចប់សំណួរនេះរំលងទៅសំណួរ 3.29) | | | | |
| **3.8** បើសិនអ្នកមិនបានចុះបញ្ជីដីអ្នកទេ តើមូលហេតុធំជាងគេមកពីអ្វី? | | | | |
| 1. គិតថាមិនចាំបាច់ | 1 | 1 | 1 | 1 |
| 2. ចៀសវាងការបង់ពន្ធ | 2 | 2 | 2 | 2 |
| 3. សោហ៊ុយបង់ក្រៅផ្លូវការអស់ច្រើនពេក | 3 | 3 | 3 | 3 |
| 4. មិនដឹងពីរបៀបរបបចុះបញ្ជី | 4 | 4 | 4 | 4 |
| 5. ដីមានជម្លោះ | 5 | 5 | 5 | 5 |
| 6. គ្មានជំនឿលើប័ណ្ណកម្មសិទ្ធិ | 6 | 6 | 6 | 6 |
| 7. ដំណើការរដ្ឋបាលស្មុគស្មាញពេក | 7 | 7 | 7 | 7 |
| 8. គ្មានយុត្តិធម៌ | 8 | 8 | 8 | 8 |
| 9. ផ្សេងទៀត (បញ្ជាក់)............................ | 9 | 9 | 9 | 9 |
| **3.9.** បើសិនក្នុងពេលនេះអ្នកគ្មានដីឡូត៍លំនៅដ្ឋានទេ តើដោយសារមូលហេតុអ្វី? | | | | |
| 1. លក់ដីឡូត៍លំនៅដ្ឋាន | 1 | 1 | 1 | 1 |
| 2. មិនដែលមានដីឡូត៍លំនៅដ្ឋាន | 2 | 2 | 2 | 2 |
| 3. បាត់បង់ដីឡូត៍លំនៅដ្ឋានដោយសារគេរំលោភយក | 3 | 3 | 3 | 3 |
| 4. បាត់បង់ដោយសារការភៀសខ្លួន (ទើបចូលមករស់នៅក្នុងភូមិ) | 4 | 4 | 4 | 4 |
| 5. ផ្សេងទៀត (បញ្ជាក់) .................................................... | 5 | 5 | 5 | 5 |
| **3.10.** តើអ្នកប្រើដីលំនៅដ្ឋានធ្វើអ្វីខ្លះទៀត? | | | | |
| 1. ទុកចោល | 1 | 1 | 1 | 1 |
| 2. ជួលឱ្យគេ | 2 | 2 | 2 | 2 |
| 3. ជួលផ្ទះឱ្យគេ | 3 | 3 | 3 | 3 |
| 4. ឱ្យបងប្អូនប្រើប្រាស់ដោយមិនយកថ្លៃ | 4 | 4 | 4 | 4 |

## ដីក្រៅពីដីលំនៅដ្ឋានដែលកាន់កាប់ ឬជួលពីគេ:

*(ក្នុងការសួរអំពីទំហំដី ទោះបីជាឯកតាអ្វីៗក៏ដោយ សូមគណនាឱ្យមកជាហិកតា)*

**3.10.** តើអ្នកមានដីសំរាប់កសិកម្មកាន់កាប់ ឬក៏ជួលពីគេឬទេ? 1. មាន 2. គ្មាន (ឆ្លងទៅសំណួរ 3.38)

**3.11.** តើមានដីប៉ុន្មានកន្លែង? ........................ កន្លែង

ទំហំផ្ទៃដីដែលជាកម្មសិទ្ធិរបស់គ្រួសារ (គិតទាំងដីទុកចំនេរចោល និងដីប្រវ៉ាស់ ឬជួលឱ្យគេធ្វើ)

3.12. ដីស្រែវស្សា ........................................................ហិកតា

3.13. ដីស្រែប្រាំង ........................................................ហិកតា

3.14. ដីចំការ ...............................................................ហិកតា

3.15. ដីទុកទំនេរចោល ..................................................ហិកតា

3.16. ដីចំរុះ ................................................................ហិកតា

3.17. ដីផ្សេងទៀត (បើមាន).........................................ហិកតា

3.18. ផ្ទៃដីសរុប ..........................................................ហិកតា

3.19. ផ្ទៃដីប្រវាស់ ឬជួលពីគេ .........................................ហិកតា

3.19. ផ្ទៃដីប្រវាស់ ឬជួលឱ្យគេ ........................................ហិកតា

3.20. ផ្ទៃដីដាំដុះបានលើសពី ១ដង ក្នុងមួយឆ្នាំ ....................................ហិកតា *(គិតទាំងប្រវាស់ ឬជួលពីគេ)*

**<u>ទិន្នន័យលំអិតស្តីពីដីកសិកម្មដែលជាកម្មសិទ្ធិរបស់គ្រួសារ</u>** (ទោះជានៅភូមិណាក៏ដោយ)

*(រាល់សំណួរក្នុងតារាងត្រូវផ្តោតលើដី ឬកន្លែងណាមួយច្បាស់លាស់ ។ ចុះលេខ ឬគូសរង្វង់លេខណាមួយ)*

| | កន្លែងទី 1 | កន្លែងទី 2 | កន្លែងទី 3 | កន្លែងទី 4 | កន្លែងទី 5 | កន្លែងទី 6 | កន្លែងទី 7 |
|---|---|---|---|---|---|---|---|
| 3.21. ផ្ទៃក្រឡា (សូមគិតមកជាហិកតា) | ........... | ........... | ........... | ........... | ........... | ........... | ........... |
| 3.22. តើដីនេះជាដីប្រភេទអ្វី? | | | | | | | |
| 1. ដីស្រែវស្សា | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ដីស្រែប្រាំង | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. ដីស្រែវស្សាផង ប្រាំងផង | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. ដីចំការ | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. ដីសំរាប់ដាំដើមឈើ | 5 | 5 | 5 | 5 | 5 | 5 | 5 |
| 6. ដីចំរុះ | 6 | 6 | 6 | 6 | 6 | 6 | 6 |
| 7. ទុកចោល | 7 | 7 | 7 | 7 | 7 | 7 | 7 |
| 3.23. តើដីនេះបច្ចុប្បន្នលក់បានថ្លៃប៉ុន្មាន? (គិតមកជាម៉ឺនរៀល) | ........... | ........... | ........... | ........... | ........... | ........... | ........... |
| 3.24. តើអ្នកបានដីនេះតាំងពីណា? (ឆ្នាំ) | ........... | ........... | ........... | ........... | ........... | ........... | ........... |
| 3.25. តើអ្នកបានដីនេះតាមរបៀបណា? | | | | | | | |
| 1. រដ្ឋផ្តល់ឱ្យ (ឬរដ្ឋអំណាចមូលដ្ឋាន) | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ទទួលមរតក ឬសាច់ញាតិផ្តល់ឱ្យ | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. ទិញ | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. ដីរានបាន ឬដីកាន់កាប់ដោយសេរី | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. មិត្តភក្តិផ្តល់ឱ្យ | 5 | 5 | 5 | 5 | 5 | 5 | 5 |
| | កន្លែងទី 1 | កន្លែងទី 2 | កន្លែងទី 3 | កន្លែងទី 4 | កន្លែងទី 5 | កន្លែងទី 6 | កន្លែងទី 7 |
| 3.26. បើអ្នកបានទិញវា តើទិញនៅឆ្នាំណា? | ........... | ........... | ........... | ........... | ........... | ........... | ........... |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **3.27.** តើអ្នកទិញវាថ្លៃប៉ុន្មាន? | ........... | ........... | ........... | ........... | ........... | ........... | ........... |
| **3.28.** តើអ្នកមានលិខិតអ្វីសំរាប់បញ្ជាក់ | | | | | | | |
| កម្មសិទ្ធិឬទេ? | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 1 = មាន (បំពេញ 3.29) | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 2 = មិនដែលមានលិខិត | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 3 = បាត់លិខិត (រំលង 3.31) | | | | | | | |
| **3.29.** តើអ្នកមានអ្វីសំរាប់បញ្ជាក់ពីកម្មសិទ្ធិដី | | | | | | | |
| របស់អ្នកនេះ? | | | | | | | |
| 1. បង្កាន់ដៃ | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. កំណត់ហេតុអង្កេតដី | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. ប្លង់រឹង | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. គ្មានលិខិតអ្វីទេ | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. ផ្សេងៗ | 5 | 5 | 5 | 5 | 5 | 5 | 5 |
| **3.30.** បើសិនអ្នកមិនបានចុះបញ្ជីដីអ្នកទេ | | | | | | | |
| តើ**មូលហេតុធំជាងគេ**មកពីអ្វី? | | | | | | | |
| 1. គិតថាមិនចាំបាច់ | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ចៀសវាងការបង់ពន្ធ | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. សោហ៊ុយបង់ក្រៅផ្លូវការអស់ច្រើនពេក | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. មិនដឹងពីរបៀបរបបចុះបញ្ជី | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. ដីមានជម្លោះ | 5 | 5 | 5 | 5 | 5 | 5 | 5 |
| 6. គ្មានជំនឿលើប័ណ្ណកម្មសិទ្ធិ | 6 | 6 | 6 | 6 | 6 | 6 | 6 |
| 7. ដំណើការរដ្ឋបាលស្មុគស្មាញពេក | 7 | 7 | 7 | 7 | 7 | 7 | 7 |
| 8. គ្មានយុត្តិធម៌ | 8 | 8 | 8 | 8 | 8 | 8 | 8 |
| 9. ផ្សេងទៀត (បញ្ជាក់)................. | 9 | 9 | 9 | 9 | 9 | 9 | 9 |
| **3.31.** តើអ្នកធ្វើអ្វីនៅលើដីនេះ? | | | | | | | |
| 1. ធ្វើការដាំដុះ | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ជួលឱ្យគេ | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. ទុកទំនេរចោល (បន្តទៅសំណួរ 3.35.) | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. ផ្សេងទៀត (បញ្ជាក់).................. | 4 | 4 | 4 | 4 | 4 | 4 | 4 |
| **3.32.** តើអ្នកដាំដុះអ្វីនៅលើដី? | | | | | | | |
| 1. ស្រូវ | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ដំណាំផ្សេងទៀត (ឧ. ឪឡឹក ល្ពៅ បន្លែ | 2 | 2 | 2 | 2 | 2 | 2 | 2 |
| ពោត សណ្តែក...) | | | | | | | |
| 3. ស្រូវ ហើយដាំដំណាំផ្សេងៗទៀត | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. ដើមឈើ/ដំណាំចំការរយៈពេលវែង | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. ផ្សេងទៀត (បញ្ជាក់)............ | 5 | 5 | 5 | 5 | 5 | 5 | 5 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **3.33.** តើអ្នកអាចដាំដុះបានប៉ុន្មានដង/ឆ្នាំ? | | | | | | | |
| 1. ស្រូវវស្សាមួយដង | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. ស្រូវប្រាំងមួយដង | 2 | 2 | 2 | 2 | 2 | 2 | 2 |
| 3. ស្រូវវស្សាមួយដង និងស្រូវប្រាំងមួយដង | 3 | 3 | 3 | 3 | 3 | 3 | 3 |
| 4. ស្រូវប្រាំងពីរដង | 4 | 4 | 4 | 4 | 4 | 4 | 4 |
| 5. ស្រូវវស្សាមួយដង និងដំណាំផ្សេងទៀត | 5 | 5 | 5 | 5 | 5 | 5 | 5 |
| 6. ស្រូវប្រាំងមួយដង និងដំណាំផ្សេងទៀត | 6 | 6 | 6 | 6 | 6 | 6 | 6 |
| 7. ដំណាំឈើហូបផ្លែប្រចាំឆ្នាំ | 7 | 7 | 7 | 7 | 7 | 7 | 7 |
| **3.34.** តើដីនេះមានប្រព័ន្ធស្រោចស្រពឬទេ? | | | | | | | |
| 1. មាន (បើមានបន្តទៅសំណួរ 3.36.) | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 2. គ្មាន (បើគ្មានបន្តទៅសំណួរ 3.38.) | 2 | 2 | 2 | 2 | 2 | 2 | 2 |

**3.35.** ហេតុអ្វីបានជាអ្នកទុកដីចោលទំនេរ?

1. ខ្វះកំលាំងពលកម្ម
2. មិនចំណេញ
3. បំលាស់ប្តូរទីតាំង
4. ខ្វះទុនវិនិយោគ
5. ផ្សេងទៀត ..............................

**3.36.** តើអ្នកស្រោចស្រពយ៉ាងដូចម្តេច? (អាចមានចម្លើយច្រើន)

1. ទំនប់ទឹក ប្រលាយ ឬព្រែកជីកដោយរដ្ឋាភិបាល/អង្គការ NGO
2. ការគ្រប់គ្រងទឹកជាក្រុម
3. អណ្តូងផ្ទាល់ខ្លួនម្នាក់ៗ
4. ផ្សេងទៀត (បញ្ជាក់).................................

**3.37.** បើសិនជាអ្នកគ្មានដីកសិកម្ម តើមកពីមូលហេតុអ្វី? (ជ្រើសលេខកូដឱ្យបានត្រឹមត្រូវ)

1. លក់
2. ឱ្យទៅកូនចៅអស់
3. មិនដែលមានដីធ្លី (ឧ. ចាប់តាំងពីរៀបការមក)
4. បាត់បង់ដីធ្លីដោយសារការផ្លាស់ទីតាំង (ទើបតែមកតាំងទីនៅក្នុងភូមិនេះ)
5. បាត់បង់ដីធ្លីដោយសារជម្លោះ
6. ផ្សេងទៀត (បញ្ជាក់) .................................

**3.38.** តើអ្នកមានលក់ដីឬទេ តាំងពីឆ្នាំ១៩៨៩ មក? (ឆ្នាំ១៩៨៩ គឺជាឆ្នាំសំខាន់នៃការកាន់កាប់ និងលក់ដីធ្លី។ សូមគូសរង្វង់លេខកូដឱ្យបានត្រឹមត្រូវ ។)

1. មាន 2. គ្មាន (បើគ្មាន សូមរំលងទៅសំណួរ 3.47.)

| **(សួរដីមួយកន្លែងម្តង)** | កន្លែងទី 1 | កន្លែងទី 2 | កន្លែងទី 3 | កន្លែងទី 4 |
|---|---|---|---|---|
| **3.39.** តើដីដែលអ្នកលក់មានទំហំប៉ុណ្ណា? (គិតជាហិកតា) | ............... | ............... | .............. | ............... |
| **3.40.** តើដីនេះជាដីប្រភេទអ្វី? | | | | |
| 1. ដីលំនៅដ្ឋាន | 1 | 1 | 1 | 1 |
| 2. ដីស្រែ | 2 | 2 | 2 | 2 |
| 3. ដីចំការ | 3 | 3 | 3 | 3 |
| 4. ដីដាំដើមឈើ | 4 | 4 | 4 | 4 |
| **3.41.** តើអ្នកលក់បានថ្លៃប៉ុន្មាន? (គិតជាម៉ឺនរៀល) | .............. | .............. | .............. | .............. |
| **3.42.** តើអ្នកលក់ពីឆ្នាំណា? | .............. | .............. | .............. | .............. |
| **3.43.** តើអ្នកកាត់ឈ្មោះការលក់យ៉ាងដូម្តេច? | | | | |
| 1. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ភូមិ | 1 | 1 | 1 | 1 |
| 2. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ឃុំ | 2 | 2 | 2 | 2 |
| 3. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ស្រុក | 3 | 3 | 3 | 3 |
| 4. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ខេត្ត | 4 | 4 | 4 | 4 |
| 5. ផ្ទេរឈ្មោះដោយធ្វើប័ណ្ណកម្មសិទ្ធិនៅក្រសួងនគរូបនីយកម្ម និងសំណង់ | 5 | 5 | 5 | 5 |
| 6. ផ្សេងទៀត (បញ្ជាក់) .................................. | 6 | 6 | 6 | 6 |
| **3.44.** តើអ្នកចំណាយអស់ប៉ុន្មានក្នុងការៈ | | | | |
| 1. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ភូមិ | ............... | ............... | ............... | ............... |
| 2. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ឃុំ | ............... | ............... | ............... | ............... |
| 3. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ស្រុក | ............... | ............... | ............... | ............... |
| 4. ផ្ទេរឈ្មោះដោយធ្វើបង្កាន់ដៃថ្នាក់ខេត្ត | ............... | ............... | ............... | ............... |
| 5. ផ្ទេរឈ្មោះដោយធ្វើប័ណ្ណកម្មសិទ្ធិនៅក្រសួងនគរូបនីយកម្ម និងសំណង់ | ............... | ............... | ............... | ............... |
| 6. ផ្សេងទៀត (បញ្ជាក់) .................................. | ............... | ............... | ............... | ............... |
| **3.45.** ហេតុអ្វីអ្នកលក់ដីនេះ? *(ជ្រើសយកមូលហេតុធំជាងគេមួយ)* | | | | |
| 1. ត្រូវការប្រាក់យកទៅធ្វើរបររកស៊ីផ្សេងទៀត | 1 | 1 | 1 | 1 |
| 2. បង់ថ្លៃព្យាបាលជំងឺ | 2 | 2 | 2 | 2 |
| 3. ត្រូវការប្រាក់ដោះស្រាយការហូបចុកប្រើប្រាស់ | 3 | 3 | 3 | 3 |
| 4. សងបំណុល | 4 | 4 | 4 | 4 |
| 5. សមាជិកគ្រួសារស្លាប់ (បុណ្យសព) | 5 | 5 | 5 | 5 |
| 6. ដីតូចពេកធ្វើការដាំដុះមិនបានចំណេញ | 6 | 6 | 6 | 6 |
| 7. ដើម្បីចាកចេញពីភូមិស្រុក | 7 | 7 | 7 | 7 |
| 8. ដើម្បីផ្លាស់ប្តូរមុខរបរ | 8 | 8 | 8 | 8 |
| 9. ដីគ្មានជីជាតិ | 9 | 9 | 9 | 9 |
| 10. គ្មានផលិតភាព | 10 | 10 | 10 | 10 |
| 11. ដីជំនន់ | 11 | 11 | 11 | 11 |
| 12. នៅឆ្ងាយពេក | 12 | 12 | 12 | 12 |
| 13. ផ្សេងទៀត (បញ្ជាក់) ............. | 13 | 13 | 13 | 13 |

**ទំនាស់ដីធ្លី:**

3.46. តើអ្នកដែលមានទំនាស់ដីធ្លីដែរឬទេ ចាប់តាំងពីមានការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់មក?

1. មាន
2. គ្មាន (ឆ្លងទៅផ្នែកទី IV ទីផ្សារឥណទាន)

3.47. តើទំនាស់កើតឡើងនៅពេលណា? ក្នុងឆ្នាំ ...........

3.48. តើទំនាស់កើតឡើងនៅលើដីប្រភេទណា?

1. ដីលំនៅដ្ឋាន
2. ដីកសិកម្ម

3.49. តើដីទំហំប៉ុន្មានដែលមានទំនាស់? ........................................... ហិកតា

3.50. តើដីមានទំនាស់យ៉ាងដូចម្ដេច? (អាចមានចម្លើយច្រើន)

1. រដ្ឋអំណាចរំលោភយក
2. ទាហាន/មន្ត្រីមានអាវុធរំលោភយក
3. ទំនាស់ព្រំដី
4. ទំនាស់កម្មសិទ្ធិជាមួយនឹងមនុស្សដែលមិនមែនជាសាច់ញាតិ
5. ទំនាស់កម្មសិទ្ធិជាមួយនឹងមនុស្សជាសាច់ញាតិ
6. ផ្សេងទៀត (បញ្ជាក់) .............................

3.51. បើសិនជាអ្នកមានជម្លោះដីធ្លី តើទីកន្លែងណា និង/ឬអ្នកណាដែលអ្នកសុំឱ្យគេជួយដោះស្រាយជម្លោះនោះ? *(សូមប្រើសញ្ញា "✓" ឆ្លើយសំណួរដែលពាក់ព័ន្ធនូវជម្លោះលើកទី១ ទី២ និងទី៣ រួចលេខកូដសំរាប់សំណួរដែលបានឆ្លើយឱ្យបានត្រឹមត្រូវ)*

| | លើកទី១ | ដោះស្រាយរួចឬទេ? (1=រួច, 2= មិនរួច) | ចំណាយសោហ៊ុយអស់ប៉ុន្មាន? (គិតជា៛) | លើកទី២ | ដោះស្រាយរួចឬទេ? (1=រួច, 2=មិនរួច) | ចំណាយសោហ៊ុយអស់ប៉ុន្មាន? (គិតជា៛) | លើកទី៣ | ដោះស្រាយរួចឬទេ? (1=រួច, 2=មិនរួច) | ចំណាយសោហ៊ុយអស់ប៉ុន្មាន? (គិតជា ៛) |
|---|---|---|---|---|---|---|---|---|---|
| 1. កិច្ចព្រមព្រៀងទាំងសងខាង | | | | | | | | | |
| 2. អ្នកជិតខាង គ្រួសារ មិត្តភក្តិ | | | | | | | | | |
| 3. ព្រះសង្ឃ អាចារ្យ | | | | | | | | | |
| 4. ប្រធានភូមិ | | | | | | | | | |
| 5. មេឃុំ | | | | | | | | | |
| 6. គណៈកម្មាធិការដោះស្រាយជម្លោះ (ថ្នាក់ស្រុក) | | | | | | | | | |
| 7. គណៈកម្មាធិការដោះស្រាយជម្លោះ (ថ្នាក់ខេត្ត) | | | | | | | | | |
| 8. គណៈកម្មាធិការដោះស្រាយជម្លោះ (នៅភ្នំពេញ) | | | | | | | | | |
| 9. តុលាការខេត្ត | | | | | | | | | |
| 10. តុលាការឧទ្ធរនៅភ្នំពេញ | | | | | | | | | |
| 11. ផ្សេងទៀត (បញ្ជាក់)... | | | | | | | | | |

3.52. បើសិនជាដីធ្លីរបស់អ្នកដោះស្រាយទំនាស់បានហើយ តើអ្នកមានបាត់បង់ដីឬទេ ( បាត់ខ្លះ ឬទាំងអស់)?

1. បាត់បង់ដីមួយចំនួន
2. បាត់បង់ដីទាំងអស់
3. គ្មានបាត់បង់ដីទេ
4. គ្មានចម្លើយ ឬគ្មានយោបល់

3.53. តើអ្នកពេញចិត្តនឹងដំណោះស្រាយនោះដែរឬទេ? 1 = ពេញចិត្ត 2 = មិនពេញចិត្ត

3.54. តើអ្នកគិតថាដំណោះស្រាយមានយុត្តិធម៌ និងត្រឹមត្រូវដែរឬទេ? 1 = មាន 2 = គ្មាន 3 = គ្មានយោបល់

3.55. បើមានយុត្តិធម៌ ហេតុអ្វី?..........................................................................................................

3.56. បើគ្មានយុត្តិធម៌ ហេតុអ្វី? ..........................................................................................................

## IV. ទីផ្សារឥណទាន

4.1. ចាប់ពីដើមរដូវវស្សាឆ្នាំ២០០៣ មក តើគ្រួសារអ្នកមានជំពាក់បំណុលគេជាប្រាក់រៀល/មាស ឬទេ ?

1. មាន ( សូមបន្តទៅសំណួរ 4.2.)
2. គ្មាន ( គ្មានរំលងទៅ 4.7)

**4.2.** ប្រសិនបើមានជំពាក់ តើអ្នកមានជំពាក់បំណុលគេជាប្រាក់ ឬជាមាសប៉ុន្មានបំណុល?............(ចំនួនបំណុល) *បំណុលនៅជំពាក់គេជាប្រាក់ និងជាមាស ( ដុល្លារ និងមាសត្រូវគិតចេញជារៀលវិញ)*

